ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ



# ឯកសារសម្រាប់ចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១២

## ២៤ ឧសភា ២០២៤

# មាតិកា

**ទំព័រ**

**ក. សេចក្តីណែនាំស្តីពី ការចូលរួម និងបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក**........................១

**ខ. ឯកសារបញ្ជាញផ្លូវសម្រាប់ចូលរួមមហាសន្និបាតភាគហ៊ុនិក** ......................................................២

**គ. ការតែងតាំងអាណត្តិគាហក:** (**អ្នកតំណាង**)...........................................................................២

**ឃ. ឯកសារសម្រាប់មហាសន្និបាតភាគហ៊ុនិក**..............................................................................២

១. របាយការណ៍លទ្ធផលអាជីវកម្ម ឆ្នាំ២០២៣ ………………………………………………………. ២

២. ទិសដៅអាជីវកម្ម ឆ្នាំ២០២៤ …………………………………………………………………….២

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ ១: របៀបចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១២ និងនីតិវិធីនៃការបោះឆ្នោតមហាសន្និបាតភាគហ៊ុនិកលើកទី១២

ឧបសម្ព័ន្ធ ២: លិខិតតែងតាំងអាណត្តិគាហក: (អ្នកតំណាង)

ឧបសម្ព័ន្ធ ៣: របាយការណ៍ប្រចាំឆ្នាំ២០២៣

ឧបសម្ព័ន្ធ ៤: ទិសដៅអាជីវកម្មឆ្នាំ២០២៤

ឧបសម្ព័ន្ធ ៥: សេចក្តីសម្រេចស្តីពី ការផ្ទេរសិទ្ធិលើការរៀបចំមហាសន្និបាតភាគហ៊ុនិក លើកទី១២

ឧបសម្ព័ន្ធ ៦: សេចក្តីសម្រេចស្តីពី ការផ្ទេរសិទ្ធិជាប្រធានគណៈអធិបតី និងដឹកនាំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី១២ របស់ រ.ទ.ស.ភ ជូន **ឯកឧត្តម មុី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ ៧: សេចក្តីសម្រេចស្តីពី ការចាត់តាំងគណៈកម្មការរៀបចំ និងដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី១២

ឧបសម្ព័ន្ធ ៨: សម្រង់ខ្លឹមសារនៃលក្ខន្តិកៈ រ.ទ.ស.ភ

## ក. សេចក្តីណែនាំស្តីពី ការចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក

- ភាគហ៊ុនិកដែលមានសិទ្ធិចុះឈ្មោះចូលរួមនៅក្នុងមហាសន្និបាតនេះ លុះត្រាតែមានលិខិតអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១២ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) និងបានធ្វើការបញ្ជាក់ការចូលរួមជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់) ចាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤។

- ដំណើរការនៃការចុះឈ្មោះចូលរួមក្នុងមហាសន្និបាត ត្រូវបានកំណត់ដូចតទៅ ៖
  - **ការចុះឈ្មោះ** ប្រព្រឹត្តទៅដូចខាងក្រោម ៖
    - **ចូលរួមដោយផ្ទាល់** : សូមអញ្ជើញទៅចុះឈ្មោះនៅស្នាក់ការ រ.ទ.ស.ភ (សូមពិនិត្យឯកសារបង្ហាញផ្លូវ សម្រាប់ចូលរួមមហាសន្និបាតភាគហ៊ុនិកដូចមានក្នុង ទំព័រទី២ នៃឯកសារនេះ)
    - **ចូលរួមតាមប្រព័ន្ធអនឡាញ** : សូមស្កេន QR Code នៅក្នុងលិខិតអញ្ជើញដែលបានភ្ជាប់ជូន ដើម្បីចុះឈ្មោះចូលរួម និងទាញយកឯកសារមហាសន្និបាតភាគហ៊ុនិក ដោយអនុវត្តតាមរបៀបចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១២ តាមរយៈកុំព្យូទ័រ និងស្មាតហ្វូន (ចំណុច ក ក្នុង **ឧបសម្ព័ន្ធ១**)។ អ្នកចូលរួមទាំងអស់ រួមទាំងភាគហ៊ុនិក ត្រូវមានទូរស័ព្ទដៃ ថេប្លេត ឬកុំព្យូទ័រ ព្រមទាំងត្រូវដំឡើងកម្មវិធី ZOOM ជាមុន។
  - **កាលបរិច្ឆេទ** : ថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤
  - **ពេលវេលា** : ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ០៩:០០ ព្រឹក

- ដំណើរការនៃការបោះឆ្នោតមហាសន្និបាតភាគហ៊ុនិកលើកទី១២ នឹងធ្វើឡើងតាមរយៈប្រព័ន្ធអនឡាញទៅលើកម្មវត្ថុចំនួន២ គឺ (ទី១) ការបោះឆ្នោតអនុម័តបែងចែកភាគលាភប្រចាំឆ្នាំ២០២៣ និង (ទី២) ការបោះឆ្នោតអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល។ ភាគហ៊ុនិកទាំងអស់ត្រូវមានទូរស័ព្ទដៃ ថេប្លេត ឬកុំព្យូទ័រ ព្រមទាំងត្រូវអនុវត្តតាមនីតិវិធីនៃការបោះឆ្នោតមហាសន្និបាតភាគហ៊ុនិកលើកទី១២ ដូចមានក្នុង**ឧបសម្ព័ន្ធ១** នៃឯកសារនេះ។

- ភាគហ៊ុនិកដែលចូលរួមដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហក:(អ្នកតំណាង) ក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១២ របស់ រ.ទ.ស.ភ ត្រូវភ្ជាប់មកជាមួយនូវលិខិតអញ្ជើញ នៅថ្ងៃប្រារព្ធមហាសន្និបាតភាគហ៊ុនិកនេះ តាមពេលវេលា និងកាលបរិច្ឆេទខាងលើ ដើម្បីចុះឈ្មោះចូលរួមនៅក្នុងមហាសន្និបាតភាគហ៊ុនិកនេះ។

## ខ. ឯកសារបង្ហាញផ្លូវសម្រាប់ចូលរួមមហាសន្និបាតភាគហ៊ុនិក




## គ. ការតែងតាំងអាណត្តិគាហក: (អ្នកតំណាង)

ភាគហ៊ុនិកដែលចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី១២ របស់ រ.ទ.ស.ភ តាមរយៈអាណត្តិគាហក: ត្រូវ តែងតាំងអាណត្តិគាហក:តាមទម្រង់ **“លិខិតតែងតាំងអាណត្តិគាហក: (អ្នកតំណាង)”** ដូចមានក្នុង **ឧបសម្ព័ន្ធ២** នៃឯកសារនេះ។

ភាគហ៊ុនិកម្នាក់តែងតាំងអាណត្តិគាហក:បានតែ ០១រូប ប៉ុណ្ណោះ។ ភាគហ៊ុនិកច្រើននាក់អាចតែងតាំងអាណត្តិគាហក:រួមគ្នាបាន។

## ឃ. ឯកសារសម្រាប់មហាសន្និបាតភាគហ៊ុនិក

### ១. របាយការណ៍លទ្ធផលអាជីវកម្ម ឆ្នាំ២០២៣

លទ្ធផលអាជីវកម្ម ឆ្នាំ២០២៣ របស់ រ.ទ.ស.ភ ត្រូវបានបង្ហាញនៅក្នុង **របាយការណ៍ប្រចាំឆ្នាំ២០២៣** ដូចមាននៅក្នុង **ឧបសម្ព័ន្ធ ៣** នៃឯកសារនេះ។

### ២. ទិសដៅអាជីវកម្ម ឆ្នាំ២០២៤

ទិសដៅអាជីវកម្ម ឆ្នាំ២០២៤ របស់ រ.ទ.ស.ភ ត្រូវបានបង្ហាញនៅក្នុង **ឧបសម្ព័ន្ធ ៤** នៃឯកសារនេះ។

# ឧបសម្ព័ន្ធ ១

## របៀបចូលរួម និងនីតិវិធីនៃការបោះឆ្នោត

## មហាសន្និបាតភាគហ៊ុនិកលើកទី១២

# របៀបចូលរួមមហាសន្និបាត ភាគហ៊ុនិកលើកទី ១២ តាមរយៈកុំព្យូទ័រ



## ក. ការចុះឈ្មោះ

### ☛ ការចូលរួមតាមរយៈ Online

1. ចូលទៅកាន់គេហទំព័រ **http://gms12.ppwsa.com.kh/**
2. ចុចលើរូបទង់ជាតិដើម្បីជ្រើសរើសភាសាខ្មែរ ឬអង់គ្លេស។
3. វាយបញ្ចូល Investor **ID** និង **Passcode** ដែលមាននៅក្នុងលិខិតអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិក ទៅក្នុងប្រអប់លេខអត្តសញ្ញាណអ្នកចូលរួម និងប្រអប់លេខសម្ងាត់។
4. ចុចលើប៊ូតុង **Submit**
5. ផ្ទៀងផ្ទាត់ព័ត៌មានវិនិយោគិនផ្ទាល់ខ្លួនរបស់លោក-អ្នក ដែលបានបង្ហាញនៅលើផ្ទៃអេក្រង់។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**លិខិតអញ្ជើញ**

**ក្រុមប្រឹក្សាភិបាល អាណត្តិទី៨**
មានកិត្តិយសសូមគោរពអញ្ជើញ
ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ឬអ្នកតំណាង
**XXX XXXXXXXX** កាន់កាប់អត្តសញ្ញាណវិនិយោគិនលេខ **DXXXXXXXXX**
ជាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ចំនួន ***77,777,777*** ភាគហ៊ុន នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤ ដើម្បីចូលរួម
**មហាសន្និបាតភាគហ៊ុនិក លើកទី១២ របស់ រ.ទ.ស.ភ**
ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹង
**ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤** ចាប់ពីវេលាម៉ោង **០៨:០០នាទីព្រឹក**
**នៅទីស្នាក់ការ រ.ទ.ស.ភ និងតាមប្រព័ន្ធអនឡាញ (Zoom)**

***បញ្ជាក់៖សូមមេត្តាយកមកជាមួយនូវលិខិតអញ្ជើញនេះ នាថ្ងៃមហាសន្និបាតដើម្បីចុះឈ្មោះចូលរួមនៅទីស្នាក់ការ រ.ទ.ស.ភ ឬ ស្កេនដើម្បីចូលរួមតាមប្រព័ន្ធអនឡាញ និងទាញយកឯកសារមហាសន្និបាតភាគហ៊ុនិកលើកទី១២ របស់ រ.ទ.ស.ភ***

gms12.ppwsa.com.kh ①
Investor ID: DXXXXXXXXXX
Passcode: XXXX ③

**INVITATION**
**The Board of Directors for the 8th mandate**
has the honor to invite
Your Excellency, Neak Oknha, Lok Oknha, Sir, Madam, or the proxy of
**XXX XXXXXXXX** holding Investor Identification No **DXXXXXXXXX**
who owns PPWSA's ordinary shares of 77,777,777 , on April 24th, 2024, to attend
**The 12th General Meeting of Shareholders of PPWSA**
that will be held on **Friday, May 24, 2024, at 08:00 AM**
**at PPWSA's headquarter and through the online meeting (Zoom)**

*NOTE: Please kindly bring this invitation letter for the registration of attending at PPWSA's headquarter or scan the above QR code to participate through the online meeting (Zoom) and download document of the 12th General Meeting of Shareholders of PPWSA*
*(Unofficial Translation)*

### ☛ ការចូលរួមដោយផ្ទាល់

- សូមបង្ហាញលិខិតអញ្ជើញរបស់លោក-អ្នក ទៅកាន់ភ្នាក់ងារទទួលភ្ញៀវនៅតាមបញ្ជរ






## ខ. ការចូលរួមប្រជុំមហាសន្និបាតភាគហ៊ុនិកតាមរយៈប្រព័ន្ធ ZOOM

លើទំព័រព័ត៌មានវិនិយោគិន សូមចុចប៊ូតុង **Zoom** ដើម្បីចូលរួមប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី១២ ដោយតម្រូវឲ្យ លោក-អ្នក ដំឡើងកម្មវិធី **Zoom** ជាមុន។ លោក-អ្នកអាចជ្រើសរើសស្តាប់ការបកប្រែជាភាសាអង់គ្លេស ដោយអនុវត្តជំហានដូចខាងក្រោម៖

1. នៅក្នុងកម្មវិធី Zoom សូមចុចលើ Interpretation
2. បន្ទាប់មកសូមជ្រើសរើស English
3. ជ្រើសរើស Mute Original Audio បើសិនលោក-អ្នកមិនត្រូវការស្តាប់សំឡេងដើមនៃការប្រជុំ។







## គ. ការបោះឆ្នោត

ត្រឡប់មកគេហទំព័រ **http://gms12.ppwsa.com.kh/** វិញ

1. លើទំព័រព័ត៌មានវិនិយោគិន ចុចប៊ូតុង **Vote**
2. ចុចសញ្ញា ☑ លើជម្រើសក្នុងកម្មវត្ថុបោះឆ្នោតទាំង២ ដែលលោក-អ្នកពេញចិត្ត
3. ចុចប៊ូតុង បោះឆ្នោត ។












# របៀបចូលរួមមហាសន្និបាត ភាគហ៊ុនិកលើកទី ១២ តាមរយៈស្មាតហ្វូន (Smart Phone)



## ក. ការចុះឈ្មោះ

### ☞ ការចូលរួមតាមរយៈ Online

1. ធ្វើការស្កេន **QR Code** ដែលមានក្នុងលិខិតអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិក
2. ចុចលើរូបទង់ជាតិដើម្បីជ្រើសរើសភាសាខ្មែរ ឬអង់គ្លេស។
3. វាយបញ្ចូល **Passcode** ទៅក្នុងប្រអប់ លេខសម្ងាត់
4. ចុចលើប៊ូតុង **Submit**
5. ផ្ទៀងផ្ទាត់ព័ត៌មាននិយោគិនផ្ទាល់ខ្លួនរបស់លោក-អ្នក ដែលបានបង្ហាញនៅលើផ្ទៃអេក្រង់។



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**លិខិតអញ្ជើញ**

**ក្រុមប្រឹក្សាភិបាល អាណត្តិទី៨**

មានកិត្តិយសសូមគោរពអញ្ជើញ
ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ឬអ្នកតំណាង
**XXX XXXXXXXX** កាន់កាប់អត្តសញ្ញាណវិនិយោគិនលេខ **XXXXXXXXX**
ជាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ចំនួន ***777,777,777*** ភាគហ៊ុន នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣
ដើម្បីចូលរួម

**មហាសន្និបាតភាគហ៊ុនិក លើកទី១១ របស់ រ.ទ.ស.ភ**

ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ ៧ កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹង
**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣** ចាប់ពីវេលាម៉ោង **០៨:០០ ព្រឹក**

**តាមប្រព័ន្ធអនឡាញ (ZOOM)**

សូមស្កេនដើម្បីចូលរួម និងទាញយក
ឯកសារមហាសន្និបាតភាគហ៊ុនិកលើកទី១១ របស់ រ.ទ.ស.ភ

❶

gms11.ppwsa.com.kh
Investor ID: XXXXXXXXX
Passcode: XXXX ❸

**INVITATION**
**The Board of Directors for the 8th mandate**

has the honor to invite
Your Excellency, Neak Oknha, Lok Oknha, Sir, Madam, or the proxy of
**XXX XXXXXXXX** holding Investor Identification No **XXXXXXXXX**
who owns PPWSA's ordinary shares of **777,777,777** shares, on April 26th, 2023, to attend
**the 11th General Meeting of Shareholders of PPWSA**
that will be held on **Friday, May 26th , 2023, at 08:00 AM**
**through the online meeting (ZOOM)**

Please scan the above QR code to participate and download
the 11th General Meeting of Shareholders of PPWSA

### ☞ ការចូលរួមដោយផ្ទាល់

• សូមបង្ហាញលិខិតអញ្ជើញរបស់លោក-អ្នក ទៅកាន់ភ្នាក់ងារទទួលភ្ញៀវនៅតាមបញ្ជរ






## ខ. ការចូលរួមប្រជុំមហាសន្និបាតភាគហ៊ុនិកតាមរយៈប្រព័ន្ធ ZOOM

លើទំព័រព័ត៌មានវិនិយោគិន ចុចប៊ូតុង **Zoom** ដើម្បីចូលរួមប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី១២ ដោយតម្រូវឲ្យ លោក-អ្នក ដំឡើងកម្មវិធី **Zoom** ជាមុន។ លោក-អ្នកអាចជ្រើសរើសស្តាប់ការបកប្រែជាភាសាអង់គ្លេស ដោយអនុវត្តជំហានដូចខាងក្រោម៖

1. នៅក្នុងកម្មវិធី Zoom សូមចុចលើ Interpretation
2. បន្ទាប់មកសូមជ្រើសរើស English
3. ជ្រើសរើស Mute Original Audio បើសិនលោក-អ្នកមិនត្រូវការស្តាប់សំឡេងដើមនៃការប្រជុំ។







## គ. ការបោះឆ្នោត

ត្រឡប់មកគេហទំព័រ **http://gms12.ppwsa.com.kh/** វិញ

1. លើទំព័រព័ត៌មានវិនិយោគិន ចុចប៊ូតុង **Vote**
2. ចុចសញ្ញា ☑ លើជម្រើសក្នុងកម្មវត្ថុបោះឆ្នោតទាំង២ ដែលលោក-អ្នកពេញចិត្ត
3. ចុចប៊ូតុង បោះឆ្នោត ។












# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

# នីតិវិធីនៃការបោះឆ្នោតមហាសន្និបាតភាគហ៊ុនិកលើកទី១២

## ១) នីតិវិធីចុះឈ្មោះចូលរួមបោះឆ្នោត

ភាគហ៊ុនិកមានសិទ្ធិចូលរួមបោះឆ្នោតបានលុះត្រាតែ៖

១.១ បានបញ្ជាក់ការចូលរួមជាមួយ ធនាគារអេស៊ីលីដា។

១.២ បានចុះឈ្មោះចូលរួមមហាសន្និបាតតាមកម្មវិធីកំណត់ដូចមានក្នុងរបៀបវារៈ (ចាប់ផ្តើមពីម៉ោង៨:០០ព្រឹក ដល់ម៉ោង៩:០០ព្រឹក)។

## ២) នីតិវិធីបោះឆ្នោត

ដំណើរការនៃការបោះឆ្នោត ត្រូវប្រព្រឹត្តទៅតាមលំដាប់លំដោយដូចខាងក្រោម៖

### ២.១ ការបោះឆ្នោត

ការបោះឆ្នោតត្រូវធ្វើឡើងតែមួយ(១)លើក និងមានពីរកម្មវត្ថុ ក្នុងនោះ៖

**២.១.១ កម្មវត្ថុទី១ : ការបោះឆ្នោតអនុម័តបែងចែកភាគលាភជូនភាគហ៊ុនិក**

កម្មវត្ថុនេះត្រូវបានចាត់ទុកថា<u>បានទទួលការគាំទ្រ</u> លុះត្រាតែ<u>ទទួលបានសំឡេងបោះឆ្នោត "**គាំទ្រ**" ភាគច្រើន គឺច្រើនជាងហាសិបភាគរយ(៥០%)</u> ផ្ទុយទៅវិញត្រូវបានចាត់ទុកថា <u>មិនបានទទួលការគាំទ្រ</u>។

**២.១.២ កម្មវត្ថុទី២ : ការបោះឆ្នោតអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល**

កម្មវត្ថុនេះត្រូវបានចាត់ទុកថា<u>បានទទួលការគាំទ្រ</u> លុះត្រាតែ<u>ទទួលបានសំឡេងបោះឆ្នោត "**គាំទ្រ**" ភាគច្រើន គឺច្រើនជាងហាសិបភាគរយ(៥០%)</u> ផ្ទុយទៅវិញត្រូវបានចាត់ទុកថា <u>មិនបានទទួលការគាំទ្រ</u>។

### ២.២ ដំណើរការនៃការបោះឆ្នោតចាប់ផ្តើមពីម៉ោង១០ និង៣០នាទី ដល់ម៉ោង១១ និង៣០នាទី។

### ២.៣ ការប្រកាសលទ្ធផលបោះឆ្នោត

លទ្ធផលនៃការបោះឆ្នោត នឹងត្រូវបង្ហាញជាក្រាហ្វិចដោយស្វ័យប្រវត្តិនៅក្នុងកិច្ចប្រជុំប្រព័ន្ធ Zoom ព្រមទាំងប្រកាសដោយអនុគណៈកម្មការទទួលបន្ទុកបោះឆ្នោត បន្ទាប់ពីដំណើរការបោះឆ្នោតត្រូវបានបញ្ចប់ ។

## ៣) កំណត់សម្គាល់នៅក្នុងនីតិវិធីបោះឆ្នោតមហាសន្និបាតភាគហ៊ុនិកលើកទី១២

៣.១ <u>**មួយភាគហ៊ុន**</u> ស្មើនឹង "<u>**មួយសំឡេង**</u>" ។

៣.២ បោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិក, បោះឆ្នោតអនុម័តលាភការរបស់ក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងដោយភាគហ៊ុនិកសាធារណៈ និងភាគហ៊ុនិកឯកជន ។

## ៤) ឯកសារយោងពាក់ព័ន្ធ

- លក្ខន្តិកៈរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២
- គោលការណ៍ណែនាំស្តីពីមហាសន្និបាតភាគហ៊ុនិក សម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រលេខ ០០៥/២១នមក/គណន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១

## ៥) របៀបចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១២

សូមអនុវត្តតាមរបៀបចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១២ ដូចមានឯកសារជូនភ្ជាប់មកជាមួយ។

# ឧបសម្ព័ន្ធ ២

## លិខិតតែងតាំងអាណត្តិគាហកៈ ( អ្នកតំណាង )

# លិខិតតែងតាំងអាណត្តិគាហក: (អ្នកតំណាង)
# Proxy Letter

ធ្វើនៅ ..........................................................................
Written at

ថ្ងៃ........................ ខែ........................ ឆ្នាំ...............
Date Month Year

លេខអត្តសញ្ញាណវិនិយោគិនចេញដោយគណៈកម្មការមូលបត្រកម្ពុជា ឬនិយ័តករមូលបត្រកម្ពុជា.............................................................
Investor ID number issued by Securities and Exchange Commission of Cambodia or Securities and Exchange Regulator of Cambodia

☐ រូបវន្តបុគ្គល / Natural Person
☐ នីតិបុគ្គល / Legal Person

ខ្ញុំ/យើងខ្ញុំ...................................................................................................... សញ្ជាតិ..........................................................
I / We Nationality

មានអាសយដ្ឋានលេខ.............................................. ផ្លូវ............................................... ឃុំ/សង្កាត់.......................................................
address no. Street Commune/Sangkat

ស្រុក/ក្រុង/ខណ្ឌ.......................................................... ខេត្ត/រាជធានី.............................. ប្រទេស...........................................................
District/Town/Khan Province/Capital Country

គឺជាភាគហ៊ុនិករបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ("រ.ទ.ស.ភ") **នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤** (កាលបរិច្ឆេទកំណត់ទុក) កាន់កាប់
am/are a shareholder of Phnom Penh Water Supply Authority ("PPWSA") on **April 24, 2024** (Record Date ), holding

ភាគហ៊ុនធម្មតាសរុបចំនួន................................ភាគហ៊ុនមានសិទ្ធិចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១២ របស់ រ.ទ.ស.ភ
the total number of ordinary share share(s) entitled to attend and vote in the 12th General Meeting of Shareholders of PPWSA.

**តែងតាំង**
**hereby appoint**

ឈ្មោះ.......................................................................................... ភេទ............ អាយុ............ ឆ្នាំ សញ្ជាតិ......................................
Name Gender Age Year Nationality

កាន់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ......................................................... មានអាសយដ្ឋានលេខ............ ផ្លូវ.......................
holding identity card or passport number address no. Street

ឃុំ/សង្កាត់.................................................................................... ស្រុក/ក្រុង/ខណ្ឌ........................................................................
Commune/Sangkat District/Town/Khan

ខេត្ត/រាជធានី............................................................................... ប្រទេស.......................................................................................
Province/Capital Country

ជាអាណត្តិគាហកៈរបស់ ខ្ញុំ/យើងខ្ញុំ ដើម្បីចូលរួម និងបោះឆ្នោតក្នុងនាម ខ្ញុំ/យើងខ្ញុំ ក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១២ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ០៨:០០ព្រឹក ☐ នៅទីស្នាក់ការ រ.ទ.ស.ភ ឬ ☐ តាមប្រព័ន្ធអនឡាញ(ZOOM) ឬកាលបរិច្ឆេទ ពេលវេលា ទីកន្លែង ឬទម្រង់អនឡាញណាមួយ ដែលមហាសន្និបាតភាគហ៊ុនិកលើកទី១២ នេះអាចប្រព្រឹត្តទៅ។ រាល់សកម្មភាពទាំងឡាយរបស់អាណត្តិគាហកៈខាងលើ នៅក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១២ គឺជាសកម្មភាពស្របច្បាប់តំណាងឱ្យ ខ្ញុំ/យើងខ្ញុំ ដែលជាភាគហ៊ុនិករបស់ រ.ទ.ស.ភ។
As my/our proxy to attend and vote on my/our behalf at the 12th General Meeting of Shareholders to be held on Friday, May 24, 2024 at 08:00AM ☐ at PPWSA headquarter or ☐ through an online meeting (ZOOM) or such other date, time and place or other online platforms as this 12th General Meeting of Shareholders may be held. Any act performed by the above proxy in this 12th General Meeting of Shareholders shall be the legal actions performed by myself/ourselves as PPWSA's shareholder.

Unofficial Translation

**ហត្ថលេខា ត្រា[1] និងឈ្មោះភាគហ៊ុនិក**
**Signature Stamp[1] and Name of shareholder**

**ហត្ថលេខា និងឈ្មោះអាណត្តិគាហកៈ**
**Signature and Name of the proxy**

[1] *ក្នុងករណីភាគហ៊ុនិកជាស្ថាប័ន*
*In case of the institutional shareholder*

# ឧបសម្ព័ន្ធ ៣

## របាយការណ៍ប្រចាំឆ្នាំ ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ





# របាយការណ៍ប្រចាំឆ្នាំ២០២៣

**គោលដៅយុទ្ធសាស្ត្រចម្បងរបស់ រ.ទ.ស.ភ មានដូចខាងក្រោម៖**

ពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដារដូចគ្នានៅក្នុងរាជធានីភ្នំពេញ។ វិភាគថ្លៃដើម និងកំណែទម្រង់ដំណើការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក បង្កើនប្រសិទ្ធិភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស។ តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និង បរិស្ថាន។ ប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។


លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ: (៨៥៥)២៣ ៦៣៥ ០៨ ០៨
លេខទូរសារ: (៨៥៥)២៣ ៦២៥ ០៧ ០៧

អ៊ីម៉ែល:
ir@ppwsa.com.kh

# ទស្សនវិស័យ និងបេសកកម្ម

## ទស្សនវិស័យ

រ.ទ.ស.ភ បានប្តេជ្ញាចិត្តបន្តធ្វើឱ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សា ជាអ្នកសម្របសម្រួលដើម្បីឱ្យប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជនខេត្ត-ក្រុង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងពិភពលោក មានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា។

## បេសកកម្ម

បេសកកម្មរបស់ រ.ទ.ស.ភ គឺជានាផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ ២៤ម៉ោង លើ ២៤ម៉ោង ក្នុងមួយសប្តាហ៍ មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់និងរាជធានីភ្នំពេញដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រ។ក្រៅពីនេះ រ.ទ.ស.ភ បាននឹងកំពុងចែករំលែកបទពិសោធន៍ការងាររបស់ខ្លួន ដល់បណ្តារដ្ឋាករទឹកខេត្ត-ក្រុងមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជាព្រមទាំងបណ្តាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោកតាមសំណូមពរសំដៅសម្រេចអោយបាននូវ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (CSDGs)។

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប(ពាន់រៀល) | ៣.១៥៩.០៦០.៣២៣ | ២.៦៨៤.១៣៥.៨៧៥ | ២.៣០៦.៨០៦.១៧៤ |
| បំណុលសរុប(ពាន់រៀល) | ១.៧៦៤.៥៤២.៨៥២ | ១.៤១១.៩២២.៨២៨ | ១.១៤០.១៧៧.៩៦១ |
| មូលធនសរុប(ពាន់រៀល) | ១.៣៩៤.៥១៧.៤៧១ | ១.២៧២.២១៣.០៤៧ | ១.១៦៦.៦២៨.២១៣ |

| លទ្ធផលហិរញ្ញវត្ថុ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|
| ចំណូលសរុប(ពាន់រៀល) | ៣៩២.០៥៤.៣៦៥ | ៣៤៧.២៨៣.៨៥៦ | ៣៦៩.១៤៥.២៥៧ |
| ចំណេញមុនបង់ពន្ធប្រាក់ចំណេញ(ពាន់រៀល) | ១៥៣.៤៧២.៥៤៣ | ១៣០.៥១៥.៨៩២ | ១៦៥.៨៥៦.៥៨៦ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ(ពាន់រៀល) | ១២៦.៦០៩.៥៨២ | ១០៨.១៨៥.៨៦៥ | ១២៩.២៧៣.៩១៧ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ(ពាន់រៀល) | ១២៦.៦០៩.៥៨២ | ១០៨.១៨៥.៨៦៥ | ១២៩.២៧៣.៩១៧ |

| អនុបាតហិរញ្ញវត្ថុ | | ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|---|
| អនុបាតសាធនភាព | | | | |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត(ចំនួនដង) | ២,៦០ | ២,២១ | ១,៦៥ |
| | អនុបាតចរន្តលឿន(ចំនួនដង) | ១,៥១ | ១,៤៦ | ១,១១ |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រពសកម្ម (ភាគរយ) | ៤,៣៣ | ៤,៣៤ | ៦,២០ |
| | អនុបាតចំណេញធៀបនឹងមូលធន (ភាគរយ) | ៩,៥០ | ៨,៨៧ | ១២,០៣ |
| | អនុបាតគម្លាតចំណេញដុល (ភាគរយ) | ៣៨,៣៣ | ៣៧,២៨ | ៤២,៥៦ |
| | អនុបាតគម្លាតចំណេញភាព (ភាគរយ) | ៣២,២៩ | ៣១,១៥ | ៣៥,០២ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១.៤៥៥,៧៣ | ១.២៤៣,៩០ | ១.៤៨៦,៣៧ |
| អនុបាតលទ្ធភាពសងការប្រាក់ (ចំនួនដង) | | ៤២,៥៩ | ៣៥,៨៦ | ៣២,៧៦ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

## បម្រែបម្រួលតម្លៃភាគហ៊ុន (គិតជារៀល) និងទំហំជួញដូរ




## ប្រាក់ចំណេញតាមបណ្ដាឆ្នាំនីមួយៗ (លានរៀល)




## ប្រាក់ចំណេញសម្រាប់ឆ្នាំ២០២៣ (លានរៀល)



# សមាសភាព
# ក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ស៊ឹម ស៊ីថា**
រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍

**ប្រធានក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ឡុង ណារ៉ូ**
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ម៉ី វ៉ាន់**
រដ្ឋលេខាធិការ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ទួន ផារ័ត្ន**
អភិបាលរងនៃគណៈអភិបាល
រាជធានីភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ម៉ា ណូវ៉ាទីន**
តំណាងនិយោជិត
នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ណាំ ចន្ទ្រី**
អភិបាលមិនប្រតិបត្តិតំណាង
ភាគហ៊ុនិកឯកជន

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ស្រេង សំឌិក**
អភិបាលឯករាជ្យ

**សមាជិកក្រុមប្រឹក្សាភិបាល**

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ស៊ឹម ស៊ីថា**
រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម
វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**ប្រធានក្រុមប្រឹក្សាភិបាល**

## ក្នុងឆ្នាំ២០២៣ នេះ

"ដោយទទួលបានទំនុកចិត្តពីរាជរដ្ឋាភិបាល ជាមួយនឹងការឧបត្ថម្ភគាំទ្រពីក្រសួងអាណាព្យាបាលទាំងពីរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានបំពេញកាតព្វកិច្ចដោយជោគជ័យ គ្រប់សកម្មភាពធុរកិច្ចរបស់ខ្លួន។ យើងកំពុងបន្តអភិវឌ្ឍសេវាទឹកស្អាតជារៀងរាល់ថ្ងៃ ទាំងគុណភាពនិងបរិមាណដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់របស់ប្រជាជននៃទីក្រុងភ្នំពេញ និងទីក្រុងតាខ្មៅ និងចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍរបស់ទីក្រុងទាំងពីរ។"

ក្នុងឆ្នាំ២០២៣នេះ រ.ទ.ស.ភ បានទទួលចំណូលសរុប ៣៩២.០៥៤.៣៦៥.០០០រៀល និងប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល ១៥៣.៤៧២.៥៤៣.០០០រៀល។ លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិកមានចំនួន ១២៦.៦០៩.៥៨២.០០០រៀល។ ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន( Basic Earnings per Share ) ១.៤៥៥,៧៣រៀល។

រ.ទ.ស.ភ វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ។ ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើនផលិតកម្ម-សេវាកម្ម និងធានាគុណភាពទឹកស្អាតដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅ អាជីវកម្ម សេវាកម្ម និងឧស្សាហកម្ម។ ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗទៀតដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុងឬក្រៅប្រទេស តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដោយអនុលោមតាមច្បាប់។

សហប្រតិបត្តិការលើផ្នែកបច្ចេកទេសពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍទាំងក្នុង និងក្រៅប្រទេសដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ធានាឱ្យបាននូវចេរភាពដំណើរការផលិតកម្មអាជីវកម្ម និងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស វិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទ ដើម្បីកាត់បន្ថយថ្លៃដើមទឹកប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។

## សេវាដ៏មានប្រសិទ្ធភាព

យើងនៅតែបន្តធានាការផ្គត់ផ្គង់ទឹកស្អាត ២៤ម៉ោងលើ២៤ម៉ោង ជាមួយនឹងគុណភាពដែលអាចទទួលទានបានដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ។ ក្នុងឆ្នាំ២០២៣ នេះ យើងបានដាក់បំពង់មេនាំទឹក និងបណ្តាញចែកចាយទឹកស្អាតសរុបប្រវែង ៤៦២.៩៨៥,៤០ម៉ែត្រ និងផលិតបានចំនួន ២៧៩.០៥៣.៦៥១ម៣។ កំណើនអតិថិជនក្នុងគ្រាបានចំនួន ៣០.១១៣បណ្តាញ ក្នុងនោះអតិថិជនចំណូលទាបចំនួន ៣.៧០៨បណ្តាញ និងអត្រាទឹកបាត់បង់ស្ថិតក្នុងកម្រិត ៨,៧៥% ប៉ុណ្ណោះ។

## ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន៧លើក ដូចខាងក្រោម៖

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១ អាណត្តិទី៨ របស់ រ.ទ.ស.ភ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១ អាណត្តិទី៨ កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ៨:៣០នាទី នៅទីស្នាក់ការរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (បន្ទប់ប្រជុំលេខ២) ដែលមានរបៀបវារៈដូចខាងក្រោម ៖

១) សំណើសុំពិនិត្យ-អនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០២២ និងគោលការណ៍បែងចែកប្រាក់ចំណេញ និងបែងចែកភាគលាភដល់ភាគហ៊ុនិកឆ្នាំ២០២២

ក្រុមប្រឹក្សាភិបាល *បានអនុម័ត ៖*

១. ឯកភាពជាឯកច្ឆន្ទលើសំណើសុំបែងចែកប្រាក់ចំណេញឆ្នាំ២០២២ ដូចខាងក្រោម៖

| | | |
|---|---|---|
| - រង្វាន់សរសើរមន្ត្រី-និយោជិត (បីខែ) | : | ៩.៣២៦.១១០.៣៥៦,១៣រៀល |
| - មូលនិធិបម្រើផលប្រយោជន៍សង្គម (៥%) | : | ៤.២៩៩.១៣៦.៤៦៤,០៧រៀល |
| - មូលនិធិបម្រុងតាមច្បាប់ (៥%) | : | ៥.៤០៩.២៩៣.២៥០,០០រៀល |
| - មូលនិធិបម្រុងដោយសេរី (៥%) | : | ៥.៤០៩.២៩៣.២៥០,០០រៀល |
| ២. ឯកភាពជាឯកច្ឆន្ទលើប្រាក់ចំណេញរក្សាទុក | : | ៩៣.០៦២.១០៦.៧៥០,០០រៀល |
| ៣. ភាគលាភសរុបដែលត្រូវបែងចែក | : | ២៨.៧០១.១៤៣.៤៦០,០០រៀល |
| - ទិន្នផលភាគលាភ | : | ៤,១៥% |
| - ចំនួនភាគលាភក្នុងមួយភាគហ៊ុន | : | ៣៣០រៀល/ភាគហ៊ុន |
| - អនុបាតនៃការបែងចែកភាគលាភ | : | ៣,៩៨% |

- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ : ៣០ ឧសភា ២០២៣
- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ និងបញ្ចប់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣។

២) សំណើសុំគោលការណ៍លុបចេញពីបញ្ជីនូវអចលនទ្រព្យខូចបាត់បង់គុណភាព និងធ្វើសំវិធានធនសន្និធិបរិក្ខារ ដែលមិនប្រើប្រាស់ខូចបាត់បង់គុណភាពក្នុងឆ្នាំ២០២២ ដើម្បីស្នើសុំគោលការណ៍ជម្រះចេញពីបញ្ជីទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលបានឯកភាពជាគោលការណ៍ឱ្យជម្រះចេញពីបញ្ជីតាមសំណើនិងស្នើសុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការវាយតម្លៃ និងប្រកាសលក់ឡាយឡុងតាមនីតិវិធីជាធរមាន។

៣) សំណើសុំគោរពអនុវត្តកាតព្វកិច្ចក្នុងការប្រកាសព័ត៌មានផ្នែកទី២ ក្នុងឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ "របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ" និងផ្តល់ឯកសារគាំទ្រតាមទម្រង់ របាយការណ៍សាមាយិករបស់និយ័តករមូលបត្រកម្ពុជា ជាភាសាខ្មែរ និងអង់គ្លេស

ក្រុមប្រឹក្សាភិបាលបានឯកភាពទៅលើសំណើទី១ (ការធ្វើបច្ចុប្បន្នភាពជីវប្រវត្តិរូបសង្ខេបរបស់អភិបាល ទាំងភាសាខ្មែរ និងភាសាអង់គ្លេស), និងសំណើទី២ (សុំផ្តល់ព័ត៌មានបញ្ជាក់អំពីទំនាក់ទំនងរបស់ខ្លួននៅក្នុង ក្រុមហ៊ុនផ្សេងទៀត) រីឯសំណើទី៣ (សំណើសុំអនុវត្តការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនិមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ) រិញស្នើ រ.ទ.ស.ភ ទំនាក់ទំនងសុំគំរូទម្រង់វាយតម្លៃពី ន.ម.ក ដើម្បីជាមូលដ្ឋានឈានទៅអនុវត្តកិច្ចការនេះនាពេលខាងមុខ។

៤) សំណើសុំពិនិត្យ-អនុម័តលើពិធីមហាសន្និបាតភាគហ៊ុនិកលើកទី១១

ក្រុមប្រឹក្សាភិបាលបានអនុម័ត-ឯកភាព៖

១. យកថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ជាថ្ងៃប្រារព្ធពិធីមហាសន្និបាតភាគហ៊ុនិកលើកទី១១ និងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ជាកាលបរិច្ឆេទកំណត់ទុកសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១១

២. ដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី១១ រួមទាំងការបោះឆ្នោតនឹងរៀបចំតាមប្រព័ន្ធអនឡាញ (Online)។

៣. មហាសន្និបាតចាប់ផ្តើមពីម៉ោង៨:០០ព្រឹក ដោយគ្រោងរៀបចំឱ្យមានរបៀបវារៈដូចខាងក្រោម៖

- ចុះវត្តមាន (តាមប្រព័ន្ធអនឡាញ)
- ប្រកាសហេតុ
- គោរពទង់ជាតិ
- បទបង្ហាញស្តីពីលទ្ធផលអាជីវកម្មឆ្នាំ២០២២ និងទិសដៅអាជីវកម្មឆ្នាំ២០២៣ របស់សហគ្រាស
- ការបោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិក និងលាភការរបស់ក្រុមប្រឹក្សាភិបាល
- មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណរបស់ប្រធានគណៈអធិបតី

៤. ប្រគល់ភារកិច្ចធ្វើបទបង្ហាញស្តីពីលទ្ធផលអាជីវកម្មឆ្នាំ២០២២ និងទិសដៅអាជីវកម្មឆ្នាំ២០២៣ របស់សហគ្រាស ជូនអគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច (លោក ដេង ប៉ូលីដែន)។

៥. ផ្ទេរសិទ្ធិជូនឯកឧត្តមអគ្គនាយកក្នុងការរៀបចំដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី១១ និងអនុញ្ញាតឱ្យ រ.ទ.ស.ភ ធ្វើសេចក្តីសម្រេចផ្ទេរសិទ្ធិនេះ ដោយយោងស្មារតីកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១ នេះ។

៥) សំណើសុំពិនិត្យ-អនុម័តកែសម្រួលសមាសភាពគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលបានឯកភាពកែសម្រួល និងតែងតាំងសមាសភាពគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល ដូចខាងក្រោម៖

ក. គណៈកម្មាធិការតែងតាំងនិងលាភការ

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ស៊ឹម ស៊ីថា | ប្រធានក្រុមប្រឹក្សាភិបាល<br>តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ជាប្រធាន |
| ២. | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល<br>តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៣. | ឯកឧត្តម នួន ផារ័ត្ន | សមាជិកក្រុមប្រឹក្សាភិបាល<br>តំណាងរដ្ឋបាលរាជធានីភ្នំពេញ | ជាសមាជិក |
| ៤. | ឯកឧត្តមអគ្គនាយក រ.ទ.ស.ភ | | ជាសមាជិក |
| ៥. | លេខាធិការសហគ្រាស ០១រូប | | ជាលេខា |

ខ. គណៈកម្មាធិការសវនកម្ម

| | | | |
|---|---|---|---|
| ១. | លោក ស្រេង សំឱក | សមាជិកក្រុមប្រឹក្សាភិបាល<br>អភិបាលឯករាជ្យ | ជាប្រធាន |
| ២. | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល<br>តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៣. | លោក ណាំ ចន្ទ្រី | សមាជិកក្រុមប្រក្សាភិបាល<br>អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន | ជាសមាជិក |
| ៤. | ឯកឧត្តម នេត មុន្នី | មន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ | ជាសមាជិក |
| ៥. | លោក ម៉ា ណូរ៉ាវីន | សមាជិកក្រុមប្រឹក្សាភិបាល<br>តំណាងនិយោជិត រ.ទ.ស.ភ | ជាសមាជិក |

៦) សំណើសុំអនុម័តលើកម្មវិធីប្រជុំក្រុមប្រឹក្សាភិបាលឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាលបានអនុម័ត-ឯកភាព ៖

១) សម្រាប់ត្រីមាសទី២ កំណត់យកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣

២) សម្រាប់ត្រីមាសទី៣ កំណត់យកថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

៣) សម្រាប់ត្រីមាសទី៤ កំណត់យកថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣

៧) សំណើសុំពិនិត្យពិភាក្សា និងអនុម័តអំពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់ រ.ទ.ស.ភ

ក្រុមប្រឹក្សាភិបាលបានឯកភាពជាគោលការណ៍ជ្រើសរើសយករចនាសម្ព័ន្ធគ្រប់គ្រងជម្រើសទី១ ដែលបាន ស្នើឡើងមកធ្វើការកែសម្រួលបន្ថែមផ្នែកទៅតាមអនុសាសន៍ ដោយលុបចោលនូវប្រអប់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ព្រមទាំងស្នើសុំឱ្យពិនិត្យកែសម្រួលឈ្មោះប្រអប់នីតិកម្មនិងអធិការកិច្ច និងភារកិច្ចមួយចំនួនដែលអង្គភាពនេះមិនមែនជាអ្នកទារប្រាក់បំណុលថ្លៃទឹកទេ តែដោះស្រាយវិវាទប្រសិនបើកើតមាន។ លើសពីនេះ ក្រុមប្រឹក្សាភិបាលក៏បានណែនាំឱ្យឯកឧត្តមអគ្គនាយកចាត់ចែងផ្សព្វផ្សាយនូវលក្ខន្តិកៈ, ឯកសារស្តីពីភាពមិនអនុលោមនៃឯកសារគតិយុត្តពាក់ព័ន្ធរបស់ រ.ទ.ស.ភ ជាមួយ ប្រកាសលេខ០១១/១៨ គ.ម.ក/ប្រ.ក និងបណ្តាអនុសាសន៍របស់ក្រុមមេធាវី អេច.អឹម.អិល និងខន់សាល់ចិន ជូនដល់បុគ្គលិកជាន់ខ្ពស់ និងនិយោជិត គ្រប់រូបនៅតាមបណ្តានាយកដ្ឋានដើម្បីជាចំណេះដឹង។

៨) សំណើសុំពិភាក្សាអំពីគោលការណ៍រួមនៃក្រុមសីលធម៌ ទំនាស់ផលប្រយោជន៍ និងការអនុវត្តឱ្យសមស្រប និងអនុលោមទៅនឹងប្រកាសលេខ០១១/១៨ គ.ម.ក/ប្រ.ក ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយ លក់មូលបត្រជាសាធារណៈ

ក្រុមប្រឹក្សាភិបាលបានឯកភាពទទួលជ្រាបជាព័ត៌មាន និងបានណែនាំឱ្យ រ.ទ.ស.ភ អនុវត្តតាមអនុសាសន៍ របស់ក្រុមប្រឹក្សាភិបាលដែលបានលើកឡើង។

៩) របាយការណ៍ស្តីពីលទ្ធផលការងារត្រីមាសទី១ និងផែនការត្រីមាសទី២ ឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាលបានឯកភាពទាំងស្រុងលើរបាយការណ៍ស្តីពីលទ្ធផលការងារត្រីមាសទី១ ឆ្នាំ២០២៣ និងផែនការត្រីមាសទី២ ឆ្នាំ២០២៣។ ដោយឡែកចំពោះការងារជំរុញការតបណ្តាញទឹកស្អាតជូនប្រជាពលរដ្ឋ នៅខេត្តត្បូងឃ្មុំ ក្រុមប្រឹក្សាភិបាលបានណែនាំឱ្យ រ.ទ.ស.ភ រៀបចំនូវការវិភាគហិរញ្ញវត្ថុ ឱ្យបានច្បាស់លាស់ និងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលតាមគ្រូបតេឡេក្រាម នាពេលក្រោយ។

១០) របាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្ម អនុវត្តក្នុងដំណាច់ឆ្នាំ២០២២ និងត្រីមាសទី១ ឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាលបានឯកភាពលើរបាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងដំណាច់ឆ្នាំ២០២២ និងត្រីមាសទី១ ឆ្នាំ២០២៣ ព្រមទាំងបានជំរុញឱ្យ រ.ទ.ស.ភ ពន្លឿនការងារស្នើសុំការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅលើនីតិវិធីក្នុងការជ្រើសរើសសវនករឯករាជ្យសម្រាប់រយៈពេលពីរឆ្នាំម្តងផងដែរ។

១១) របាយការណ៍ស្តីពីមូលនិធិបម្រើផលប្រយោជន៍សង្គម ចុងឆ្នាំ២០២២ និងត្រីមាសទី១ ឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាលបានឯកភាពទាំងស្រុងលើ របាយការណ៍លទ្ធផលប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមចុងឆ្នាំ២០២២ និងត្រីមាសទី១ ឆ្នាំ២០២៣ ព្រមទាំងបានឯកភាពលើសំណើចំណាយចំនួន៣ (សំណើទី១, ទី២ និងទី៣)។ ដោយឡែក ចំពោះសំណើទី៤ ក្រុមប្រឹក្សាភិបាលបានស្នើឱ្យ រ.ទ.ស.ភ ធ្វើការសិក្សាឱ្យបានច្បាស់លាស់ មុននឹងដាក់ស្នើសុំការសម្រេចពីក្រុមប្រឹក្សាភិបាល ក្នុងកិច្ចប្រជុំលើកក្រោយ។

១២) របាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ទៃក្នុង ត្រីមាសទី១ ឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាលបានឯកភាពទទួលជ្រាបជារបាយការណ៍ ព្រមទាំងណែនាំឱ្យ រ.ទ.ស.ភ អនុវត្តទៅតាម អនុសាសន៍ណែនាំដែលបានលើកឡើង។

១៣) ផ្សេងៗ

ក- សំណើសុំពិភាក្សាអំពីហេដ្ឋារចនាសម្ព័ន្ធអង្គភាព រួមទាំងការិយាល័យធ្វើការរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល បានឯកភាពទៅតាមការរៀបចំរបស់ រ.ទ.ស.ភ។

ខ- សេចក្តីព្រាងយុទ្ធសាស្ត្រស្តពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ

ក្រុមប្រឹក្សាភិបាល បានទទួលជ្រាបជាព័ត៌មាន និងបានស្នើឱ្យឯកឧត្តមអគ្គនាយក តំណាងនិយោជិត និងបុគ្គលិកជាន់ខ្ពស់ទាំងអស់នៃ រ.ទ.ស.ភ ត្រូវយកឯកសារបទបង្ហាញខាងលើ និងឯកសារគតិយុត្តពាក់ព័ន្ធ ទៅធ្វើការផ្សព្វផ្សាយបន្តជូនដល់មន្ត្រី-និយោជិតក្រោមឱវាទទាំងអស់បានជ្រាបជាមុន មុននឹងច្បាប់ថ្មីស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈត្រូវបានដាក់ចេញឱ្យប្រើប្រាស់ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលវិញ នូវលទ្ធផលនៃការផ្សព្វផ្សាយនាកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកក្រោយ។

គ- សំណើសុំពិនិត្យ-សម្រេច លើរបាយការណ៍ជម្រើសទីតាំងដីដែលមានឧត្តមភាពបច្ចេកទេស និងសេដ្ឋកិច្ច សម្រាប់សាងសង់ស្ថានីយបូមទឹកឆៅបាក់ខែងដំហានទី៣ រួមទាំងបទបង្ហាញរបស់ទីប្រឹក្សាបច្ចេកទេស SAFEGE ស្តីពីការសិក្សាសមិទ្ធិលទ្ធភាពរបស់គម្រោងបាក់ខែងដំហានទី៣

ក្រុមប្រឹក្សាភិបាលបាន ៖

១) ឯកភាពជាគោលការណ៍ទៅលើលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពអំពីគម្រោងបាក់ខែងដំហានទី៣ ដែលបានបង្ហាញដោយទីប្រឹក្សាបច្ចេកទេសរបស់ក្រុមហ៊ុន SAFEGE ពីខាងលើ ព្រមទាំង បានអនុញ្ញាតឱ្យ រ.ទ.ស.ភ រាយការណ៍អំពីលទ្ធផលនៃការសិក្សាដែលនៅខ្វះជូនក្រុមប្រឹក្សាភិបាលជ្រាបនៃពេលក្រោយទៀត។

២) ឯកភាពជាគោលការណ៍ជ្រើសរើសយកទីតាំងដីដែលមានលក្ខណៈអំណោយផលបច្ចេកទេស និងសេដ្ឋកិច្ចខ្ពស់ជាងគេ សម្រាប់ការសាងសង់ស្ថានីយបូមទឹកឆៅបាក់ខែងដំហានទី៣។

៣) ស្នើឱ្យឯកឧត្តមអគ្គនាយកអនុវត្តទៅតាមអនុសាសន៍របស់ឯកឧត្តម ម៉ី វ៉ាន់ ដែលបានលើកឡើង សម្រាប់ត្រៀមឆ្លើយតបចំពោះដៃគូអភិវឌ្ឍន៍ក្នុងកិច្ចប្រជុំពិគ្រោះយោបល់កម្រិតនយោបាយ។

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី១ ឆ្នាំ២០២៣ (កិច្ចប្រជុំលើកទី២) អាណត្តិទី៨ របស់ រ.ទ.ស.ភ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី១ ឆ្នាំ២០២៣ (ប្រជុំលើកទី២) អាណត្តិទី៨ កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង១៤:00 នៅស្នាក់ការរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (បន្ទប់ប្រជុំលេខ ២) និងតាម ប្រព័ន្ធអនឡាញ Zoom ដែលមានរបៀបវារៈស្តីពី "សំណើសុំពិភាក្សានិងពិនិត្យលទ្ធភាពក្នុងការផ្គត់ផ្គង់ទឹកស្អាត នៅរាជធានី ភ្នំពេញ និងក្រុងតាខ្មៅ និងដំណោះស្រាយការខ្វះទឹកស្អាតជាបណ្តោះអាសន្ន ក្នុងខែមេសា-ឧសភា"

ក្រុមប្រឹក្សាភិបាលបាន ៖

១) ណែនាំឱ្យ រ.ទ.ស.ភ រៀបចំចងក្រងនូវមូលហេតុនៃការខ្វះទឹកជាទិដ្ឋភាពបច្ចេកទេស ដោយសរសេរខ្លីៗ និងចំៗ ដោយភ្ជាប់ជាមួយសំណូមពរដល់អតិថិជនឱ្យមានការសន្សំសំចៃទឹក សម្រាប់ជំរុញការផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មានឱ្យបានច្រើន និងកាន់តែទូលាយ និងតាមរយៈអាជ្ញាធរមូលដ្ឋាន។

២) ណែនាំឱ្យ រ.ទ.ស.ភ ទំនាក់ទំនងជាមួយអតិថិជនធំៗ ឱ្យគាត់ជួយសម្រួល ដូចជាការកាត់បន្ថយ ឬប្តូរម៉ោងផលិតកម្មរបស់ពួកគាត់ ព្រមទាំងស្នើសុំរដ្ឋបាលរាជធានីភ្នំពេញឱ្យប្រើប្រាស់ទឹកទន្លេជាបណ្តោះអាសន្នសិន សម្រាប់ការលាងថ្នល់ និងស្រោចសួនសាធារណៈ។

៣) ស្នើសុំរៀបចំការចែកចាយទឹកនេះជាលក្ខណៈយុទ្ធសាស្រ្ត (ប្រមូលផ្តុំ) ដោយកំណត់ឱ្យបានច្បាស់លាស់នូវទីតាំងឬគោលដៅផ្គត់ផ្គង់, ពេលវេលាចែកចាយទឹក, ចំនួនរថយន្តដឹកទឹកដែលត្រូវផ្គត់ផ្គង់ទៅតាមច្រកនីមួយៗ, ទីតាំងបង្គោលពន្លត់អគ្គិភ័យដែលត្រូវយកទឹក និងទីតាំងដំឡើង Standpipe ជាដើម។

៤) ណែនាំឱ្យ រ.ទ.ស.ភ ត្រូវជួបពិភាក្សាជាមួយក្រុមហ៊ុនម៉ៅការសាងសង់វិរៈកមធ្យោបាយ និងពិនិត្យលទ្ធភាពក្នុងការបង្កើនល្បឿនការសាងសង់រោងចក្របាក់ខែងដំហានទី១ ព្រមទាំងត្រូវពន្លឿនការដាក់បំពង់តភ្ជាប់ជាមួយរោងចក្រ ក៏ដូចជាការកាត់ភ្ជាប់យកទឹកពីរោងចក្រនេះទៅផ្គត់ផ្គង់ខណ្ឌជ្រោយចង្វារ ហើយបញ្ជូនទឹកទាំងអស់ពីរោងចក្រជ្រោយចង្វារមកផ្គត់ផ្គង់នៅរាជធានីភ្នំពេញវិញ។

៥) អនុញ្ញាតឱ្យ រ.ទ.ស.ភ ប្រើប្រាស់នូវមូលនិធិបម្រើផលប្រយោជន៍សង្គម ដើម្បីទូទាត់រាល់ការចំណាយរួមទាំងថ្លៃទឹកសម្រាប់ការងារដឹក ទឹកស្អាតយកទៅចែកចាយជូនដល់អតិថិជននៅរាជធានីភ្នំពេញ និង ក្រុងតាខ្មៅដែលកំពុងប្រឈមខ្វះទឹកប្រើប្រាស់ ក្នុងអំឡុងរដូវក្តៅនេះ។

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៦រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**
**សមាជិកក្រុមប្រឹក្សាភិបាលអវត្តមានចំនួន១រូប។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៣ អាណត្តិទី៨ របស់ រ.ទ.ស.ភ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៣ អាណត្តិទី៨ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង៨:៣០នាទី នៅទីស្នាក់ការរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (បន្ទប់ប្រជុំលេខ១)ដែលមានរបៀបវារៈដូចខាងក្រោម ៖

១) សំណើសុំពិនិត្យ-សម្រេចលើការចំណាយបន្ថែមក្នុងការរៀបចំតភ្ជាប់ចរន្តអគ្គិសនី ដើម្បីផ្គត់ផ្គង់ក្នុងរោងចក្រផលិតទឹកស្អាតបឹងធំ និង Compact Water Treatment System

ក្រុមប្រឹក្សាភិបាល បានឯកភាពទៅលើការចំណាយបន្ថែម ដែលមានទឹកប្រាក់សរុបចំនួន ៣៦១.០០០ ដុល្លារអាមេរិក សម្រាប់រៀបចំតភ្ជាប់ចរន្តអគ្គិសនីដើម្បីផ្គត់ផ្គង់ក្នុងរោងចក្រផលិតទឹកស្អាតបឹងធំ និង Compact Water Treatment System ។

២) សំណើសុំពិនិត្យ-ពិភាក្សាអំពីទម្រង់វាយតម្លៃលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល និងទម្រង់វាយតម្លៃលទ្ធផលការងាររបស់អភិបាលនីមួយៗ

ក្រុមប្រឹក្សាភិបាល បានឯកភាពជាគោលការណ៍ជ្រើសរើសយកទម្រង់វាយតម្លៃលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល (ទម្រង់ទី១) សម្រាប់អនុវត្តន៍ចាប់ពីឆ្នាំនេះតទៅ ព្រមទាំងស្នើសុំឱ្យគ្រប់សមាជិកក្រុមប្រឹក្សាភិបាលចូលរួមផ្តល់យោបល់បន្ថែមទៅលើទម្រង់វាយតម្លៃនេះ បើមាន។

៣) របាយការណ៍ស្តីពីលទ្ធផលការងារត្រីមាសទី២-ឆមាសទី១ និងផែនការត្រីមាសទី៣ ឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាល បានឯកភាពទាំងស្រុងលើរបាយការណ៍ស្តីពីលទ្ធផលការងារត្រីមាសទី២-ឆមាសទី១ និងផែនការត្រីមាសទី៣ ឆ្នាំ២០២៣ ព្រមទាំងបានណែនាំឱ្យ រ.ទ.ស.ភ ធ្វើលិខិតសុំអន្តរាគមន៍ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការស្នើសុំរដ្ឋបាល ខេត្តកណ្តាលជួយពិនិត្យលទ្ធភាពផ្តល់ដីសម្បទាននៅតំបន់អរិយក្សត្រ សម្រាប់ធ្វើជាទីតាំងសាងសង់រោងចក្រផលិតទឹកស្អាតដើម្បីផ្គត់ផ្គង់ទឹកស្អាតនៅទីនោះ។

៤) របាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្ម អនុវត្តក្នុងត្រីមាសទី២ និងសំណើសុំពិនិត្យ-អនុម័តលើផែនការកែតម្រូវឆមាសទី២ ឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាល បានឯកភាពលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី២ និងបានអនុម័ត-ឯកភាពលើគម្រោងលទ្ធកម្មកែតម្រូវឆមាសទី២ ឆ្នាំ២០២៣។

៥) របាយការណ៍ស្តីពីមូលនិធិបម្រើផលប្រយោជន៍សង្គម ត្រីមាសទី២ ឆ្នាំ២០២៣ និងសំណើសុំពិនិត្យអនុម័តលើការចំណាយឧបត្ថម្ភចំនួន ៣សំណើ

ក្រុមប្រឹក្សាភិបាល បានឯកភាពលើរបាយការណ៍លទ្ធផលប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមត្រីមាសទី២ ឆ្នាំ២០២៣ ព្រមទាំងបានឯកភាពទៅលើសំណើទាំង៣ និងទឹកប្រាក់គ្រោងចំណាយប៉ាន់ស្មានសរុបប្រមាណ ១០៩.៣៦០ដុល្លារអាមេរិក។

៦) របាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី២ ឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាលបានឯកភាពទទួលជ្រាបជារបាយការណ៍ព្រមទាំងបានណែនាំឱ្យសវនកម្មផ្ទៃក្នុងពិនិត្យលទ្ធភាពកែសម្រួលរបាយការណ៍សវនកម្ម ឬរៀបចំទម្រង់របាយការណ៍ថ្មី ដោយមានរំលេចនូវឧបករណ៍ជំនួយផ្សេងៗទៀត ដើម្បីផ្តល់ភាពងាយស្រួលដល់ការត្រួតពិនិត្យនិងការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល។

៧) របាយការណ៍ស្តីពីលទ្ធផលនៃយុទ្ធនាការអនុវត្តវិធានការដោះស្រាយបន្ទាន់ ចំពោះបញ្ហាកង្វះទឹកស្អាតនារដូវប្រាំង ឆ្នាំ២០២៣ នៅតាមបណ្តាសង្កាត់-ខណ្ឌមួយចំនួននៅរាជធានីភ្នំពេញ និងសង្កាត់មួយចំនួននៅជាយក្រុងតាខ្មៅ

ក្រុមប្រឹក្សាភិបាល បានទទួលជ្រាបជារបាយការណ៍។

៨) ផ្សេងៗ

ប្រធានក្រុមប្រឹក្សាភិបាលបានផ្តល់ព័ត៌មាន និងអនុសាសន៍ណែនាំឱ្យ រ.ទ.ស.ភ ពិនិត្យគិតគូរទៅលើការងារចំនួន៣ ដូចខាងក្រោម ៖

ក) ច្បាប់ថ្មីស្ដីពីការគ្រប់គ្រងសហគ្រាសសាធារណៈ ដែលគ្រោងនឹងប្រកាសដាក់ឱ្យប្រើប្រាស់នាចុងឆ្នាំ ២០២៣ នេះ ពុំមានចែងនិងតម្រូវឱ្យមានការតែងតាំងស្នងការគណនី និងភ្នាក់ងារគណនេយ្យទៀតនោះទេ។ ដូច្នេះ រ.ទ.ស.ភ ពុំចាំបាច់រៀបចំស្នើសុំការតែងតាំងនេះទេ។

ខ) ចំពោះការងារអភិវឌ្ឍនធនធានមនុស្ស ដោយពិនិត្យឃើញថាមានភាពយឺតយ៉ាវក្នុងការស្វែងរកអ្នកបច្ចេកទេសគិតគូរអំពីគម្រោងសិក្សា សេចក្ដីត្រូវការបណ្ដុះបណ្ដាលធនធានមនុស្ស រ.ទ.ស.ភ អាចពិនិត្យលទ្ធភាពក្នុងការរៀបចំបង្កើតបន្ថែមនូវការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីទទួលបន្ទុក ការងារនេះតែម្ដង និងរៀបចំរចនាសម្ព័ន្ធការិយាល័យនេះ។

គ) សាខាសេវាកម្មទឹកស្អាតនិងអនាម័យ មានតែអគ្គនាយករងទទួលបន្ទុក តែមិនទាន់មានប្រធានសាខា គ្រប់គ្រងនៅឡើយ ដោយបច្ចុប្បន្នអគ្គនាយកនៅជាប្រធានគ្រប់គ្រងនៅឡើយ ហើយម្យ៉ាងទៀត សាខាត្រូវទទួលបន្ទុកគម្រោងនៅតាមបណ្ដាខេត្តនានា ដូចជាការដេញថ្លៃជាដើម។ ឯកឧត្តមបារម្ភថាអាចខុសនឹងលក្ខន្តិកៈនៃការគ្រប់គ្រង។ ហេតុនេះ ស្នើពិនិត្យក្នុងការរៀបចំឱ្យមានប្រធានសាខាសេវាកម្មទឹកស្អាតនិងអនាម័យឡើងវិញ។

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី២ ឆ្នាំ២០២៣ (កិច្ចប្រជុំលើកទី៤) អាណត្តិទី៨ របស់ រ.ទ.ស.ភ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី២ ឆ្នាំ២០២៣ (ប្រជុំលើកទី៤) អាណត្តិទី៨ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង៨:៣០នាទី នៅស្នាក់ការរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (បន្ទប់ប្រជុំលេខ១) ដែលមានរបៀបវារៈ ដូចខាងក្រោម៖

១) សំណើសុំផ្ដល់អនុសាសន៍ទៅលើសំណើរបស់រដ្ឋបាលរាជធានីភ្នំពេញ សុំឱ្យ រ.ទ.ស.ភ ពិនិត្យលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតនៅសង្កាត់ពញាពន់ សង្កាត់សំរោង និងសង្កាត់ព្រែកព្នៅ ស្ថិតក្នុងខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

ក្រុមប្រឹក្សាភិបាល បាន៖

១- ស្នើសុំឯកឧត្តម នួន ផារ័ត្ន ជួយធ្វើលិខិតក្នុងនាមរដ្ឋបាលរាជធានីភ្នំពេញ ទៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្នើសុំអន្តរាគមន៍ក្នុងការកាត់យកសង្កាត់ពញាពន់ សង្កាត់សំរោង និងសង្កាត់ព្រែកព្នៅ នៃខណ្ឌព្រែកព្នៅ បញ្ចូលមកក្នុងដែនសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ រ.ទ.ស.ភ ដោយយោងកំណត់ហេតុនេះ។

២- គាំទ្រឱ្យ រ.ទ.ស.ភ ធ្វើការសិក្សាស៊ីជម្រៅនិងច្បាស់លាស់អំពីស្ថានភាពអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ក្រុមហ៊ុនព្រៃគុប ខនស្ត្រាក់សិន នៅក្នុងសង្កាត់ពញាពន់ សង្កាត់សំរោង និងសង្កាត់ព្រែកព្នៅ ដោយលទ្ធផលនៃការសិក្សានេះត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល នៅក្នុងកិច្ចប្រជុំបន្ទាប់នាខែកញ្ញា ឆ្នាំ២០២៣ ដើម្បីសុំគោលការណ៍ពីក្រសួងអាណាព្យាបាលសម្រាប់អនុវត្តបន្ត។

៣- អនុញ្ញាតឱ្យ រ.ទ.ស.ភ បង្កើតគណៈកម្មការចម្រុះមួយ ដោយមានសមាសភាពចូលរួមពី រ.ទ.ស.ភ, ក្រសួងអាណាព្យាបាលទាំងពីរ និងរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីធ្វើការសិក្សាខាងលើនេះឱ្យបានឆាប់រហ័ស។

២) របាយការណ៍ស្ដីពីលទ្ធផលនៃការរៀបចំម៉ូដែលវិភាគហិរញ្ញវត្ថុឆ្នាំ២០២១-២០២២របស់ រ.ទ.ស.ភ ក្រោមជំនួយឥតសំណងរបស់រដ្ឋាភិបាលបារាំង តាមរយៈទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD)

ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍។

៣) របាយការណ៍ស្ដីពីលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពបឋមទៅលើគម្រោង Smart Water Management Sytstem ក្រោមជំនួយឥតសំណងរបស់សាធារណរដ្ឋកូរ៉េ និងសំណើសុំពិនិត្យ-អនុញ្ញាតជាគោលការណ៍ដើម្បី បន្តការសិក្សាសមិទ្ធិលទ្ធភាពនេះ សម្រាប់អនុតំបន់ដែលនៅសល់ពីអនុតំបន់ដែលទទួលពីជំនួយឥតសំណង

ក្រុមប្រឹក្សាភិបាល បានបានទទួលជ្រាបនូវរបាយការណ៍លទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពបឋមលើគម្រោង Smart Water Management System ក្រោមជំនួយឥតសំណងរបស់រដ្ឋាភិបាលកូរ៉េ និងបានឯកភាពជាជគោលការណ៍ ឱ្យ រ.ទ.ស.ភ បន្តការសិក្សាសិទ្ធិលទ្ធភាពនេះសម្រាប់អនុតំបន់ដែលនៅសល់ពីគម្រោងជំនួយឥតសំណងខាងលើ។

៤) ផ្សេងៗ- សំណើសុំផ្តល់អនុសាសន៍ណែនាំ ពាក់ព័ន្ធនឹងបញ្ហាផ្គត់ផ្គង់ទឹកស្អាតក្នុងបុរី ម៉ន ដានី ស្ថិតក្នុងភូមិអណ្តូងតាអន សង្កាត់សំពោងក្រោម ខណ្ឌពោធិ៍សែនជ័យ

ក្រុមប្រឹក្សាភិបាល បានទទួលជ្រាបជារបាយការណ៍ ព្រមទាំងបាន ៖

១- សំណូមពរឯកឧត្តម នួន ផារ័ត្ន ជួយអន្តរាគមន៍ទៅអាជ្ញាធរខណ្ឌឱ្យធ្វើលិខិតតាមរយៈរដ្ឋបាលរាជធានីភ្នំពេញ ស្នើសុំ រ.ទ.ស.ភ ជួយផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋនៅក្នុងបុរី ម៉ន ដានី គម្រោងទី២៦។

២- ឯកភាពឱ្យ រ.ទ.ស.ភ ប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម ដើម្បីទូទាត់រាល់ចំណាយក្នុងការផ្គត់ផ្គង់ទឹកចូលទីតាំងបុរីនេះ។

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៥ អាណត្តិទី៨ របស់ រ.ទ.ស.ភ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៥ អាណត្តិទី៨ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង៩:០០ព្រឹក នៅទីស្នាក់ការរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (បន្ទប់ប្រជុំលេខ១) ដែលមានរបៀបវារៈដូចខាងក្រោម ៖

១) សំណើសុំពិនិត្យ-អនុម័តលើថ្លៃលក់ទឹកដុំ ជូនអ្នកលក់ទឹកបន្តនៅខេត្តត្បូងឃ្មុំ

ក្រុមប្រឹក្សាភិបាល បានអនុម័តជាគោលការណ៍ឱ្យ រ.ទ.ស.ភ លក់ទឹកដុំជូនអ្នកលក់ទឹកបន្តនៅខេត្តត្បូងឃ្មុំ ក្នុងថ្លៃចន្លោះពី ១.៧៥០រៀល/ម៣ ទៅ ១.៨០០រៀល/ម៣ ដោយកំណត់យកថ្លៃគោលគឺ ១.៨០០រៀល/ម៣។

២) របាយការណ៍ស្តីពីស្ថានភាពផ្គត់ផ្គង់ទឹកស្អាតចូលបុរី ម៉ន ដានី ទាំង១៣ទីតាំង

ក្រុមប្រឹក្សាភិបាល បាន៖

១- ស្នើសុំឯកឧត្តម នួន ផារ័ត្ន ជួយអន្តរាគមន៍ និងសម្របសម្រួលឱ្យមានកិច្ចប្រជុំរវាងក្រុមការងាររដ្ឋបាលរាជធានីភ្នំពេញទទួលបន្ទុកដោះស្រាយករណីបុរី ម៉ន ដានី, រ.ទ.ស.ភ, តំណាងបុរី ម៉ន ដានី និងតំណាងប្រជាពលរដ្ឋនៅក្នុងបុរីទាំងអស់ ដើម្បីពិភាក្សានិងស្ទាបស្ទង់មតិរបស់ប្រជាពលរដ្ឋទៅលើដំណោះស្រាយបញ្ហាផ្គត់ផ្គង់ទឹកស្អាតនៅក្នុងបុរីនេះ ដោយឈរលើគោលការណ៍ "រ.ទ.ស.ភ ជាអ្នកចេញថ្លៃវិនិយោគលើការដាក់បំពង់មេចែកចាយទឹក និង/ឬបំពង់មេនាំទឹកហូតដល់មាត់ច្រកបុរី ដើម្បីអាចផ្គត់ផ្គង់ទឹកស្អាតបានគ្រប់គ្រាន់ជូនប្រជាពលរដ្ឋនៅក្នុងបុរីប្រើប្រាស់ រីឯចំណាយវិនិយោគ សម្រាប់រៀបចំបណ្តាញចែកចាយទឹកក្នុងបុរី គឺជាបន្ទុករបស់ប្រជាពលរដ្ឋនៅក្នុងបុរីផ្ទាល់ ហើយថ្លៃលក់ទឹកនឹងអនុវត្តតាមថ្លៃទឹកបច្ចុប្បន្ន របស់ រ.ទ.ស.ភ។

២- អនុញ្ញាតឱ្យ រ.ទ.ស.ភ ប្រើប្រាស់ថវិកាមូលនិធិបម្រើផលប្រយោជន៍សង្គម សម្រាប់ទូទាត់ថ្លៃវិនិយោគខាងលើ និងថ្លៃតបណ្តាញចូលផ្ទះជូនប្រជាពលរដ្ឋដែលកំពុងរងគ្រោះនៅបុរី ម៉ន ដានី។

៣- អនុញ្ញាតឱ្យ រ.ទ.ស.ភ ធ្វើការកាត់កងបំណុលថ្លៃទឹកដែលបុរី ម៉ន ដានី ជំពាក់ជាមួយនឹងប្រាក់កក់ធានាការប្រើប្រាស់ទឹករយៈពេល៣ខែរបស់បុរី ឱ្យស្របទៅតាមគោលការណ៍ជាធរមានរបស់ រ.ទ.ស.ភ។

៣) របាយការណ៍ស្តីពីមូលនិធិបម្រើផលប្រយោជន៍សង្គម ត្រីមាសទី៣ ឆ្នាំ២០២៣ និងសំណើសុំពិនិត្យ-អនុម័តលើគម្រោងប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមឆ្នាំ២០២៤

ក្រុមប្រឹក្សាភិបាល បានឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមត្រីមាសទី៣ ឆ្នាំ២០២៣ ព្រមទាំងបានអនុម័ត-ឯកភាពជាគោលការណ៍លើគម្រោងថវិកាមូលនិធិសម្រាប់ ឆ្នាំ២០២៤ ដោយបែងចែកទៅតាមជំពូកចំណាយទាំង៥ ដូចខាងក្រោម៖

ក- ចំណាយកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម : ២០% នៃមូលនិធិសរុប

ខ- ចំណាយសង្គ្រោះ : ២០% នៃមូលនិធិសរុប
គ- ចំណាយសង្គ្រោះនិយោជិត : ៣៥% នៃមូលនិធិសរុប
ឃ- ចំណាយឧបត្ថម្ភបណ្ដាញចំណូលទាប : ១០% នៃមូលនិធិសរុប
ង- ចំណាយផ្សេងៗ : ១៥% នៃមូលនិធិសរុប

៤) របាយការណ៍ពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី៣ ឆ្នាំ២០២៣ និងផែនការឆ្នាំ២០២៤ និងសុំការអនុម័តជាគោលការណ៍លើគម្រោងជួលទីប្រឹក្សាពិគ្រោះយោបល់ ដើម្បីកសាងឯកសារក្បួនសវនកម្មផ្ទៃក្នុង

ក្រុមប្រឹក្សាភិបាល *បានអនុម័តៈ*

១- ឯកភាពទាំងស្រុងទៅលើរបាយការណ៍ស្ដីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុងត្រីមាសទី៣ឆ្នាំ ២០២៣ និងផែនការសកម្មភាពសវនកម្មឆ្នាំ២០២៤។

២- អនុញ្ញាតជាគោលការណ៍ឱ្យ រ.ទ.ស.ភ ធ្វើការចងក្រងសៀវភៅក្បួនសវនកម្មផ្ទៃក្នុង ដោយស្នើសុំលោកអភិបាលឯករាជ្យជួយរៀបចំលក្ខខណ្ឌការងារ (TOR) សម្រាប់គម្រោងនេះជូន រ.ទ.ស.ភ ដើម្បីជាមូលដ្ឋានក្នុងការស្នើសុំដៃគូអភិវឌ្ឍន៍បញ្ចូលទៅក្នុងគម្រោងធ្វើឱ្យប្រសើរឡើងនូវស្ថាប័ន។ ចំណែកឯគម្រោងជួលទីប្រឹក្សាបច្ចេកទេសដើម្បីចងក្រងសៀវភៅនេះនឹងត្រូវលើកយកមកពិនិត្យ-អនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនាពេលក្រោយ ក្នុងករណីមិនទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ចំពោះសំណើខាងលើទេ។

៥) របាយការណ៍ស្ដីពីលទ្ធផលនៃការសិក្សាស្ថានភាពផ្គត់ផ្គង់ទឹកស្អាតនៅសង្កាត់ព្រែកព្នៅ, សង្កាត់ពញាពន់ និងសង្កាត់សំរោង ស្ថិតក្នុងខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

ក្រុមប្រឹក្សាភិបាល បានទទួលជ្រាបជារបាយការណ៍ ព្រមទាំងបានផ្ដល់នូវអនុសាសន៍ណែនាំ ដូចខាងក្រោមៈ

១- រ.ទ.ស.ភ ត្រូវពន្លឿនការរៀបចំសេចក្ដីសម្រេចបង្កើតគណៈកម្មការចម្រុះ ដើម្បីចុះសិក្សាស្ថានភាពអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ក្រុមហ៊ុនព្រែកុប ខនស្រ្ដាក់សិន នៅសង្កាត់ព្រែកព្នៅ, សង្កាត់ពញាពន់ និងសង្កាត់សំរោង ស្ថិតក្នុងខណ្ឌព្រែកព្នៅ ស្របតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ក្នុងសម័យប្រជុំវិសាមញ្ញកាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣។

២- គណៈកម្មការចម្រុះដែលនឹងត្រូវបង្កើតឡើងដូចខាងលើ និងក្រុមការងារជំនាញរបស់ រ.ទ.ស.ភ ត្រូវបន្តចុះទៅប្រមូលព័ត៌មាននិងទិន្នន័យបន្ថែមទៀតពីក្រុមហ៊ុន យកមកធ្វើការសិក្សា វិភាគ និងវាយតម្លៃឱ្យបានកាន់តែស៊ីជម្រៅ ព្រមទាំងលើកយោបល់ជូនក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ-សម្រេច នាកិច្ចប្រជុំលើកក្រោយ។

៦) របាយការណ៍ស្ដីពីលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពរបស់គ្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ជំហានទី៣

ក្រុមប្រឹក្សាភិបាល បានអនុម័តៈ

១- ឯកភាពទាំងស្រុងទៅលើរបាយការណ៍លទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពរបស់គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែងជំហានទី៣។

២- ផ្ដល់ការគាំទ្រទៅលើគម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែងជំហានទី៣ ព្រមទាំងប្រគល់សិទ្ធិជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃ រ.ទ.ស.ភ ក្នុងការចរចាហិរញ្ញប្បទានជាមួយ ដៃគូអភិវឌ្ឍន៍ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទាន ដើម្បីឈានទៅអនុវត្តគម្រោងនេះតាមកម្មវិធីកំណត់។

៧) របាយការណ៍ស្ដីពីការសិក្សាបឋម នៃគម្រោងសិក្សាសមិទ្ធិលទ្ធភាពគម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាពនូវការផ្គត់ផ្គង់ទឹកស្អាតភាគខាងកើតនិងខាងត្បូងនៃរាជធានីភ្នំពេញ ក្រោមហិរញ្ញប្បទានឥតសំណងរបស់សាធារណរដ្ឋកូរ៉េ

ក្រុមប្រឹក្សាភិបាល បានទទួលជ្រាបជារបាយការណ៍ ព្រមទាំងបានអនុញ្ញាតឱ្យ រ.ទ.ស.ភ បង្វែរគម្រោងសិក្សាសមិទ្ធិលទ្ធភាពគម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាព នូវការផ្គត់ផ្គង់ទឹកស្អាតភាគខាងកើតទៅអនុវត្តគម្រោងសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោង Smart Water Management System ជំនួសវិញក្រោមហិរញ្ញប្បទាន ឥតសំណងរបស់សាធារណរដ្ឋកូរ៉េ និងស្នើឱ្យទីប្រឹក្សាបច្ចេកទេសធ្វើការសិក្សាវិភាគ

សេដ្ឋកិច្ចអំពីគម្រោងនេះឱ្យបានច្បាស់លាស់។ ចំណែកឯគម្រោងសិក្សាសមិទ្ធិលទ្ធភាពគម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាពនូវការផ្គត់ផ្គង់ទឹកស្អាតភាគខាងត្បូង នៅបន្តអនុវត្តដដែល។

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៦រូប។**

**សមាជិកក្រុមប្រឹក្សាភិបាលអវត្តមានចំនួន១រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី៣ ឆ្នាំ២០២៣ (កិច្ចប្រជុំលើកទី៦) អាណត្តិទី៨ របស់ រ.ទ.ស.ភ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី៣ ឆ្នាំ២០២៣ (ប្រជុំលើកទី៦) អាណត្តិទី៨ កាលពី ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង៩:០០ព្រឹក នៅស្នាក់ការរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (បន្ទប់ប្រជុំលេខ១) និងតាមប្រព័ន្ធអនឡាញ Zoom ដែលមានរបៀបវារៈ ដូចខាងក្រោម៖

១) របាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ២០២៣ (៨ខែបូក៤ខែប៉ាន់ស្មាន) និងសំណើសុំពិនិត្យ-អនុម័តលើគម្រោងផែនការសហគ្រាស និងទុនវិនិយោគឆ្នាំ២០២៤

ក្រុមប្រឹក្សាភិបាល បានឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលការងារឆ្នាំ២០២៣ (៨ខែបូក៤ខែ ប៉ាន់ស្មាន)។ លើសពីនេះ ក្រុមប្រឹក្សាភិបាលបានណែនាំឱ្យ រ.ទ.ស.ភ ពិនិត្យកែសម្រួលលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ វាយតម្លៃនិងផ្តល់បណ្តាញជូនអតិថិជនចំណូលទាប ផ្អែកតាមលក្ខណៈវិនិច្ឆ័យកម្រិតភាពក្រីក្រ (ក្រកម្រិត១ និងក្រកម្រិត២) ដែលកំពុងអនុវត្តដោយរាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ន ព្រមទាំងស្នើសុំកិច្ចអន្តរាគមន៍ពីឯកឧត្តម នួន ផារ័ត្ន ក្នុងការជួយពន្លឿនសំណើរបស់ រ.ទ.ស.ភ សុំការអនុញ្ញាត ជីកកាត់កំណាត់ផ្លូវដើម្បីដាក់បំពង់មេនាំទឹក។ ដោយឡែកចំពោះផែនការឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាល បានស្នើឱ្យកែសម្រួលតួលេខប្រាក់ចំណេញ ប្រមាណ១៤៨.៧៧២.៨៤៣.០០០រៀល និងទុនវិនិយោគប្រមាណ ៦១០.៣៦៨.៧២៤.៤១១រៀល និងឯកភាពដំឡើងកាំបៀវត្សរ៍ចំនួនមួយ(១)កាំ ជូនដល់មន្ត្រី-និយោជិតក្នុងក្របខ័ណ្ឌទាំងបួន។ ក្នុងនេះសន្ទស្សន៍ សំខាន់ៗនៃគម្រោងផែនការសហគ្រាស និងទុនវិនិយោគសម្រាប់ឆ្នាំ២០២៤ ដែលត្រូវលើកជាសំណើស្នើសុំការគាំទ្រ និងការអនុម័តពីក្រសួងអាណាព្យាបាលទាំង២ មានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | គម្រោងចំណូលសរុប | | ៤៧០.៦០០.៦៩២.០០០រៀល |
| ២. | គម្រោងចំណាយសរុប | | ២៨៤.៦៣៤.៦៣៨.០០០រៀល |
| ក្នុងនោះ៖ | ២.១ | ចំណាយដំណើរការសហគ្រាស | ១៨៣.៧៣៤.៨២៩.០០០រៀល |
| | ២.២ | ខាតលើអត្រាប្តូរប្រាក់ | ១០.៨៣៨.៧៤៥.០០០រៀល |
| | ២.៣ | រំលស់ | ៦៩.៩១៤.៣៩៩.០០០រៀល |
| | ២.៤ | ការប្រាក់ធនាគារ | ៩.៥៧៥.៩៥១.០០០រៀល |
| | ២.៥ | ដោះដូរនាឡិកា | ៥.២០៧.៤១៧.០០០រៀល |
| | ៣.៦ | ចំណាយក្រៅដំណើរការសហគ្រាស | ៥.៣៦៣.២៩៧.០០០រៀល |
| ៣. | គម្រោងចំណាយក្រោយបង់ពន្ធ | | ១៤៨.៧៧២.៨៤៣.០០០រៀល |
| ៤. | គម្រោងវិនិយោគសរុប | | ៦១០.៣៦៨.៧២៤.៤១១រៀល |
| ក្នុងនោះ៖ | ៤.១ | ថវិកាបដិភាគ | ១៧២.៧៨២.៨១៤.៤៦១រៀល |
| | ៤.២ | ហិរញ្ញប្បទានទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) | ៤២៦.៧៧៩.៣៣៤.៩៥០រៀល |
| | ៤.៣ | ធនាគារវិនិយោគអឺរ៉ុប (EIB) | ១០.៨០៦.៥៧៥.០០០រៀល |

២) របាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ និងសំណើសុំពិនិត្យ-អនុម័តលើគម្រោងផែនការលទ្ធកម្មឆ្នាំ២០២៤

ក្រុមប្រឹក្សាភិបាល បានអនុម័ត-ឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្ម អនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ និងគម្រោងផែនការលទ្ធកម្មសម្រាប់ឆ្នាំ២០២៤។

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៧ អាណត្តិទី៨ របស់ រ.ទ.ស.ភ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៧ អាណត្តិទី៨ កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ៩:០០ព្រឹក នៅទីស្នាក់ការរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (បន្ទប់ប្រជុំលេខ១) ដែលមានរបៀបវារៈដូចខាងក្រោម ៖

១) សំណើសុំអនុម័តលើកម្មវិធីប្រជុំក្រុមប្រឹក្សាភិបាលឆ្នាំ២០២៤

ក្រុមប្រឹក្សាភិបាល បានអនុម័ត-ឯកភាព៖

១- សម្រាប់ត្រីមាសទី១ កំណត់យកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤

២- សម្រាប់ត្រីមាសទី២ កំណត់យកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤

៣- សម្រាប់ត្រីមាសទី៣ កំណត់យកថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤

៤- សម្រាប់ត្រីមាសទី៤ កំណត់យកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤

២) សំណើសុំពិភាក្សាលើលទ្ធផលវាយតម្លៃការងាររបស់ក្រុមប្រឹក្សាភិបាល ប្រចាំឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាល បានឯកភាពទៅលើរបាយការណ៍ស្តីពីលទ្ធផលវាយតម្លៃការងាររបស់ ក្រុមប្រឹក្សាភិបាល ប្រចាំឆ្នាំ២០២៣។

៣) របាយការណ៍ស្តីពីលទ្ធផលការងារ១០ខែ បូក២ខែប៉ាន់ស្មានឆ្នាំ២០២៣ និងផែនការត្រីមាសទី១ ឆ្នាំ២០២៤

ក្រុមប្រឹក្សាភិបាល បានឯកភាពទាំងស្រុងទៅលើរបាយការណ៍ស្តីពីលទ្ធផលការងារ១០ខែ បូក២ខែប៉ាន់ស្មាន ឆ្នាំ២០២៣ និងទិសដៅផែនការត្រីមាសទី១ ឆ្នាំ២០២៤ ព្រមទាំងបានឯកភាពលើសំណើសុំពន្យារពេលកម្មវិធីអនុវត្តគម្រោងសាងសង់រោងចក្រផលិតទឹកស្អាតបឹងធំ និងបានណែនាំឱ្យ រ.ទ.ស.ភ យកចិត្តទុកដាក់អនុវត្តគម្រោងនេះឱ្យបានទាន់តាមកម្មវិធីកំណត់។

៤) របាយការណ៍ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមអនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ និងសំណើសុំពិនិត្យ-អនុម័តលើថវិកចំណាយចំនួន៣គម្រោង

ក្រុមប្រឹក្សាភិបាល បានឯកភាពលើរបាយការណ៍លទ្ធផលប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមត្រីមាសទី៤ ឆ្នាំ២០២៣ និងគម្រោងចំណាយទាំង៣ ខាងលើ។

៥) របាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាល បានអនុម័ត-ឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០២៣។

៦) របាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី៤ ឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍ព្រមទាំងណែនាំឱ្យ រ.ទ.ស.ភ អនុវត្តទៅតាមអនុសាសន៍ណែនាំដែលបានលើកឡើងខាងលើ។

៧) របាយការណ៍ស្តីពីលទ្ធផលនៃដំណើរការសាងសង់រោងចក្រផលិតទឹកស្អាតបឹងធំ សមត្ថភាពផលិត៦.០០០ម$^{3}$/ថ្ងៃ

ក្រុមប្រឹក្សាភិបាល បានទទួលជ្រាប និងសម្រេចរួចហើយ ក្នុងរបៀបវារៈទី៣។

៨) របាយការណ៍ស្តីពីលទ្ធផលការងារផ្គត់ផ្គង់ទឹកស្អាតចូលក្នុងបុរី ម៉ន ដានី

ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍ និងបានសំណូមពរឯកឧត្តម នួន ផារ័ត្ន ជួយអន្តរាគមន៍បង្កើតបន្ថែមនូវតំណាងប្រជាពលរដ្ឋនៅទីតាំងបុរីគម្រោងទី១៤ និងទី២២ ដើម្បីសម្របសម្រួលការងារប្រមូលថវិកាពីប្រជាពលរដ្ឋ មកបង់ជូន រ.ទ.ស.ភ សម្រាប់ថ្លៃវិនិយោគក្នុងការរៀបចំបណ្តាញចែកចាយទឹកនៅទីតាំងខាងលើ ព្រមទាំងជំរុញឱ្យបុរី ម៉ន ដានី ផ្ទាល់ជាអ្នកទទួលបន្ទុកលើការចំណាយវិនិយោគដាក់បណ្តាញចែកចាយទឹកនៅក្នុងទីតាំងបុរីគម្រោងទី៣១ ផងដែរ។

៩) ផ្សេងៗ

ក- សំណើសុំពិនិត្យ-អនុញ្ញាតជាគោលការណ៍លើការផ្តល់អាហារូបករណ៍ប្រចាំឆ្នាំ សម្រាប់ការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រចំនួន៥កន្លែង នៅសាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកម្ពុជា (CamTech)

ក្រុមប្រឹក្សាភិបាល បានអនុម័តឧបត្ថម្ភតែទៅលើថ្លៃសិក្សា (Tuition Fee) រយៈពេល២ឆ្នាំ សម្រាប់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) ចំនួន៥កន្លែង ជូនដល់បុគ្គលិករបស់ក្រសួង

ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅសាកលវិទ្យាល័យ CamTech ដែលមានទឹកប្រាក់សរុបរួមចំនួន ៤៥.០០០ដុល្លារអាមេរិក ឬ ២២.៥០០ដុល្លារអាមេរិកក្នុងមួយឆ្នាំតែប៉ុណ្ណោះ។

ខ- របាយការណ៍ស្តីពីការទទួលសិទ្ធិអនុវត្តគម្រោងសេវាខាងក្រៅ និងបច្ចុប្បន្នភាពលើឯកសារគតិយុត្តសម្រាប់ ការចូលរួមដេញថ្លៃគម្រោងខាងក្រៅនានា របស់សាខាសេវាកម្មទឹកស្អាតនិងអនាម័យ

ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជាព័ត៌មាន ព្រមទាំងឯកភាពប្រគល់សិទ្ធិជូនលោកអគ្គនាយករងទទួលបន្ទុកសាខាសេវាកម្មទឹកស្អាតនិងអនាម័យ ក្នុងការចុះហត្ថលេខាលើកិច្ចសន្យាជាមួយក្រុមហ៊ុន គូបូតា ខនស្រ្តាក់សិន និងឯកភាពពាក់ព័ន្ធនឹងគម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅខេត្តស្វាយរៀង។

គ- របាយការណ៍ស្តីពីលទ្ធផលនៃការផ្សព្វផ្សាយខ្លឹមសារលក្ខន្តិកៈ រ.ទ.ស.ភ ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រី រ.ទ.ស.ភ

ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជាព័ត៌មាន។

សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។

រ.ទ.ស.ភ មានយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការពង្រីកបណ្តាញចែកចាយទឹក ដោយមានទំនាក់ទំនងជាមួយនឹងការពង្រីកសមត្ថភាពប្រព្រឹត្តកម្ម ហើយការពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ គឺធ្វើយ៉ាងណារក្សាអត្រានិងស្តង់ដារដូចគ្នា នៅក្នុងរាជធានីភ្នំពេញ និងតាំងចិត្តខ្ពស់ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។

សម្រាប់ឆ្នាំ២០២៤ យើងគ្រោងផលិតទឹកស្អាត ៣១១.២២៤.៣០០ម៣ ជាមួយនឹងការពង្រីកបណ្តាញចែកចាយទឹកបន្ថែម ៤៨៨.៤៥០ម៉ែត្រ និងគ្រោងចំណូលសរុបចំនួន ៤៧០.៦០០.៦៩២.០០០រៀល និងចំណាយសរុបចំនួន ២៨៤.៦៣៤.៦៣៨.០០០រៀល ដូចដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាលទាំងពីរ។

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងនូវសេចក្តីដឹងគុណដ៏ជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាល អាណាព្យាបាលទាំងពីរ គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និយ័តករមូលបត្រកម្ពុជា ផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលបានផ្តល់ទំនុកចិត្តនិងការគាំទ្រចំពោះ រ.ទ.ស.ភ ។

យើងក៏មានមោទនភាព និងសូមថ្លែងអំណរគុណចំពោះមន្ត្រី និងនិយោជិតគ្រប់ថ្នាក់របស់ រ.ទ.ស.ភ ដែលបានខិតខំបំពេញការងារដោយស្មារតីទទួលខុសត្រូវខ្ពស់ ជំរុញឱ្យសម្រេចបាននូវលទ្ធផលដ៏ល្អប្រសើរនេះ។

ថ្ងៃច័ន្ទ ១៥កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤

**ប្រធានក្រុមប្រឹក្សាភិបាល**

**ស៊ឹម ស៊ីថា**

# សេចក្ដីថ្លែងរបស់អគ្គនាយក



**ឯកឧត្តម ឡុង ណារ៉ូ**
អគ្គនាយក

## សមិទ្ធិផលសម្រេចបានក្នុងឆ្នាំ២០២៣

" តាងនាម រ.ទ.ស.ភ ខ្ញុំមានកិត្តិយសនិងក្ដីសោមនស្សរីករាយ ក្នុងការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០២៣ និងរបាយការណ៍ហិរញ្ញវត្ថុ របស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ រ.ទ.ស.ភ បានកត់ត្រានូវរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៣ នេះ ដោយទទួលបានចំណូលសរុបចំនួនប្រមាណ ៣៩២ប៊ីលានរៀល និងចំណេញមុនបង់ពន្ធលើប្រាក់ចំណូលចំនួនប្រមាណ ១៥៣ប៊ីលានរៀល និងលទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិកចំនួនប្រមាណ ១២៦ប៊ីលានរៀល។"

## សកម្មភាពសំខាន់ៗក្នុងឆ្នាំ២០២៣

ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាល ក្រសួងអាណាព្យាបាល និង ក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងឆ្នាំនេះ រ.ទ.ស.ភ នៅតែមានការរីកចម្រើនយ៉ាងខ្លាំងក្លា ដោយការគ្រប់គ្រងហានិភ័យបានល្អប្រសើរបានប្រើប្រាស់ នូវធនធានហិរញ្ញវត្ថុមានប្រសិទ្ធភាពខ្ពស់ និងគ្រប់គ្រងការចំណាយបានយ៉ាងហ្មត់ចត់ ជាពិសេសដោយការយកចិត្ត ទុកដាក់ខ្ពស់លើការកាត់បន្ថយអត្រាទឹកបាត់បង់។ ទោះបីសកម្មភាពជួសជុលនិងពង្រីកថ្នល់ទូទាំងរាជធានីភ្នំពេញ ជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលបណ្ដាលឱ្យមានការលេចធ្លាយបំពង់ទឹក ដូចបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យរួច ក៏នៅក្នុងឆ្នាំ២០២៣ នេះ រ.ទ.ស.ភ ទទួលបានចំណូលសរុបចំនួន ៣៩២.០៥៤.៣៦៥.០០០រៀល ហើយប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញមានចំនួន ១៥៣.៤៧២.៥៤៣.០០០រៀល និងប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិកមានចំនួន ១.៤៥៥,៧៣រៀល។ នាចុងការិយបរិច្ឆេទនេះទ្រព្យសកម្មសរុបបានកើនឡើងរហូតដល់ចំនួន ៣.១៥៩.០៦០.៣២៣.០០០រៀល ចំណែកឯដើមទុនវិញបានកើនឡើងរហូតដល់ចំនួន ១.៣៩៤.៥១៧.៤៧១.០០០រៀល។ ការកើនឡើងនេះដោយសារ រ.ទ.ស.ភ សម្រេចបានជោគជ័យយ៉ាងធំធេងក្នុងការកាត់បន្ថយអត្រាទឹកបាត់បង់ឱ្យនៅក្នុងកម្រិតលេខ១ខ្ទង់ដែលអត្រានៅក្នុងឆ្នាំ២០២៣នេះ មានត្រឹមតែ ៨,៧៥%។ ការកាត់បន្ថយទឹកបាត់បង់ជាកត្តាស្លាប់-រស់ របស់ រ.ទ.ស.ភ ក្នុងដំណើរការប្រព្រឹត្តកម្មនិងអាជីវកម្មរបស់ខ្លួន។ ជាមួយគ្នានេះដែរ ដើម្បីសម្របទៅតាមការប្រែប្រួលនៃអតិផរណា យើងបានធ្វើការកែសម្រួលនូវថ្លៃលក់ទឹកស្អាតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់បច្ចុប្បន្នដែលធ្វើឱ្យយើងនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ ដែលអាចបង្កលក្ខណៈឱ្យយើងមានទឹកស្អាតសម្រាប់ផ្គត់ផ្គង់ និងអាចផឹកបានពីក្បាលរ៉ូប៊ីណេដល់រាប់ម៉ឺនគ្រួសារ រួមទាំងគ្រួសារមានចំណូលទាបក្នុងតម្លៃមួយដ៏សមរម្យ ដើម្បីចូលរួមចំណែកក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលកម្ពុជា។ រ.ទ.ស.ភ មានសមត្ថភាពផ្គត់ផ្គង់ទឹក ២៤ម៉ោង/ថ្ងៃ និង៧ថ្ងៃ/សប្ដាហ៍ ដោយក្នុងឆ្នាំនេះអាចធ្វើការផលិតទឹកស្អាតបានចំនួន ២៧៩.០៥៣.៦៥១ម$^{៣}$។

ការធ្វើប្រព្រឹត្តកម្មទឹកស្អាត គឺគោរពតាមស្តង់ដារគុណភាពទឹកជាតិ និងអង្គការសុខភាពពិភពលោក(WHO) ដោយមានបន្ទប់ពិសោធន៍គុណភាពទឹកអាចវិភាគបាន៥៣មុខ ជាមួយគ្នានេះយើងតែងតែបានធ្វើការវិភាគគុណភាពទឹក ពីមន្ទីរពិសោធន៍ ក្រៅប្រទេស(មន្ទីរពិសោធន៍ សិង្ហបុរី និងសៀងហៃ) ផងដែរ។ ការយកចិត្តទុកដាក់លើគុណភាពទឹកនេះធ្វើឱ្យ រ.ទ.ស.ភ អាចធានាជូនអតិថិជនបាននូវការផឹកដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ ដើម្បីចូលរួមចំណែកក្នុងការទទួលខុសត្រូវចំពោះសង្គមក្នុងគោលដៅជំរុញឱ្យប្រជាជនគ្រប់រូបមានទឹកស្អាតប្រើប្រាស់ដែលជាកម្មវិធីទឹកស្អាតសម្រាប់ទាំងអស់គ្នា (Water for All) ដោយមានសេវាអនាម័យត្រឹមត្រូវ ដើម្បីការរស់នៅប្រកបដោយសុខមាលភាព មានជីវភាពល្អប្រសើរ និងមានបរិស្ថានល្អ។

ទិសដៅនៃការពង្រីកបណ្តាញចែកចាយទឹក គឺទៅតំបន់មានសក្តានុពលសេដ្ឋកិច្ច ដោយមិនមើលរំលងប្រជាពលរដ្ឋដែលមានចំណូលទាប ដោយក្នុងឆ្នាំ២០២៣ នេះ រ.ទ.ស.ភ ដាក់បំពង់បានប្រវែង ៤៦២.៩៨៥,៤០ម៉ែត្រ ដែលធ្វើឱ្យប្រវែងបំពង់មេ និងបំពង់ចែកចាយទឹកបច្ចុប្បន្នសរុបស្មើនឹងប្រមាណ ៤.៧២៣គីឡូម៉ែត្រ និងរក្សាសម្ពាធជាមធ្យម២០ម៉ែត្រ ក្នុងបណ្តាញចែកចាយទឹកទាំងមូល ដែលបំពង់ចាប់ពីទំហំ៦៣ម.ម ដល់ទំហំ១៦០០ម.ម ដោយ រ.ទ.ស.ភ បានធ្វើការដាក់ដោយខ្លួនឯង។យើងបានខិតខំធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាព សេវាអតិថិជនដើម្បីស្វែងរក និងបង្កើនចំនួនអតិថិជនធំៗដែលមានតម្រូវការទឹកច្រើន ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការប្រមូលប្រាក់ថ្លៃទឹកដែលអត្រាទារប្រាក់ក្នុងឆ្នាំនេះ រក្សាបានជាអតិបរិមា ហើយកំណើនបណ្តាញអតិថិជនសម្រាប់ចុងឆ្នាំ២០២៣នេះ បានកើនឡើងដល់ចំនួន ៤៧៨.១៤១ បណ្តាញ។

## ការរំពឹងទុកសម្រាប់ឆ្នាំ២០២៤

ចំពោះឆ្នាំ២០២៤ ខាងមុខ យើងនឹងខិតខំប្រឹងប្រែងព្យាយាមបន្ថែមទៀតដើម្បីធ្វើឱ្យកាន់តែប្រសើរក្នុងការពង្រឹងនូវអភិបាលកិច្ច សាជីវកម្មល្អរបស់ រ.ទ.ស.ភ ហើយនៅតែប្រកាន់ខ្ជាប់នូវទស្សនវិស័យ និងបេសកកម្ម ដែលបានលើកពីបណ្តាឆ្នាំមុនដដែល។ ទិសដៅសម្រាប់ឆ្នាំ២០២៤ រ.ទ.ស.ភ សង្ឃឹមថានឹងទទួលបានប្រាក់ចំណេញពិត ប្រមាណ ១៤៨.៧៧២.៨៤៣.០០០រៀល ដែលក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាលបានអនុម័ត។

រ.ទ.ស.ភ. ក៏នៅតែប្តេជ្ញាចិត្តផ្តល់សេវាកម្ម និងផ្គត់ផ្គង់ទឹកស្អាតប្រកបដោយគុណភាពនិងប្រសិទ្ធភាព ដើម្បីផ្តល់ការជឿជាក់ពីអតិថិជន។ ជាងនេះទៅទៀត រ.ទ.ស.ភ នៅតែខិតខំផ្តល់បណ្តាញទឹកជូនប្រជាពលរដ្ឋដែលមាន ចំណូលទាប តាមរូបភាព ឧបត្ថម្ភថ្លៃសិទ្ធិជាវទឹក ស្របទៅតាមកម្រិតជីវភាពគ្រួសារនីមួយៗ ពី៣០% ៥០% ៧០% និង ១០០% ដើម្បីអនុវត្តគម្រោងចែកចាយទឹក ពិសេសជូនសហគមន៍ក្រីក្រ ដោយប្រើថវិការបស់ រ.ទ.ស.ភ ដើម្បីប្រយោជន៍ប្រជាជន។

## សេចក្តីថ្លែងអំណរគុណ

ជាថ្មីម្តងទៀត រ.ទ.ស.ភ មានសេចក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីរាជរដ្ឋាភិបាលក៏ដូចជាអាណាព្យាបាលទាំងពីរគឺ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសូមសម្តែងនូវអំណរគុណដល់ក្រុមប្រឹក្សាភិបាល ចំពោះការគាំទ្រ និងការដឹកនាំល្អសម្រាប់ឆ្នាំ២០២៣ និងសូមថ្លែងអំណរគុណជូនចំពោះអតិថិជនទាំងអស់ដែលបានគាំទ្រធ្វើឱ្យ រ.ទ.ស.ភ បានទទួលជោគជ័យដូចសព្វថ្ងៃនេះ។

ថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤

**អគ្គនាយក រ.ទ.ស.ភ**

**ឡុង ណារ៉ូ**

# មាតិកា


ទស្សនវិស័យ និងបេសកកម្ម i

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ii

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប iii

សមាសភាពក្រុមប្រឹក្សាភិបាល iv

សេចក្ដីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល vi

សេចក្ដីថ្លែងរបស់អគ្គនាយក xviii

**ផ្នែកទី១: ព័ត៌មានទូទៅពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១**

ក- អត្តសញ្ញាណរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១

ខ- លក្ខណៈនៃធុរកិច្ច ០១

គ- សម្ព័ន្ធភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១

ឃ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ ០២

ង- ស្ថានភាពទីផ្សារ ០៣

ច- ស្ថានភាពប្រកួតប្រជែង ០៣

ឆ- ផែនការអនាគត ០៣

ជ- កត្តាហានិភ័យ ០៣

**ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ០៧**

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ០៧

ខ- រចនាសម្ព័ន្ធចំណូល ០៩

**ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម ១០**

ក- អង្គការលេខ ១០

ខ- ក្រុមប្រឹក្សាភិបាល ១១

គ- បុគ្គលិកជាន់ខ្ពស់ ១១

**ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ១៣**

ក- ព័ត៌មានអំពីមូលបត្រ ១៣

ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ ១៣

គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ១៣

ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ១៣

ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ ១៤

**ផ្នែកទី៥: របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង ១៥**

**ផ្នែកទី៦: របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ ១៧**

**ផ្នែកទី៧: ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍** **១៩**
ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ ១៩
ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ ១៩
គ- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម ១៩
ឃ- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់
និងភាគហ៊ុនិកដែមានភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ ១៩
ង- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជី
លក់មូលបត្រក្រុមហ៊ុនបុត្រសម្ព័ន្ធឬក្រុមហ៊ុនហូលឌីងរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ១៩
ច- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល
ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជា អភិបាល ១៩
ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម
ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពី រ.ទ.ស.ភ. ១៩
ជ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពី រ.ទ.ស.ភ.
ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ១៩

**ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** **២០**
ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ២០
ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ២៤
គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ២៥
ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ២៥
ង- ផលប៉ះពាល់នៃអតិផរណា ២៥
ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ២៦

**ផ្នែកទី៩: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន** **២៦**

**ហត្ថលេខាអភិបាលរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** **២៧**

ឧបសម្ព័ន្ធ១ ៖ របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ២០២៣
ឧបសម្ព័ន្ធ២ ៖ របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុង ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការប្រចាំឆ្នាំ២០២៣
ឧបសម្ព័ន្ធ៣ ៖ របាយការណ៍ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ សម្រាប់
ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣
ឧបសម្ព័ន្ធ៤ ៖ លទ្ធផលពិនិត្យគុណភាពទឹកពីបណ្តាញចែកចាយក្នុងតំបន់ស្ទឹងមានជ័យ រាជធានីភ្នំពេញ
Test Report: 7191321955-CHM23-NHT

# ផ្នែកទី១: ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ក- អត្តសញ្ញាណ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

### PHNOM PENH WATER SUPPLY AUTHORITY (PPWSA)

- លេខកូដស្តង់ដារ: KH1000010004
- ទីស្នាក់ការ: អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- លេខទូរស័ព្ទ: (៨៥៥) ៣១ ៣២២ ៦៣៤៥
- គេហទំព័រ: www.ppwsa.com.kh អ៊ីម៉ែល: ir@ppwsa.com.kh
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម: Co.០៨៣៩Et/២០១២
  កាលបរិច្ឆេទ: ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២
- លេខអាជ្ញាបណ្ណអាជីវកម្ម: អនុក្រឹត្យលេខ៥២អនក្រ.បក ចេញដោយ: រាជរដ្ឋាភិបាលកម្ពុជា
  កាលបរិច្ឆេទ: ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ: ០១២/១២គ.ម.ក/ស.ស.រ.
  កាលបរិច្ឆេទ: ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២
- ឈ្មោះបុគ្គលតំណាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ: **ឯកឧត្តម ឡុង ណារ៉ូ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ខ- លក្ខណៈនៃធុរកិច្ច

- វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ
- ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើន ផលិតម្មសេវាកម្ម និង ធានាគុណភាព ទឹកស្អាតឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅ អាជីវកម្មសេវាកម្មនិងឧស្សាហកម្ម ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុងឬក្រៅប្រទេស តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដោយអនុលោមតាមច្បាប់
- សហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ជាមួយដៃគូអភិវឌ្ឍក្នុង និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ធានាឱ្យបាននូវចិរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម
- ពង្រីកការផ្គត់ផ្គង់ទឹកនៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដាដូចគ្នានៅក្នុងរាជធានីភ្នំពេញ
- បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស
- វិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក
- ប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាញអង្គភាពទឹកស្អាតនានាដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក
- តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។

## គ- សម្ព័ន្ធភាព រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពុំមានសម្ព័ន្ធភាពជាមួយក្រុមហ៊ុនណាមួយឡើយ។

# ផ្នែកទី១:ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ឃ- ព្រឹត្តការណ៍សំខាន់ៗប្រចាំឆ្នាំ

១. ពិធីសម្ពោធដាក់ឱ្យដំណើរការរោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១

នាថ្ងៃចន្ទ ២កើត ខែបឋមសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ រ.ទ.ស.ភ បានរៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការរោងចក្រផលិតទឹកស្អាតថ្មី បាក់ខែង ជំហាន១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលនេះជាសមិទ្ធិផលដ៏ត្រចះត្រចង់មួយរបស់ រ.ទ.ស.ភ ដោយលាតសន្ធឹងលើផ្ទៃដី ១៥ហិកតា មានសមត្ថភាពផលិតទឹកស្អាតបានចំនួន ១៩៥.០០០ម$^{៣}$/ថ្ងៃ ដោយប្រើប្រាស់ប្រភពទឹកទន្លេមេគង្គលើក្នុងការផលិតដែលមានទីតាំងនៅភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ (តាមបណ្តោយមហាវិថីឈ្នះៈឈ្នះ)។

គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែងជំហានទី១ គឺជាសហហិរញ្ញប្បទានរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា រ.ទ.ស.ភ ជាមួយនឹងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ធនាគារវិនិយោគអ៊ឺរ៉ុប (EIB) និងសហគមន៍អឺរ៉ុប (EU) ដោយប្រើប្រាស់ថវិការសរុបចំនួន ២៤៧លាន ដុល្លារអាមេរិក ។

ការសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១ ចាប់ផ្តើមដំណើរការសាងសង់ពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ និងបានដាក់ដំណើរការសាកល្បងផលិត និងចែកចាយទឹកស្អាតចាប់ពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ ព្រមទាំងឈានដល់បញ្ចប់ការដ្ឋានសាងសង់ជាស្ថាពរនាថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ ពោលគឺមានរយៈពេលសាងសង់ចំនួន ៣៦ខែ។ រោងចក្រផលិតទឹកស្អាតបាក់ខែង ជំហាន១ គឺជាគម្រោងធំជាងគេជាប្រវត្តិសាស្ត្រក្នុងវិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតកម្ពុជា ដែលអនុវត្តការងារសាងសង់ដោយក្រុមហ៊ុន Vinci Construction Grands Projets មកពីប្រទេសបារាំង ស្ថិតក្រោមការត្រួតពិនិត្យរបស់ រ.ទ.ស.ភ និងការជួយផ្តល់យោបល់ពីទីប្រឹក្សាបច្ចេកទេស SAFEGE Consulting Engineers មកពីប្រទេសបារាំង។ សម្រាប់គម្រោងនេះ ត្រូវបានអនុវត្តកិច្ចសន្យាក្នុងក្របខ័ណ្ឌ រចនា និងប្លង់។

រោងចក្រផលិតទឹកស្អាតបាក់ខែងជំហាន១ មានសមត្ថភាពផលិតទឹកស្អាតចំនួន ១៩៥.០០០ម$^{៣}$/ថ្ងៃ បានបន្ថែមលើសមត្ថភាពផលិតទឹកស្អាតរបស់ រ.ទ.ស.ភ ដែលមានស្រាប់ចំនួន ៦៤០.០០០ម$^{៣}$/ថ្ងៃ នាំអោយ រ.ទ.ស.ភ មានសមត្ថភាពផលិត និងផ្គត់ផ្គង់ទឹកស្អាតសរុបបានប្រមាណ ៨៣៥.០០០ម$^{៣}$/ថ្ងៃ ព្រមទាំងបន្ថែមការផ្គត់ផ្គង់ជូនប្រជាពលរដ្ឋបានប្រមាណ ១៧០.០០០គ្រួសារ និងជួបដោះស្រាយបញ្ហាទឹកស្អាតរបស់ប្រជាជនរស់នៅតំបន់ជាយរាជធានីភ្នំពេញ និងសង្កាត់ចំនួន៣ នៅក្រុងតាខ្មៅ។

នៅដើមឆ្នាំ២០២៤ ក្រោយដាក់ដំណើរការរោងចក្រផលិតទឹកស្អាតបាក់ខែង ជំហាន២ រ.ទ.ស.ភ និងមានសមត្ថភាពផលិត និងផ្គត់ផ្គង់ទឹកស្អាតសរុបកើនដល់ប្រមាណជាង ១លាន ម៉ែត្រគូបក្នុងមួយថ្ងៃ។ ការណ៍នេះធ្វើអោយប្រជាពលរដ្ឋដែលរស់នៅជាយរាជធានីភ្នំពេញ ទទួលបានការផ្គត់ផ្គង់ទឹកស្អាតដែលធានាបាននូវសម្ពាធទឹកល្អប្រសើរ ព្រមទាំងបានបិទបញ្ចប់នូវនិន្នាការកង្វះខាតទឹកស្អាតក្នុងពេលបច្ចុប្បន្ន ត្រឹមដើមឆ្នាំ២០២៤។

**២. ពិធីអបអរសាទរការបញ្ចប់ខួងដាក់បំពង់មេនាំទឹកស្អាត ដែលមានមុខកាត់ ២ម៉ែត្រ ឆ្លងកាត់ក្រោមទន្លេសាបដោយជោគជ័យជាប្រវត្តិសាស្ត្រ**

នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ រ.ទ.ស.ភ បានប្រារព្ធពិធីអបអរសាទរ នៃការសម្រេចបានដោយជោគជ័យនូវការងារខួងដាក់បំពង់មេនាំទឹកស្អាត ដែលមានមុខកាត់ទំហំ ២ម៉ែត្រ និងបានប្រសិទ្ធនាមថា «**មហាបំពង់មេនាំទឹក សម្តេច ប៊ុន រ៉ានី ហ៊ុន សែន**» ក្រោមបាតទន្លេសាប ប្រវែង ៥៤០ម៉ែត្រ ពីចំណុចអណ្តូងត្រើយខាងកើតទន្លេសាប (Inlet Shaft) មកដល់ជញ្ជាំង អណ្តូងត្រើយ ខាងលិចទន្លេសាប (Receiving Shaft) ដើម្បីនាំទឹកស្អាតពីរោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងមកផ្គត់ផ្គត់ជូនប្រជាពលរដ្ឋនៅទូទាំងរាជធានីភ្នំពេញ។

**៣. ការដាក់ឱ្យប្រើប្រាស់ការផ្លូវការនូវកម្មវិធីទូរស័ព្ទដៃ PPWSA App**

បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីទូរស័ព្ទដៃ PPWSA APP ដែលផ្តល់ភាពងាយស្រួលជូនដល់អតិថិជន ក្នុងការតាមដាន ត្រួតពិនិត្យវិក្កយបត្រប្រើប្រាស់ទឹកស្អាត និងសេវាកម្មផ្សេងៗទៀតរបស់ រ.ទ.ស.ភ តាំងពីខែធ្នូ ឆ្នាំ២០២៣។

# ផ្នែកទី១:ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ង- ស្ថានភាពទីផ្សារ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញគឺជាសហគ្រាសសាធារណៈតែមួយគត់ (Monopoly) ក្នុងការធ្វើអាជីវកម្មនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលមានលក្ខណៈបច្ចេកទេស និងសេដ្ឋកិច្ច។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមិនបានធ្វើការប្រកួតប្រជែងលើថ្លៃលក់ទឹកនៅក្នុងទីផ្សារទេ និងមិនរងសំពាធផ្នែកនយោបាយ ទោះស្ថិតក្នុងដំណាក់កាលណាក៏ដោយ។

## ច- ស្ថានភាពប្រកួតប្រជែង

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺជាសហគ្រាសសាធារណៈតែមួយគត់ (Monopoly) ក្នុងការធ្វើអាជីវកម្មនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលមានលក្ខណៈបច្ចេកទេស និងសេដ្ឋកិច្ច។ រ.ទ.ស.ភ មិនធ្វើការប្រកួតប្រជែងលើថ្លៃលក់ទឹកនៅក្នុងទីផ្សារទេ និងមិនរងសម្ពាធផ្នែកនយោបាយ ទោះស្ថិតក្នុងដំណាក់កាលណាក៏ដោយ។

## ឆ- ផែនការអនាគត

- ជំរុញការតាមដាន និងអនុវត្តផែនការមេឆ្នាំ ២០២១-២០៣០ ក្នុងការពង្រឹងសក្តានុពល និងវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ។
- ជំរុញការធ្វើនវានុវត្តន៍លើបច្ចេកទេស និងបច្ចេកវិទ្យាលើវិស័យទឹកស្អាត ដើម្បីឱ្យស្របទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ លើអាទិភាពគន្លឹះចំនួន២ ក្នុងចំណោម ៥ គឺ ទឹក និងបច្ចេកវិទ្យា ព្រមទាំងនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាក្នុងការធានាឱ្យបាននូវនិរន្តរភាពលើការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងចែកចាយទឹកប្រកបដោយប្រសិទ្ធភាព។
- បន្តការកាត់បន្ថយការចំណាយណាដែលមិនចាំបាច់ និងបង្កើនប្រសិទ្ធភាពទារប្រាក់ថ្លៃទឹក ព្រមទាំងខិតខំរកចំណូលពីសេវាកម្ម និងចំណូលផ្សេងៗ ឱ្យបានតាមផែនការ។
- ជំរុញ និងផ្សព្វផ្សាយបន្ថែមអំពីគុណសម្បត្តិនៃការប្រើប្រាស់ Mobile App របស់អង្គភាព ដល់អតិថិជនឱ្យបានទូលំទូលាយ។
- បន្តបង្កើនប្រសិទ្ធភាពក្នុងការជួសជុលថែទាំប្រព័ន្ធប្រព្រឹត្តកម្ម និងប្រព័ន្ធផ្គត់ផ្គង់ដើម្បីរក្សាអាយុកាលឱ្យបានយូរអង្វែង និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ ២៤ម៉ោង/៧ ថ្ងៃ។
- សិក្សា និងរៀបចំលើឯកសារបទដ្ឋានបច្ចេកទេសឱ្យមានលក្ខណៈស្តង់ដារ ដើម្បីធានានូវគុណភាពខ្ពស់របស់ប្រព័ន្ធផ្គត់ផ្គង់ទឹក។
- កសាងកម្មវិធីបណ្តុះបណ្តាល មេរៀន គ្រូបង្គោល ដើម្បីត្រៀមបណ្តុះបណ្តាលមន្ត្រី និយោជិត រដ្ឋាករទឹកស្វយ័តមកពីបណ្តាខេត្ត។
- ធ្វើការកាត់បន្ថយអត្រាទឹកបាត់បង់ឱ្យបានកាន់តែទាប និងក្នុងកម្រិតដែលអាចធ្វើទៅបាន។

## ជ- កត្តាហានិភ័យ (ការវិភាគ និងទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់)

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទទួលបន្ទុកការងារផលិតកម្ម និងចែកចាយទឹកសម្រាប់ប្រើប្រាស់ទូទៅក្នុងការបម្រើដល់ផ្នែកសេវាកម្មសាធារណៈជាលក្ខណៈរដ្ឋបាល និងបច្ចេកទេស ដោយមានការធានាទាំងបរិមាណ និងគុណភាពទឹកស្អាតគ្មានមេរោគ ព្រមទាំងអាចផឹកបានពីបណ្តាញដោយផ្ទាល់។ ទោះជាយ៉ាងណាក៏នៅមានកត្តាហានិភ័យមួយចំនួន ដែលកំពុងជួបប្រទះ និងមានវិធានការទប់ស្កាត់ ដូចខាងក្រោម៖

| កត្តាហានិភ័យ/កត្តាប្រឈម | វិធានការទប់ស្កាត់ និងដំណោះស្រាយ |
|---|---|
| **១. ការងារសិក្សាគម្រោង** | |
| ▪ ភាពយឺតយ៉ាវ ក្នុងការខួងឆ្លងដាក់បំពង់មេនាំទឹកស្អាត មុខកាត់ទំហំ ២ម៉ែត្រ (DIC 2000mm) ក្រោមបាតទន្លេសាប ទីតាំងស្ពានព្រែកព្នៅ អនុវត្តមិនទាន់កម្មវិធីដែលគ្រោងទុក មូលហេតុ ដោយសារ កត្តាបច្ចេកទេស បញ្ហាខ្សែទឹកក្រោមដី ជ្រាបចូលបាតអណ្តូង និងកត្តាធម្មជាតិ ភ្លៀងធ្លាក់ក្នុងកម្រិតខ្ពស់ ដែលធ្វើឱ្យប៉ះពាល់ដល់ ការងារចាក់បេតុងបាតអណ្តូង។ ការងារខាងលើនេះ ត្រូវបានប៉ាន់ស្មាន និងពន្យាពេល ដល់ត្រីមាសទី១ ឆ្នាំ២០២៤ ខាងមុខ។ | ▪ បានសិក្សាជាបន្ទាន់ ក្នុងការអនុវត្តដាក់បំពង់មេនាំទឹកស្អាត មុខកាត់ ១ម៉ែត្រ៤តឹក នៅបាតទន្លេសាប (HPDE 1400mm) ដើម្បីបញ្ជូនទឹកស្អាតចេញពីរោងចក្រផលិតទឹកស្អាតបាក់ខែង ឱ្យបានមុនខែឧសភា ឆ្នាំ២០២៣ ស្របតាមផែនការផលិតទឹក។<br>▪ បានជម្រុញ និងណែនាំឱ្យក្រុមហ៊ុនម៉ៅការសាងសង់ ធ្វើយ៉ាងណា ដើម្បីបញ្ចប់ការងារខួងដាក់បំពង់មេនាំទឹកស្អាតឆ្លងក្រោមបាតទន្លេ ឱ្យចប់រួចរាល់ត្រឹមចុងខែធ្នូ ឆ្នាំ២០២៣ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការបន្តការងារផ្សារបំពង់ សំអាត និងធ្វើតេស្តសំពាធទឹក ក្នុងត្រីមាសទី១ ឆ្នាំ២០២៤។ |
| ▪ កង្វះខាតទឹកស្អាតផ្គត់ផ្គង់ក្នុងរដូវប្រាំង អំឡុងដើមឆ្នាំ២០២៣ (ខែមីនា - ខែឧសភា)។ | ▪ បានសហការជាមួយ សាលារាជធានីភ្នំពេញ និងអាជ្ញាធរមូលដ្ឋាន ក្នុងរៀបចំឡានទឹក ដើម្បីផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ នៅតាមបណ្តាជាយតំបន់ផ្ទៃសេវា និងតំបន់ដែលមានសំពាធទឹកទាប។<br>▪ ពន្លឿនការសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែង ជំហានទី១ និងត្រូវបញ្ចប់ការងារស្របតាមផែនការ ឱ្យបានមុនខែឧសភា ឆ្នាំ២០២៣។ ***ជាលទ្ធផល រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១ បានដំណើរការសាកល្បង ចុងខែមេសា ឆ្នាំ២០២៣។***<br>▪ បានដាក់ឱ្យរោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១ ដំណើរការផលិត ជាមធ្យម ១៩០ ពាន់ម៉ែត្រគូប/ថ្ងៃ ដើម្បីបង្កើនបរិមាណទឹកផលិតសរុបជាមធ្យម ទូទាំងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ហួតដល់ ៨០០ ពាន់ម៉ែត្រគូប/ថ្ងៃ។ |
| **២. ការងារគ្រប់គ្រងប្រព័ន្ធផលិតកម្ម** | |
| ▪ ការអភិវឌ្ឍចាក់ដី ក្នុងទន្លេ (កោះនរា និងបាក់ខែង) ធ្វើឱ្យមានបម្រែបម្រួលគុណភាពទឹកឆៅ និងកត្តាបម្រែបម្រួលអាកាសធាតុជាសកល (Global Climate Change) និងការរស់នៅរបស់ប្រជានេសាទតាមដងទន្លេ ការបោះចោលសម្រាមក្នុងប្រភពទឹកទន្លេ។ | ▪ បានតំលើងឧបករណ៍សម្រាប់វាស់រយៈកំពស់ទឹកទន្លេ និងគុណភាពទឹកឆៅ តាមស្ថានីយបូមទឹកល្អក់ ដើម្បីគ្រប់គ្រង និងតាមដានបម្រែបម្រួលគុណភាពទឹក។<br>▪ បង្កើនការប្រើប្រាស់វត្ថុធាតុដើម ដើម្បីធានាគុណភាពទឹកស្អាតចេញពីស្ថានីយបូមទឹកស្អាត ស្របតាមស្តង់ដារគុណភាពទឹកស្អាត។ |
| ▪ ការងារគ្រប់គ្រងថែទាំ-ជួសជុល ឧបករណ៍-បរិក្ខារ បម្រើដល់ការងារផលិតកម្ម មិនទាន់ភាពល្អប្រសើរ និងមិនទាន់មានកម្មវិធីគ្រប់គ្រង-តាមដានច្បាស់លាស់។ រោងចក្រផលិតទឹកបាក់ខែងបានចាប់ផ្តើម ដាក់ដំណើរការផលិត ក៏ដូចជារោងចក្រ ផ្សេងៗទៀត ដែលគ្រោងដាក់ឱ្យដំណើរ នៅក្នុងឆ្នាំបន្ទាប់ (២០២៤) ដែលទាមទារឱ្យមានការរៀបចំឯកសារ-សៀវភៅណែនាំ សម្រាប់ការ | ▪ បានរៀបចំសមាសភាពក្រុមការងារជំនាញ សម្រាប់អនុវត្តការងារ SUMS-OFAMS ក្នុងការត្រួតពិនិត្យ និងរៀបចំឡើងវិញ នូវការងារជួសជុល-ថែទាំគ្រឿងចក្រ ឧបករណ៍បរិក្ខារផ្សេងៗតាមបណ្តារោងចក្រទាំងអស់។<br>▪ បានដាក់ផែនការសិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រង Asset Management & Maintenance សម្រាប់អនុវត្តការងារជួសជុល-ថែទាំតាមបណ្តារោងចក្រទាំងអស់។ |

| កត្តាហានិភ័យ/កត្តាប្រឈម | វិធានការទប់ស្កាត់ និងដំណោះស្រាយ |
|---|---|
| គ្រប់គ្រង តានដាន កម្មវិធីថែទាំ-ជួសជុល ច្បាស់លាស់ និងហ័ស ដើម្បីធានាដល់ការថែទាំប្រកប ដោយប្រសិទ្ធភាព និងនិរន្តភាពនៃការផលិត។ | |
| **៣. ការងារគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក** | |
| ▪ កត្តាអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការងារសំណង់មួយចំនួន បានប៉ះពាល់ដល់បំពង់ទឹក កប់ក្នុងដីធ្វើឱ្យមានទឹកធ្លាយ។<br>▪ កត្តាប្រឈមរយៈពេលខ្លី ក្នុងឆ្នាំ២០២៣ ដែលរោងចក្រផលិតទឹកស្អាតថ្មី បាក់ខែងជំហាន១ ដាក់ឱ្យដំណើរការ នឹងធ្វើឱ្យមានការលេចធ្លាយលើបំពង់ចែកចាយទឹកទីតាំងមួយចំនួន។ | ▪ ដាក់ក្រុមប្រចាំការ សហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីកាត់បន្ថយផលប៉ះពាល់។<br>▪ ការគ្រប់គ្រង បែងចែកដំណើរការផលិតកម្មតាមបណ្តារោងចក្រទាំងអស់ ក្នុងលក្ខខណ្ឌសំពាធទឹកផ្គត់ផ្គង់សមស្រប។<br>▪ មានវិធានការណ៍គ្រប់គ្រងត្រឹមត្រូវ ដោយតំលើងឧបករណ៍វាស់សំពាធទឹកផ្គត់ផ្គង់នៅលើបណ្តាញក្នុងផ្ទៃសេវាផ្គត់ផ្គង់ដើម្បីពិនិត្យ គ្រប់គ្រង តាមដាន និងមានវិធានការទាន់ពេលវេលា (Pressure Management)។ |
| **៤. ការងារអាជីវកម្ម** | |
| ▪ អាត្រាថ្លៃលក់ទឹកជាមធ្យមប្រឈមនឹងការធ្លាក់ចុះ ដែលអាចបណ្តាលមកពី បញ្ហាប្រឈមនៅទ្រឹងវិស័យអចលនទ្រព្យ និងដំណើការអាក់ខាននៃវិស័យឧស្សាហកម្ម សិប្បកម្ម អាជីវកម្ម ក្នុងឆ្នាំ២០២២-២០២៣។ | ▪ បានដាក់ផែនការក្នុងការស្វែងរកអតិថិជនដែលមានសក្តានុពលមានតម្រូវការប្រើប្រាស់ទឹកស្អាតខ្ពស់។<br>▪ បានពង្រឹងនៃការអនុវត្តកិច្ចសន្យាអតិថិជនដែលប្រើប្រាស់នាឡិកាធំៗ ប្រភេទអាជីវកម្ម។ |
| ▪ សំណួរ និងសំណើរបស់អតិថិជន និងការប្រើប្រាស់សេវាបម្រើអតិថិជនតាមប្រព័ន្ធសង្គមឌីជីថល មានការកើនឡើង ដែលធ្វើឱ្យការឆ្លើយតប នឹងការបម្រើសេវាអតិថិជន មានការយឺតយ៉ាវ។ | ▪ បានដាក់ផែនការអភិវឌ្ឍគម្រោង Customer Care តាមរយៈថ្នាលឌីជីថល គ្រោងដាក់ដំណើរការ PPWSA Mobile App នៅដើមត្រីមាសទី១ ឆ្នាំ២០២៤ ដើម្បីសម្រួលដល់សេវាអតិថិជន ក្នុងការទូទាត់វិក្កយបត្របានទាន់ពេលវេលាមុនកាលកំនត់ ការស្នើសុំតភ្ជាប់បណ្តាញតាមរយៈប្រព័ន្ធ Online<br>▪ បង្កើតសេវាកម្មច្រកចេញចូលតែមួយ ដើម្បីធានាការគ្រប់គ្រង (One Window Service) និងផ្តល់សេវាកម្មអតិថិជនប្រកបដោយប្រសិទ្ធភាព និងតម្លាភាពខ្ពស់។ |
| **៥. ការងារគណនេយ្យ និងហិរញ្ញវត្ថុ** | |
| ▪ ការគ្រប់គ្រងចំណាយលើការងារជួសជុលទឹកធ្លាយ និង ការចំណាយលើការងារថែទាំ-ជួសជុលប្រព័ន្ធបរិក្ខារ ផ្គត់ផ្គង់ទឹកមានការកើនឡើង ក្នុងអំឡុងពេលរោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១ ដាក់ដំណើរការ។ | ▪ នាយកដ្ឋានជំនាញ ត្រូវចាត់ចែងគ្រប់គ្រងសំពាធទឹកផ្គត់ផ្គង់ ឱ្យបានសមស្រប ដើម្បីកាត់បន្ថយការលេចធ្លាយ។<br>▪ នាយកដ្ឋានជំនាញ បានរៀបចំ តំលើងឧបករណ៍វាស់សំពាធដើម្បីគ្រប់គ្រង និងតាមដានសំពាធទឹកតាមបណ្តាញទឹក។ |
| **៦. ការងាររដ្ឋបាល និងធនធានមនុស្ស** | |
| ▪ កង្វះអគារការិយាល័យ សម្រាប់មន្ត្រីនិយោជិត ក្នុងការបំពេញភារកិច្ច ។ | ▪ក្រុមប្រឹក្សាភិបាល ក្រសួងអាណាព្យាល និងដៃគូអភិវឌ្ឍន៍ AFD/EU បានសម្រេចឱ្យ ទេសភ វិនិយោគ ដើម្បីសិក្សារៀបចំប្លង់ទីតាំងអគារ និងការសិក្សាសាងសង់អគារថ្មី |

| កត្តាហានិភ័យ/កត្តាប្រឈម | វិធានការទប់ស្កាត់ និងដំណោះស្រាយ |
|---|---|
| | កម្ពស់១៦ជាន់ ទទឹង១៦.៦ម៉ែត្រ, បណ្តោយ៦០ម៉ែត្រ នៅស្នាក់ការកណ្តាល រទសក(២០២៣-២០២៧)។ |
| **៧. ការងារព័ត៌មានវិទ្យា** | |
| ▪ ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាទំនើប ធ្វើឱ្យមានកត្តាប្រឈមគំរាមគំហែងនៃសន្តិសុខសាយប័រ (ការវាយប្រហារតាមរយៈបច្ចេកវិទ្យាអ៊ីនធឺណេត)។ | ▪ ត្រូវរៀបចំប្រព័ន្ធការងារការពារការវាយប្រហារតាមរយៈប្រព័ន្ធបច្ចេកវិទ្យាឱ្យបានច្បាស់លាស់។<br>▪ បង្កើនកម្រិតនៃការពារសុវត្ថិភាពរបស់ប្រព័ន្ធ និងការគ្រប់គ្រងទិន្នន័យ ឱ្យមានប្រសិទ្ធភាពខ្ពស់។<br>▪ កំពុងអនុវត្តរៀបចំនីតិវិធីស្តង់ដារ សន្តិសុខសាយប័រ និងយន្តការក្នុងការពារការវាយប្រហារតាមរយៈប្រព័ន្ធបច្ចេកវិទ្យា។ |

# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

## ក.១- លទ្ធផលការងារប្រព្រឹត្តកម្មប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកបាត់បង់

### ក.១.១- លទ្ធផលការងារប្រព្រឹត្តកម្ម

ការប្រព្រឹត្តកម្មទឹកស្អាតនៅក្នុងឆ្នាំ២០២៣ នេះ មានដូចក្នុងតារាងខាងក្រោម៖

| **បរិយាយ** | **ផែនការ** (គិតជាម៉ែត្រគូប) | **អនុវត្តជាក់ស្តែង** (គិតជាម៉ែត្រគូប) | **អត្រា** (គិតជា %) |
|---|---|---|---|
| រោងចក្រភូមិព្រែក | ៥៨.៦៤៨.៧០០ | ៦០.៩៤៤.៧៦៨ | ១០៤ |
| រោងចក្រជ្រោយចង្វារ | ៥៤.០០៧.០០០ | ៥៥.៦៨៨.៤៦០ | ១០៣ |
| រោងចក្រចំការមន | ១៨.៨៥៧.០០០ | ១៩.០៣៦.៤៥១ | ១០១ |
| រោងចក្រនិរោធ | ៩៥.៤២៨.០០០ | ៩៥.០៧៦.៦២០ | ១០០ |
| រោងចក្របាក់ខែង | ៤៣.៧៥២.០០០ | ៤៧.៤៦៤.២១៨ | ១០៨ |
| រោងចក្រម្លេច | ៣២៥.២០០ | ៤៩៧.១៨៣ | ១៥៣ |
| រោងចក្រត្បូងឃ្មុំ | ២៧៣.៩០០ | ៣៤៥.៩៥១ | ១២៦ |
| រោងចក្របឹងធំ | ៩៧១.៣០០ | - | - |
| **សរុប** | **២៧២.២៦៣.១០០** | **២៧៩.០៥៣.៦៥១** | **១០២** |

គុណភាពទឹកតាមបណ្តារោងចក្រប្រព្រឹត្តកម្មទឹកស្អាត និងបណ្តាញចែកចាយ៖

| មុខវិភាគ | ឯកតា | WHO | រោងចក្រ ភូមិព្រែក | រោងចក្រ ជ្រោយចង្វារ | រោងចក្រ ចំការមន | រោងចក្រ និរោធ | រោងចក្រ បាក់ខែង | រោងចក្រ ម្លេច | រោងចក្រ ត្បូងឃ្មុំ | បណ្តាញ ចែកចាយ |
|---|---|---|---|---|---|---|---|---|---|---|
| **ភាពល្អក់** | NTU | ≤ ៥ | ០,៣០ | ០,២៥ | ០,១៤ | ០,៣៤ | ០,១៧ | ០,៤៦ | ០,៥៧ | ០,៣៤ |
| **តម្លៃប៉េហាស់** | pH | ៦,៥ - ៨,៥ | ៧,៣៨ | ៧,៥២ | ៧,៥១ | ៧,២៣ | ៧,៥២ | ៧,១៣ | ៧,៤៣ | ៧,៣៤ |
| **ក្លរសេរី** | mg/l | ០,១ - ១ | ១,៥៧ | ១,៣៥ | ១,១៤ | ១,៣៨ | ១,១៨ | ១,៤០ | ១,០០ | ០,៤៥ |
| **ក្លរសរុប** | mg/l | <២ | ១,៧៩ | ១,៥០ | ១,៣០ | ១,៥៤ | ១,២៩ | ១,៦០ | ១,១៤ | ០,៥៩ |
| **មេរោគកូលីហ្វម** | cfu/100ml | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **មេរោគអ៊ីកូលី** | cfu/100ml | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

### ក.១.២- លទ្ធផលការងាររៀបចំ ប្រព័ន្ធចែកចាយទឹកស្អាត

ប្រវែងបំពង់ដែលបានដាក់តាមឆ្នាំនីមួយៗ (គិតជាគីឡូម៉ែត្រ)



# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ( ត )

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

## ក.១- លទ្ធផលការងារប្រព្រឹត្តកម្មប្រព័ន្ធចែកចាយទឹកនិងការងារកាត់បន្ថយទឹកបាត់បង់ (ត)

### ក.១.៣- លទ្ធផលការងារកាត់បន្ថយទឹកបាត់បង់

អត្រាទឹកបាត់បង់របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅមានកម្រិតនៅក្នុងរង្វង់លេខមួយខ្ទង់ប៉ុណ្ណោះ ពោលគឺបានបន្ថយទឹកបាត់បង់មកនៅត្រឹមអត្រា ៨,៧៥% ដូចបានបង្ហាញក្នុងក្រាហ្វិចខាងក្រោម។

ក្រាហ្វិចបង្ហាញពីអត្រាទឹកបាត់បង់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០២៣ (គិតជាភាគរយ)




## ក.២- សកម្មភាព និងលទ្ធផលការងារអាជីវកម្ម

### ក.២.១- ការងារផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋមានចំណូលទាប




### ក.២.២- ការងារតបណ្តាញចូលផ្ទះ និងការគ្រប់គ្រងអតិថិជន

| ប្រភេទអតិថិជន | ២០១៨ (ចំនួនបណ្តាញ) | ២០១៩ (ចំនួនបណ្តាញ) | ២០២០ (ចំនួនបណ្តាញ) | ២០២១ (ចំនួនបណ្តាញ) | ២០២២ (ចំនួនបណ្តាញ) | ២០២៣ (ចំនួនបណ្តាញ) | ២០២៣ (ភាគរយ) |
|---|---|---|---|---|---|---|---|
| ជីវភាព | ៣០១.៨៣៤ | ៣២១.២១២ | ៣៣៣.០៩៩ | ៣៥០.៤៦៣ | ៣៦០.៩៤៨ | ៣៨១.៧៥២ | ៧៩,៨៤០៩ |
| អាជីវកម្ម | ៥៨.៧៨៩ | ៦២.៣៦៦ | ៦៨.១៣៦ | ៧៤.៣៤៤ | ៨៣.៨៧៤ | ៨៩.៧០២ | ១៨,៧៦០៦ |
| អង្គភាពរដ្ឋ | ៦៦៤ | ៦៩៦ | ៧៤៤ | ៨២៣ | ៩១៣ | ៩១៨ | ០,១៩២០ |
| អ្នកលក់ទឹក | ០៧ | ០៧ | ១០ | ១១ | ០៩ | ០៦ | ០,០០១៣ |
| តំណាងចែកចាយ | ២១ | ១៧ | ១៤ | ១៦ | ០៥ | ០៣ | ០,០០០៦ |
| Standpipe | ១៤ | ១៧ | ១៧ | ១៦ | ១៦ | ១៤ | ០,០០២៩ |
| បន្ទប់ជួល | ៥.៧០៣ | ៥.៧៥២ | ៥.៧៥៩ | ៥.៧២៨ | ៥.៧៨៩ | ៥.៧៤៦ | ១,២០១៧ |
| | **៣៦៧.០៣២** | **៣៩០.០៦៧** | **៤០៧.៧៧៩** | **៤៣១.៤០១** | **៤៥១.៥៥៤** | **៤៧៨.១៤១** | |

# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច (ត)

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ក.៣- ការងារគ្រប់គ្រងធនធានមនុស្ស




*សរុបចំនួនមន្ត្រី-និយោជិតក្នុងឆ្នាំ២០២៣: ១.៣៧០រូប (ស្រី: ២២៩រូប)*

## ខ- រចនាសម្ព័ន្ធចំណូល

| ល. រ | ប្រភពចំណូល | ឆ្នាំ២០២៣ | | ឆ្នាំ២០២២ | | ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | (ពាន់រៀល) | ភាគរយ | (ពាន់រៀល) | ភាគរយ | (ពាន់រៀល) | ភាគរយ |
| ១ | ចំណូលពីការលក់ | ៣៤៩.៦៤០.០៧៣ | ៨៩,១៨% | ២៩៩.៧២៣.៥០៧ | ៨៦,៣១% | ២៨២.៣៦៩.៧៩៧ | ៧៦,៤៩% |
| ២ | កម្រៃពីសេវាសាងសង់ | ១៦.៦៦៥.៦១៧ | ៤,២៥% | ២៤.៩៧៦.៣១៦ | ៧,១៩% | ២៦.២៤១.៩៨៩ | ៧,១១% |
| ៣ | ចំណូលពីការប្តូររូបិយប័ណ្ណ-សុទ្ធ | ៤.១១១.០៣៩ | ១,០៥% | ១.១០៥.៧០០ | ០,៣២% | ២.២៧៣.៩៨៤ | ០,៦២% |
| ៤ | ចំណូលផ្សេងៗ | ២១.៦៣៧.៦៣៦ | ៥,៥២% | ២១.៤៧៨.៣៣៣ | ៦,១៨% | ៥៨.២៥៩.៤៨៧ | ១៥,៧៨% |
| | **ចំណូលសរុប** | **៣៩២.០៥៤.៣៦៥** | | **៣៤៧.២៨៣.៨៥៦** | | **៣៦៩.១៤៥.២៥៧** | |

# ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

## ក- អង្គការលេខ



# ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម (ត)

## ខ- ក្រុមប្រឹក្សាភិបាល

| ល.រ. | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯកឧត្តម ស៊ឹម ស៊ីថា | ប្រធានក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ២ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៣ | ឯកឧត្តម ឡុង ណារ៉ូ | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៤ | ឯកឧត្តម នួន ផារ័ត្ន | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៥ | លោក ម៉ា ណូរ៉ាវីន | សមាជិកក្រុមប្រឹក្សាភិបាល | ២៧/០២/២០២៣ | ២៧/០២/២០២៦ |
| ៦ | លោក ស្រេង សំឌិក | អភិបាលឯករាជ្យ | ១៣/០៥/២០២២ | ១៣/០៥/២០២៥ |
| ៧ | លោក ណាំ ចន្ទ្រី | អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន | ១៣/០៥/២០២២ | ១៣/០៥/២០២៥ |

- ឈ្មោះលេខាធិការសហគ្រាសរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ:
  - **លោក ជូ ផល្លា**
  - **លោក ហួត សុខហេង**

## គ- បុគ្គលិកជាន់ខ្ពស់

សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | ឯកឧត្តម ឡុង ណារ៉ូ | ប្រុស | អគ្គនាយក |
| ២ | ឯកឧត្តម នេត មុន្នី | ប្រុស | មន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ |
| ៣ | ឯកឧត្តម សំរិទ្ធ សុវិទ្យា | ប្រុស | អគ្គនាយករង |
| ៤ | ឯកឧត្តម ចាន់ ពិសិដ្ឋ | ប្រុស | អគ្គនាយករង |
| ៥ | លោកជំទាវ រឿន ណារី | ស្រី | អគ្គនាយករង |
| ៦ | លោក ម៉ា ណូរ៉ាវីន | ប្រុស | អគ្គនាយករង |
| ៧ | លោក ជា សតិភទ្ទ | ប្រុស | អគ្គនាយករង |
| ៨ | លោក ផេង ទី | ប្រុស | អគ្គនាយករង |
| ៩ | លោក ដេង ប៉ូលីដែន | ប្រុស | អគ្គនាយករង និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន |
| ១០ | លោក ជូ ផល្លា | ប្រុស | លេខាធិការសហគ្រាស និងជាបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន |
| ១១ | លោក ហួត សុខហេង | ប្រុស | លេខាធិការសហគ្រាស |
| ១២ | លោក សោម សុវណ្ណ | ប្រុស | ប្រធាននាយកដ្ឋានអាជីវកម្ម |
| ១៣ | លោកស្រី សេង គាតារា | ស្រី | ប្រធានសវនកម្មផ្ទៃក្នុង |
| ១៤ | លោក សារុជ វឌ្ឍនា | ប្រុស | ប្រធានមណ្ឌលព័ត៌មានវិទ្យា |
| ១៥ | ហេង សុផាន់ណារ៉ាត | ប្រុស | ប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស |
| ១៦ | លោក អ៊ុំ គុណវឌ្ឍន៍ | ប្រុស | ប្រធាននាយកដ្ឋានផែនការ និងគម្រោង |
| ១៧ | លោក សុខ ណារ៉េត | ប្រុស | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ |
| ១៨ | លោក ឈឹម សេរីរ៉ុជ | ប្រុស | ប្រធាននីតិកម្ម និងដោះស្រាយវិវាទ |
| ១៩ | លោក ទុយ ប៊ុនសេរីទ្ធ | ប្រុស | ប្រធាននាយកដ្ឋានសាខាសេវាកម្មទឹកស្អាត |

# ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម (ត)

## គ- បុគ្គលិកជាន់ខ្ពស់ (ត)

សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ២០ | លោក កាំង សោភីណា | ប្រុស | ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក |
| ២១ | លោក កែម កានវិចិត្រ | ប្រុស | ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម |
| ២២ | លោកស្រី ស៊ឹម វល្លិកា | ស្រី | ប្រធានអង្គភាពលទ្ធកម្ម |
| ២៣ | លោក មាស កុសល | ប្រុស | ជំនួយការអគ្គនាយករងទទួលបន្ទុកផែនការ និងគម្រោង |
| ២៤ | លោកស្រី ប្រាក់ ចាន់មករា | ស្រី | ជំនួយការអគ្គនាយករងទទួលបន្ទុករដ្ឋបាល និងធនធានមនុស្ស |
| ២៥ | លោក រស់ បូរិន្ទ | ប្រុស | ជំនួយការអគ្គនាយក |

សម្គាល់: ព័ត៌មានលម្អិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាមួយឧបសម្ព័ន្ធ១។

# ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក

## ក- ព័ត៌មានអំពីមូលបត្រ

### ១- ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

- ឈ្មោះមូលបត្រកម្មសិទ្ធិ: ភាគហ៊ុនធម្មតា
- និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ: PWSA
- ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ: មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត
- តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ: ១.០០០រៀល
- ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (IPO Price): ៦.៣០០រៀល
- បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ: ១៣.០៤៥.៩៧៥មូលបត្រកម្មសិទ្ធិ
- មូលធនូបនីយកម្មទីផ្សារ: ៦៣៣.១៦៤.៦១៩.៣៦០រៀល (ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣)
- ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត: ផ្សារមូលបត្រកម្ពុជា (ផមក)
- កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ: ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២

## ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្រកម្មសិទ្ធិ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ៧.៨៤០ | ៨.០៦០ | ៨.០០០ | ៧.៨០០ | ៧.៨២០ | ៧.៨៨០ |
| | មធ្យម | ៧.៧៣៨ | ៧.៩៣៥ | ៧.៨៣៥ | ៧.៧៨២ | ៧.៧៤៧ | ៧.៥៦៥ |
| | អប្បបរមា | ៧.៦៤០ | ៧.៨៤០ | ៧.៦២០ | ៧.៧៦០ | ៧.៦៨០ | ៧.៤៤០ |
| បរិមាណជួញដូរ | អតិបរមា | ២៤.២៩៦ | ៨.៥៣៧ | ៤៧.៥០៥ | ១១.៤២៨ | ១១.៦៦១ | ១២.៣៨៧ |
| | មធ្យម | ៤.៣៨៥ | ៣.៧៨៤ | ៥.៥៧០ | ២.២០៩ | ៣.៨៣៤ | ៣.៤៦៤ |
| | អប្បបរមា | ២៩៩ | ៣១០ | ៥១៦ | ៤៤៥ | ២៨៣ | ៣០៧ |

| មូលបត្រកម្មសិទ្ធិ | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ៧.៥០០ | ៧.៥០០ | ៧.៤៦០ | ៧.៣៤០ | ៧.២៨០ | ៧.៣២០ |
| | មធ្យម | ៧.៤៧១ | ៧.៤៧៣ | ៧.៣៨៧ | ៧.២៥០ | ៧.២២៧ | ៧.២៨៦ |
| | អប្បបរមា | ៧.៤០០ | ៧.៤៤០ | ៧.៣០០ | ៧.១២០ | ៧.១៨០ | ៧.២៦០ |
| បរិមាណជួញដូរ | អតិបរមា | ៥.៨០៦ | ១៥.៣៣១ | ២៣.៩៤៣ | ១៤.៣៨២ | ៧.១៥៩ | ៣៣.៥១០ |
| | មធ្យម | ១.៩៣២ | ១.៩០១ | ៣.៨៣៥ | ២.៨៩៥ | ១.៨៤៣ | ៤.២៨៣ |
| | អប្បបរមា | ២១៥ | ៥០ | ១៤ | ១៧៤ | ៥៤ | ៣៨៧ |

## គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | រដ្ឋ តំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខ្មែរ | ៧៣.៩២៧.១៨៧ | ៨៥% |
| សរុប | | | ៧៣.៩២៧.១៨៧ | ៨៥% |

## ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ រ.ទ.ស.ភ ពុំមានភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើននោះទេ។

# ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក (ត)

## ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល៣(បី)ឆ្នាំចុងក្រោយ

| **ពិពណ៌នាលំអិតអំពីការបែងចែកភាគលាភ** | **២០២២** | **២០២១** | **២០២០** |
|---|---|---|---|
| ចំណេញសុទ្ធ (ពាន់រៀល) | ១០៨.១៨៥.៨៦៥ | ១២៩.២៧៣.៩១៧ | ៨៨.៣៥១.៨៤៥ |
| ភាគលាភជាសាច់ប្រាក់សរុប (ពាន់រៀល) | ២៨.៧០១.១៤៣ | ២៦.៩៦១.៦៨០ | ២២.៧៨៦.៩៦៨ |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | គ្មាន | គ្មាន | គ្មាន |
| ភាគលាភផ្សេងៗទៀត | គ្មាន | គ្មាន | គ្មាន |
| អនុបាតនៃការបែងចែកភាគលាភ | ២៦,៥៣ % | ២០,៨៦% | ២៥,៧៩% |
| ទិន្នផលភាគលាភ | * ៤,៣៧ % | * *៤,៣៣% | * * *៤,៣០% |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៣៣០ រៀល | ៣១០រៀល | ២៦២រៀល |

* ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ គឺ ៧.៥៦០រៀល
* * ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ គឺ ៧.១៦០រៀល
* * * ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ គឺ ៦.១០០រៀល

# ផ្នែកទី៥:

# របាយការណ៍សវនកម្ម របស់សវនករផ្ទៃក្នុង

## លើការត្រួតពិនិត្យផ្ទៃក្នុង

# របាយការណ៍សវនកម្មផ្ទៃក្នុង

## ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ

### ប្រចាំឆ្នាំ២០២៣

### ត្រូវបានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ២

# ផ្នែកទី៦:

# របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយ

## សវនករឯករាជ្យ

# របាយការណ៍ក្រុមប្រឹក្សាភិបាល
# និង
# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

**ត្រូវបានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ៣**

# ផ្នែកទី៧: ព័ត៌មានអំពីប្រតិបត្តិការ ជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

គ- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ឃ- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ង- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជី

ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គល ទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយ រ.ទ.ស.ភ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ច- ប្រតិបត្តិការសំខាន់ៗជាមួយ បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធ ជាមួយបុគ្គលធ្លាប់ជាអភិបាល

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពី រ.ទ.ស.ភ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ជ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពី រ.ទ.ស.ភ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

រ.ទ.ស.ភ មានចំណូល៣ប្រភេទធំៗគឺចំណូលបានមកពីការលក់ទឹក សេវាសាងសង់ និងចំណូលផ្សេងៗ៖

- ចំណូលបានមកពីការលក់ទឹករួមមានៈចំណូលពីការប្រើប្រាស់ប្រភេទជីវភាព អាជីវកម្ម ឧស្សាហកម្ម អង្គភាពរដ្ឋ បន្ទប់ជួល និងអ្នកលក់ទឹកបន្ត។ ចំណូលទាំងនេះត្រូវបានរាយការណ៍តាមតម្លៃទទួលបានសុទ្ធ ក្រោយការកាត់កងជាមួយអប្បហារវិភាជន៍ និងឥណទានហើយត្រូវបានទទួលស្គាល់តាមបរិមាណទឹកដែលបានផ្គត់ផ្គង់ជូនអតិថិជនរបស់ខ្លួន។ ការធ្វើវិក្កយបត្រនៃការប្រើប្រាស់ទឹក ត្រូវបានធ្វើឡើងក្នុងរយៈពេលរៀងរាល់២ខែម្តង។

- ចំណូលបានពីសេវាសាងសង់: គឺជាចំណូលបានមកពីសេវាសាងសង់ ទាក់ទិនទៅនឹងការប្តូរ និងការពង្រីកប្រព័ន្ធចែកចាយទឹកដែល រ.ទ.ស.ភ បានសាងសង់ជូនក្រុមហ៊ុនសំណង់មួយ។

- ចំណូលផ្សេងៗរួមមាន: ចំណូលបានមកពីការថែទាំនាឡិកា លក់សម្ភារតបណ្តាញទឹក ការផាកពិន័យលើការប្រើប្រាស់ទឹកពុំមានការអនុញ្ញាតពី រ.ទ.ស.ភ និងផ្សេងៗ។

- **ចំណូលថែទាំនាឡិកា៖** គឺចំណូលបានពីថ្លៃឈ្នួលថែទាំនាឡិកាដោយគិតថ្លៃ៥០រៀលក្នុង១មីលីម៉ែត្រក្នុងមួយខែនៃទំហំនាឡិកាទឹកក្នុងអំឡុងវដ្តនៃការគិតប្រាក់ ហើយត្រូវបានកត់ត្រាជាប្រាក់ចំណូល។ ចំណូលនេះត្រូវបានប្រើប្រាស់សម្រាប់ផ្លាស់ប្តូរនាឡិកាជូនអតិថិជននាពេលអនាគត។
- **ចំណូលពីការលក់សម្ភារតបណ្តាញទឹក៖** គឺជាចំណូលទទួលបានពីការលក់នាឡិកាស្ទង់ទឹក បំពង់ និងសម្ភារតភ្ជាប់។
- **ចំណូលពីការផាកពិន័យ៖** គឺជាចំណូលទទួលបានពីការផាកពិន័យលើការបង់ថ្លៃប្រើប្រាស់ទឹកយឺតយ៉ាវ និងពិន័យលើបទល្មើសតបណ្តាញទឹកដោយពុំមានការអនុញ្ញាតពី រ.ទ.ស.ភ។
- **ចំណូលផ្សេងៗ៖** គឺជាចំណូលទទួលបានមកពីការរួមចំណែករបស់អតិថិជនប្រភេទពាណិជ្ជកម្ម និងឧស្សាហកម្មក្នុងការវិនិយោគសម្រាប់ការភ្ជាប់បណ្តាញពិសេសចូលទីតាំងផ្ទាល់របស់ពួកគេ។ក្រៅពីនោះ គឺជាចំណូលដែលទទួលបានពីកម្រៃសេវាលើការទារថ្លៃថែទាំលូទឹកស្អុយរបស់សាលារាជធានីភ្នំពេញ។

➢ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២**

| បរិយាយ | ឆ្នាំ២០២៣ (ពាន់រៀល) | ឆ្នាំ២០២២ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល) | ភាគរយ |
|---|---|---|---|---|
| | (ក) | (ខ) | (ក-ខ) | (ក-ខ)/ខ*១០០ |
| ចំណូលសរុប | ៣៩២.០៥៤.៣៦៥ | ៣៤៧.២៨៣.៨៥៦ | ៤៤.៧៧០.៥០៩ | ១២,៨៩% |

រ.ទ.ស.ភ មានចំណូលសរុប ៣៩២.០៥៤.៣៦៥.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ៣៤៧.២៨៣.៨៥៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលមានទឹកប្រាក់កើនឡើងចំនួន ៤៤.៧៧០.៥០៩.០០០រៀល ស្មើនឹង ១២,៨៩%។ យើងឃើញថាកត្តាចម្បងនៃការកើនឡើងនៃចំណូលសរុបនេះ ដោយសារចំណូលពីការលក់បានកើនឡើងចំនួន ៤៩.៩១៦.៥៦៦.០០០រៀល ស្មើនឹង ១៦,៦៥% និងចំណេញពីការប្តូររូបិយប័ណ្ណសុទ្ធបានកើនឡើងចំនួន ៣.០០៥.៣៣៩.០០០រៀល ស្មើនឹង ២៧១,៨០%។

### ២- ការវិភាគចំណូលតាមផ្នែក

ការវិភាគចំណូលតាមផ្នែករបស់ រ.ទ.ស.ភ មានដូចខាងក្រោម:

| បរិយាយ | ឆ្នាំ២០២៣ (ពាន់រៀល) | ភាគរយ | ឆ្នាំ២០២២ (ពាន់រៀល) | ភាគរយ |
|---|---|---|---|---|
| ចំណូលពីការលក់ | ៣៤៩.៦៤០.០៧៣ | ៨៩,១៨% | ២៩៩.៧២៣.៥០៧ | ៨៦,៣១% |
| កម្រៃពីការសាងសង់ | ១៦.៦៦៥.៦១៧ | ៤,២៥% | ២៤.៩៧៦.៣១៦ | ៧,១៩% |
| ចំណូលពីការប្តូររូបិយប័ណ្ណ-សុទ្ធ | ៤.១១១.០៣៩ | ១,០៥% | ១.១០៥.៧០០ | ០,៣២% |
| ចំណូលផ្សេងៗ | ២១.៦៣៧.៦៣៦ | ៥,៥២% | ២១.៤៧៨.៣៣៣ | ៦,១៨% |
| **ចំណូលសរុប** | ៣៩២.០៥៤.៣៦៥ | | ៣៤៧.២៨៣.៨៥៦ | |

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ២- ការវិភាគចំណូលតាមផ្នែក (ត)

មានតែប្រាក់ចំណូលតាមប្រភេទជាសារវន្តត្រូវបានលើកឡើងសម្រាប់ការវិភាគខាងក្រោម៖

➤ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| បរិយាយ | ឆ្នាំ២០២៣ | | ឆ្នាំ២០២២ | | បម្រែបម្រួល | | |
|---|---|---|---|---|---|---|---|
| | បរិមាណ (ម³) | ទឹកប្រាក់ (ពាន់រៀល) | បរិមាណ (ម³) | ទឹកប្រាក់ (ពាន់រៀល) | បរិមាណ (ម³) | ទឹកប្រាក់ (ពាន់រៀល) | ភាគរយ |
| | (ក) | (ខ) | (គ) | (ឃ) | (ក-គ) | (ខ-ឃ) | (ខ-ឃ)/ឃ*១០០ |
| ជីវភាព | ១២៩.៣០៩.៥៣៤ | ១២៩.០៣៨.២០៤ | ១១២.០២៧.៦០០ | ១១០.៨៧៣.៥១៩ | ១៧.២៨១.៩៣៤ | ១៨.១៦៤.៦៨៥ | ១៦,៣៨% |
| អាជីវកម្ម | ៩២.៩៧៣.៤៥៤ | ១៦៩.៧៤៣.៩៣៩ | ៨៤.៧៧៥.០១៧ | ១៥១.៨៧០.១៥៣ | ៨.១៩៨.៤៣៧ | ១៧.៨៧៣.៧៨៦ | ១១,៧៧% |
| គ្រឹះស្ថានសាធារណៈ | ១០.២១៣.៨៦១ | ២៣.៧៨៥.៩៥៧ | ៩.១៩៥.៩៦៤ | ១៩.៦៧១.០៣៦ | ១.០១៧.៨៩៧ | ៤.១១៤.៩២១ | ២០,៩២% |
| តំណាងចែកចាយ និងបន្ទប់ជួល | ១៦.៦៨៣.៥៤៧ | ១១.៩៤០.០៦០ | ១២.៨១៤.១៨៦ | ១០.៣១៧.៣៨៩ | ៣.៨៦៩.៣៦១ | ១.៦២២.៦៧១ | ១៥,៧៣% |

- **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់តាមផ្ទះ (ប្រភេទជីវភាព)**

ចំណូលថ្លៃលក់ទឹកជូនអតិថិជនប្រភេទជីវភាពមានចំនួន ១២៩.០៣៨.២០៤.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ១១០.៨៧៣.៥១៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលមានទឹកប្រាក់កើនឡើងចំនួន ១៨.១៦៤.៦៨៥.០០០រៀល ស្មើនឹង ១៦,៣៨%។ យើងឃើញថាការកើនឡើងនេះដោយសារចំនួនអតិថិជនបានកើនឡើងចំនួន ២០.៨០៤បណ្តាញ ពី ៣៦០.៩៤៨បណ្តាញ ទៅ ៣៨១.៧៥២បណ្តាញ, បរិមាណទឹកប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែបានកើនឡើងចំនួន ២,៨៣ម³ ពី ២៦,៣១ម³ ទៅ ២៩,១៤ម³ និងថ្លៃលក់ទឹកជាមធ្យមបានកើនឡើងចំនួន ៨,២០រៀល/ម³ ពី ៩៨៩,៧០រៀល/ម³ ទៅ ៩៩៧,៩០រៀល/ម³។

- **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម (ប្រភេទអាជីវកម្ម និងឧស្សាហកម្ម)**

ចំណូលថ្លៃលក់ទឹកជូនអតិថិជនប្រភេទអាជីវកម្មចំនួន ១៦៩.៧៤៣.៩៣៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ១៥១.៨៧០.១៥៣.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលមានទឹកប្រាក់កើនឡើងចំនួន ១៧.៨៧៣.៧៨៦.០០០រៀល ស្មើនឹង ១១,៧៧%។ យើងឃើញថាការកើនឡើងនេះដោយសារចំនួនអតិថិជនបានកើនឡើង ៥.៨២៨បណ្តាញ ពី ៨៣.៨៧៤បណ្តាញ ទៅ ៨៩.៧០២បណ្តាញ, បរិមាណទឹកប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែបានកើនឡើងចំនួន ០,៨៨ម³ ពី ៨៩,៣៧ម³ ទៅ ៩០,២៥ម³ និងថ្លៃលក់ទឹកជាមធ្យមបានកើនឡើងចំនួន ៣៤,២៨រៀល/ម³ ពី ១.៧៩១,៤៥រៀល/ម³ ទៅ ១.៨២៥,៧២រៀល/ម³។

- **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់គ្រឹះស្ថានសាធារណៈ (ប្រភេទអង្គភាពរដ្ឋ)**

ចំណូលថ្លៃលក់ទឹកជូនអតិថិជនប្រភេទអង្គភាពរដ្ឋចំនួន ២៣.៧៨៥.៩៥៧.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ១៩.៦៧១.០៣៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលមានទឹកប្រាក់កើនឡើងចំនួន ៤.១១៤.៩២១.០០០រៀល ស្មើនឹង ២០,៩២%។ យើងឃើញថាការកើនឡើងនេះ ដោយសារចំនួនអតិថិជនបានការកើនឡើងចំនួន ៥បណ្តាញ ពី ៩១៣បណ្តាញ ទៅ ៩១៨បណ្តាញ, បរិមាណទឹកប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែបានកើនឡើងចំនួន ៤៥,៥៣ម³ ពី ៧៣៧,៥០ម³ ទៅ ៧៨៣,០៣ម³ និងថ្លៃលក់ទឹកជាមធ្យមថេរ ២.៥០០រៀល។

- **ចំណូលបានពីការលក់ទឹកស្អាតជូនតំណាងចែកចាយ និងបន្ទប់ជួល**

ចំណូលពីការលក់ទឹកស្អាតជូនតំណាងចែកចាយ/បន្ទប់ជួលចំនួន ១១.៩៤០.០៦០.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ១០.៣១៧.៣៨៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលមានទឹកប្រាក់កើនឡើងចំនួន ១.៦២២.៦៧១.០០០រៀល ស្មើនឹង ១៥,៧៣%។ យើងឃើញថាការកើនឡើងនេះដោយសារបរិមាណទឹកប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែបានកើនឡើងចំនួន ៥៥,១៧ម³ ពី ១៨៤,៩៤ម³ ទៅ ២៤០,១១ម³ និងថ្លៃលក់ទឹកជាមធ្យមបានកើនឡើងចំនួន ១៥,៦៨រៀល/ម³ ពី ៧០០,០០រៀល/ម³ ទៅ ៧១៥,៦៨រៀល/ម³។ ដោយឡែកចំនួនអតិថិជនបានថយចុះ ៥០បណ្តាញ ពី ៥.៨១៩បណ្តាញ មកត្រឹម ៥.៧៦៩បណ្តាញ។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៣-ការវិភាគគម្លាតចំណេញដុល

រ.ទ.ស.ភ បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមប្រភេទ ដូចនេះពុំមានការបង្ហាញ ឲ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឲ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការ ដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ។

ចំណាយប្រត្តិបត្តិការនឹងលើកយកមកពិភាក្សានៅចំណុចទី ៤- ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធខាងក្រោម។

### ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

ការចំណេញមុនបង់ពន្ធគឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ និង ចំណូល (ចំណាយ) ការប្រាក់សុទ្ធ។ ក្នុងការពិភាក្សា និងការវិភាគនៃចំណាយប្រតិបត្តិការ យើងលើកយកតែចំណាយរំលស់ ទ្រព្យសកម្មរូបីនិងអរូបី ចំណាយលើការប្រើប្រាស់អគ្គិសនី និងចំណាយលើប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត ចំណាយសេវាសាងសង់ ចំណូល (ចំណាយ)ការប្រាក់ យកមកពិភាក្សាដូចខាងក្រោម៖

- **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២**

| បរិយាយ | ឆ្នាំ២០២៣ (ពាន់រៀល) | ឆ្នាំ២០២២ (ពាន់រៀល) | បម្រែបម្រួល | |
|---|---|---|---|---|
| | | | (ពាន់រៀល) | ភាគរយ |
| | ក | ខ | ក - ខ | (ក-ខ)/ខ*១០០ |
| ចំណូលសរុប | ៣៩២.០៥៤.៣៦៥ | ៣៤៧.២៨៣.៨៥៦ | ៤៤.៧៧០.៥០៩ | ១២,៨៩% |
| ចំណាយអត្ថប្រយោជន៍របស់និយោជិត | (៨០.២៩២.៤៣៨) | (៧០.១៧៥.៤២២) | ១០.១១៧.០១៦ | ១៤,៤២% |
| ចំណាយរំលស់លើ ទ្រព្យសកម្មរូបី និងអរូបី | (៦១.៩៧៨.១៣៥) | (៥៩.៤៥៥.០៧៤) | ២.៥២៣.០៦១ | ៤,២៤% |
| ចំណាយការប្រើប្រាស់អគ្គិសនី | (៤២.២៩១.៤៤៦) | (៣៥.២១៨.៧៤៣) | ៧.០៧២.៧០៣ | ២០,០៨% |
| ចំណាយវត្ថុធាតុដើមសម្រាប់ ផលិតទឹកស្អាត | (១៥.៨៧៥.៣១៣) | (១២.១៤០.៧៤០) | ៣.៧៣៤.៥៧៣ | ៣០,៧៦% |
| ចំណាយសេវាសាងសង់ | (៩.៧៣១.៥១៨) | (១៦.៦១៨.០២៤) | (៦.៨៨៦.៥០៦) | (៤១,៤៤%) |
| ចំណូលការប្រាក់ | ៦.៧៣៧.៧៦៦ | ៤.៦៥៦.៦១៨ | ២.០៨១.១៤៨ | ៤៤,៦៩% |
| ចំណាយការប្រាក់ | (៣.៥២៧.៧៣០) | (៣.៦១០.៤៣៤) | (៨២.៧០៤) | (២,២៩%) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | **១៥៣.៤៧២.៥៤៣** | **១៣០.៥១៥.៨៩២** | **២២.៩៥៦.៦៥១** | **១៧,៥៩%** |

រ.ទ.ស.ភ មានចំណេញមុនបង់ពន្ធលើប្រាក់ចំណូលចំនួន ១៥៣.៤៧២.៥៤៣.០០០រៀល នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ១៣០.៥១៥.៨៩២.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលមានទឹកប្រាក់កើនឡើងចំនួន ២២.៩៥៦.៦៥១.០០០រៀល ស្មើនឹង ១៧,៥៩%។ យើងឃើញថាកត្តាចម្បងនៃការកើនឡើងចំណេញមុនបង់ពន្ធលើប្រាក់ចំណូល ដោយសារចំណូលពីការលក់បានកើនឡើងចំនួន ៥៩.៩១៦.៥៦៦.០០០រៀល ស្មើនឹង ១៦,៦៥% និងចំណេញពីការប្តូររូបិយប័ណ្ណសុទ្ធបានកើនឡើងចំនួន ៣.០០៥.៣៣៩.០០០រៀល ស្មើនឹង ២៧១,៨០% ទោះបីជាចំណាយលើសេវាសាងសង់បានថយចុះចំនួន ៦.៨៨៦.៥០៦.០០០រៀល ស្មើនឹង ៤១,៤៤%។

### ៥- ការវិភាគចំណេញ/(ខាត) និងលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

រ.ទ.ស.ភ ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ រ.ទ.ស.ភ មានកាតព្វកិច្ចត្រូវបង់ពន្ធលើប្រាក់ចំណូលអត្រា ២០%។ ដោយឡែកពន្ធលើប្រាក់ចំណូលដែលជាប់អត្រា ២០% បានមកពីលទ្ធផលនៃប្រាក់ចំណេញគណនេយ្យទូទាត់ជាមួយនឹងចំណាយដែលមិនអាចកាត់កងបានក្នុងអត្រាពន្ធ ២០%។

# ផ្នែកទី៤: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៥- ការវិភាគចំណេញ/(ខាត) និងលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (ត)

➢ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២**

| បរិយាយ | ឆ្នាំ២០២៣ (ពាន់រៀល) | ឆ្នាំ២០២២ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល) | ភាគរយ |
|---|---|---|---|---|
| | គ | ឃ | គ - ឃ | (គ-ឃ)/ឃ*១០០ |
| ចំណេញមុនបង់ពន្ធ (ក) | ១៥៣.៤៧២.៥៤៣ | ១៣០.៥១៥.៨៩២ | ២២.៩៥៦.៦៥១ | ១៧,៥៩% |
| ចំណាយពន្ធលើប្រាក់ចំណូល (ខ) | (២៦.៨៦២.៩៦១) | (២២.៣៣០.០២៧) | ៤.៥៣២.៩៣៤ | ២០,៣០% |
| ចំណេញក្នុងការិយបរិច្ឆេទ | ១២៦.៦០៩.៥៨២ | ១០៨.១៨៥.៨៦៥ | ១៨.៤២៣.៧១៧ | ១៧,០៣% |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១២៦.៦០៩.៥៨២ | ១០៨.១៨៥.៨៦៥ | ១៨.៤២៣.៧១៧ | ១៧,០៣% |
| អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ (ខ)/(ក) | ១៧,៥០% | ១៧,១១% | | |

រ.ទ.ស.ភ មានចំណេញក្នុងការិយបរិច្ឆេទចំនួន ១២៦.៦០៩.៥៨២.០០០រៀល នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ១០៨.១៨៥.៨៦៥.០០០រៀល នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលមានទឹកប្រាក់កើនឡើងចំនួន ១៨.៤២៣.៧១៧.០០០រៀល ស្មើនឹង១៧,០៣%។ យើងឃើញថាកត្តាចម្បងនៃការកើនឡើងចំណេញក្នុងការិយបរិច្ឆេទ ដោយសារចំណូលពីការលក់បានកើនឡើងចំនួន ៤៩.៩១៦.៥៦៦.០០០រៀល ស្មើនឹង ១៦,៦៥% និងចំណេញពីការប្តូររូបិយប័ណ្ណសុទ្ធបានកើនឡើងចំនួន ៣.០០៥.៣៣៩.០០០រៀល ស្មើនឹង ២៧១,៨០% ទោះបីជាចំណាយលើសេវាសាងសង់បានថយចុះចំនួន ៦.៨៨៦.៥០៦.០០០រៀល ស្មើនឹង ៤១,៤៤% លើសពីនេះចំណូលការប្រាក់បានកើនឡើងចំនួន ២.០៨១.១៤៨.០០០រៀល ស្មើនឹង ៤៤,៦៩% ផងដែរ។

### ៦-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ស្ថានភាពអូសបន្លាយពេលនៃសង្គ្រាមរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន ក៏ដូចជាស្ថានភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោកបានបន្តធ្វើអោយប៉ះពាល់ដល់ការរីកចំរើននៃសេដ្ឋកិច្ចពិភពលោក និងនៅក្នុងតំបន់ផងដែរ ប៉ុន្តែទោះជាយ៉ាងណា រ.ទ.ស.ភ នៅតែបន្តប្រតិបត្តិការប្រចាំថ្ងៃ និងនៅតែមានផលចំណេញ ក្នុងឆ្នាំ២០២៣។ ការបន្តរក្សាបាននូវផលចំណេញនេះដោយសារចំណូលពីការលក់នៅតែមានកំណើនដែរ គឺដោយសារតែមានកត្តាគាំទ្រ ដូចខាងក្រោម៖

- **អត្រាទឹកបាត់បង់៖** រ.ទ.ស.ភ បានប្រើប្រាស់នូវយន្តការដ៏មានប្រសិទ្ធភាព ដើម្បីកាត់បន្ថយអត្រាទឹក បាត់បង់ស្មើនឹង ៨,៧៥% នៅឆ្នាំ២០២៣នេះ។ ការរក្សាបានអត្រាទឹកបាត់បង់នៅត្រឹមកម្រិតនេះជាកត្តាចម្បងដែលធ្វើឲ្យ រ.ទ.ស.ភ មានចេរភាពហិរញ្ញវត្ថុ និងអភិវឌ្ឍ សហគ្រាសរក្សានូវស្ថានភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍសហគ្រាសប្រកបដោយនិរន្តភាព។
- **ការបង្កើនចំនួនអតិថិជន៖** ដើម្បីទទួលបាននូវចំណូលពីការលក់ទឹកស្អាត រ.ទ.ស.ភ. បានបង្កើនចំនួនអតិថិជន របស់ខ្លួន ដោយពង្រីកផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាតទៅតំបន់ដែលពុំទាន់មានការផ្គត់ផ្គង់ទឹកស្អាត ដូចជាការបំពេញផ្ទៃសេវាឲ្យបាន ១០០% នៅក្នុងរាជធានីភ្នំពេញ តំបន់ជុំវិញរាជធានីភ្នំពេញ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច។
- **ការបង្កើនថ្លៃលក់ទឹកមធ្យម៖** តាមរយៈការស្វែងរកអតិថិជន ដែលជាប្រភេទអាជីវកម្ម-ឧស្សាហកម្ម ធ្វើឲ្យថ្លៃលក់ទឹកមធ្យមរបស់ រ.ទ.ស.ភ កើនឡើងដោយសារតែថ្លៃប្រើប្រាស់ទឹករបស់អតិថិជនប្រភេទនេះ មានកម្រិតខ្ពស់ជាងអតិថិជនប្រភេទផ្សេងទៀត។
- **ការគ្រប់គ្រងលើការចំណាយប្រតិបត្តិការ៖** រ.ទ.ស.ភ ធ្វើការគ្រប់គ្រងលើការចំណាយនេះ ពិសេសការចំណាយលើការប្រើប្រាស់ថាមពលអគ្គិសនីដែលជាចំណាយដ៏ធំ និងសំខាន់ក្នុងដំណើរការផលិតទឹកស្អាត តាមរយៈការប្រើប្រាស់នូវ បច្ចេកវិទ្យាថ្មីៗ ដូចជាជ្រើសរើសយកការប្រើប្រាស់ម៉ាស៊ីនបូមទឹកដែលអាចប្រែប្រួលទៅតាមសំពាធទឹក ក៏ដូចជាការចាត់ចែងការប្រើប្រាស់នូវវត្ថុធាតុដើមក្នុងការផលិតទឹកប្រកបដោយប្រសិទ្ធភាព និងសន្សំសំចៃខ្ពស់។

ចំពោះការចំណាយដំណើរការសហគ្រាស រ.ទ.ស.ភ ក៏បានខិតខំកាត់បន្ថយនូវការចំណាយដែលមិនចាំបាច់ ដូចជាចំណាយរដ្ឋបាលទូទៅ ចំណាយលើការជួសជុលថែទាំទូទៅ ដែលអង្គភាពបានយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យ និងថែទាំឧបករណ៍បរិក្ខាប្រើប្រាស់ជាប្រចាំ ដើម្បីធានាបានគុណភាពប្រើប្រាស់ និងកាត់បន្ថយការចំណាយជួសជុលនានា។

# ផ្នែកទី៤: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ( ត )

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៦-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ (ត)

- **ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវដំណើរការកិច្ចលទ្ធកម្ម៖** រ.ទ.ស.ភ បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់បញ្ញត្តិ និងគោលការណ៍ណែនាំផ្សេងៗសម្រាប់ដំណើរការកិច្ចលទ្ធកម្មក្នុងការទិញសម្ភារ បរិក្ខារ និងវត្ថុធាតុដើម ដែលដំណើរការនេះឆ្លុះបញ្ចាំងឱ្យឃើញពី តម្លាភាព និងការប្រកួតប្រជែងថ្លៃទំនិញនៅលើទីផ្សារដែលជាហេតុធ្វើឲ្យ រ.ទ.ស.ភ ទទួលបានការទិញទំនិញមានតម្លៃសមរម្យ គុណភាពអាចទទួលយកបាន។

- **ការគ្រប់គ្រងសាច់ប្រាក់៖** តាមរយៈអត្រាទារប្រាក់ដែលមានកម្រិតខ្ពស់៩៩,៩០% បានធ្វើឲ្យ រ.ទ.ស.ភ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសាច់ប្រាក់ដោយទទួលបាននូវប្រសិទ្ធភាពខ្ពស់។ ក្នុងការគ្រប់គ្រង រ.ទ.ស.ភ បានរក្សាទុកនូវសាច់ប្រាក់សម្រាប់ប្រើប្រាស់ជាទុនបង្វិលក្នុងរយៈពេល ២ទៅ៣ខែ ឯសាច់ប្រាក់ដែលទំនេរពុំមានតម្រូវការប្រើប្រាស់ រ.ទ.ស.ភ បានធ្វើការវិនិយោគរយៈពេលខ្លី ដោយដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេលខ្លីនៅធនាគារពាណិជ្ជជាមួយនឹងការទទួលបាននូវអត្រាការប្រាក់ខ្ពស់ ប៉ុន្តែ រ.ទ.ស.ភ ក៏បានធ្វើការថ្លឹងថ្លែងពីហានិភ័យ និងផលចំណេញពីអត្រាការប្រាក់ខ្ពស់នេះផងដែរ។

- **ការជ្រើសរើសយកនូវអ្នកផ្តល់ហិរញ្ញប្បទានដែលផ្តល់អត្រាការប្រាក់ទាប៖** ដោយសារមានតម្រូវការប្រើប្រាស់ទឹកស្អាត កើនឡើងខ្ពស់ ធ្វើឲ្យ រ.ទ.ស.ភ មានតម្រូវការហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគដូចជាការ សាងសង់រោងចក្រផលិតទឹកស្អាត ការតបណ្តាញមេនាំទឹក និងបណ្តាញចែកចាយ។ រ.ទ.ស.ភ បានស្វែងរកដៃគូអភិវឌ្ឍអន្តរជាតិដូចជាទីភ្នាក់ងារបារាំង សម្រាប់អភិវឌ្ឍន៍(AFD) ដើម្បីទទួលបាននូវហិរញ្ញប្បទាន ដែលមានអត្រាការប្រាក់ទាប។

- **ស្ថានភាពសេដ្ឋកិច្ច៖** ទោះបីជាសង្គ្រាមរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន ក៏ដូចសង្គ្រាមរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន នៅតែបន្តអូសបន្លាយ បានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោក ក៏ដូចប្រទេសកម្ពុជា ក៏ថ្លៃលក់ទឹកមធ្យមរបស់ រ.ទ.ស.ភ ពុំមានការប៉ះពាល់ខ្លាំងឡើយ។

## ខ- កត្តាសំខាន់ដែលប៉ះពាល់លើប្រាក់ចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ដោយយោងទៅតាមការសិក្សា នៃតម្រូវការប្រើប្រាស់ទឹកធៀបទៅនឹងកំណើនប្រជាជន នៅក្នុងរាជធានីភ្នំពេញដោយសារការពង្រីកតំបន់ជុំវិញរាជធានីភ្នំពេញ រ.ទ.ស.ភ បានធ្វើការសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងដំហាន១ ដែលមានសមត្ថភាពផលិត ១៩៥.០០០ម³/ថ្ងៃ និងបានប្រកាសដាក់ឱ្យដំណើរការកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ និងកំពុងបន្តសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងដំហាន២ ដែលមានសមត្ថភាពផលិត ១៩៥.០០០ម³/ថ្ងៃ ដូចគ្នាដែលគ្រោងនឹងដាក់ឱ្យដំណើរការនៅដើមឆ្នាំ២០២៤ និងរោងចក្រផលិតទឹកស្អាតបឹងធំ ដែលមានសមត្ថភាពផលិត ៥.០០០ម³/ថ្ងៃ គ្រោងដាក់ឱ្យដំណើរការពាក់កណ្តាលឆ្នាំ២០២៤ ផងដែរ ដើម្បីបំពេញតម្រូវការទឹកស្អាតនាបច្ចុប្បន្ន និងពេលអនាគត។

### ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការប្រែប្រួលនៃថ្លៃវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត អាចប៉ះពាល់ដល់ថ្លៃដើមផលិត ប៉ុន្តែមិនមានផលប៉ះពាល់ធ្ងន់ធ្ងរនោះទេ ដោយសារការចំណាយនេះមានអត្រាមិនលើសពី១០% នៃចំណាយប្រតិបត្តិការ។ ទោះជាយ៉ាងណា ក៏ដោយ រ.ទ.ស.ភ ក៏បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាថ្លៃវត្ថុធាតុដើមសមស្របទៅតាមតម្លៃលើទីផ្សារ ជាក់ស្តែង ហើយនីតិវិធីនេះ ក៏ផ្តល់លទ្ធភាពសម្រាប់ រ.ទ.ស.ភ ទទួលបាននូវតម្លៃប្រកួតប្រជែងដែលមានតម្លៃទាប។

### ៣- ការវិភាគលើពន្ធ

រ.ទ.ស.ភ. ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ រ.ទ.ស.ភ មានកាតព្វកិច្ច ត្រូវបង់ពន្ធអាករទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ រ.ទ.ស.ភ មានកាតព្វកិច្ចបង់ពន្ធអាករ ទៅតាមរបបស្វ័យប្រកាស និង ជាសហគ្រាសជាប់ពន្ធធំ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

### ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ នេះ គណៈគ្រប់គ្រងយល់ថា រ.ទ.ស.ភ ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ រ.ទ.ស.ភ គឺចំណូលពីការលក់ (ចំណូលលក់ទឹក និងភ្ជាប់បណ្តាញ) ដែលជាតម្រូវការចាំបាច់របស់ប្រជាជននៅក្នុងរាជធានីភ្នំពេញ។ ចំណូលនេះបានចូលរួមចំណែកប្រមាណ ៨៩,១៨% នៃចំណូលសរុបនៅក្នុងឆ្នាំ២០២៣ ហើយ រ.ទ.ស.ភ ក៏ជាអ្នកផ្គត់ផ្គង់ផ្តាច់មុខនៅក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ។ ប្រាក់ចំណូលនេះអាចមានការកើនឡើង អាស្រ័យទៅតាមកំណើននៃចំនួនប្រជាពលរដ្ឋដែលរស់នៅ ក្នុងរាជធានីភ្នំពេញ និងតំបន់ទីក្រុងតាខ្មៅផងដែរ។

## ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

### ឃ.១- ផលប៉ះពាល់នៃអត្រាប្តូរប្រាក់

រ.ទ.ស.ភ បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ"ប្រាក់រៀល"។ប្រតិបត្តិការជារូបិយប័ណ្ណបរទេសត្រូវបានប្តូរទៅជារូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះការប្តូរទ្រព្យសកម្ម និងបំណុលរូបិយប័ណ្ណបរទេសត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិត។ ចំពោះការទូទាត់ទំនិញរបស់ រ.ទ.ស.ភ ភាគច្រើនធ្វើឡើងដោយប្រាក់រៀល ដូចនេះពុំមានផលប៉ះពាល់ខ្លាំងដោយអត្រាប្តូរប្រាក់នោះទេ។

### ឃ.២- ផលប៉ះពាល់នៃអត្រាការប្រាក់

#### ឃ.២.១- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណូលការប្រាក់

ដោយសារនៅប្រទេសកម្ពុជាពុំមានទីផ្សាររូបិយប័ណ្ណ ដូច្នេះ រ.ទ.ស.ភ មានលទ្ធភាពត្រឹមតែវិនិយោគរយៈពេលខ្លី លើការដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេល ៣ខែ ទៅ៩ខែ ទៅ១២ខែ នៅធនាគារពាណិជ្ជក្នុងស្រុកតែប៉ុណ្ណោះ។

#### ឃ.២.២- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណាយការប្រាក់

រ.ទ.ស.ភ មានប្រភពហិរញ្ញប្បទានពីរ ដែលមានអត្រាការប្រាក់ថេរ និងប្រែប្រួល។ ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ ថេរមាន ហិរញ្ញប្បទានដែលទទួលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានកម្រិតអត្រា១,៦៥% និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA)មានកម្រិតអត្រា០,៦៦% ក្នុងមួយឆ្នាំ។ ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ប្រែប្រួលមាន ហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD) នៅអត្រា EURIBOR ៦ខែ ដក១,៣៥ពិន្ទុ។ តែអត្រានេះមិនឲ្យទាបជាង០,២៥% និងមិនខ្ពស់ជាង៥,២១% ក្នុងឆ្នាំនោះទេ។

### ឃ.៣- ផលប៉ះពាល់នៃថ្លៃទំនិញ

តាមរយៈដំណើរការកិច្ចលទ្ធកម្មរបស់ រ.ទ.ស.ភ ដែលអនុលោមទៅតាមច្បាប់ និង បញ្ញត្តិជាធរមាន រួមផ្សំនឹងគោលការណ៍ណែនាំផ្សេងៗ ដែលតម្រូវឲ្យ រ.ទ.ស.ភ ធ្វើកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់សម្ភារ និង វត្ថុធាតុដើមទៅតាមតម្លៃប្រកួតប្រជែងឬតម្លៃថោររួច។ ការអូសបន្លាយនៃសង្គ្រាមរវាងប្រទេសរុស្សីនិងអ៊ុយក្រែន និងសង្គ្រាមរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីនបានធ្វើអោយតម្លៃសម្ភារ និងវត្ថុធាតុដើមនៅលើទីផ្សារក្នុងស្រុក និងក្រៅស្រុកមានការកើនឡើង។ ការកើនឡើងនៃតម្លៃសម្ភារ និងវត្ថុធាតុដើម ក៏បានជះឥទ្ធិពលដល់ចំណាយវិនិយោគ និងចំណាយដំណើរការរបស់ រ.ទ.ស.ភ ផងដែរ។ ប៉ុន្តែទោះបីជាការកើនឡើងនៃតម្លៃសម្ភារ និងវត្ថុធាតុដើមដូចនេះក្តីក៏គណៈគ្រប់គ្រងបានគិតគូរយ៉ាងហ្មត់ចត់លើផែនការ និងតម្រូវការសម្ភារ បរិក្ខា វត្ថុធាតុដើម ដើម្បីធានាអោយការប្រើប្រាស់បានទាន់ពេល និងមានតម្លៃសមរម្យ ដោយអនុវត្តតាមច្បាប់លទ្ធកម្មសាធារណៈជាធរមាន។

## ង- ផលប៉ះពាល់នៃអតិផរណា

រ.ទ.ស.ភ បានរក្សានូវថ្លៃលក់ទឹកថេរមិនប្រែប្រួលចាប់តាំងពីឆ្នាំ២០០១ រហូតដល់ឆ្នាំ២០១៩។ ដើម្បីធ្វើការកែសម្រួលទៅ តាមការប្រែប្រួលនៃអតិផរណា យើងបានធ្វើការកែសម្រួលនូវថ្លៃលក់ទឹកស្អាតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់បច្ចុប្បន្ន ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល

ធុរកិច្ចរបស់ រ.ទ.ស.ភ ទទួលការជះឥទ្ធិពលពីគោលនយោបាយមួយចំនួន ដែលកំណត់ដោយរាជរដ្ឋាភិបាលដូចជា៖

- **ការពង្រីកផ្ទៃសេវា៖** ការពង្រីកផ្ទៃសេវាបន្ថែមដើម្បីផ្គត់ផ្គង់ទឹកស្អាត ត្រូវបានរឹតត្បិតដោយបេសកកម្មរបស់ រ.ទ.ស.ភ ដែលអនុញ្ញាតឲ្យផលិត និងចែកចាយទឹកសម្រាប់ការប្រើប្រាស់របស់សាធារណជននៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ការរឹតត្បិតនេះត្រូវបានកំណត់ដោយអនុក្រឹត្យលេខ៥២អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើត រ.ទ.ស.ភ។
- **ការពង្រីករាជធានីភ្នំពេញ៖**រាជរដ្ឋាភិបាលមានគោលនយោបាយពង្រីករាជធានីភ្នំពេញ ដោយបញ្ចូលឃុំ បន្ថែមចំនួន២០ឃុំ ទៀត ទៅក្នុងតំបន់រាជធានីភ្នំពេញដែលធ្វើឲ្យផ្ទៃសេវារបស់ រ.ទ.ស.ភ ក្នុងការផ្គត់ផ្គង់ទឹកស្អាតក៏ត្រូវពង្រីកបន្ថែមដែរ។
- **គោលនយោបាយពន្ធលើអចលនទ្រព្យ៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្តនូវប្រកាសលេខ ៤៩៣សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពី "ការប្រមូលពន្ធលើអចលនទ្រព្យ" ។ អចលនទ្រព្យរបស់ រ.ទ.ស.ភ គឺសម្រាប់បម្រើឱ្យប្រព័ន្ធផលិតកម្មទឹកស្អាត ដែលអចលនទ្រព្យប្រភេទនេះ ត្រូវបានលើកលែងពន្ធតាមរយៈសេចក្តីជូនដំណឹងលេខ០០៦សហវ. អពដ. ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ផ្នែកទី៩: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

រ.ទ.ស.ភ បាន និងកំពុង ខិតខំប្រឹងប្រែងផលិតទឹកស្អាតប្រកបដោយគុណភាព និងមានសុវត្ថិភាពជូនប្រជាពលរដ្ឋដែលប្រើប្រាស់ទឹកស្អាតរបស់ រ.ទ.ស.ភ។ ដើម្បីទទួលបានទំនុកចិត្តបន្ថែមពីប្រជាពលរដ្ឋ ដែលជាអតិថិជនរបស់ខ្លួន នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ រ.ទ.ស.ភ បានបញ្ជូនទឹកគំរូសាកដែលចេញពី *បណ្តាញចែកចាយក្នុងតំបន់ស្ទឹងមានជ័យ* ក្នុងរាជធានីភ្នំពេញ ទៅពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ឯករាជ្យ TUV SUD PSB Pts Ltd. នៃប្រទេសសឹង្ហបុរី ដែលមានមុខវិភាគចំនួន **១២៥មុខ** ដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ប៉ារ៉ាម៉ែត្រមីក្រូជីវសាស្ត្រ | (Microbiological Parameter) | ចំនួន | ១ មុខ |
| ២. | ប៉ារ៉ាម៉ែត្រលក្ខណៈរូប | (Physical Parameters) | ចំនួន | ៦ មុខ |
| ៣. | ប៉ារ៉ាម៉ែត្រវិទ្យុសកម្ម | (Radiological Parameters) | ចំនួន | ២ មុខ |
| ៤. | ប៉ារ៉ាម៉ែត្រលក្ខណៈគីមី | (Chemical Parameters) | ចំនួន | ១១៦ មុខ |

ជាលទ្ធផល ទឹកស្អាតដែលផលិតពី*បណ្តាញចែកចាយក្នុងតំបន់ស្ទឹងមានជ័យ* ក្នុងរាជធានីភ្នំពេញ របស់ រ.ទ.ស.ភ គឺបានអនុលោមទៅតាមស្តង់ដារទឹកផឹកថ្នាក់ជាតិ និងស្តង់ដាររបស់ អង្គការសុខភាពពិភពលោក សម្រាប់គុណភាពទឹកផឹក (1$^{st}$ Addendum to 4$^{th}$ Edition 2017 ) ដូចមានបង្ហាញលទ្ធផលលម្អិតទាំងស្រុងនៅក្នុងឧបសម្ព័ន្ធ TEST REPORT: 7191321955-CHM23-NHT ។

# ហត្ថលេខាអភិបាល
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ថ្ងៃ ចន្ទ ១រោច ខែផល្គុន ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ស៊ឹម ស៊ីថា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃ ចន្ទ ១រោច ខែផល្គុន ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ឡុង ណារ៉ូ**
អភិបាល

ថ្ងៃ ចន្ទ ១រោច ខែផល្គុន ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ម៉ី វ៉ាន់**
អភិបាល

ថ្ងៃ ចន្ទ ១រោច ខែផល្គុន ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ទួន ផារ័ត្ន**
អភិបាល

ថ្ងៃ ចន្ទ ១រោច ខែផល្គុន ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ម៉ា ណូរ៉ាវីន**
អភិបាល

ថ្ងៃ ចន្ទ ១រោច ខែផល្គុន ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ណាំ ចន្ទ្រី**
អភិបាល

ថ្ងៃ ចន្ទ ១រោច ខែផល្គុន ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ស្រេង សំឱក**
អភិបាល

# ឧបសម្ព័ន្ធ ១

## របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ២០២៣

# មាតិកា


ផ្នែកទី១: ភាគហ៊ុនិក ១

ក- រចនាសម្ព័ន្ធភាគហ៊ុនិក ១

ខ- សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក ២

គ- មហាសន្និបាតភាគហ៊ុនិក ២

ឃ- ការបែងចែកភាគលាភ ៣

ផ្នែកទី២: ក្រុមប្រឹក្សាភិបាល ៥

ក- ក្រុមប្រឹក្សាភិបាល ៥

ខ- គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ១០

គ- លាភការ ឬប្រាក់បំណាច់ ១២

ឃ- ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល ១២

ង- ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ១៣

ផ្នែកទី៣: ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច ១៥

ក- គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ១៥

ខ- ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ដោយនិយោជិត (Whistle Blower) ១៨

គ- យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច ១៨

ឃ- ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ១៨

ផ្នែកទី៤: ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម ១៩

ក- សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ ១៩

ខ- សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ១៩

គ- ការធ្វើសវនកម្ម ២០

ផ្នែកទី៥: ភាគីពាក់ព័ន្ធ ២១

ក- បង្ហាញពីគោលនយោបាយ និងសកម្មភាព ២១

ខ- ពិពណ៌នាអំពីទំនួលខុសត្រូវសង្គមរបស់ រ.ទ.ស.ភ ២៤

ផ្នែកទី៦: ការបង្ហាញព័ត៌មាន និងតម្លាភាព ២៧

ក- ការបង្ហាញព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំ ២៧

ខ- យន្តការនៃការបង្ហាញព័ត៌មាន មធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលព័ត៌មាន ២៧

គ- ទំនាក់ទំនងជាមួយវិនិយោគិន ២៨

# ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ២០២៣
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
# របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

## ផ្នែកទី១. ភាគហ៊ុនិក

### ក- របនាសម្ព័ន្ធភាគហ៊ុនិក(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣)

### ១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៣.៩០៦ | ៤.៨២៣.៧៤០ | ៥,៥៤៦% |
| | | នីតិបុគ្គល | ៦ | ២.៥៣៥.៨៦២ | ២,៩១៦% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៥៩៨ | ៥.២៣៣.០៣២ | ៦,០១៧% |
| | | នីតិបុគ្គល | ៦ | ៤៥៣.៣៤១ | ០,៥២១% |
| ចាប់ពី៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ៧៣.៩២៧.១៨៧ | ៨៥% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

### ២. ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត រ.ទ.ស.ភ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ២ | ២០.២១៦ | ០,០២៣% |
| បុគ្គលិកជាន់ខ្ពស់ | ២០ | ១២៥.៩០០ | ០,១៤៥% |
| និយោជិត | ៣៨៣ | ៧០៧.៩០៦ | ០,៨១៤% |
| សរុប | ៤០៥ | ៨៥៤.០២២ | ០,៩៨២% |

# ផ្នែកទី១. ភាគហ៊ុនិក ( ត )

## ខ- សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាហ៊ុនិក

### ១. សិទ្ធិរបស់ភាគហ៊ុនិក

ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ មានសិទ្ធិស្មើៗគ្នា ដែលសិទ្ធិទាំងនោះរួមមាន៖

- សិទ្ធិទទួលបានព័ត៌មានដែលផ្តល់ដោយ រ.ទ.ស.ភ ស្របតាមច្បាប់ និងបញ្ញតិជាធរមាន។
- សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិករបស់ រ.ទ.ស.ភ ដោយត្រូវអនុវត្តតាមសេចក្តីណែនាំសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក ដោយត្រូវអនុវត្តតាមសេចក្តីណែនាំសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិទទួលភាគលាភ ដែលប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ តាមសមាមាត្រភាគហ៊ុនដែលខ្លួនកាន់កាប់។
- សិទ្ធិក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ រ.ទ.ស.ភ នៅពេលមានការរំលាយតាមសមាមាត្រភាគហ៊ុន។
- សិទ្ធិផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងបញ្ញតិជាធរមាន។

### ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្តក្នុងឆ្នាំ២០២៣

សិទ្ធិរបស់ភាគហ៊ុនិករបស់ រ.ទ.ស.ភ ត្រូវបានការពារដោយលក្ខន្តិកៈរបស់ រ.ទ.ស.ភ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ និងតាមរយៈការបង្កើតឱ្យមាននូវ ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

ក្នុងឆ្នាំ២០២៣ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី១១ ដែលប្រព្រឹត្តិទៅកាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ដែលភាគហ៊ុនិកទាំងអស់ ទទួលបានព័ត៌មានស្មើគ្នា មានសិទ្ធិចូលរួមស្មើគ្នា ដោយគោរពតាមនីតិវិធី នៃការចូលរួមមហាសន្និបាតភាគហ៊ុនិក របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងធ្វើការបោះឆ្នោតលើរបៀបវារៈ ដែលបានលើកឡើង។

ទន្ទឹមនេះដែរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក៏បានធ្វើការបែងចែកភាគលាភប្រចាំឆ្នាំ២០២២ ជូនដល់ភាគហ៊ុនិករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយធ្វើការទូទាត់នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ កន្លងមក។

### ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្តក្នុងឆ្នាំ២០២៣

ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិចរបស់ រ.ទ.ស.ភ ទទួលបានស្មើគ្នានូវការការពារ និងការអនុវត្តដូចទៅនឹងភាគហ៊ុនិកដទៃដូចបានរៀបរាប់ខាងលើ ដោយពុំមានការរិតត្បិតសិទ្ធិណាមួយទេ។

## គ- មហាសន្និបាតភាគហ៊ុនិក

### ១. និតិវិធីនៃការរៀបចំសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

ការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោតត្រូវបានអនុវត្តទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។

# ផ្នែកទី១. ភាគហ៊ុនិក (ត)

## គ- មហាសន្និបាតភាគហ៊ុនិក (ត)

### ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិកលើកទី១១

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|---|
| ១ | ២៦ ឧសភា ២០២៣ | សាមញ្ញ | ១៨០នាក់ (៧៥.៧៦៦.៤៤៨ ភាគហ៊ុន) ស្មើនឹង៩៩,៦៥% | ១.របាយការណ៍លទ្ធផលអាជីវកម្មឆ្នាំ២០២២ និងទិសដៅអាជីវកម្មឆ្នាំ២០២៣<br>២.សំនួរ-ចម្លើយ<br>៣.កម្មវិធីបោះឆ្នោតអនុម័តលើ៖<br>➢ ការបោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២២<br>➢ ការអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល ឆ្នាំ២០២៣ | លទ្ធផលនៃការបោះឆ្នោត៖<br>➢ ឯកភាពបែងចែកភាគលាភឆ្នាំ២០២២ ដែលបានមកពីប្រាក់ចំណេញឆ្នាំ២០២២ គិតជាសាច់ប្រាក់ចំនួន ២៨.៧០១.១៤៣.៤៦០រៀល៖<br>▪ ចំនួន ៣៣០ រៀលក្នុង១ភាគហ៊ុន<br>▪ កាលបរិច្ឆេទកំណត់ទុក:ថ្ងៃទី៩ខែមិថុនា ឆ្នាំ២០២៣<br>▪ កាលបរិច្ឆេទទូទាត់: ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ខែមិថុនា ឆ្នាំ២០២៣<br>➢ ឯកភាពលើលាភការរបស់ក្រុមប្រឹក្សាភិបាល ៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋ ១រូប សម្រាប់ឆ្នាំ ២០២៣ ដែលមានទឹកប្រាក់សរុបចំនួន ១.១០៧.៩៧៩.០០០រៀល។ |

## ឃ- ការបែងចែកភាគលាភ

### ១- គោលនយោបាយបែងចែកភាគលាភ

ក្រោយពីបានអនុម័តលើគណនី បើពិនិត្យឃើញថាមានចំណេញ ក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ អាចសម្រេចផ្ទេរទឹកប្រាក់ទាំងនោះដើម្បី៖

១.១. ការទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅ

១.២. បន្ទាប់ពីបានទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅរួច ប្រសិនបើមានប្រាក់ចំណេញ នោះប្រាក់ចំណេញនេះត្រូវបែងចែកសម្រាប់៖

ក ថ្លៃងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិត តាមលក្ខខណ្ឌ៖

- ក្នុងករណីប្រាក់ចំណេញនៅសល់មានចំនួនពី ៥% ដល់ ១០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លៃងសរសើរត្រូវស្មើនឹងមួយខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ។
- ក្នុងករណីប្រាក់ចំណេញលើសពី ១០% ដល់ ២០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លៃងសរសើរត្រូវស្មើនឹងពីរខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និង និយោជិតម្នាក់ៗ។
- ក្នុងករណីប្រាក់ចំណេញលើសពី ២០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លៃងសរសើរត្រូវស្មើនឹងបីខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ។

ខ ចំនួន ២% សម្រាប់ប្រាក់សោធននិវត្ត និងអសមត្ថភាពវិជ្ជាជីវៈ។

គ បង្កើតភាគបម្រុងតាមច្បាប់ ៥%។

ឃ បង្កើតភាគបម្រុងសេរីចំនួន ៥%។

ង មូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម ដែលត្រូវកត់ត្រាចូលក្នុងបន្ទុកក្នុងឆ្នាំដែលធ្វើប្រតិបត្តិការចំណាយនោះ។

# ផ្នែកទី១. ភាគហ៊ុនិក (ត)

## ឃ- ការបែងចែកភាគលាភ (ត)

### ១- គោលនយោបាយបែងចែកភាគលាភ (ត)

១.៣. ចំនួនប្រាក់ដែលនៅសល់បន្ទាប់ពីការបែងចែកខាងលើនេះត្រូវ៖

ក ដកប្រាក់រក្សាទុកដើម្បីធ្វើការវិនិយោគនាពេលខាងមុខ ដែលចំនួននេះត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។

ខ ប្រាក់នៅសល់ក្រោយពីការរក្សាទុកសម្រាប់ធ្វើការវិនិយោគត្រូវធ្វើការបែងចែក ៨៥% ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ១៥% ទៅភាគហ៊ុនិកដែលជាវិនិយោគិនសាធារណៈ។

### ២. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ

| ល.រ | ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០២២ | ២០២១ | ២០២០ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ | ២៦ ឧសភា ២០២៣ | ១៣ ឧសភា ២០២២ | ២៦ មីនា ២០២១ |
| ២ | កាលបរិច្ឆេទកំណត់ទុក | ០៩ មិថុនា ២០២៣ | ៣០ ឧសភា ២០២២ | ២១ មេសា ២០២១ |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | ២០ មិថុនា ២០២៣ | ០៨ មិថុនា ២០២២ | ០១ មិថុនា ២០២១ |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល

## ក. ក្រុមប្រឹក្សាភិបាល

### ១. សមាសភាពក្រុមភិបាល

| ល.រ. | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯកឧត្តម ស៊ឹម ស៊ីថា | ប្រធានក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ២ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៣ | ឯកឧត្តម ឡុង ណារ៉ូ | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៤ | ឯកឧត្តម នួន ផារ័ត្ន | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៥ | លោក ម៉ា ណូរ៉ាវីន | សមាជិកក្រុមប្រឹក្សាភិបាល | ២៧/០២/២០២៣ | ២៧/០២/២០២៦ |
| ៦ | លោក ស្រេង សំឌិក | អភិបាលឯករាជ្យ | ១៣/០៥/២០២២ | ១៣/០៥/២០២៥ |
| ៧ | លោក ណាំ ចន្រ្ទី | អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន | ១៣/០៥/២០២២ | ១៣/០៥/២០២៥ |

- ឈ្មោះលេខាធិការសហគ្រាសរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញៈ
    - **លោក ជុ ផល្លា**
    - **លោក ហួត សុខហេង**

### ២. ជីវប្រវត្តិរូបសង្ខេបរបស់អភិបាលនីមួយៗ

#### - ជីវប្រវត្តិរូបសង្ខេបរបស់ឯកឧត្តម ស៊ឹម ស៊ីថា

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៦១ និងបានទទួលជាវិស្វករសំណង់ស៊ីវិលឧស្សាហកម្ម នៅវិទ្យាស្ថានជាន់ខ្ពស់មិត្តភាពកម្ពុជា-សូវៀត (រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា) ក្នុងឆ្នាំ១៩៨៩។ ឯកឧត្តមបានទទួលបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម នៅសកលវិទ្យាល័យគ្រប់គ្រប់សេដ្ឋកិច្ច ខេត្តព្រះសីហនុ នៃព្រះរាជាណាចកម្ពុជានៅ ឆ្នាំ២០០៧។ ក្នុងឆ្នាំ២០១៤ ឯកឧត្តមបានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតដោយជោគជ័យ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសកលវិទ្យាល័យ អាស៊ីអ៊ឺរ៉ុប រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៣ ឯកឧត្តមជាអនុប្រធានអង្គភាពរដ្ឋាករទឹកខេត្តព្រះសីហនុ។ ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០១២ ឯកឧត្តមមានតួនាទីជាប្រធានអង្គភាពរដ្ឋាករទឹកខេត្តព្រះសីហនុ។ ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០២១ ឯកឧត្តមជាអគ្គនាយក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ អាណត្តិទី៥។ ចាប់ពីឆ្នាំ២០២១ **ឯកឧត្តម ស៊ឹម ស៊ីថា** ត្រូវបានតែងតាំងជា រដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ព្រមទាំងបានទទួលការតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលអាណត្តិទី៨ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ រហូតដល់បច្ចុប្បន្ន។ នៅក្នុងឆ្នាំ២០២៣នេះដែរ ក្នុងខែសីហា ឯកឧត្តម ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល រដ្ឋាករទឹកស្វាយរៀង អាណត្តិទី១ និងក្នុងខែវិច្ឆិកា ឯកឧត្តម ត្រូវបានតែងតាំងជាសមាជិកនៃ គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

#### - ជីវប្រវត្តិសង្ខេបរបស់ឯកឧត្តម ម៉ី វ៉ាន់

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៦៩ និងបានទទួលអនុបណ្ឌិតគោលនយោបាយសេដ្ឋកិច្ចនៃសកលវិទ្យាល័យ D'AUVERGNE ប្រទេសបារាំងនៅឆ្នាំ១៩៩៩។ ឯកឧត្តមបានទទួលបណ្ឌិតសេដ្ឋកិច្ចពាណិជ្ជកម្មនៃសកលវិទ្យាល័យ PRESTON សហរដ្ឋអាមេរិក នៅឆ្នាំ២០០៩។ ចាប់ពីឆ្នាំ២០១៣ ឯកឧត្តមបានបម្រើការងារឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សហកម្មហិរញ្ញវត្ថុ និងឆ្នាំ២០១៧ ឯកឧត្តមត្រូវបានតែងតាំងជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឋានៈស្មើអនុរដ្ឋលេខាធិការ។ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ ឯកឧត្តម បានក្លាយជាទីប្រឹក្សា នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើរដ្ឋលេខាធិការ។ ចាប់ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន ឯកឧត្តមត្រូវបានតែងតាំងជារដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ **ឯកឧត្តម ម៉ី វ៉ាន់** ចូលជាសមាជិក ក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ក. ក្រុមប្រឹក្សាភិបាល (ត)

## ២. ជីវប្រវត្តិរូបសង្ខេបរបស់អភិបាលនីមួយៗ (ត)

### - ជីវប្រវត្តិសង្ខេបរបស់ឯកឧត្តម ឡុង ណារ៉ូ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៦។ ឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៨៨ សិក្សានៅសាលា Engineering School for Plant and Construction " Georgi Dimitroff " Glauchau (East Germany) ដោយទទួលបានសញ្ញាបត្រវិស្វករយន្តសាស្ត្រ។ នៅឆ្នាំ២០០៤ ទទួលបានអនុបណ្ឌិតរដ្ឋបាល ពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Charles Sturt University (Australia University)។ **ឯកឧត្តម ឡុង ណារ៉ូ** បានចូលបម្រើការងារនៅ រ.ទ.ស.ភ នៅឆ្នាំ១៩៨៩ និង ទទួលបានការតែងតាំងជាប្រធាននាយកដ្ឋានបច្ចេកទេស ផលិតកម្ម និងផ្គត់ផ្គង់ទឹកនៅឆ្នាំ១៩៩៧។ ចាប់ពីឆ្នាំ២០០២ ដល់ ឆ្នាំ២០០៦ ជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានបច្ចេកទេស និង ផលិតកម្ម និងផ្គត់ផ្គង់ទឹក។ ពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០១២ ជាអគ្គនាយករងទទួលបន្ទុកត្រួតពិនិត្យ និងគ្រប់គ្រងគម្រោងសាង់សង់រោងចក្រផលិតទឹកស្អាត ជ្រោយចង្វារ និងនិរោធ។ ឆ្នាំ២០១២ ដល់ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ជាអគ្គនាយករងទទួលបន្ទុកសាខាសេវាកម្ម ទឹកស្អាត និងអនាម័យ និងចាប់ពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ដល់បច្ចុប្បន្ន ជាអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ព្រមទាំងបានតែងតាំង និងផ្តល់ឋានៈជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពី **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ ដល់បច្ចុប្បន្ន។

### - ជីវប្រវត្តិសង្ខេបរបស់ឯកឧត្តម នួន ផារ័ត្ន

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨០ និងបានទទួលបរិញ្ញាបត្រច្បាប់ផ្នែកសាធារណៈ និង ផ្នែកឯកជន នៅឆ្នាំ២០០១ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ នៅ Jean Moulin Lyon3 ឯកឧត្តមបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ វិជ្ជាជីវៈតុលាការ និងវិទ្យាសាស្ត្រព្រហ្មទណ្ឌ និងបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ នៅឆ្នាំ២០០៣។ ឆ្នាំ២០០៣ ដល់ឆ្នាំ២០០៥ ឯកឧត្តមជាជំនួយការនាយិការនៅសាលាភូមិន្ទចៅក្រម។ ឆ្នាំ២០០៥ ដល់ ២០០៦ ឯកឧត្តម ជាមន្ត្រីទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ នៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។ ឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ ឯកឧត្តមជាសាស្ត្រាចារ្យច្បាប់នៅចំនួនបីសកលវិទ្យាល័យ។ ឆ្នាំ២០០៨ ដល់ឆ្នាំ២០១៥ ឯកឧត្តម ជាប្រធានក្រុមអ្នកច្បាប់ នៃការិយាល័យចៅក្រមស៊ើបអង្កេត នៅអង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ឆ្នាំ២០០៧ ដល់បច្ចុប្បន្ន ឯកឧត្តមជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ ចាប់ពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៧ មកដល់បច្ចុប្បន្ន ឯកឧត្តមជាអភិបាលរងនៃសាលារាជធានីភ្នំពេញ។ **ឯកឧត្តម នួន ផារ័ត្ន** ចូលជាសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៦ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ រហូតដល់បច្ចុប្បន្ន។

### - ជីវប្រវត្តិសង្ខេបរបស់លោក ម៉ា ណូរ៉ាវីន

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៣។ នៅឆ្នាំ១៩៩៦ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រលើជំនាញផ្នែកវារីសាស្ត្រនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ បន្ទាប់មក នៅឆ្នាំ២០០៨ លោកទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតជំនាញ Socio-Environmental Engineering នៅប្រទេសជប៉ុន។ លោកចូលបម្រើការនៅ រ.ទ.ស.ភ នៅឆ្នាំ១៩៩៧ និងទទួលការតែងតាំងជាប្រធានការិយាល័យសិក្សាគម្រោង នាឆ្នាំ២០០៣។ នៅឆ្នាំ២០០៨ បានទទួលការតែងតាំងជាអនុប្រធាននាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក និងពីឆ្នាំ២០១២ ដល់ ឆ្នាំ២០១៨ ជាប្រធាននាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក។ ឆ្នាំ២០១៨ ដល់បច្ចុប្បន្នជាអគ្គនាយករងទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធផលិតកម្ម។ លោក ម៉ា ណូរ៉ាវីន បានចូលជា សមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី៧ នៃ រ.ទ.ស.ភ ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ក. ក្រុមប្រឹក្សាភិបាល (ត)

## ២. ជីវប្រវត្តិរូបសង្ខេបរបស់អភិបាលនីមួយៗ (ត)

### - ជីវប្រវត្តិសង្ខេបរបស់លោក ស្រេង សំឌិក

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៦២ ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែក គ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិពី West Coast University នៃរដ្ឋកាលីហ្វ័រញ៉ា ក្នុងឆ្នាំ១៩៩៤ និងបរិញ្ញាបត្រ វិទ្យាសាស្ត្រផ្នែកវិស្វកម្មអគ្គិសនី California State University of Long Beach ក្នុងឆ្នាំ១៩៨៨ នៃសហរដ្ឋ អាមេរិក។ លោក ស្រេង សំឌិក បានចាប់ផ្តើមការងារនៅក្រុមហ៊ុនភេសជ្ជៈកូកាកូឡា ជាប្រធានផ្នែកលក់ប្រចាំប្រទេស ឆ្នាំ១៩៩៥ ដល់ឆ្នាំ២០០២។ ក្នុងឆ្នាំ២០០២ លោកបានក្លាយជាមន្ត្រីវិនិយោគ នៃគម្រោង MPDF របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។ ឆ្នាំ២០០៣ លោកបានចាប់ផ្តើមការងារនៅ ធនាគារអេអិនហ្ស៊ិត រ៉ូយ៉ាល់ ជានាយគ្រប់គ្រងជាន់ខ្ពស់។ ឆ្នាំ២០១០ ដល់២០១១ លោកមានតួនាទីជានាយកពាណិជ្ជកម្ម នៃអាកាសយានស្ថានកម្ពុជា (ភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ)។ ឆ្នាំ២០១២ ដល់ឆ្នាំ២០១៦ លោកមានតួនាទីជានាយកគ្រប់គ្រងបណ្តាញសាខា នៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា។ ឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ លោក បានក្លាយអភិបាលឯករាជ្យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ភីអិលស៊ី ហើយបានក្លាយជាប្រធានគណៈកម្មការសវនកម្ម ក្នុងអំឡុងឆ្នាំ២០១៦ ដល់ឆ្នាំ២០២០។ ចាប់ពីឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន លោកជាទីប្រឹក្សាធុរកិច្ច របស់ក្រុមហ៊ុន អែកស៊ីស អិនវែសមេន ខនសាល់ធីង។ ចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ លោកក៏បានក្លាយជាអភិបាលឯករាជ្យ សមាជិកក្រុមប្រឹក្សាភិបាលនៃ វ.ទ.ស.ភ ។

### - ជីវប្រវត្តិសង្ខេបរបស់លោក ណាំ ចន្ទ្រី

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៨៦ ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រង អាជីវកម្មឯកទេសគ្រប់គ្រងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុង ឆ្នាំ ២០១៣។ នៅឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ លោក ណាំ ចន្ទ្រី បានបម្រើការងារជាប្រធានគណនេយ្យ និងហិរញ្ញវត្ថុសម្រាប់គម្រោងទឹកស្អាត និងអនាម័យ នៅកាកបាទក្រហមកម្ពុជា សហការជាមួយកាកបាទក្រហមស្វិស។ ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៥ លោកបានក្លាយជាទីប្រឹក្សាហិរញ្ញវត្ថុ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់គម្រោងមូលនិធិសកល (Global Fund) និងអង្គការ MAGNA Children at Risk ។ ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ លោកជាទីប្រឹក្សាហិរញ្ញវត្ថុ នៅគម្រោងអភិវឌ្ឍកសិកម្ម និងជម្រុញកំណើនសេដ្ឋកិច្ច នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ លោកជាប្រធានរដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ និងពន្ធ នៅក្រុមហ៊ុន KC JSM Service Co Ltd ជាគម្រោងអភិវឌ្ឍន៍ និងវិនិយោគអចលនទ្រព្យ។ រហូតមកដល់ពេលបច្ចុប្បន្ន លោក ណាំ ចន្ទ្រី បម្រើការជាប្រធានហិរញ្ញវត្ថុ នៅក្រុមហ៊ុន AXS Ventures Co Ltd និងជាភ្នាក់ងារគ្រប់គ្រងមូលនិធិឯកជន នៅក្រុមហ៊ុន អូបរ មេនេចម៉ិន ឯ.ក ចាប់ពីឆ្នាំ២០១៩, ជានាយកប្រតិបត្តិនៃក្រុមហ៊ុន ព្រីនស៍ លេប័រ ប្ស៊ូ ចាប់ពីឆ្នាំ២០២២, ជាសហស្ថាបនិក និងជានាយកប្រតិបត្តិនៃក្រុមហ៊ុន ADMIT GROUP ចាប់ពីឆ្នាំ២០២៣នេះ, និងក្លាយជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សមាជិកក្រុមប្រឹក្សាភិបាលនៃ វ.ទ.ស.ភ ចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

## ៣. ករណីអភិបាលណាម្នាក់ជាអភិបាលជាភាគហ៊ុនិក ឬសហកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សេងទៀត

| ល.រ | ឈ្មោះអភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | ឯកឧត្តម ស៊ឹម ស៊ីថា | រដ្ឋាករទឹកស្វាយរៀង | ប្រធានក្រុមប្រឹក្សាភិបាល |
| ២ | លោក ស្រេង សំឌិក | សាជីវកម្មធានាឥណទានកម្ពុជា | អភិបាលឯករាជ្យ |
| ៣ | លោក ណាំ ចន្ទ្រី | ១. ADMIT GROUP | អភិបាល និងជាសហកម្មសិទ្ធិករ |
| | | ២. ក្រុមហ៊ុន ព្រីនស៍ លេប័រ ប្ស៊ូ | អភិបាល និងកម្មសិទ្ធិករ |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ក. ក្រុមប្រឹក្សាភិបាល (ត)

### ៤. តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

- កំណត់គម្រោងអភិវឌ្ឍន៍សហគ្រាស ដោយអនុលោមតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល យោងតាមសំណើរបស់អគ្គនាយក
- កំណត់គម្រោងថវិកាប្រចាំឆ្នាំ និង កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបម្រុងសម្រាប់សម្រេច កម្មវិធីវិនិយោគ
- អនុម័តលើរបាយការណ៍គណនេយ្យ(របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលលម្អិត)
- កំណត់នូវរចនាសម្ព័ន្ធចាត់តាំងចំនួនក្របខ័ណ្ឌការបែងចែកមុខងារទូទៅ និង ប្រាក់បៀវត្សរ៍របស់និយោជិតតាមសំណើរបស់អគ្គនាយក
- អនុញ្ញាតឱ្យបើក ឬសម្រេចឱ្យបិទសកម្មភាពរបស់ការិយាល័យភ្នាក់ងារ ឬតំណាង
- អនុញ្ញាតឱ្យទិញអចលនទ្រព្យគ្រប់ប្រភេទ ដោយគោរពតាមប្រកាសលេខ៩៩៧ សហវ.ទរ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងលទ្ធកម្មនៅសហគ្រាសសាធារណៈ
- ជ្រើសរើសស្នងការគណនី និងកំណត់នូវលាភការជូនចំពោះស្នងការគណនី
- សម្រេចយល់ព្រមលើកិច្ចសន្យា ឬសន្ធិសញ្ញាផ្សេងៗ
- ធ្វើការពិនិត្យក្នុងចន្លោះពេលទៀតទាត់មួយ លើទិសដៅដែលបានកំណត់ឱ្យសហគ្រាស និងលើកឡើងនូវបណ្តាវិធានការកែសម្រួលលើកសំណើសុំកែប្រែលក្ខន្តិកៈ។

### ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ១៥ មីនា ២០២៣ | សាមញ្ញ | ▪ ឯកឧត្តម ស៊ឹម ស៊ីថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ាវីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ អម រ.ទ.ស.ភ) |
| ២ | ២៩ មីនា ២០២៣ | វិសាមញ្ញ | ▪ ឯកឧត្តម ស៊ឹម ស៊ីថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ាវីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ អម រ.ទ.ស.ភ) |

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ៣ | ២២ មិថុនា ២០២៣ | សាមញ្ញ | ▪ ឯកឧត្តម ស៊ឹម ស៊ីថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ារីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ អម រ.ទ.ស.ភ) |
| ៤ | ១៧ កក្កដា ២០២៣ | វិសាមញ្ញ | ▪ ឯកឧត្តម ស៊ឹម ស៊ីថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ារីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ អម រ.ទ.ស.ភ) |
| ៥ | ២២ កញ្ញា ២០២៣ | សាមញ្ញ | ▪ ឯកឧត្តម ស៊ឹម ស៊ីថា<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ារីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក |
| ៦ | ២៧ កញ្ញា ២០២៣ | វិសាមញ្ញ | ▪ ឯកឧត្តម ស៊ឹម ស៊ីថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ារីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ អម រ.ទ.ស.ភ) |
| ៧ | ២២/ធ្នូ/២០២៣ | សាមញ្ញ | ▪ ឯកឧត្តម ស៊ឹម ស៊ីថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ារីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ អម រ.ទ.ស.ភ) |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១- រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

#### ១-១ គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក ស្រេង សំឌិក | ប្រធានគណៈកម្មាធិការ - អភិបាលឯករាជ្យ | ២៨-មីនា-២០២៣ | ៤ | ៤ |
| ២ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកគណៈកម្មាធិការ - អភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២៨-មីនា-២០២៣ | ១ | |
| ៣ | លោក ណាំ ចន្ទ្រី | សមាជិកគណៈកម្មាធិការ -អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន | ២៨-មីនា-២០២៣ | ៤ | |
| ៤ | ឯកឧត្តម នេត មុន្នី | សមាជិកគណៈកម្មាធិការ - មន្ត្រីត្រួតពិនិត្យរដ្ឋអមរ.ទ.ស.ភ | ២៨-មីនា-២០២៣ | ២ | |
| ៥ | លោក ម៉ា ណូរ៉ាវីន | សមាជិកគណៈកម្មាធិការ - តំណាងនិយោជិត រ.ទ.ស.ភ | ២៨-មីនា-២០២៣ | ៤ | |

##### តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម៖

១- ពិនិត្យលើរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ

២- ពិនិត្យលើការត្រួតពិនិត្យផ្ទៃក្នុង

៣- ពិនិត្យលើការធ្វើសវនកម្មផ្ទៃក្នុង

៤- ពិនិត្យលើការធ្វើសវនកម្មខាងក្រៅ

៥- ពិនិត្យលើការគ្រប់គ្រងហានិភ័យ ករណីមិនមានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ

៦- រាយការណ៍ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាភិបាល

៧- អនុវត្តកិច្ចការផ្សេងៗទៀត ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

##### លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម

បានផ្តល់អនុសាសន៍ ដូចខាងក្រោម៖

១- បង្ហាញនូវនិយមន័យ ឬតារាងគំរូវាយតម្លៃ សម្រាប់ផ្តល់ Rating និង Classification។

២- គួរបានបន្ថែមកម្មវិធីចុះធ្វើសវនកម្មពុំព្រាងទុក (Surprise Audit) ក្នុងអង្គភាព រ.ទ.ស.ភ យ៉ាងហោចឱ្យបាន ២ ទៅ ៣ដង ក្នុងមួយឆ្នាំ។

៣- កែសម្រួលនូវវិសាលភាពការងារមួយចំនួន នៅតាមបណ្តានាយកដ្ឋាន/អង្គភាព ដែលស្ថិតក្នុងវិសាលភាពការងារសវនកម្មទៅក្នុងផែនការប្រចាំឆ្នាំ នៅឆ្នាំបន្ទាប់។ ក្នុងនោះ សម្រាប់ការិយាល័យបណ្តាញចូលផ្ទះ នៃនាយកដ្ឋានអាជីវកម្ម គួរបានបន្ថែមមួយចំណុចទៀត "ការទទួលប្រាក់ពីថ្លៃតបណ្តាញ, ការសុំបើកទឹកឡើងវិញ និងការស្នើសុំតម្លើងទំហំនាឡិកា"។

៤- រៀបចំផែនការសម្រាប់កម្មវិធីសិក្សានានា ពាក់ព័ន្ធនឹងការងារចុះធ្វើសវនកម្ម ក៏ដូចជាការបណ្តុះបណ្តាលបន្ថែមទៅដល់សវនករ។

៥- ឯកភាពលើតម្លៃសេវាសម្រាប់សវនកម្មឯករាជ្យ ដែលមានតម្លៃសរុបចំនួន ១.២០០.០០០.០០០,០០រៀល (មួយពាន់ពីររយលានរៀលគត់) ក្នុងរយៈពេល ២ឆ្នាំ។ គម្រោងចំណាយនេះនឹងត្រូវដាក់ជូនក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៥ អាណត្តិទី៨ ពិនិត្យ-សម្រេច។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

### ១- រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

#### ១-១ គណៈកម្មាធិការសវនកម្ម (ត)

៦- ការរៀបចំស្តង់ដានីតិវិធីប្រតិបត្តិការការងារសវនកម្មផ្ទៃក្នុង SOP ដែលបានទទួលអនុសាសន៍ណែនាំចំនួន ១១ចំណុច ពីប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចំណុចពាក់ព័ន្ធដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានលើកឡើងនៅក្នុងសៀវភៅណែនាំសវនកម្មផ្ទៃក្នុងឆ្នាំ២០១៧ និងអនុក្រឹត្យលេខ ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង។ វិសាលភាពនៃស្តង់ដារនីតិវិធីនៅមានកម្រិត បើធ្វើការប្រៀបធៀបទៅនឹងស្តង់ដារអន្តរជាតិ ដូច្នេះ លោកប្រធាននឹងធ្វើការស្នើសុំនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៥ អាណត្តិទី៨ ដើម្បីរកផ្នែកជំនាញប្រឹក្សាជួយរៀបចំស្តង់ដារនេះឡើងវិញ ហើយក៏ដូចជាអភិវឌ្ឍន៍មន្ត្រី-និយោជិតសវនកម្មផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។

#### ១.២. គណៈកម្មាធិការតែងតាំង និងលាភការ

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ឯកឧត្តម ស៊ឹម ស៊ីថា | ប្រធានគណៈកម្មាធិការ - ប្រធានក្រុមប្រឹក្សាភិបាល | ២៨-មីនា-២០២៣ | ១ | ១ |
| ២ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកគណៈកម្មាធិការ - អភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២៨-មីនា-២០២៣ | ១ | |
| ៣ | ឯកឧត្តម នួន ផារ័ត្ន | សមាជិកគណៈកម្មាធិការ - សមាជិកក្រុមប្រឹក្សាភិបាល | ២៨-មីនា-២០២៣ | ១ | |
| ៤ | ឯកឧត្តមអគ្គនាយក រ.ទ.ស.ភ | សមាជិកគណៈកម្មាធិការ - សមាជិកក្រុមប្រឹក្សាភិបាល | ២៨-មីនា-២០២៣ | ១ | |
| ៥ | លេខាធិការសហគ្រាស | លេខា | ២៨-មីនា-២០២៣ | ១ | |

### តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការតែងតាំងនិងលាភការ

- ពិនិត្យ និងផ្តល់អនុសាសន៍លើលក្ខខណ្ឌគុណវឌ្ឍិ និងនីតិវិធីការជ្រើសរើសបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់
- វាយតម្លៃបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់ ដើម្បីដាក់ស្នើទៅក្រុមប្រឹក្សាភិបាល
- ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើយន្តការ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល អភិបាល និងគណៈកម្មាធិការនានាយ៉ាងហោចណាស់១(មួយ)ដងក្នុង១ឆ្នាំ
- រៀបចំនីតិវិធីពិនិត្យ និងផ្តល់អនុសាសន៍លើលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់
- អនុវត្តកិច្ចការផ្សេងៗទៀត ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

### លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំងនិងលាភការ

- ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ : បានបើកកិច្ចប្រជុំ ដើម្បីពិនិត្យ-ពិភាក្សាលើលទ្ធផលនៃការវាយតម្លៃការងាររបស់ក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ២០២៣។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

### ២. ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ

| គណៈកម្មាធិការ | ឈ្មោះ | មូលហេតុ |
|---|---|---|
| គណៈកម្មាធិការតែងតាំង និងលាភការ | ឯកឧត្តម ស៊ឹម ស៊ីថា | ឯកឧត្តម ស៊ឹម ស៊ីថា ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលជំនួសអោយ ឯកឧត្តម អ៊ុំ សុថា ដែលផុតអាណត្តិជាប្រធានក្រុមប្រឹក្សាភិបាល។ |

## គ. លាភការ ឬប្រាក់បំណាច់

### ១. បុគ្គលទទួលលាភការ ឬប្រាក់បំណាច់

| ល.រ | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការ ឬប្រាក់បំណាច់ | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | ១២៧.៥២៩.០៤០រៀល | |
| ២ | អភិបាលប្រតិបត្តិ | ៥៧.៣២៥.០២៨រៀល | |
| ៣ | បុគ្គលិកជាន់ខ្ពស់ | ៣២៦.២១៤.៨៩០រៀល | |
| ៤ | បុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥រូប | ១០៧.៩០៩.៣៧៣រៀល | |

## ឃ. ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល

| ល.រ | បរិយាយ | ដំណើរការនៃការវាយតម្លៃ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាភិបាល | ក្រុមប្រឹក្សាភិបាលបានវាយតម្លៃលើលទ្ធផលការងារប្រចាំឆ្នាំ២០២៣ | ▪ រចនាសម្ព័ន្ធ និងលក្ខណៈរបស់ក្រុមប្រឹក្សាភិបាល<br>▪ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល<br>▪ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>▪ ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល<br>▪ ទំនាក់ទំនងជាមួយគណៈគ្រប់គ្រង<br>▪ ស្វ័យអភិវឌ្ឍន៍របស់អភិបាល និងការអភិវឌ្ឍន៍របស់បុគ្គលិកជាន់ខ្ពស់ |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

| ល.រ. | ឈ្មោះ | មុខជំនាញ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| ▪ ក្នុងប្រទេសៈ បុគ្គលិកជាន់ខ្ពស់សរុប ២២រូប (នារីៈ៤រូប) | | | | |
| ១ | លោក សារុជ វឌ្ឍនា<br>លោក ហេង សុផាន់ណារ៉ាត<br>លោកស្រី សេង គាតារា<br>លោក សោម សុវណ្ណ<br>លោកស្រី ស៊ឹម វល្លិកា<br>លោកស្រី ប្រាក់ ចាន់មករា<br>លោក កែម កានវិចិត្រ<br>លោក ទុយ ប៊ុនសេរីវិទ្ធ<br>លោក កាំង សោភីណា | ភាសាអង់គ្លេសទូទៅ | ចាប់ផ្តើមពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ | ELT |
| ២ | លោក សុខ ណារ៉េត | Financial Model | ចាប់ផ្តើមពីថ្ងៃទី២៧ ខែមេសា ដល់ ថ្ងៃទី១៩, ២៣, ៣០ ខែឧសភា ឆ្នាំ២០២៣ | វ.ទ.ស.ភ |
| ៣ | លោក ហួត សុខហេង | Data Analytics | ចាប់ផ្តើមពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ (សិក្សា ៤ខែ) | វិទ្យាស្ថាន ISTAD (Online) |
| ៤ | លោក ផេង ទី | សិក្ខាសាលាផ្សព្វផ្សាយស្តីពីការចែករំលែកលទ្ធផលស្រាវជ្រាវ និងពិគ្រោះយោបល់លើការកែលម្អកម្មវិធីសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ នៃជំនាញវិស្វកម្មទឹក និងអនាម័យទីក្រុង | ថ្ងៃទី៣១ ខែមិថុនា ឆ្នាំ ២០២៣ | សណ្ឋាគារ Himawari |
| ៥ | លោក ដេង ប៉ូលីដែន | ចូលរួមសិក្ខាសាលាប្រមូលផ្តុំធាតុចូលជាមូលដ្ឋានសម្រាប់រៀបចំសេចក្តីព្រៀងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ និងភាគហ៊ុនរបស់រដ្ឋ | ថ្ងៃទី២០ ដល់២៣ ខែកញ្ញា ឆ្នាំ២០២៣ | ខេត្តសៀមរាប |

| ល.រ. | ឈ្មោះ | មុខជំនាញ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| ៦ | ឯកឧត្តម សំរិទ្ធ សុរិទ្យា<br>ឯកឧត្តម ចាន់ ពិសិដ្ឋ<br>លោកជំទាវ រឿន ណារី<br>លោក ជា សតិភទ្ទ<br>លោក ដេង ប៉ូលីដេន<br>លោក ផេង ទី<br>លោក ជូ ផល្លា<br>លោក សោម សុវណ្ណ<br>លោក អ៊ូ គុណវឌ្ឍន៍<br>លោក សុខ ណារ៉េត<br>លោក ទុយ ប៊ុនសេរីទ្ធ<br>លោក កាំង សោភីណា<br>លោក កែម កានវិចិត្រ<br>លោកស្រី សេង គាតារា<br>លោក សារ៉ុធ វឌ្ឍនា<br>លោក ហួត សុខហេង<br>លោក ឈឹម សេរីរ៉ុធ<br>លោកស្រី ប្រាក់ ចាន់មករា<br>លោកស្រី ស៊ឹម វល្លិកា<br>លោក មាស កុសល<br>លោក រស់ បូរិន្ទ | ការផ្សព្វផ្សាយលក្ខន្តិកៈ<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣ | រ.ទ.ស.ភ |
| ▪ **ក្រៅប្រទេស: បុគ្គលិកជាន់ខ្ពស់សរុប ០២រូប** | | | | |
| ១ | លោក សុខ ណារ៉េត | វគ្គបណ្តុះបណ្តាលបច្ចេកទេសរួមរវាង ACMF និងក្រុមប្រឹក្សាស្តង់ដានិរន្តរភាពអន្តរជាតិ (ISSB) | ថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០២៣ | ប្រទេសឥណ្ឌូនេស៊ី |
| ២ | លោក សារ៉ុធ វឌ្ឍនា | វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចស្តីពី "JP-US-EU Industrial Control Systems Cybersecurity Week"។ | ថ្ងៃទី៨-១៤ ខែតុលា ឆ្នាំ២០២៣ | ប្រទេសជប៉ុន |

# ផ្នែកទី៣.- ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត៖

### ការអនុវត្តច្បាប់ និងបទបញ្ញត្តិជាធរមាន

ក្នុងពេលបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ត្រូវតែអនុវត្ត និងព្យាយាមធ្វើឱ្យ រ.ទ.ស.ភ អនុវត្តតាមច្បាប់ និងបទបញ្ញត្តិជាធរមាន។ ប្រសិនបើអភិបាល ឬ បុគ្គលិកជាន់ខ្ពស់ណាមួយបានដឹងពីព័ត៌មានដែលខ្លួនជឿជាក់ថា រ.ទ.ស.ភ អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ ឬនិយោជិតណាមួយបានបំពានច្បាប់ និងបទបញ្ញត្តិជាធរមាន អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ដែលបានដឹងត្រូវផ្តល់ព័ត៌មាននេះជូន អគ្គនាយក ប្រធានក្រុមប្រឹក្សាភិបាល ប្រធានគណៈកម្មាធិការសវនកម្ម ឬ សវនករផ្ទៃក្នុង។

### អំពើទំនាស់ផលប្រយោជន៍

បន្ថែមលើបទបញ្ញត្តិទាំងឡាយនៃមាត្រា ១៣៤ ១៣៥ ១៣៦ និងមាត្រា ១៣៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាងនូវរាល់អំពើទំនាស់ផលប្រយោជន៍ដែលអាចកើតមានជាមួយ រ.ទ.ស.ភ។

ជាទូទៅទំនាស់ផលប្រយោជន៍កើតឡើងនៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬ ផលប្រយោជន៍របស់សមាជិកគ្រួសារផ្ទាល់របស់អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ បានជ្រៀតចូលក្នុង ឬ អាចនឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់៖

(ក) ផលប្រយោជន៍ទូទៅ ឬអាជីវកម្មរបស់ រ.ទ.ស.ភ ។

(ខ) លទ្ធភាពរបស់អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ផ្សេងទៀតក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈនូវប្រតិបត្តិការឬទំនាក់ទំនងណាមួយ ដែលខ្លួនគិតថានឹងនាំឱ្យកើតមានទំនាស់ផលប្រយោជន៍ជាមួយ រ.ទ.ស.ភ តាមការកំណត់របស់និយ័តករមូលបត្រកម្ពុជា ឬ ផ្សារមូលបត្រកម្ពុជា។

អភិបាល ឬ បុគ្គលិកជាន់ខ្ពស់របស់ រ.ទ.ស.ភ ត្រូវបង្ហាញនូវផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរទៅ រ.ទ.ស.ភ ឬ ស្នើឱ្យមានសេចក្តីប្រកាស ដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលក្នុងករណីដែល៖

(ក) អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ ជាភាគីនៃកិច្ចសន្យា ឬ ជាអ្នកស្នើធ្វើកិច្ចសន្យាជាមួយនឹង រ.ទ.ស.ភ ឬ

(ខ) អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ មានផលប្រយោជន៍សំខាន់ជាមួយនឹងបុគ្គល ឬ នីតិបុគ្គលដែលជាភាគីក្នុងកិច្ចសន្យា ឬ ភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយ រ.ទ.ស.ភ ។

ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន អភិបាលឯករាជ្យមិនត្រូវមានផលប្រយោជន៍ណាមួយនៅក្នុង រ.ទ.ស.ភ ដែលធ្វើឱ្យប៉ះពាល់ឯករាជ្យភាពរបស់ខ្លួន និងមិនត្រូវកាន់កាប់ភាគហ៊ុនលើសពីមួយ (១)ភាគរយនៃភាគហ៊ុនសរុបរបស់ រ.ទ.ស.ភ ឡើយ។

### កាលានុវត្តភាពអាជីវកម្ម

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវយកចិត្តទុកដាក់ជាអាទិភាពដល់ផលប្រយោជន៍ស្របច្បាប់របស់ រ.ទ.ស.ភ នៅពេលសមស្រប។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាង៖

(ក) ឆ្លៀតឱកាសធ្វើកិច្ចការដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនដែលខ្លួនបានដឹងក្នុងពេលអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុង រ.ទ.ស.ភ ។

(ខ) ប្រើប្រាស់ទ្រព្យសម្បត្តិ ឬព័ត៌មានរបស់ រ.ទ.ស.ភ ឬឋានៈ និងមុខតំណែងរបស់ខ្លួន ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។

(គ) ប្រកួតប្រជែងជាមួយ រ.ទ.ស.ភ ។

# ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច (ត)

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (ត)

ក្រុមប្រឹក្សាភិបាលនិងកំណត់ពីទង្វើដែលផ្ទុយពីខ្លឹមសារនៃប្រការនេះ ដោយពិចារណាលើអង្គហេតុ និងស្ថានការណ៍ដែលពាក់ព័ន្ធទាំងឡាយនៃទង្វើនោះ។

### ទំនាក់ទំនងដោយស្មើភាព

នៅក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវធ្វើឱ្យមានភាពស្មើគ្នាក្នុងទំនាក់ទំនងរវាងគ្នា និងជាមួយអតិថិជន អ្នកផ្គត់ផ្គង់ គូប្រជែង អ្នកម៉ៅការ និងនិយោជិត រ.ទ.ស.ភ ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយកប្រយោជន៍ពីបុគ្គលណាម្នាក់ដោយមិនស្មោះត្រង់ ដោយប្រើប្រាស់ឧបាយកល ការលាក់បាំង ការបំភ័ន្តព័ត៌មានសំខាន់ ការបង្ហាញហេតុការណ៍ដែលខុសពីការពិត ឬដោយអំពើមិនស្មោះត្រង់ផ្សេងទៀតក្នុងអាជីវកម្ម។

ការប្រើប្រាស់ ព័ត៌មានអំពីសិទ្ធិព័ត៌មានសម្ងាត់នៃអាជីវកម្មរបស់ រ.ទ.ស.ភ ឬការបញ្ចុះបញ្ចូល អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ រ.ទ.ស.ភ ទាំងអតីត និងបច្ចុប្បន្នឱ្យទម្លាយនូវព័ត៌មានទាំងនោះ ត្រូវបានហាមឃាត់ដាច់ខាត។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដោយសុចរិត និងដើម្បីផលប្រយោជន៍របស់ រ.ទ.ស.ភ និងភាគហ៊ុនិកទាំងអស់របស់ រ.ទ.ស.ភ ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មិនត្រូវទាញយកផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួនជាអភិបាល ឬ ជាបុគ្គលិកជាន់ខ្ពស់ និងមិនត្រូវទទួលអំណោយណាមួយពីតតិយជន ដោយសារមុខតំណែងជាអភិបាល ឬ បុគ្គលិកជាន់ខ្ពស់។

### ការការពារ និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជំរុញឱ្យមានការត្រួតពិនិត្យ និងការប្រើប្រាស់ឱ្យបានត្រឹមត្រូវ ដោយមានការទទួលខុសត្រូវ នូវទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ រួមទាំងទ្រព្យរូបិយ និងទ្រព្យអរូបិយ។

ទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ មានដូចជា ព័ត៌មាន សម្ភារៈ គ្រឿងបរិក្ខារ កម្មសិទ្ធិបញ្ញា ឧបករណ៍ ប្រភពធនធាន ប្រព័ន្ធព័ត៌មានវិទ្យា និងទ្រព្យដទៃទៀត ដែលជាកម្មសិទ្ធិរបស់ រ.ទ.ស.ភ ឬ ទ្រព្យដែល រ.ទ.ស.ភ ជួលពីគេ ឬ ទ្រព្យដែលស្ថិតក្រោមការកាន់កាប់របស់ រ.ទ.ស.ភ ត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅអាជីវកម្មស្របច្បាប់របស់ រ.ទ.ស.ភ តែប៉ុណ្ណោះ។

### បណ្តឹងពាក់ព័ន្ធនឹងគណនេយ្យ

គណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ រ.ទ.ស.ភ ត្រូវទទួលខុសត្រូវក្នុងការរៀបចំនីតិវិធីសមស្របមួយសម្រាប់ទទួលពាក្យបណ្តឹង និងរក្សាទុកនូវពាក្យបណ្តឹង និងពិនិត្យលើពាក្យបណ្តឹងទាក់ទងនឹងគណនេយ្យ ការត្រួតពិនិត្យគណនេយ្យផ្ទៃក្នុង ឬបញ្ហាផ្សេងទៀតដែលទាក់ទងទៅនឹងសវនកម្ម។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ អាចដាក់ពាក្យបណ្តឹងពីបញ្ហាខាងលើ ទៅគណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ រ.ទ.ស.ភ។ ការស្នើសុំឱ្យពិនិត្យបណ្តឹងជាសម្ងាត់ អាចធ្វើឡើងបានតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

### ការលើកទឹកចិត្តឱ្យរាយការណ៍ពីទង្វើខុសច្បាប់ ឬអសីលធម៌

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវខិតខំជម្រុញឱ្យ រ.ទ.ស.ភ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងលើកទឹកចិត្តនិយោជិតឱ្យរាយការណ៍ពីភស្តុតាងនៃទង្វើខុសច្បាប់ ឬ អសីលធម៌ទៅនាយកដ្ឋាន ឬ បុគ្គលដែលមានសមត្ថកិច្ចនៅក្នុង រ.ទ.ស.ភ ។

### ការជួញដូរផ្ទៃក្នុង

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្ត និងប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិ ជាធរមានបទបញ្ជាផ្ទៃក្នុង និងគោលនយោបាយរបស់ រ.ទ.ស.ភ ពាក់ព័ន្ធនឹងការលក់-ទិញភាគហ៊ុន របស់ រ.ទ.ស.ភ ។

# ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច (ត)

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (ត)

### ការរក្សាការសម្ងាត់

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាការសម្ងាត់នៃព័ត៌មានសម្ងាត់របស់ រ.ទ.ស.ភ ដែលខ្លួនបានដឹងលើកលែងតែក្នុងករណីដែល រ.ទ.ស.ភ អនុញ្ញាតឱ្យផ្តល់ព័ត៌មាន ឬការផ្តល់ព័ត៌មាននេះត្រូវបានតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬមានការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

ពាក្យថា "ព័ត៌មានសម្ងាត់" រួមមានជាអាទិ៍ ព័ត៌មានមិនមែនសាធារណៈ ដែលអាចត្រូវបានប្រើដោយគូប្រកួតប្រជែងរបស់ រ.ទ.ស.ភ ឬព័ត៌មានមិនមែនសាធារណៈដែលធ្វើឱ្យប៉ះពាល់ដល់ រ.ទ.ស.ភ ឬ អតិថិជនរបស់ រ.ទ.ស.ភ ប្រសិនបើព័ត៌មាននោះត្រូវបានបង្ហាញ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវពិភាក្សាជាមុនជាមួយអគ្គនាយក ឬ ប្រធានក្រុមប្រឹក្សាភិបាល ប្រសិនបើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ គិតថាខ្លួនមានកាតព្វកិច្ចតាមច្បាប់ក្នុងការបង្ហាញព័ត៌មានសំងាត់នោះ។

### ការផ្តល់ព័ត៌មាន

អភិបាល និងបុគ្គលិកជាន់ខ្ពស់តម្រូវឱ្យយល់ច្បាស់ពីនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ដើម្បីឱ្យសេចក្តីប្រកាសជាសាធារណៈ របាយការណ៍ និងឯកសារផ្តល់ព័ត៌មាន ដែលត្រូវចុះបញ្ជីជាមួយអាជ្ញាធររដ្ឋ រួមបញ្ចូលទាំងនិយ័តករមូលបត្រកម្ពុជា អាចរៀបចំធ្វើឡើងដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន រួមទាំងគោលការណ៍ណែនាំរបស់និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា។

ម្យ៉ាងវិញទៀត ក្នុងទំហំនៃតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមានអំណាចដឹកនាំ ឬ គ្រប់គ្រងការចុះបញ្ជីឯកសារជាមួយ និយ័តករមូលបត្រកម្ពុជា និង/ឬ ផ្សារមូលបត្រកម្ពុជា ឬ ការជូនដំណឹងជាសាធារណៈផ្សេងទៀតរបស់ រ.ទ.ស.ភ ពាក់ព័ន្ធអាជីវកម្មទូទៅលទ្ធផលលក្ខខណ្ឌ និងលទ្ធភាពហិរញ្ញវត្ថុ ត្រូវពិភាក្សាជាមួយនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ផ្សេងទៀត និងជាមួយនិយោជិតពាក់ព័ន្ធ ហើយចាត់វិធានការសមស្របសម្រាប់នីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មាន ដើម្បីឱ្យការផ្តល់ព័ត៌មានធ្វើបានពេញលេញ ច្បាស់លាស់ ត្រឹមត្រូវ ទាន់ពេល និងអាចយល់បាន។

ក្នុងទំហំដែលពាក់ព័ន្ធនឹងនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ អភិបាល និងបុគ្គលិកជាន់ខ្ពស់ម្នាក់ៗ៖

- ត្រូវយល់ច្បាស់អំពីលក្ខខណ្ឌតម្រូវនៃការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ក៏ដូចជាប្រតិបត្តិការអាជីវកម្ម និងហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ។
- មិនត្រូវធ្វើសេចក្តីថ្លែងខុសពីការពិត ឬ ធ្វើឱ្យអ្នកដទៃថ្លែងខុសពីការពិតទាក់ទងអំពីព័ត៌មានរបស់ រ.ទ.ស.ភ ប្រាប់អ្នកដទៃ ទោះបីជាអ្នកនោះនៅក្នុង ឬ នៅក្រៅ រ.ទ.ស.ភ រួមទាំងសវនករឯករាជ្យ និយ័តករ របស់រាជរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត។

### វិសោធនកម្ម និងការលើកលែង

ក្រមសីលធម៌នេះអាចត្រូវបានធ្វើវិសោធនកម្មឬលើកលែងមិនអនុវត្តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ជាវិធានទូទៅក្រុមប្រឹក្សាភិបាលនឹងមិនផ្តល់ការលើកលែងមិនអនុវត្តប្រការណាមួយនៃក្រមសីលធម៌នេះឡើយ ប្រសិនបើគ្មានមូលហេតុសមស្រប និងចាំបាច់ទេនោះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មានកាតព្វកិច្ចយល់ដឹងពីក្រមសីលធម៌នេះ និងស្វែងរកការពន្យល់ និងការផ្តល់ប្រឹក្សាបន្ថែមទាក់ទងនឹងការបកស្រាយខ្លឹមសារ និងលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌នេះជាពិសេសនៅពេលមានហេតុការណ៍ណាមួយដែលអាចមានទំនាស់ជាមួយនឹងក្រមសីលធម៌នេះ។

ក្រុមប្រឹក្សាភិបាលត្រូវបានចាត់វិធានការសមស្រប ក្នុងករណីដែលមានការបំពានក្រមសីលធម៌នេះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់អាចសាកសួរដោយផ្ទាល់ទៅអគ្គនាយក ទាក់ទងនឹងការអនុវត្ត ឬ ការបកស្រាយក្រមសីលធម៌នេះ។

# ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច(ត)

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (ត)

### អានុភាព

ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ និងមានអានុភាពអនុវត្តចាប់ពី រ.ទ.ស.ភ ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជាសាធារណៈដោយនិយ័តករមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។ ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ និងមានអានុភាពអនុវត្តចាប់ពី រ.ទ.ស.ភ ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដោយនិយ័តករមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

ក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ បានអនុម័តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច ដោយត្រូវបានផ្សព្វផ្សាយ និងមានបង្ហាញក្នុងរបាយការណ៍ប្រចាំឆ្នាំ ជូនដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និយោជិត ភាគហ៊ុនិករបស់ រ.ទ.ស.ភ និងសាធារណជន។

## គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

ពុំមាន

## ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

### ១- គោលនយោបាយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | គ្មាន |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | គ្មាន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | គ្មាន |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងច្រើនលើសលប់ | គ្មាន |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | គ្មាន |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | គ្មាន |
| ៧ | ផ្សេងៗ | គ្មាន |

### ២- ប្រតិបត្តិការសំខាន់ៗ ជាមួយភាគីជាប់ពាក់ព័ន្ធ

ពុំមាន

# ផ្នែកទី៤.- គ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

## ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ

- ការងារចុះផ្អាកការផ្គត់ផ្គង់ទឹកបណ្តោះអាសន្ន អនុវត្តពុំទាន់មានភាពច្បាស់លាស់ ដោយរក្សាគម្លាតរយៈពេលយូរ។ *ដោយសារជាទីតាំងផ្ទះចាក់សោរពុំមានមនុស្សរស់នៅ និងជាផ្លូវបេតុង។ ការិយាល័យទទួលបន្ទុក នឹងកែសម្រួលឡើងវិញ។*
- ការអនុវត្តគម្រោងសំណង់ស៊ីវិល អនុវត្តពុំស្របតាមស្តង់ដារនីតិវិធីប្រតិបត្តិការការងារបច្ចេកទេស និងគម្រោង។ *ការិយាល័យទទួលបន្ទុក បានរៀបចំកែសម្រួល SOP ថ្មីរួចហើយដែរ ដោយបានទទួលស្គាល់ត្រឹមថ្នាក់អគ្គនាយករងទទួលបន្ទុក នឹងគ្រោងដាក់ឆ្លងការសម្រេចពី* ***ឯកឧត្តមប្រធានក្រុមប្រឹក្សាភិបាល*** *ក្នុងខែតុលា ឆ្នាំ២០២៣។*
- ការអនុវត្តគម្រោងរបស់សាខាសេវាកម្មទឹកស្អាត និងអនាម័យ អនុវត្តមុនលើក/ទទួលបានគម្រោង *មូលហេតុដោយមានតម្រូវការប្រើប្រាស់ទឹកស្អាតបន្ទាន់សម្រាប់ការងារសង្គមជាច្រើនកន្លែង ដូចជា មន្ទីរពេទ្យ សាលារៀន ក៏ដូចជាសហគមន៍ (ប្រជានសត្តិ និងអាទិភាព)។ សាខានឹងសហការជាមួយបណ្តានាយកដ្ឋានពាក់ព័ន្ធក្នុងការអនុវត្តគម្រោង។*
- ការលើកផែនការថែទាំ-ជួសជុលអគាររដ្ឋបាល អនុវត្តពុំស្របតាមផែនការប្រចាំឆ្នាំ *ដោយយោងតាមការណែនាំរបស់* ***ឯកឧត្តមប្រធាន*** *ឱ្យជួសជុលបឋមលើកន្លែងដែលស្រុតខ្លាំង និងត្រៀមសាងសង់អគារថ្មី។*
- ការងារទូទាត់ចំណាយលើការងារដាក់បំពង់ចែកចាយទឹកថ្មី ក្នុងកំណត់ហេតុរបស់គណៈកម្មការស្តីពីការចុះពិនិត្យ លើការងារជីកដាក់បំពង់ ពុំបានបញ្ជាក់ពីគម្រោងបានអនុវត្តរួច និងគម្រោងកំពុងអនុវត្តបន្ត *ដោយមន្ត្រីទទួលបន្ទុក បានតាមដានតារាងការអនុវត្តគម្រោងរួម ទើបមិនញែកឱ្យតាមផ្នែកនូវការអនុវត្តរួច និងកំពុងអនុវត្តដោយគ្រាន់តែដាក់កំណត់សម្គាល់ប៉ុណ្ណោះ ដូច្នេះនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នឹងណែនាំមន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវធ្វើការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងការកត់ត្រាលើគម្រោង ដែលបានអនុវត្តបញ្ចប់ និងគម្រោងដែលកំពុងបន្តអនុវត្ត ដោយធ្វើជាតារាងរួមភ្ជាប់ដើម្បីជាឧបសម្ព័ន្ធកំណត់ហេតុ។*

## ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការនៃប្រតិបត្តិដោយ ក្រុមប្រឹក្សាភិបាល, គណៈកម្មាធិការសវនកម្ម, សវនកម្មផ្ទៃក្នុង, សវនកម្មខាងក្រៅ, គណៈគ្រប់គ្រង និងបុគ្គលិក ក្នុងគោលបំណងធានាបាននូវប្រសិទ្ធភាព ភាពត្រឹមត្រូវនៃប្រតិបត្តិការ និងភាពជឿទុកចិត្តលើការរាយការណ៍ព័ត៌មាន អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ក្នុងនោះរក្សាសុវត្ថិភាពទ្រព្យសកម្ម ព្រមទាំងអភិបាលកិច្ចសមស្របរបស់សហគ្រាស។ ដើម្បីឱ្យដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុងសម្រេចបានត្រូវមានសមាសធាតុដូចជា បរិយាកាសគ្រប់គ្រង, ការវាយតម្លៃហានិភ័យ, ការគ្រប់គ្រងសកម្មភាព, ព័ត៌មានទំនាក់ទំនង និងសកម្មភាពត្រួតពិនិត្យ។

យោងតាមផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ២០២៣ ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការសម្រាប់ការិយបរិច្ឆេទ ២០២២ ដោយទទួលបានការឯកភាពពីលោកប្រធានគណៈកម្មាធិការសវនកម្ម ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ បានចុះត្រួតពិនិត្យនៅ៖

| | |
|---|---|
| ១- នាយកដ្ឋានអាជីវកម្ម | (ត្រីមាសទី០១) |
| ២- នាយកដ្ឋានផែនការ និងគម្រោង | (ត្រីមាសទី០២) |
| ៣- សាខាសេវាកម្មទឹកស្អាត និងអនាម័យ | (ត្រីមាសទី០៣) |
| ៤- នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស និងនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | (ត្រីមាសទី០៤) |

ក្រោយពីទទួលបានការណែនាំពីគណៈកម្មាធិការសវនកម្ម និងក្រុមប្រឹក្សាភិបាល តម្រូវឱ្យសវនកម្មផ្ទៃក្នុង ស្នើសវនកម្មពុំព្រាងទុក (Surprise Audit) យ៉ាងហោចឱ្យបាន ២-៣ដងក្នុងមួយឆ្នាំ។ ដូចនេះ សវនកម្មផ្ទៃក្នុងយើងខ្ញុំបានជ្រើសរើសយក៖

- ការិយាល័យបណ្តាញចូលផ្ទះ នៃនាយកដ្ឋានអាជីវកម្ម ពិនិត្យទៅលើសន្និធិស្តុក អនុវត្តក្នុងត្រីមាសទី២
- ការិយាល័យហិរញ្ញវត្ថុ នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ពិនិត្យទីលើបេឡាទទួលប្រាក់ថ្លៃតបណ្តាញចូលផ្ទះ អនុវត្តក្នុងត្រីមាសទី៤។

# ផ្នែកទី៤.- គ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម (ត)

## គ. ការធ្វើសវនកម្ម

## ១- សវនកម្មផ្ទៃក្នុង

### ១-១ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង៖

- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្ម ៣ឆ្នាំ, ផែនការសវនកម្មប្រចាំឆ្នាំ ដាក់ជូនប្រធានគណៈកម្មាធិការសវនកម្ម ពិនិត្យ-សម្រេច និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពិនិត្យឡើងវិញនូវបណ្ដាបែបបទ, គោលការណ៍ រួមទាំងបទដ្ឋានបច្ចេកទេស ដែលបានដាក់ចេញឱ្យ អនុវត្ត និងផ្ដល់អនុសាសន៍ក្នុងការកែលម្អ។
- កំណត់ភាពសមស្រប គ្រប់គ្រាន់ និងការផ្ដល់លទ្ធផលល្អ លើកិច្ចប្រតិបត្តិការរបស់អង្គភាព។
- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន លើអនុលោមភាព និងកិច្ចប្រតិបត្តិការ តាមបណ្ដានាយកដ្ឋាន/អង្គភាព ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណ វាស់វែង ចំណាត់ថ្នាក់ និងរាយការណ៍ អំពីព័ត៌មានទាំងនោះ។
- ត្រួតពិនិត្យលើការធ្វើសវនកម្មប្រចាំត្រីមាស និងឆ្នាំ ផ្ញើជូនផ្នែកនីមួយៗ របស់អង្គភាពដែលទទួលបន្ទុកកែលម្អតាមអនុសាសន៍ និងដាក់ជូនគណៈកម្មាធិការសវនកម្ម ពិនិត្យ-សម្រេច, រាយការណ៍ជូនក្រុមប្រឹក្សា ភិបាល និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ឬក្រសួងពាក់ព័ន្ធ។
- ត្រួតពិនិត្យឡើងវិញ នូវប្រព័ន្ធដែលកំពុងប្រើប្រាស់ ដើម្បីធានាបានតាមច្បាប់ និងបទបញ្ញត្តិនានា របស់រដ្ឋ និងអង្គភាពលើកិច្ចប្រតិបត្តិការ និងរបាយការណ៍។
- វាយតម្លៃឡើងវិញលើ ការគ្រប់គ្រង, ថែទាំ, ការពារ, ផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិ, វាយតម្លៃភាពសន្សំសំចៃ, ប្រសិទ្ធភាពប្រើប្រាស់ធនធាន, កំណត់កែលម្អលើការអនុវត្តន៍ និងផ្ដល់អនុសាសន៍។
- សិក្សា និងវិភាគហានិភ័យ ដាក់ជូនប្រធានគណៈកម្មាធិការសវនកម្ម និងក្រុមប្រឹក្សាភិបាល ពិនិត្យ-សម្រេច ដើម្បីរកដំណោះស្រាយតាមស្ថានភាពជាក់ស្ដែង។
- រៀបចំផែនការចំណាយការផ្ដល់សេវាសវនកម្ម និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។
- សម្របសម្រួលការងារសវនកម្មជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឱ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា។
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ១-២ ការតែងតាំង និងការដកហូត/ការលាលែងតំណែងរបស់ប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

ពុំមាន

### ១-៣ ការតែងតាំងថ្មីប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

ពុំមាន

## ២- សវនកម្មខាងក្រៅ

| ល.រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទ ជ្រើសតាំង | តម្លៃសេវា សវនកម្ម(រៀល) | តម្លៃសេវាមិនមែន សវនកម្ម |
|---|---|---|---|---|
| ១ | បេកឃើរ ធីលលី(ខេមបូឌា) ឯ.ក | ២១ កុម្ភៈ ២០២៣ | ២៨០.០០០.០០០ | |

មូលហេតុនៃការផ្លាស់ប្ដូរ, ការផ្អាក និងការបញ្ឈប់ក្រុមហ៊ុនផ្ដល់សេវាសវនកម្មក្នុងវិស័យមូលបត្រគឺពុំមានទេ។

# ផ្នែកទី៥.- ភាគីពាក់ព័ន្ធ

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម៖

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ១ | សុខមាលភាពរបស់អតិថិជន | - ផ្តល់សេវា និងផ្តល់ទឹកស្អាតជូនអតិថិជនដោយជានាគុណភាព ទៅតាមស្តង់ដារជាតិ និងស្តង់ដារអន្តរជាតិ | នៅក្នុងឆ្នាំ២០២៣ រ.ទ.ស.ភ បានផ្តល់សេវាជូនអតិថិជន ក្នុងរាជធានីភ្នំពេញ ក្រុងតាខ្មៅ និងខេត្តត្បូងឃ្មុំ បាន ចំណូលតបណ្តាញចំនួនសរុប ៣០.១១៣បណ្តាញ (ក្នុងនោះបណ្តាញតថ្មី ចំនួន ២៩.៣៣១បណ្តាញ, បណ្តាញចាស់(ប្តូរទីតាំង) ចំនួន ៧០៧បណ្តាញ និងបណ្តាញចាស់ (ប្តូរទំហំនាឡិកាទឹក) ចំនួន ៧៥បណ្តាញ<br>– ផ្តល់សេវាបណ្តាញទឹកជូនអតិថិជនប្រភេទឧបត្ថម្ភធន ចំនួន ៣.៧០៨ បណ្តាញ ក្នុងនោះ៖<br>▪ ឧបត្ថម្ភធន ៣០% ចំនួន ២៤៣ បណ្តាញ<br>▪ ឧបត្ថម្ភធន ៥០% ចំនួន ១.០១៩ បណ្តាញ<br>▪ ឧបត្ថម្ភធន ៧០% ចំនួន ៥៤៣ បណ្តាញ<br>▪ ឧបត្ថម្ភធន ១០០% ចំនួន ១.៩០៣ បណ្តាញ<br>– សរុបកំណើនបណ្តាញអតិថិជន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានចំនួន ៤៧៨.១៤១ អតិថិជន(Active)<br>– ជានាគុណភាពទឹកស្អាត ជូនអតិថិជនប្រើប្រាស់ប្រចាំថ្ងៃ និងទទួលស្គាល់ពីថ្នាក់អន្តរជាតិ<br>– ដំណោះស្រាយជូនអតិថិជន ចែកចេញជាពីរផ្នែក៖<br>១. ទទួលព័ត៌មានពីអតិថិជនផ្ទាល់ និងតាមរយៈប្រព័ន្ធទូរស័ព្ទរបស់អង្គភាពសរុប ១.៥៧៦ ករណី<br>២. ទទួលព័ត៌មានគេហទំព័រហ្វេសប៊ុករបស់អង្គភាពសរុប ៦.២៤២ ករណី |
| | | - ផលិតនិងផ្គត់ផ្គង់ទឹកជូនអតិថិជនដែលជានាបានទាំងបរិមាណនិងសំពាធទឹកសមស្របនិងទឹកមានគុណភាពស្របទៅទាមស្តង់ដារទឹកផឹកថ្នាក់ជាតិនិងស្តង់ដាររបស់អង្គការសុខភាពពិភពលោក។ | - បរិមាណទឹកផលិតសរុបចំនួន ២៧៩.០៥៣.៦៥១ ម៉ែត្រគូបក្នុងឆ្នាំ២០២៣<br>- គុណភាពទឹកស្របតាមស្តង់ដារទឹកផឹកថ្នាក់ជាតិ និង WHO<br>- មន្ទីរពិសោធន៍ទឹកបានធ្វើការត្រួតពិនិត្យគុណភាពទឹក ៣ ដងក្នុងមួយថ្ងៃ និងមានឧបករណ៍តាមដាន Real times Monitoring ដោយប្រព័ន្ធ SCADA ។<br>- ពិនិត្យតាមដានគុណភាពទឹកស្អាតតាមបណ្តាញចែកចាយចំនួន ៨០គំរូ សាករៀងរាល់សប្តាហ៍។<br>- មន្ទីរពិសោធន៍ទឹកបានបញ្ជូនទឹកស្អាតទៅមន្ទីរពិសោធន៍ឯករាជ្យនៅប្រទេសសិង្ហបុរី ជារៀងរាល់ឆ្នាំ ហើយលទ្ធផលដែលទទួលបានជាអំណះ អំណាងបញ្ជាក់អំពីគុណភាពទឹករបស់ រ.ទ.ស.ភ គឺជាទឹកស្អាតផឹកបាន ដោយផ្ទាល់ពីបណ្តាញ។<br>- មន្ទីរពិសោធន៍ទឹកនិរោធទទួលបានវិញ្ញាបនបត្រISO/IEC 17025 : 2017។<br>- មានយន្តការឆ្លើយតបនិងដោះស្រាយជូនអតិថិជនបន្ទាន់ក្នុងករណីមាន បញ្ហាពាក់ពន្ធ័នឹងគុណភាពទឹកតាមរយៈចុះទៅពិនិត្យគុណភាពទឹក និងធ្វើ ការពន្យល់ជូនអតិថិជនដល់ទីតាំងផ្ទាល់ ។ |

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម (ត)

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់ អ្នកម៉ៅការ | - លទ្ធកម្មក្នុងស្រុក: អនុវត្តទៅតាមនីតិវិធីលទ្ធកម្ម (ច្បាប់លទ្ធកម្មសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា)<br><br>- លទ្ធកម្មបរទេស | - រៀបចំផែនការលទ្ធកម្ម ស្នើសុំការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ដំណាក់កាលនៃការរៀបចំដេញថ្លៃ<br>- ការផ្សព្វផ្សាយ លក់ ទទួលបើកសំណើដេញថ្លៃ<br>- ការវាយតម្លៃលើសំណើដេញថ្លៃ<br>- ការចុះកិច្ចសន្យា<br>ការគ្រប់គ្រង និងការអនុវត្ត កិច្ចសន្យា<br>អនុលោមទៅតាមនីតិវិធីរួម សម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងនីតិវិធីគោលការណ៍ណែនាំ ស្តីពីការដេញថ្លៃរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ (ADB, AFD, JICA, EIB, WB, EDCF) |
| ៣ | ការគ្រប់គ្រង និងការពារនិយោជិត | - លក្ខន្តិកៈបុគ្គលិក<br><br>- កិច្ចសន្យាការងារ<br><br>- បទបញ្ជាផ្ទៃក្នុង និងវិន័យ | អនុវត្តបានយ៉ាងខ្ជាប់ខ្ជួននូវបណ្ដាចំណុចដែលមានចែងក្នុងលក្ខន្តិកៈបុគ្គលិកដូចជា ៖<br>១- ការផ្តល់នូវថ្នាក់-កាំបៀវត្សរ៍តាមតួនាទី និងភារកិច្ច និងបើកបៀវត្សរ៍យ៉ាង ទៀងទាត់ជូន២ដង ក្នុងមួយខែ<br>២- ផ្តល់នូវប្រាក់ផ្សេងៗដូចជាប្រាក់បំណាច់មុខងារ, ប្រាក់ប៉ះពាល់សុខភាព, ប្រាក់លើសម៉ោង, ប្រាក់បំណាច់អតីតភាពការងារ និងប្រាក់បុព្វលាភ ប្រចាំឆ្នាំ ជាដើម<br>៣- ផ្តល់ជូននូវសំលៀកបំពាក់ឯកសណ្ឋាន និងសម្ភារៈសុវត្ថិភាពពលកម្ម<br>៤- ធានាសុវត្ថិភាពការងារជូននិយោជិត ដោយអង្គភាពបាន បង់ប្រាក់ទៅ បេឡាជាតិរបបសន្តិសុខសង្គម ផ្នែកគ្រោះថ្នាក់ ការងារ, ថែទាំសុខភាព និងផ្នែកសោធន<br>៥- ផ្តល់នូវប្រាក់ឧបត្ថម្ភបន្ថែមជូនដល់មន្ត្រី-និយោជិត ដែលជួបគ្រោះថ្នាក់ ក្នុងម៉ោងការងារ។<br>បានចុះកិច្ចសន្យាការងារជាមួយ:<br>• និយោជិតជាប់កិច្ចសន្យា<br>• និយោជិតសាកល្បងការងារ<br>• និយោជិតក្របខណ្ឌពេញសិទ្ធិ<br>និយោជិតគ្រប់រូបគោរពបានតាមបទបញ្ជាផ្ទៃ ក្នុងរបស់អង្គភាព ដូចជា:<br>• ពេលវេលាធ្វើការពីម៉ោង៨:០០ព្រឹក ដល់ម៉ោង៤:៣០ ល្ងាច<br>• សំលៀកបំពាក់ឯកសណ្ឋានមាន៤ប្រភេទតាមការកំណត់<br>• គោរពឋានានុក្រមក្នុងការបំពេញការងារ |
| ៤ | ការគាំពារបរិស្ថាន | - ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលជាពិសេសក្រសួងបរិស្ថានលើការគិតគូរ និងគាំពារបរិស្ថាន | ការអនុវត្តគម្រោងពង្រីកប្រព័ន្ធផលិតកម្ម និងប្រព័ន្ធមេនាំទឹករបស់ រ.ទ.ស.ភ គឺចាប់ផ្តើមឡើង ដោយអង្គភាពបានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថាន និងសង្គមដំបូង ព្រមទាំងស្នើសុំការឯកភាពពីក្រសួងបរិស្ថាន។ ក្រោយពីទទួលបានឯកភាព និងនៅពេលដែលអនុវត្តគម្រោង រ.ទ.ស.ភ តែងតែធ្វើ ការត្រួតពិនិត្យលើផលប៉ះពាល់បរិស្ថានរបស់គម្រោងជារៀងរាល់ ឆមាស ព្រម ទាំងរៀបចំជារបាយការណ៍ជូនម្ចាស់ហិរញ្ញប្បទាន និងក្រសួងបរិស្ថាន។ |

## ផ្នែកទី៥.- ភាគីពាក់ព័ន្ធ (ត)

### ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម (ត)

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ៥ | អន្តរកម្មជាមួយសហគមន៍ | ពង្រីកផ្ទៃសេវាដល់សហគមន៍ទៅតាមលទ្ធភាពជាក់ស្តែង | រ.ទ.ស.ភ បានធ្វើការពង្រីកផ្ទៃសេវាជូនប្រជាពលរដ្ឋដែលរស់នៅ តាមបណ្តាក្រៅសហគមន៍ បានចំនួន ១២ខណ្ឌ ៦១ភូមិ ស្មើនឹង ៣.៧០៨បណ្តាញ៖<br>១- ខណ្ឌដូនពេញ (ភូមិរថភ្លើង ចំនួន ០១បណ្តាញ)<br>២- ខណ្ឌ៧មករា(ភូមិ១, ២, ៣, ៤ និង ៥ ចំនួន ៣បណ្តាញ)<br>៣- ខណ្ឌទួលគោក (ភូមិ២៣ ចំនួន ១៤បណ្តាញ)<br>៤- ខណ្ឌឬស្សីកែវ (ភូមិស្ពាន់ខ្ពស់,ក្រោលគោ និងបឹងសាឡាង ចំនួន ១០០បណ្តាញ)<br>៥- ខណ្ឌជ្រោយចង្វារ(ភូមិបាក់ខែង ចំនួន ០៤បណ្តាញ)<br>៦- ខណ្ឌព្រែកព្នៅ(ភូមិកប់ស្រូវតូច, កប់ស្រូវធំ, ស្វាយចេក, ព្រៃធំ,ចំការស្បែង និងត្រពាំងសំព័រ ចំនួន ៣៤៣បណ្តាញ)<br>៧- ខណ្ឌសែនសុខ(ភូមិទ្រុងមាន់, អរគីដេ, ទឹកថ្លា, ត្រពាំងឈូក និងបូរី១០០ខ្នង ចំនួន ៤១បណ្តាញ)<br>៨- ខណ្ឌមានជ័យ (ភូមិមានជ័យ១, មានជ័យ២, មានជ័យ ៣, ត្នោតជ្រុំ និងព្រែកទាល់ ចំនួន ១៦២បណ្តាញ)<br>៩- ខណ្ឌច្បារអំពៅ(ភូមិជ្រោយអំពិល, យកបាត, យកបាត១, ព្រៃធំ, ព្រៃធំ១, តាព្រហ្ម, ចំពុះក្អែក, ចំពុះក្អែក១, កោះក្របី និងកោះក្របី១ ចំនួន ៣១១បណ្តាញ)<br>១០- ខណ្ឌដង្កោ(ភូមិព្រៃវែងលិច, ព្រៃវែងកើត, ទួលសំបូរ, ដំណាក់សង្កែ, ទឹកថ្លា និងព្រៃសំព័រ ចំនួន ៥៨៨ បណ្តាញ)<br>១១-ខណ្ឌពោធិ៍សែនជ័យ (ភូមិសាម៉, កំរៀង, ប្រទះឡាង, ភា, តាំងនោម, វាល, ក្រាំង, ត្រពាំងក្រសាំង, ត្រពាំង អណ្តូង, អក្សរ និងត្រពាំងអញ្ចាញចំនួន ១.៩៩ ៩ បណ្តាញ)<br>១២-ក្រុងតាខ្មៅ (ភូមិព្រៃសំពោង៣, ព្រែកហូរលិច និង ព្រែកហូរកើត ចំនួន ១៤២បណ្តាញ)។ |
| ៦ | ការការពារសិទ្ធិរបស់ម្ចាស់បំណុល | មានការធានាពីរាជរដ្ឋាភិបាល | - លិខិតធានាផ្លូវច្បាប់ចេញដោយក្រសួងយុត្តិធម៌លេខ ២៥០២MOJ.IRDP/១៩ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ របស់គម្រោងសាងសង់រោងចក្របាក់ខែង។<br>- លិខិតធានាផ្លូវច្បាប់ចេញដោយក្រសួងយុត្តិធម៌លេខ ០៣១១MOJ.IRDP/២០ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់គម្រោងសាងសង់រោងចក្របាក់ខែង ដំណាក់២។ |
| ៧ | កម្មវិធីប្រឆាំងអំពើពុករលួយ | - អនុវត្តការងារអាជីវកម្មជាមួយអតិថិជនដោយមានតម្លាភាព<br>- អនុវត្តស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល | ១- ផ្តល់សេវាជូនអតិថិជនទាំងអស់ មិនប្រកាន់វណ្ណៈ ពណ៌សម្បុរ ឬបក្សពួកឡើយ។<br>២- គ្រប់បុគ្គលិកជាន់ខ្ពស់ចាប់ពីប្រធាននាយកដ្ឋានឡើង ត្រូវប្រកាសទ្រព្យសម្បត្តិរៀងរាល់២ឆ្នាំម្តង។ |

# ផ្នែកទី៥.- ភាគីពាក់ព័ន្ធ (ត)

## ខ. ពិពណ៌នាអំពីការទទួលខុសត្រូវសង្គមរបស់ រ.ទ.ស.ភ

| ល.រ | ខ្លឹមសារ | ទំហំនៃការបរិច្ចាគ | សកម្មភាព |
|---|---|---|---|
| ១ | ការកសាងហេដ្ឋារចនាសម្ព័ន្ធ | ទឹកប្រាក់សរុបប្រមាណ ១.៦១៣.៩៨៩.៥៦៧រៀល | - សាងសង់អគារសិក្សា១ខ្នង មាន៣បន្ទប់ធ្វើពីថ្មប្រក់ក្បឿងទំហំ៩មx ២៤ម ស្ថិតនៅ ភូមិអូរជ្រៅ ឃុំកំរៀង ខេត្តបាត់ដំបង។<br>- សាងសង់អគារសិក្សា១ខ្នង ៥បន្ទប់ ស្ថិតនៅអនុវិទ្យាល័យក្រាំងតាសែន ស្ថិតក្នុងភូមិក្រាំងតាសែន សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ រួមទាំងសម្ភារ-បរិក្ខារ បំពាក់ក្នុងអគារ រួមមាន៖ តុគ្រូ តុសិស្ស កៅអីគ្រូ និងក្ដារ ខៀន។<br>- ឧបត្ថម្ភថវិកាក្នុងការតភ្ជាប់បណ្ដាញទឹកស្អាត ជូនប្រជាពលរដ្ឋក្រីក្រទើបផ្លាស់ចូលមកទីតាំង លំនៅថ្មីនៅសហ-គមន៍សំពេងត្បូង ភូមិសំពេង សង្កាត់ព្រែកព្នៅ។<br>- ឧបត្ថម្ភដល់ការជួសជុលផ្លូវក្រាលគ្រួសក្រហម ចំនួន១ខ្សែ មានប្រវែង៩៥០ម៉ែត្រ ស្ថិតនៅក្នុងភូមិអំពេង ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។<br>- ទូទាត់ថ្លៃតបណ្ដាញទឹកស្អាត ចូលក្នុងពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ។<br>- ឧបត្ថម្ភដល់ការជួសជុលផ្លូវលំក្រាលគ្រួសក្រហម ចំនួន១ខ្សែ មានប្រវែង២.៥៨៧ម៉ែត្រ ស្ថិតនៅក្នុងភូមិភ្នំលាវ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ។<br>- ឧបត្ថម្ភថវិការៀបចំកម្មវិធីយុទ្ធនាការឃោសនាផ្សព្វផ្សាយព័ត៌មានស្ដីពីទឹកស្អាត និងការងារអនុវត្តតបណ្ដាញទឹកស្អាតជូនអតិថិជននៅខេត្តត្បូងឃ្មុំ ការងាររៀបចំបណ្ដាញទឹកស្អាតនៅខេត្តត្បូងឃ្មុំ និងថ្លៃបេសសកម្ម ជូនមន្ត្រី-និយោជិត ក្នុងរៀបចំបណ្ដាញទឹកស្អាតនៅខេត្តត្បូងឃ្មុំ។<br>- ឧបត្ថម្ភដល់វត្តពិកទូរង្សីសម្រាប់ទូទាត់សងថ្លៃសម្ភារៈសំណង់ និងថ្លៃឈ្នួលជាងក្នុងការសាងសង់ចង្ក្រានបាយ១ និងបន្ទប់ទឹកចំនួន២បន្ទប់ ស្ថិតនៅក្នុងបរិវេណវត្តពិកទូរង្សី ហៅវត្តចិនដំដែក<br>- ទូទាត់ថ្លៃទិញធុងទឹក និងសម្ភារតភ្ជាប់សម្រាប់ប្រើប្រាស់ក្នុងការផ្គត់ផ្គង់ទឹកជូនប្រជាជននៅតំបន់ជាយក្រុងក្នុងអំឡុងពេលខ្វះទឹកនារដូវប្រាំងខែមីនា-មេសាឆ្នាំ២០២៣។<br>- សាងសង់អាគារសិក្សា១ខ្នង ស្មើនិង៣បន្ទប់ នៅក្នុងសាលាបឋមសិក្សារការ ស្ថិតក្នុងភូមិរការ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។<br>- ទូទាត់ថ្លៃរៀបចំប្រព័ន្ធទឹក និងតបណ្ដាញទឹកស្អាត ជូនយោធភូមិភាគទី៣ កងពលតូចថ្មើរជើងលេខ៣១ ចំនួន៥ ទីតាំង។<br>- សាងសង់អាគារទីចាត់ការ ១ខ្នង មាន៤បន្ទប់ មានទំហំ ១៥មx ១២ម ស្ថិតនៅភូមិបាចុង សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ |
| ២ | ការឧបត្ថម្ភជួយសង្គ្រោះ | ទឹកប្រាក់សរុបប្រមាណ ៥៧៩.២៧៤.០០០រៀល | - ទិញគ្រឿង ឧបភោគ-បរិភោគ (ចំនួន ៣លើក) មានដូចជា៖ អង្ករ ១០តោន, មី ម៉ាម៉ា ១០០កេសធំ, ទឹកស៊ីអ៊ីវ ១០០យួរ, ទឹកត្រី ១០០យួរ និងទឹកបរិសុទ្ធ ១០០កេសតូច ដើម្បីជួយឧបត្ថម្ភ |

| ល.រ | ខ្លឹមសារ | ទំហំនៃការបរិច្ចាគ | សកម្មភាព |
| --- | --- | --- | --- |
| | | | ប្រជាពលរដ្ឋរងគ្រោះដោយសារទឹកជំនន់ទឹកភ្លៀង និងជូនប្រជាពលរដ្ឋជាច្រើនគ្រួសារកំពុងខ្វះខាត់ស្បៀងអាហារប្រចាំថ្ងៃ<br>- ឧបត្ថម្ភវគ្គបណ្ដុះបណ្ដាលសិស្សក្រីក្រ ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ខែ១ ដល់ខែ១២ ឆ្នាំ២០២៣។<br>- ចំណាយទូទាត់ទឹកប្រាក់បង្គ្រប់ជូនតំណាងចែកចាយទឹកសម្រាប់វគ្គ ១១-១២/២០២២/ ដល់ ខែ១-១០/២០២៣<br>- ឧបត្ថម្ភថវិកា ដើម្បីចូលរួមជាជំនួយមនុស្សធម៌ ដល់សកម្មភាពកាកបាទក្រហមកម្ពុជា ក្នុងឱកាសខួបលើកទី១៦០ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៣ តាមរយៈសាខាកាកបាទក្រហមក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, សាខាកាកបាទក្រហមកម្ពុជាខេត្តកែប និងសាខាកាកបាទក្រហមខេត្តត្បូងឃ្មុំ។<br>- ឧបត្ថម្ភជូនរដ្ឋបាលខេត្តពោធិ៍សាត់សម្រាប់ទិញអង្ករ ចំនួន១៥តោន និងគ្រឿងឧបភោគ បរិភោគមួយចំនួនទៀតជួយដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់។<br>- ឧបត្ថម្ភក្នុងកម្មវិធីរត់កំសាន្តដើម្បីសុខភាព និងកិច្ចការសប្បុរសធម៌ "CSX Fun Run 2023" ដែលរៀបចំដោយផ្សារមូលបត្រកម្ពុជាដើម្បីរួមចំណែកការងារសប្បុរសធម៌ជួយដល់មន្ទីរពេទ្យគន្ធបុប្ផាដើម្បីស្នាមញញឹមកុមារកម្ពុជា ដែលប្រព្រឹត្តទៅនូបុរីប៉េងហួតបឹងស្នោរ នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៣។<br>- ឧបត្ថម្ភជូនរដ្ឋបាលឃុំជ័យធំ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលក្នុងការទិញអំពូលសូឡាចំនួន ៣០ អំពូលដាក់តាមដងផ្លូវ ក្នុងភូមិព្រែកស្ដី ។<br>- ឧបត្ថម្ភក្នុងការបោះពុម្ពផ្សាយនូវសៀវភៅមគ្គុទេសក៍ វ.ប.ន ចំនួន ១.០០០ក្បាល សម្រាប់ផ្សព្វផ្សាយ និងចែកចាយដល់សិស្សានុសិស្សនៅតាមបណ្ដាខេត្តផ្សេងៗទៀត។ |
| ៣ | ឧបត្ថម្ភជួយសង្គ្រោះដល់និយោជិត | ទឹកប្រាក់សរុបប្រមាណ ៧១៥.២០០.០០០រៀល | នៅក្នុងឆ្នាំ២០២៣ គណៈកម្មការមូលនិធិបានចំណាយថវិកាឧបត្ថម្ភដល់និយោជិតចំនួន **១៩៦** រូបក្នុងនោះ៖<br>- ជំងឺកម្រិតស្រាល ៧៥រូប<br>- ជំងឺកម្រិតមធ្យម ២២រូប<br>- ជំងឺកម្រិតធ្ងន់ ១០រូប<br>- លំហែលមាតុភាព ០៨រូប<br>- អ្នកវិជ្ជមានកូវីដ-១៩ ៧៨រូប<br>- អ្នកជំងឺធ្ងន់ធ្ងរអាចឈានដល់មរណភាព ០១រូប<br>- មរណភាព ០២រូប |
| ៤ | ឧបត្ថម្ភអតិថិជនចំណូលទាប | ទឹកប្រាក់សរុបប្រមាណ ១.០៤៧.២៥០.៥០០រៀល | នៅក្នុងឆ្នាំ២០២៣ រ.ទ.ស.ភ ចំណាយថវិកាដើម្បីភ្ជាប់បណ្ដាញឧបត្ថម្ភធន ជូនអតិថិជនចំណូលទាប (កម្រិត ៣០%, កម្រិត ៥០%, កម្រិត ៧០% និងកម្រិត១០០%) **សរុបចំនួន ៣,៧០៨ បណ្ដាញ** ក្នុងនោះ<br>- ឧបត្ថម្ភធន ៣០% ចំនួន ២៤៣ អតិថិជន<br>- ឧបត្ថម្ភធន ៥០% ចំនួន ១.០១៩ អតិថិជន<br>- ឧបត្ថម្ភធន ៧០% ចំនួន ៥៤៣ អតិថិជន<br>- ឧបត្ថម្ភធន ១០០% ចំនួន ១.៩០៣ អតិថិជន |

| ល.រ | ខ្លឹមសារ | ទំហំនៃការបរិច្ចាគ | សកម្មភាព |
|---|---|---|---|
| ៥ | ឧបត្ថម្ភផ្សេងៗ | ទឹកប្រាក់សរុបប្រមាណ ១.៧៦៨.៨៣៦.៥៩៥រៀល | - ចំណាយថវិកាក្នុងការទិញសម្ភារ-បរិក្ខារ និងគ្រឿងសំណង់សាងសង់អគារទីបញ្ជាការកងពលចំនួន ៤លើក ដើម្បីឧបត្ថម្ភជូនកងពលតូចអន្តរាគមន៍លេខ៨ ខេត្តព្រះវិហារ ដែលជាសម្ព័ន្ធមេត្រីភាព ជាមួយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្រោមអធិបតីភាពឯកឧត្តមអគ្គនាយក និងប្រតិភូ រ.ទ.ស.ភ អមដំណើរ<br>- ឧបត្ថម្ភថវិកាក្នុងការចូលរួមកម្មវិធីពិព័រណ៍បច្ចេកវិទ្យាកម្ពុជាឆ្នាំ២០២២ (Cambodia Tech Expo 2022) អមកិច្ចប្រជុំកំពូលអាស៊ាននា ខែវិច្ឆិកា ឆ្នាំ២០២២។<br>- ចំណាយថវិកាទូទាត់ថ្លៃទឹក តាមបង្គោលពន្លត់អគ្គីភ័យ ដែលបានយកទៅប្រើប្រាស់ក្នុងគោលដៅមនុស្សធម៌ ចាប់ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០២៣។<br>- ឧបត្ថម្ភថវិកាដើម្បីឧបត្ថម្ភការរៀបចំ «ទិវាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍» និង «ពិព័រណ៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា-អន្តរជាតិលើកទី១ ឆ្នាំ២០២៣ » ដែលនឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍កោះពេជ្រ។<br>- ឧបត្ថម្ភការរៀបចំពិធីចុះសួរសុខទុក្ខ សំណេះសំណាល និងជប់លៀងជាមួយបងប្អូននាយទាហាន និងពលទាហាន ក្នុងកងពលតូចថ្មើរជើងលេខ៣១ ក្នុងឱកាសនៃការអបអរសាទរពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦។<br>- ចំណាយចូលរួមរៀបចំជាស្តង់ពិព័រណ៍ នៅក្នុងបរិវេណស្ថានទូតបារាំង ក្នុងឱកាសកម្មវិធីខួបលើកទី៣០ នៃទំនាក់ទំនងរវាង ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ ជាមួយព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ហាញសមិទ្ធផលនៃគម្រោងនានាដែលស្ថិតក្រោមហិរញ្ញប្បទានរបស់ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣។<br>- ឧបត្ថម្ភជូនរដ្ឋបាលឃុំជ័យធំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ក្នុងការទិញបង្គោល និងអំពូលសូឡា ចំនួន៣០០ដើម ដាក់បំភ្លឺលើផ្លូវបេតុង ចំនួន៥ភូមិ។<br>- ឧបត្ថម្ភថវិកាក្នុងការចូលរួមរចនាប្រទីបរបស់ក្រសួង MISTI ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែអកអំបុក ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៦-២៧-២៨ ខែវិច្ឆិកា ឆ្នាំ២០២៣<br>- ឧបត្ថម្ភថវិកាក្នុងការរៀបចំទូកចូលរួមក្នុងការប្រណាំងក្នុងឱកាសចូលរួមអបអរសាទរ ពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅខេត្តត្បូងឃ្មុំ ឆ្នាំ២០២៣។<br>- ចំណាយក្នុងការចូលរួម បច្ច័យចូលបុណ្យកឋិនទានរបស់សាលារាជធានីភ្នំពេញ ដង្ហែទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់ត្រីមាសក្នុងព័ទ្ធសីមាវត្តប្រសិទ្ធីរម្យារាមស្ថិតនៅក្នុងសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ។ |

# ផ្នែកទី៦.- ការបង្ហាញព័ត៌មាន និងតម្លាភាព

## ក. ការបង្ហាញព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| ល.រ | ព័ត៌មាន | មាន/គ្មានបង្ហាញ |
|---|---|---|
| ១ | ចក្ខុវិស័យ/បេសកកម្ម/គោលដៅអាជីវកម្ម | មានបង្ហាញ |
| ២ | សូចនាករហិរញ្ញវត្ថុ | មានបង្ហាញ |
| ៣ | សូចនាករមិនមែនហិរញ្ញវត្ថុ | មានបង្ហាញ |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មានបង្ហាញ |
| ៥ | គោលនយោបាយភាគលាភ | មានបង្ហាញ |
| ៦ | ជីវប្រវត្តិរបស់អភិបាល | មានបង្ហាញ |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មានបង្ហាញ |
| ៨ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មានបង្ហាញ |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មានបង្ហាញ |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មានបង្ហាញ |

## ខ. យន្តការនៃការបង្ហាញព័ត៌មាន មធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

លោក ដេង ប៉ូលីដែន អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច និង លោក ជូ ផល្លា លេខាធិការសេហគ្រាស ជាបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ដែលមានការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ជាជំនួយការក្នុងការផ្តល់ព័ត៌មានសាជីវកម្ម។

ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន រៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូន និងសុំការអនុម័តពីក្រុមប្រឹក្សាភិបាល រួចផ្ញើជូននិយ័តករមូលបត្រកម្ពុជា (ទម្រង់ PDF) ដើម្បីស្នើសុំការអនុញ្ញាតផ្សព្វផ្សាយរបាយការណ៍ទាំងនេះជាសាធារណៈ បន្ទាប់ពីទទួលបានការត្រួតពិនិត្យរបស់ ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន។ ក្រោយពីទទួលបានការអនុញ្ញាតពី និយ័តករមូលបត្រកម្ពុជា លើសំណើសុំរួចមក ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន ត្រូវបញ្ជូនរបាយការណ៍នេះ ទៅនាយកដ្ឋានអាជីវកម្ម ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័រផ្លូវការរបស់ រ.ទ.ស.ភ ជូនវិនិយោគិន និងសាធារណជន។

ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន ផ្តល់ព័ត៌មានពិសេស និងតាមការស្នើសុំជូននិយ័តករមូលបត្រកម្ពុជា បន្ទាប់ពីទទួលបានការត្រួតពិនិត្យរបស់ ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និងការអនុញ្ញាតរបស់ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**។ ក្រោយពីបានទទួលការអនុញ្ញាតពី និយ័តករមូលបត្រកម្ពុជា លើព័ត៌មានដែលបានស្នើសុំរួចមក ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិនត្រូវបញ្ជូនព័ត៌មាននេះ ទៅនាយកដ្ឋានអាជីវកម្ម ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័រផ្លូវការរបស់ រ.ទ.ស.ភ ជូនវិនិយោគិន និងសាធារណជន។

ដោយឡែកព័ត៌មានទាន់ពេល និងព័ត៌មានតាមការស្ម័គ្រចិត្តត្រូវបានបញ្ជូនទៅ ផ្សារមូលបត្រកម្ពុជា តាមប្រព័ន្ធ E-Disclosure របស់ផ្សារមូលបត្រកម្ពុជា ដោយការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន បន្ទាប់ពីការ ត្រួតពិនិត្យរបស់ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន។ ក្រោយពីទទួលបានការអនុញ្ញាតរបស់ផ្សារមូលបត្រកម្ពុជា លើព័ត៌មានដែលបានស្នើសុំរួចមក ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន ត្រូវបញ្ជូនព័ត៌មាននេះ ទៅនាយកដ្ឋានអាជីវកម្ម ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ នៅលើគេហទំព័រផ្លូវការរបស់ រ.ទ.ស.ភ ជូនវិនិយោគិន និងសាធារណជន។

# ផ្នែកទី៦.- ការបង្ហាញព័ត៌មាន និងតម្លាភាព (ត)

## គ. ទំនាក់ទំនងជាមួយវិនិយោគិន

### ១- យន្តការ និងនីតិវិធីនៃការទំនាក់ទំនងជាមួយវិនិយោគិន

រ.ទ.ស.ភ ធ្វើការទំនាក់ទំនងទៅវិនិយោគិន តាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ រ.ទ.ស.ភ ក្នុងការផ្តល់ព័ត៌មានអំពី ការបែងចែកភាគលាភប្រចាំឆ្នាំ និងមហាសន្និបាតភាគហ៊ុនិក។ ចំពោះវិនិយោគិនដែលមានបំណងស្វែងយល់អំពី រ.ទ.ស.ភ ត្រូវដាក់សំណើជាមុនមកកាន់ រ.ទ.ស.ភ ដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្ររបស់ខ្លួន ដើម្បីឲ្យ រ.ទ.ស.ភ មានលទ្ធភាពរៀបចំតាមសំណើរបស់វិនិយោគិន។

ក្រៅពីយន្តការទំនាក់ទំនងខាងលើ វិនិយោគិនអាចធ្វើការទំនាក់ទំនងមកកាន់បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និង/ឬ ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ តាមរយៈសារអេឡិចត្រូនិកដូចខាងក្រោម៖

- បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន: Dpolyden@ppwsa.com.kh ឬ
- ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន: Ksokuntheary@ppwsa.com.kh ឬ ir@ppwsa.com.kh

### ២- ទំនាក់ទំនងជាមួយនឹងវិនិយោគិនក្នុងឆ្នាំ២០២៣

នៅក្នុងឆ្នាំ២០២៣ រ.ទ.ស.ភ បានធ្វើការទំនាក់ទំនងជាមួយនឹងវិនិយោគិនតាមរយៈ ធនាគារអេស៊ីលីដា ភីអិលស៊ី ក្នុងការផ្តល់ព័ត៌មានអំពី ការបែងចែកភាគលាភប្រចាំឆ្នាំ២០២២ និងមហាសន្និបាតភាគហ៊ុនលើកទី១១ របស់ រ.ទ.ស.ភ។

# ឧបសម្ព័ន្ធ ២

## របាយការណ៍សវនកម្មផ្ទៃក្នុង

### ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ

**ប្រចាំឆ្នាំ២០២៣**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សវនកម្មផ្ទៃក្នុង**
លេខ .០០២......ស.ប-ក

# របាយការណ៍សវនកម្មផ្ទៃក្នុង
# ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ
# ប្រចាំឆ្នាំ ២០២៣ (ការិយបរិច្ឆេទ ២០២២)

ការងារត្រួតពិនិត្យផ្ទៃក្នុង គឺជាកត្តាចម្បងដ៏មានសារៈសំខាន់ដែលជួយដល់អង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សម្រាប់អនុវត្តការងារប្រចាំថ្ងៃប្រកបដោយជោគជ័យ និងសម្រេចបាននូវគោលដៅផ្គត់ផ្គង់ទឹកស្អាត ជូនអតិថិជនរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ប្រកបដោយសុខុមាលភាព។

ក្នុងឆ្នាំ២០២៣ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានមន្ត្រី-និយោជិត សរុបចំនួន ១.៣៧០ នាក់ (នារី ២២៩ នាក់) ក្នុងនោះ ៖

| | | | | |
|---|---|---|---|---|
| - មន្ត្រីក្របខ័ណ្ឌរដ្ឋ | ចំនួន | ០១ | នាក់ | **ឯកឧត្តមប្រតិភូ** |
| - មន្ត្រី-និយោជិតក្របខ័ណ្ឌសហគ្រាស | ចំនួន | ១.២៦០ | នាក់ | (នារី ២១៥ នាក់) |
| - និយោជិតជាប់កិច្ចសន្យា | ចំនួន | ១០៩ | នាក់ | (នារី ១៤ នាក់) |

យោងតាមផែនការសកម្មភាពសវនកម្ម ប្រចាំឆ្នាំ២០២៣ ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ សម្រាប់ការិយបរិច្ឆេទ ២០២២ ដោយទទួលបានការឯកភាពពីប្រធានគណៈកម្មាធិការសវនកម្ម ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ៖

| | |
|---|---|
| ១- នាយកដ្ឋានអាជីវកម្ម | ត្រីមាសទី ១ |
| ២- នាយកដ្ឋានផែនការ និងគម្រោង | ត្រីមាសទី ២ |
| ៣- សាខាសេវាកម្មទឹកស្អាត និងអនាម័យ | ត្រីមាសទី ៣ |
| ៤- នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស និង នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | ត្រីមាសទី ៤ |

- ក្រោយពីទទួលបានការណែនាំពីគណៈកម្មាធិការសវនកម្ម និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១ អាណត្តិទី៨ តម្រូវឱ្យសវនកម្មផ្ទៃក្នុងធ្វើសវនកម្មពុំព្រាងទុក (Surprise Audit) ឱ្យបាន ២ - ៣ ដង ក្នុង ១ឆ្នាំ។ សវនកម្មផ្ទៃក្នុង បាន៖
    - + ពិនិត្យសន្និធិស្តុក នៅការិយាល័យបណ្តាញចូលផ្ទះ នៃនាយកដ្ឋានអាជីវកម្ម ក្នុងត្រីមាសទី២
    - + ពិនិត្យបេឡាទទួលប្រាក់ថ្លៃតបណ្តាញចូលផ្ទះ នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ក្នុងត្រីមាសទី៤។

I. **របាយការណ៍លទ្ធផលការងារសវនកម្មផ្ទៃក្នុង**

**ក- ការអនុវត្តន៍អនុសាសន៍សវនកម្មគ្រាមុន**

| **អនុសាសន៍សវនកម្ម** | **ការឆ្លើយតប** | **អនុសាសន៍** | **ហានិភ័យ** |
|---|---|---|---|
| **i. នាយកដ្ឋានអាជីវកម្ម**<br>**ការិយបរិច្ឆេទ ២០១៥** | | | |
| **១- ការគ្រប់គ្រងបណ្តាញទឹក ដែលមានបរិមាណទឹកប្រើប្រាស់ចាប់ពី ៥០០.០០០ រៀល ឡើង អនុវត្តពុំស្របតាមគោលការណ៍ដែលបានកំណត់ ដោយអតិថិជនមួយចំនួន ពុំទាន់បានបង់ប្រាក់កក់បន្ថែម**<br>គ្រប់ការិយាល័យចំណូល ត្រូវធ្វើការតាមដាន និងធ្វើលិខិតអញ្ជើញអតិថិជន ដែលបានប្រើប្រាស់បរិមាណទឹកច្រើន ហើយពុំទាន់បានបង់ប្រាក់កក់ធានាលើ ការប្រើប្រាស់ទឹកបន្ថែម ស្មើនឹង ០៣ខែ ធៀបនឹងបរិមាណទឹកប្រើប្រាស់ក្នុងវគ្គ ដើម្បីធានាលើការប្រើប្រាស់ទឹករបស់អតិថិជន និងស្របតាមគោលការណ៍។ | ដោយសារ ការប្រើប្រាស់ទឹករបស់អតិថិជន មានការប្រែប្រួលជាប្រចាំតាមវគ្គនីមួយៗ។ | ការិ. ជំនាញ ត្រូវជម្រុញ ការធ្វើលិខិតជូនដំណឹងដល់អតិ. មកបង់ប្រាក់កក់បន្ថែមលើការប្រើប្រាស់ទឹក | ទាប |
| **ការិយបរិច្ឆេទ ២០១៦** | | | |
| **១- ការផ្លាស់ប្តូរទំហំនាឡិកាពីតូចទៅធំ អនុវត្តពុំស្របតាមគោលការណ៍ដែលបានកំណត់ ដោយការប្រើប្រាស់ទឹករបស់អតិថិជន ពុំស្របតាមការកំណត់ក្នុងកិច្ចសន្យា**<br>រាល់ការផ្លាស់ប្តូរទំហំនាឡិកាតាមការស្នើសុំរបស់អតិថិជន ការិយាល័យជំនាញ ត្រូវធ្វើការតាមដានពីការប្រើប្រាស់ទឹករបស់អតិថិជន ដូចដែលបានកំណត់ក្នុងកិច្ចសន្យា។ ករណី អតិថិជនពុំអាចប្រើប្រាស់តាមចំនួនកំណត់បាន ត្រូវធ្វើការគិតបន្ថែមបង្គ្រប់បរិមាណទឹកជាមធ្យមក្នុងមួយថ្ងៃ ឱ្យបានត្រឹមត្រូវតាមការព្រមព្រៀងក្នុងកិច្ចសន្យា។ | ដោយសារ ការតាមដានរបស់ការិ. បណ្តាញ ចូលផ្ទះ នៅខ្វះចន្លោះនឹងត្រូវធ្វើការកែសម្រួល ឡើងវិញ ចាប់ពីខែមីនា ឆ្នាំ ២០២៣ តទៅ។ | ការិ. ជំនាញ ត្រូវតាមដានការប្រើប្រាស់ទឹក របស់អតិ. ឱ្យបានត្រឹមត្រូវ តាមការកំណត់ក្នុងកិច្ចសន្យា។ | ទាប |
| **២- ការងារគ្រប់គ្រងស្តុកសម្ភារ អនុវត្តពុំទាន់បានត្រឹមត្រូវ ដោយសម្ភារមួយចំនួនពុំមានចលនា ពុំបានបង្វែរចូលឃ្លាំងរបស់ការិយាល័យគណនេយ្យ**<br>មន្ត្រីទទួលបន្ទុក ត្រូវធ្វើការពិនិត្យ និងតាមដានការងារឱ្យបានច្បាស់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង។ | នៅសល់សម្ភារ ចំនួន ០៣ មុខ ត្រៀមនឹងបញ្ចូលឃ្លាំង របស់ការិ. គណនេយ្យនៅខែបន្ទាប់ | ការិ. ជំនាញ ត្រូវរួសរាន់ បញ្ចប់ការងារនេះឱ្យបានឆាប់។ | ទាប |
| **ការិយបរិច្ឆេទ ២០២០** | | | |
| **១- អតិថិជន ពុំទាន់បានបង់ប្រាក់កក់ថ្លៃប្រើប្រាស់ទឹក**<br>មន្ត្រីទទួលបន្ទុក ត្រូវធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើលិខិតអញ្ជើញអតិថិជនដែលពុំទាន់បានបង់ប្រាក់កក់ លើថ្លៃប្រើប្រាស់ទឹកឱ្យស្របតាមសេចក្តីកំណត់បទបញ្ជាលេខ ៦៣៣ ស.ស ស្តីអំពីការផ្គត់ផ្គង់ និងប្រើប្រាស់ទឹកនៅរាជធានីភ្នំពេញ " **អ្នកជាវទឹក ត្រូវបង់ប្រាក់កក់មុនយ៉ាងតិចស្មើនឹងទឹកប្រាក់សម្រាប់ការប្រើប្រាស់ទឹករយៈពេល ៣ខែ** "។ | ការិ. ចំណូលយកចិត្តទុកដាក់ លើចំណុចអាទិភាពពីរគឺអតិ. ប្រើប្រាស់ទឹកច្រើនជាប្រចាំ ឬអតិ. ប្រភេទអាជីវកម្មធំ និងអតិ. ក្នុងតំបន់ងាយនឹងអភិវឌ្ឍន៍ (រុះរើដូរឡើងវិញ)។ ការិ. នឹងបន្តអនុវត្តចាប់ពីខែមីនា ឆ្នាំ២០២៣ តទៅ។ | ការិ. ជំនាញ ត្រូវជម្រុញអតិ. មកបង់ប្រាក់កក់បន្ថែមឱ្យបានឆាប់។ | ទាប |
| **២- ការត្រួតពិនិត្យ-វាស់ស្ទង់ និងលាងសម្អាតនាឡិកាទឹក ទំហំ ៤០ ម.ម ឡើង អនុវត្តពុំស្របតាម SOP**<br>មន្ត្រីទទួលបន្ទុក ត្រូវយកចិត្តទុកដាក់អនុវត្តការងាររបស់ខ្លួនឱ្យស្របទៅតាមស្តង់ដានីតិវិធីប្រតិបត្តិការ SOP ដែលបានកំណត់។ ករណី អនុវត្តលើស | ការិ. កំពុងធ្វើបច្ចុប្បន្នភាព SOP គ្រោងនឹងបញ្ចប់ នៅត្រីមាសទី២ ឆ្នាំ២០២៣។ | ការិ. ជំនាញ ត្រូវរួសរាន់ បញ្ចប់ការ | ទាប |

| អនុសាសន៍សវនកម្ម | ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
|---|---|---|---|
| ត្រូវបញ្ជាក់ពីមូលហេតុឱ្យបានត្រឹមត្រូវ ឬធ្វើបច្ចុប្បន្នភាពទៅលើ SOP ឱ្យស្របទៅនឹងការអនុវត្តន៍ជាក់ស្តែង។ | | ធ្វើ បច្ចុប្បន្នភាព SOP | |
| ii. **នាយកដ្ឋានផែនការ និងគម្រោង** (ការិយបរិច្ឆេទ ២០២០) | | | |
| **១- ការលើកគម្រោងពង្រីកផ្ទៃសេវាបណ្តាញទឹកស្អាត អនុវត្តលើសផែនការដែលបានកំណត់**<br>ការិយាល័យ ត្រូវធ្វើការសហការជាមួយនឹងវិស័យឯកជន និងសាលារាជធានីភ្នំពេញ ដើម្បីងាយស្រួលក្នុងការលើកគម្រោង និងស្នើសុំគោលការណ៍ពី **ឯកឧត្តមអគ្គនាយក** ក្នុងការទិញសម្ភារសម្រាប់បម្រុងទុក។ | អនុវត្តបានពេញលេញ | | |
| **២- នីតិវិធីនៃការលើកគម្រោងបង់វិនិយោគ អនុវត្តយឺតពុំស្របទៅនឹង SOP ដែលបានកំណត់**<br>ការិយាល័យ ត្រូវអនុវត្តការងារឱ្យបានសមស្របទៅនឹងចំណុច 4.2 " **ការងារលើកគម្រោងដាក់បំពង់ចែកចាយទឹកក្នុង និងក្រៅផែនការវិនិយោគ បន្ទាប់ពីទទួលបានការឯកភាពជាគោលការណ៍ពីថ្នាក់ដឹកនាំអង្គភាព (ឯកឧត្តមអគ្គនាយក) មកការិយាល័យបច្ចេកទេស និងគម្រោង ចាប់ផ្តើមអនុវត្តលើកគម្រោង** " ឬត្រូវធ្វើការកែសម្រួលនីតិវិធីប្រតិបត្តិការការងារ SOP ឱ្យត្រឹមត្រូវស្របទៅនឹងការអនុវត្តន៍ជាក់ស្តែង។ | អនុវត្តបានពេញលេញ | | |
| iii. **សាខាសេវាកម្មទឹកស្អាត និងអនាម័យ** (ការិយបរិច្ឆេទ ២០២១) | | | |
| **១- វិក្កយបត្រខ្សាច់ស្ទួនលេខគ្នា និងសរសេរត្រួតលើគ្នា**<br>សាខា ត្រូវធ្វើការពិនិត្យ និងកត់ត្រាឱ្យបានត្រឹមត្រូវមុននឹងធ្វើការស្នើសុំទូទាត់។ | អនុវត្តបានពេញលេញ | | |
| iv. **ក- នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស** (ការិយបរិច្ឆេទ ២០២១) | | | |
| **១- ការតាមដានទៅលើការងារលើសម៉ោងរបស់និយោជិត អនុវត្តពុំទាន់បានត្រឹមត្រូវ ដោយពុំបានរក្សាទុកនូវតារាងតាមដានបំពេញការងារបន្ថែមម៉ោង**<br>មន្ត្រីទទួលបន្ទុក ត្រូវយកចិត្តទុកដាក់ក្នុងការរក្សាទុកនូវតារាងតាមដានការងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ។ | អនុវត្តបានពេញលេញ | | |
| **ខ- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ**<br>**ការិយបរិច្ឆេទ ២០១៥** | | | |
| **១- ការងារទូទាត់ចំណាយ ជូននាយកដ្ឋាន/អង្គភាព និងក្រុមហ៊ុនផ្គត់ផ្គង់មួយចំនួន អនុវត្តយឺត**<br>មន្ត្រីទទួលបន្ទុក ត្រូវអនុវត្តការងារទូទាត់ឱ្យបានទាន់ពេល និងត្រូវមានការឯកភាពពី **ឯកឧត្តមអគ្គនាយក**។ | ដោយសារ<br>- ទំហំការងារច្រើន<br>- ខ្វះកម្លាំង<br>ការិយាល័យនឹងព្យាយាមអនុវត្ត ឱ្យបានកាន់តែប្រសើរ ចាប់ពីឆ្នាំ២០២៤ | ការិយាល័យ ត្រូវពង្រឹង ការងារទូទាត់ ឱ្យបានកាន់តែប្រសើរ។ | ទាប |
| **ការិយបរិច្ឆេទ ២០២១** | | | |
| **១- ការគ្រប់គ្រងស្តុកសម្ភារ ពុំទាន់មានភាពត្រឹមត្រូវ ដោយសម្ភារមួយចំនួនពុំមានចលនា និងមានចលនាយឺត**<br>ការិយាល័យ ត្រូវធ្វើការសហការជាមួយនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យតាមដាន និងកត់ត្រាឱ្យបានត្រឹមត្រូវលើសម្ភារមុននឹងបញ្ជាទិញ ដើម្បីចៀសវាងការកកស្ទះសម្ភារក្នុងឃ្លាំង។ | អនុវត្តបានពេញលេញ | | |

## ខ- លទ្ធផលការងារសវនកម្ម

### i. នាយកដ្ឋានអាជីវកម្ម

| | | | |
|---|---|---|---|
| **១. ការងារតបណ្តាញ** | **ចំនួន** | **២២.៣៥៣** | **បណ្តាញ** |
| • ប្រភេទជីវភាព (រ.ទ.ស.ភ) | ចំនួន | ២០.៧៣៨ | បណ្តាញ |
| • ប្រភេទជីវភាព (ត្បូងឃ្មុំ) | ចំនួន | ៤២៥ | បណ្តាញ |
| • ប្រភេទអាជីវកម្ម (រ.ទ.ស.ភ) | ចំនួន | ៥៩៣ | បណ្តាញ |
| • ប្រភេទអាជីវកម្ម (ត្បូងឃ្មុំ) | ចំនួន | ០៨ | បណ្តាញ |
| • បណ្តាញថ្មីតែប្រើលេខកូដចាស់ (ប្តូរទីតាំងនាឡិកា) | ចំនួន | ៤៨៩ | បណ្តាញ |
| • បណ្តាញថ្មីតែប្រើលេខកូដចាស់ (ប្តូរទំហំនាឡិកា) | ចំនួន | ១០០ | បណ្តាញ |
| **២. ការងារផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋចំណូលទាប** | **ចំនួន** | **១.៤៤៧** | **បណ្តាញ** |
| **៣. ការងារអនុវត្តការលើកកំរិតនាឡិកា** | **ចំនួន** | **២.៣៨៨** | **នាឡិកា** |
| **៤. ការដោះដូរនាឡិកាខូចជូនអតិថិជន** | **ចំនួន** | **៥.៩៨៥** | **នាឡិកា** |
| • នាឡិកាទំហំ ១៥ ម.ម ដល់ ២៥ ម.ម | ចំនួន | ៥.៩១០ | នាឡិកា |
| • នាឡិកាទំហំ ៤០ ម.ម ឡើង | ចំនួន | ៧៥ | នាឡិកា |

នាយកដ្ឋាន អនុវត្តការងារបានល្អ និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយចំនួន ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

### ១- របាយការណ៍តបណ្តាញទឹកថ្មីជូនអតិថិជន ពុំទាន់មានភាពពេញលេញ

ក្នុងឆ្នាំ២០២២ ការងារតបណ្តាញទឹកថ្មីជូនអតិថិជន មានចំនួន ២២.៣៥៣ បណ្តាញ ក្នុងនោះសវនកម្មបានជ្រើសយក ចំនួន ៤៥០ បណ្តាញ មកធ្វើការពិនិត្យឃើញថា ការបំពេញព័ត៌មានតបណ្តាញថ្មីរបស់អតិថិជនពុំទាន់មានភាពត្រឹមត្រូវ និងពេញលេញ៖

១. ពុំមានហត្ថលេខាប្រធានផ្នែកបច្ចេកទេស និងពុំបញ្ជាក់សម្ភារប្រើប្រាស់ មាន ៦០ បណ្តាញ

២. ពុំមានហត្ថលេខាប្រធានផ្នែកបច្ចេកទេស, ថ្ងៃចុះវាស់វែងខុសពីថ្ងៃណាត់ចុះវាស់វែង និងប្រើប្រាស់សម្ភារខុសពីកំណត់បង្ហាញ មាន ៣០៦ បណ្តាញ

ប្រការនេះ អនុវត្តពុំទាន់សមស្របដោយការបំពេញព័ត៌មានក្នុងការស្នើសុំតបណ្តាញថ្មីរបស់អតិថិជន ពុំទាន់មានភាពត្រឹមត្រូវ និងច្បាស់លាស់។

ករណីនេះ នាំឱ្យ៖

- ការងារដាក់បំពង់ជាក់ស្តែង ពុំត្រឹមត្រូវតាមកំណត់បង្ហាញ
- មានការយឺតយ៉ាវក្នុងការតបណ្តាញជូនអតិថិជន (ដោយក្រុមជាងត្រូវយកសម្ភារមកផ្លាស់ប្តូរ)
- ការកត់ត្រារបាយការណ៍ ពុំសមស្របតាមបែបបទរដ្ឋបាល។

មន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវ៖

- ធ្វើការផ្ទៀងផ្ទាត់រាល់ការយកសម្ភារទៅប្រើប្រាស់ និងបរិយាយឱ្យត្រូវគ្នាជាមួយនឹងគំនូសប្លង់នៅក្នុងកំណត់បង្ហាញ
- ធ្វើការកត់ត្រាព័ត៌មានឱ្យបានច្បាស់ព័ត៌មានស្តីពីការតបណ្តាញ ដើម្បីឱ្យរបាយការណ៍មានភាពត្រឹមត្រូវជាមួយការអនុវត្តន៍ជាក់ស្តែង ដើម្បីឱ្យរបាយការណ៍មានភាពពេញលេញ។ **កម្រិតហានិភ័យ ទាប។**

*ជាការឆ្លើយតប :*

*១. ពុំមានហត្ថលេខា និងពុំបញ្ជាក់ពីសម្ភារ ដោយសារការងារនេះទើបតែមានការណែនាំបន្ថែមពីថ្នាក់ដឹកនាំនាយកដ្ឋានឱ្យចាប់អនុវត្ត ទើបធ្វើឱ្យមានការខ្វះចន្លោះក្នុងការចុះហត្ថលេខាទទួលស្គាល់ និង*

*សរសេរបញ្ជាក់ពីសម្ភារប្រើប្រាស់។ ករណីនេះ ការិយាល័យនឹងធ្វើការកែលម្អលើចំណុចខ្វះខាតខាងលើឱ្យបានប្រសើរតាមការណែនាំរបស់សវនករ។*

*២. ពុំមានហត្ថលេខា, ថ្ងៃចុះវាស់វែង ខុសពីថ្ងៃណាត់ចុះវាស់វែង និងប្រើប្រាស់សម្ភារខុសពីកំណត់បង្ហាញ៖*

- *ថ្ងៃចុះវាស់វែងខុសពីថ្ងៃណាត់ចុះវាស់វែង ៖ ករណីនេះ និយោជិតផ្នែកបញ្ចូលទិន្នន័យបោះពុម្ពកំណត់បង្ហាញមានការភាន់ច្រលំបញ្ចូលកាលបរិច្ឆេទខុសពី ថ្ងៃ ខែ ចុះវាស់វែងជាក់ស្តែង។ ការិយាល័យនឹងធ្វើការណែនាំដល់មន្ត្រី-និយោជិតទទួលបន្ទុក ឱ្យយកចិត្តទុកដាក់មិនឱ្យមានកំហុសឆ្គងបន្តទៀត។*
- *ការប្រើប្រាស់សម្ភារខុសពីកំណត់បង្ហាញ ៖ បន្ទាប់ពីបានប្រគល់គំនូសប្លង់ជូនក្រុមជាងតបណ្តាញដើម្បីបើកសម្ភារតបណ្តាញជូនអតិថិជន ប៉ុន្តែពេលក្រុមជាងចុះអនុវត្តតបណ្តាញជូនអតិថិជនជាក់ស្តែងដល់ទីតាំងឃើញថា ទីតាំងមួយចំនួនមានបំពង់ចែកចាយខុសពីគំនូសប្លង់ក្នុងប្រព័ន្ធ **KIS** ដូចនេះ ក្រុមជាងត្រូវយកសម្ភារដែលបានបើករួចយកមកផ្លាស់ប្តូរជាមួយផ្ទាំឃ្លាំងឱ្យត្រូវទៅតាមទំហំបំពង់ និងសម្ភារជាក់ស្តែង (ដោយមានការសរសេរបញ្ជាក់បន្ថែមពីផ្ទាំឃ្លាំងលើកំណត់បង្ហាញ) ហេតុនេះ ទើបធ្វើឱ្យសវនករមើលឃើញថាការប្រើសម្ភារខុសពីកំណត់បង្ហាញ។ ការិយាល័យនឹងណែនាំឱ្យមានការកែសម្រួលលើកំណត់បង្ហាញ និងចុះហត្ថលេខាទទួលស្គាល់ពីក្រុមជាងតបណ្តាញ តាមការណែនាំរបស់សវនករ។*

*ការិយាល័យនឹងចាប់ផ្តើមអនុវត្ត ពីខែមីនា ឆ្នាំ២០២៣ នេះតទៅ។*

## ២- ការងារចុះផ្អាកការផ្គត់ផ្គង់ទឹកបណ្តោះអាសន្ន អនុវត្តពុំទាន់មានភាពច្បាស់លាស់ ដោយរក្សាគម្លាតរយៈពេលយូរ

ការផ្អាកការផ្គត់ផ្គង់ទឹកជាបណ្តោះអាសន្នរបស់អតិថិជន គឺជាជំហានដំបូងដែលតម្រូវឱ្យភាគីប្រើប្រាស់ទឹកចូលមកដោះស្រាយបញ្ហាបំណុលថ្លៃប្រើប្រាស់ទឹកឱ្យស្របទៅនឹងកិច្ចសន្យាជាវទឹក។ ក្នុងឆ្នាំ២០២២ សវនកម្មបានធ្វើការពិនិត្យការងារចុះផ្អាកការផ្គត់ផ្គង់ទឹកបណ្តោះអាសន្ន របស់ការិយាល័យចំណូលចំការមន, ការិយាល័យចំណូលពោធិ៍សែនជ័យ និងការិយាល័យចំណូលច្បារអំពៅ ឃើញថា ការងារចុះផ្អាកការផ្គត់ផ្គង់ទឹកបណ្តោះអាសន្នរបស់ការិយាល័យចំណូលពោធិ៍សែនជ័យ និងការិយាល័យចំណូលច្បារអំពៅ អនុវត្តពុំទាន់មានភាពច្បាស់លាស់ ដោយមានរយៈពេលយូរក្នុងការអនុវត្ត (ចន្លោះពី ៣០ ថ្ងៃ ទៅ ៥៨៣ ថ្ងៃ)៖

| ចំណូល | អតិថិជនសរុប | អតិ. ផ្អាកការផ្គត់ផ្គង់ទឹកសរុប | អតិ. ផ្អាកការផ្គត់ផ្គង់ទឹកក្នុងឆ្នាំ ២០២២ | អតិ. ជំពាក់ថ្លៃប្រើប្រាស់ទឹក |
|---|---|---|---|---|
| ពោធិ៍សែនជ័យ | ៧០.៩៦១ | ៣.៣៥៤ | ១.២៨០ | ៣២៦ |
| ច្បារអំពៅ | ៤៤.៤៣៩ | ១.៤០៤ | ៧២២ | ១១៨ |

ប្រការនេះ អនុវត្តពុំទាន់មានភាពច្បាស់លាស់ និងត្រឹមត្រូវ។

ករណីនេះ នាំឱ្យបរិមាណទឹកដែលអតិថិជនប្រើប្រាស់រួច បន្សល់ទុកច្រើន។

មន្ត្រីទទួលបន្ទុកផ្នែកបិទទឹកនៃការិយាល័យទំនាក់ទំនងអតិថិជន ត្រូវរៀបចំបង្កើតកម្មវិធីអនុវត្តការងារនេះឱ្យមានស្តង់ដាត្រឹមត្រូវ និងរំលេចរយៈពេលកំណត់ដែលត្រូវចុះទៅធ្វើការផ្អាកផ្គត់ផ្គង់ទឹកជាបណ្តោះអាសន្ន របស់អតិថិជន ក្នុងករណីមិនអាចអនុវត្តបានការចុះផ្អាកការផ្គត់ផ្គង់ទឹកបាន ត្រូវស្នើសុំគោលការណ៍ទៅ **ឯកឧត្តមអគ្គនាយក** សម្រាប់អនុវត្តការងារនេះឱ្យបានត្រឹមត្រូវ និងមានតម្លាភាព។ **កម្រិតហានិភ័យ មធ្យម។**

*ជាការឆ្លើយតប : ដោយសារជាទីតាំងផ្ទះចាក់សោរពុំមានមនុស្សរស់នៅ និងជាផ្លូវបេតុង។*

*ការិយាល័យនឹងចាប់ផ្តើមអនុវត្ត ពីខែមីនា ឆ្នាំ២០២៣ នេះតទៅ។*

## ៣- របាយការណ៍កែសម្រួលទីតាំងនាឡិកា (លើក/រំកិល) មានការស្ទួនគ្នា

ក្នុងឆ្នាំ២០២២ ការងារកែសម្រួលទីតាំងនាឡិកា (លើក/រំកិល) មានចំនួន ២.៣៨៨ នាឡិកា សវនករពិនិត្យឃើញថា ការកត់ត្រាស្ទួនគ្នា មានចំនួន ១៤៥ ករណី ក្នុងនោះ៖

- ស្ទួន ០២ ដង មានចំនួន ១៤០ ករណី
- ស្ទួន ០៣ ដង មានចំនួន ០៥ ករណី

ប្រការនេះ អនុវត្តពុំទាន់មានភាពត្រឹមត្រូវ និងការរៀបចំរបាយការណ៍ពុំមានភាពច្បាស់លាស់។

ករណីនេះ នាំឱ្យការគ្រប់គ្រងឯកសារ ពុំមានភាពច្បាស់លាស់តាមបែបបទរដ្ឋបាល។

មន្ត្រីទទួលបន្ទុក ត្រូវពិនិត្យ, ផ្ទៀងផ្ទាត់ និងតាមដានឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ មុននឹងបញ្ចូលទៅក្នុងរបាយការណ៍។ **កម្រិតហានិភ័យ ទាប**។

*ជាការឆ្លើយតប : ដោយសារការអនុវត្តការងារមានច្រើន ដូចនេះ ធ្វើឱ្យផ្នែកនាឡិកាមានការភាន់ច្រឡំដោយថតចម្លងកំណត់ហេតុស្ទួនភ្ជាប់ធ្វើរបាយការណ៍ ហើយកំណត់ហេតុដើមផ្នែកយកទៅទូទាត់ជាមួយឃ្លាំងសម្ភារ។ បច្ចុប្បន្នបានកែប្រែទម្រង់ដោយឱ្យផ្នែកប្រគល់កំណត់ហេតុដើមមកផ្នែកនាឡិកា ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ដកស្តុកជាមួយសំណើចូលឱ្យបានត្រឹមត្រូវ ទើបដាក់បញ្ចូលជារបាយការណ៍ប្រចាំខែ។*

*ការិយាល័យនឹងចាប់ផ្តើមអនុវត្ត ពីខែមីនា ឆ្នាំ២០២៣ នេះតទៅ។*

## ៤- ការងារលើក និងរំកិលនាឡិកាទឹករបស់អតិថិជន អនុវត្តពុំទាន់មានភាពត្រឹមត្រូវ

ក្នុងឆ្នាំ២០២២ ការិយាល័យទំនាក់ទំនងអតិថិជន បានលើក/រំកិលនាឡិកា ចំនួន ២.៣៨៨ នាឡិកា ក្នុងនោះ ៖

- ចំណាយរបស់អតិថិជន ចំនួន ៨២៧ នាឡិកា
- ចំណាយរបស់អង្គភាព ចំនួន ១.៥៦១ នាឡិកា

សវនកម្ម បានជ្រើសយក ចំនួន ៥២២ នាឡិកា៖

- ចំណាយរបស់អតិថិជន ចំនួន ១៥១ នាឡិកា
- ចំណាយរបស់អង្គភាព ចំនួន ៣៧១ នាឡិកា

ក្នុងនោះពិនិត្យឃើញថា ការបំពេញឯកសារសម្រាប់របាយការណ៍ដែលអតិថិជនត្រូវបង់ប្រាក់ ពុំទាន់មានភាពពេញលេញគ្រប់គ្រាន់៖

១. ពុំមានការឯកភាពប្រធាននាយកដ្ឋាននៅលើកំណត់បង្ហាញស្នើសុំកែសម្រួលទីតាំង មាន ០៩ នាឡិកា

២. ពុំមានហត្ថលេខាអ្នកទទួលខុសត្រូវរបស់ការិយាល័យទំនាក់ទំនងអតិថិជន មាន ៣៩ នាឡិកា

៣. ពុំមានចុះកាលបរិច្ឆេទពេលអនុវត្តការងារ មាន ៣២ នាឡិកា

៤. ពុំមានហត្ថលេខាអ្នកទទួលខុសត្រូវ និងពុំមានចុះកាលបរិច្ឆេទបញ្ចប់ការងារ មាន ១៤ នាឡិកា

ប្រការនេះ អនុវត្តពុំទាន់សមស្របតាមបែបបទរដ្ឋបាល។

ករណីនេះ នាំឱ្យឯកសារពុំច្បាស់លាស់ និងពិបាកក្នុងការតាមដានការងារនៅពេលក្រោយ។

មន្ត្រីទទួលបន្ទុក ត្រូវធ្វើការកត់ត្រាព័ត៌មានឱ្យបានច្បាស់ ដើម្បីឱ្យរបាយការណ៍មានភាពត្រឹមត្រូវ និងពេញលេញ មុននឹងចងក្រងរក្សាទុកជាឯកសារ។ **កម្រិតហានិភ័យ ទាប**។

*ជាការឆ្លើយតប :*

- *ករណីទី១ អនុវត្តតាម SOP រាល់ទីតាំងដែលមានប្រវែងក្រោម ៥ ម៉ែត្រ អាចធ្វើការចុះហត្ថលេខាត្រឹមប្រធានការិយាល័យ។ ក្នុងចុងឆ្នាំ ២០២២ ទទួលបានការណែនាំពីលោកប្រធាននាយកដ្ឋានអាជីវកម្ម គ្រប់ការងារលើក/រំកិលនាឡិកាទាំងអស់ ត្រូវធ្វើការចុះហត្ថលេខាដល់លោកប្រធាននាយកដ្ឋាន និងកំពុងកែ SOP ។*

- *ករណីទី២, ៣ និង៤ ជាងនាឡិកា មានការខ្វះចន្លោះក្នុងការបំពេញឯកសារ ពេលចុះអនុវត្តការងារ និងផ្នែកបញ្ចូលកំណត់ហេតុ ពុំបានពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ។*
- *បច្ចុប្បន្នបានកែសម្រួលតាមអនុសាសន៍របស់សវនករ។*

*ការិយាល័យនឹងចាប់ផ្តើមអនុវត្ត ពីខែមីនា ឆ្នាំ២០២៣ នេះតទៅ។*

## ៥- ការប្តូរនាឡិកាខូច ត្រូវបានប្តូរថ្មី អនុវត្តខុសពីបែបបទស្តង់ដានីតិវិធីប្រតិបត្តិការការគ្រប់គ្រងនាឡិកាទឹក

ក្នុងឆ្នាំ២០២២ ការិយាល័យទំនាក់ទំនងអតិថិជន បានធ្វើការដោះដូរនាឡិកាខូចជូនអតិថិជន ក្នុងនោះ សវនកម្ម បានជ្រើសយករបាយការណ៍មកធ្វើការពិនិត្យ ចំនួន ០៥ ខែ (កក្កដា, សីហា, កញ្ញា, តុលា និងវិច្ឆិកា) សរុបចំនួន ១.៧៦៨ នាឡិកា ឃើញថា ការចុះអនុវត្តនៅមានភាពយឺតយ៉ាវ ខុសពីបែបបទស្តង់ដានីតិវិធីប្រតិបត្តិការ ដែលបានកំណត់មាន៖

| | | | |
|---|---|---|---|
| ១. នាឡិកាខូច ទឹកមិនចេញ | មាន | ២១ | នាឡិកា |
| ២. នាឡិកាខូច ទឹកនៅចេញ | មាន | ១៩៥ | នាឡិកា |

ប្រការនេះ អនុវត្តពុំទាន់បានសមស្របទៅលើការគ្រប់គ្រងនាឡិកាទឹក ត្រង់៖ **៤.៣ នាឡិកាខូច** ចំណុច **ខ. បែបបទ- ក្រោយពេលទទួលព័ត៌មាន ការិយាល័យទំនាក់ទំនងអតិថិជន ត្រូវចាត់ចែងឱ្យជាងនាឡិកាទៅពិនិត្យ និងដោះដូរនាឡិកាភ្លាមៗមិនឱ្យលើសពីបី (០៣) ម៉ោង ករណីនាឡិកាខូចទឹកមិនចេញ ឬយ៉ាងយូរបី (០៣) ថ្ងៃការងារ ករណីនាឡិកាខូចតែទឹកនៅចេញ ដោយសហការជាមួយក្រុមគ្រប់គ្រងតំបន់ ឬក្រុមប្រចាំការជួសជុលទឹកធ្លាយ នៃការិយាល័យគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក។**

ករណីនេះ នាំឱ្យ៖

១. អនុវត្តផ្ទុយពីគោលការណ៍ដែលបានកំណត់

២. មានភាពថ្នាំងថ្នាក់ពីអតិថិជន។

មន្ត្រីទទួលបន្ទុក ត្រូវយកចិត្តទុកដាក់អនុវត្តការងាររបស់ខ្លួនឱ្យស្របទៅតាមស្តង់ដានីតិវិធីប្រតិបត្តិការ SOP ដែលបានកំណត់ ឬធ្វើបច្ចុប្បន្នភាពទៅលើ SOP ឱ្យស្របទៅនឹងការអនុវត្តន៍ជាក់ស្តែង។ **កម្រិតហានិភ័យ ទាប។**

*ជាការឆ្លើយតប :*

- *ការដោះដូរនាឡិកាខូចមានភាពយឺតយ៉ាវ មូលហេតុពេលជាងចុះទៅមិនជួបម្ចាស់ផ្ទះ (ផ្ទះចាក់សោរ) ឬអតិថិជនមិនសហការ ត្រូវប្រើពេលវេលា ដើម្បីធ្វើលិខិតអញ្ជើញអតិថិជន*
- *ការងារសហការណ៍ជាមួយក្រុមគ្រប់គ្រងតំបន់ ឬការិយាល័យពាក់ព័ន្ធអនុវត្ត ទីតាំងប្រើប្រាស់ទឹកច្រើន, សង្ស័យមានបទល្មើស និងនាឡិកាទំហំ ៤០ ម.ម ឡើង (កំពុងធ្វើបច្ចុប្បន្នភាព SOP)*
- *បច្ចុប្បន្នបានធ្វើការកែប្រែ និងទទួលយកអនុសាសន៍របស់សវនករ។*

*គ្រប់ចំណុចខ្វះចន្លោះខាងលើ ការិយាល័យនឹងចាប់ផ្តើមអនុវត្ត ពីខែមីនា ឆ្នាំ២០២៣ នេះតទៅ។*

*សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានផ្ញើរបាយការណ៍កែលម្អ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣។*

## ii. នាយកដ្ឋានផែនការ និងគម្រោង

- លើកគម្រោងសំណង់ស៊ីវិល មានចំនួន ២១ គម្រោង៖

| | | | |
|---|---|---|---|
| - គម្រោងសំណង់ស៊ីវិលក្នុងផែនការ | ចំនួន | ០៦ | គម្រោង |
| - គម្រោងសំណង់ស៊ីវិលផែនការកែតម្រូវ | ចំនួន | ០៣ | គម្រោង |
| - គម្រោងសំណង់ស៊ីវិលក្រៅផែនការ | ចំនួន | ១១ | គម្រោង |
| - គម្រោងមូលនិធិបម្រើផលប្រយោជន៍សង្គម | ចំនួន | ០១ | គម្រោង |

- ទទួលសំណើសុំសិទ្ធជាវទឹកលើសស្តង់ដា ឬគោលការណ៍កំណត់សិទ្ធ របស់ការិយាល័យបណ្តាញចូលផ្ទះ បាន ចំនួន ៤៨៣ សំណើ។

- លើកគម្រោងក្នុងផែនការ (Job Budget) ចំនួន ១.០៩៨ គម្រោង
- លើកគម្រោងបង់វិនិយោគ (Quotation) ចំនួន ៦៩២ គម្រោង

នាយកដ្ឋាន អនុវត្តការងារបានល្អ និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះ ក៏នៅមានចំណុចខ្វះចន្លោះមួយចំនួនដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

## ១- សៀវភៅចុះលេខលិខិតចេញ-ចូល របស់នាយកដ្ឋានមានស្ទួន និងរំលងលេខ

សវនកម្មផ្ទៃក្នុង បានធ្វើការពិនិត្យសៀវភៅចុះលេខលិខិតចេញ-ចូល របស់នាយកដ្ឋានផែនការ និង គម្រោង ក្នុងឆ្នាំ២០២២ ពិនិត្យឃើញថា៖

- លិខិតចេញ
  - មានចុះស្ទួនលេខ ១៨១ និង ២៥១ (ក្បាលទី១ ចាប់ពីលេខ ០០១ - ៣៨០)
  - មានចុះស្ទួនលេខ ៦៧៥ (ក្បាលទី២ ចាប់ពីលេខ ៣៨១ - ៦៧៧)
  - ចុះលេខលិខិតត្រលប់ក្រោយ ចំនួន ៤៩ លេខ (ដល់លេខ ២៩៣ ត្រលប់មកចុះលេខ ២៤៤ វិញ)
- លិខិតចូល
  - មានចុះរំលងលេខ - ២០៦ (ក្បាលទី១ ចាប់ពីលេខ ០០១ - ៤៤៥)
    - ៧០៧ (ក្បាលទី២ ចាប់ពីលេខ ៤៤៦ - ៨៧៣)
  - មានចុះស្ទួនលេខ ៤២៦ (ក្បាលទី១ ចាប់ពីលេខ ០០១ - ៤៤៥)

ប្រការនេះ អនុវត្តពុំទាន់បានសមស្របក្នុងការគ្រប់គ្រងលេខលិខិតចេញ-ចូល។

ករណីនេះ នាំឱ្យការគ្រប់គ្រងលិខិតចេញ-ចូល ពុំមានភាពច្បាស់លាស់។

មន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវយកចិត្តទុកដាក់អនុវត្តការងាររបស់ខ្លួន ក្នុងការគ្រប់គ្រងឯកសារ លិខិតចេញ-ចូលឱ្យបានត្រឹមត្រូវ និងត្រូវចុះលេខទៅតាមលំដាប់ (ស្វ៊ីត)។ **កម្រិតហានិភ័យ ទាប។**

*ជាការឆ្លើយតប : មន្ត្រីទទួលបន្ទុកការងារនេះព្រមទទួលស្គាល់កំហុសឆ្គង និងខិតខំយកចិត្តទុកដាក់អនុវត្ត ការងាររបស់ខ្លួនឱ្យបានល្អប្រសើរ ដោយសារខ្វះកម្លាំងក្នុងការបំពេញការងារ ម្យ៉ាងទៀតបានស្នើសុំកម្លាំងបន្ថែមក្នុង ឆ្នាំ២០២៣ អាចនឹងទទួលបាននៅចុងឆ្នាំ២០២៣ ដូច្នេះនឹងអនុវត្តឱ្យបានត្រឹមត្រូវចាប់ផ្តើមពី ឆ្នាំ២០២៤ តទៅ។*

## ២- ការអនុវត្តន៍គម្រោងសំណង់ស៊ីវិល អនុវត្តពុំស្របតាមស្តង់ដានីតិវិធីប្រតិបត្តិការ ការងារបច្ចេកទេស និងគម្រោង

ក្នុងឆ្នាំ២០២២ ការិយាល័យគ្រប់គ្រងគម្រោង បានអនុវត្តការងារសំណង់ស៊ីវិល ក្នុងផែនការ និងក្រៅ ផែនការ ចំនួន ២១ គម្រោង ក្នុងនោះ៖

| | | | |
|---|---|---|---|
| ១- គម្រោងសំណង់ស៊ីវិលក្នុងផែនការ | មាន | ០៦ | គម្រោង |
| ២-គម្រោងសំណង់ស៊ីវិលផែនការកែតម្រូវ | មាន | ០៣ | គម្រោង |
| ៣-គម្រោងសំណង់ស៊ីវិលក្រៅផែនការ | មាន | ១១ | គម្រោង |
| ៤- គម្រោងមូលនិធិបម្រើផលប្រយោជន៍សង្គម | មាន | ០១ | គម្រោង |

ក្នុងនោះសវនកម្មបានជ្រើសយក ចំនួន ១៣ គម្រោង មកធ្វើការពិនិត្យឃើញថា ការបរិយាយទំហំការងារ និងបទដ្ឋានបច្ចេកទេស ដែលត្រូវអនុវត្ត ពុំមានហត្ថលេខា **ឯកឧត្តមអគ្គនាយក**។

ប្រការនេះ អនុវត្តពុំទាន់បានសមស្របទៅនឹងស្តង់ដានីតិវិធីប្រតិបត្តិការការងារបច្ចេកទេស និងគម្រោង ត្រង់ចំណុច **៤.៣.៣.១.១០ លក្ខណៈបច្ចេកទេសសាងសង់ និងជួសជុលសំណង់ស៊ីវិល** " លក្ខណៈ បច្ចេកទេស និងជួសជុលសំណង់ស៊ីវិល ដែលបានប្រើប្រាស់នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺជាឯកសារ ផ្លូវការ។ រាល់ការធ្វើបច្ចុប្បន្នភាពចាំបាច់ត្រូវតែសុំការឯកភាពពីសំណាក់**ថ្នាក់ដឹកនាំ** "។

**គំរូបទដ្ឋានបច្ចេកទេសសំណង់ស៊ីវិល (ឧបសម្ព័ន្ធទី ១២ បានឃើញ និងឯកភាព អគ្គនាយក)**

ករណីនេះ នាំឱ្យការអនុវត្តន៍ការងារ ពុំស្របតាមបែបបទរដ្ឋបាល។

មន្ត្រីទទួលបន្ទុកការងារ ត្រូវយកចិត្តទុកដាក់អនុវត្តការងាររបស់ខ្លួនឱ្យស្របទៅតាមស្តង់ដានីតិវិធីប្រតិបត្តិការការងារ SOP ដែលបានកំណត់ ឬត្រូវធ្វើបច្ចុប្បន្នភាពទៅលើ SOP ឱ្យស្របទៅនឹងការអនុវត្តន៍ជាក់ស្តែង។ **កម្រិតហានិភ័យ ទាប។**

*ជាការឆ្លើយតប : ការិយាល័យបានរៀបចំកែសម្រួល SOP ថ្មីរួចហើយដែរ ដោយបានទទួលស្គាល់ត្រឹមថ្នាក់អគ្គនាយករងទទួលបន្ទុកនឹងគ្រោងដាក់ឆ្លងការសម្រេចពី **ឯកឧត្តមអគ្គនាយក** ក្នុងខែតុលា ឆ្នាំ២០២៣។*

## ៣- ការឆ្លើយតបរបស់ការិយាល័យសិក្សាគម្រោង ទៅការិយាល័យបណ្តាញចូលផ្ទះ ពុំទាន់មានភាពត្រឹមត្រូវ (យោងកាលបរិច្ឆេទរបស់ភ្នាក់ងារចុះវាស់ ជាលិខិតរបស់ការិយាល័យបណ្តាញចូលផ្ទះ)

ក្នុងឆ្នាំ២០២២ ការិយាល័យសិក្សាគម្រោង បានទទួលសំណើសុំសិទ្ធជាវទឹកលើសស្តង់ដា ឬគោលការណ៍កំណត់សិទ្ធរបស់ការិយាល័យបណ្តាញចូលផ្ទះ បានចំនួន ៤៨៣ សំណើ។ សវនកម្មបានជ្រើសយក ចំនួន ២៦៤ សំណើ មកពិនិត្យឃើញថា ការកត់ត្រាកាលបរិច្ឆេទពុំទាន់ត្រឹមត្រូវ ដោយយកកាលបរិច្ឆេទរបស់ភ្នាក់ងារចុះវាស់មកធ្វើជាកាលបរិច្ឆេទយោង។

ប្រការនេះ អនុវត្តពុំទាន់សមស្រប ដោយការបំពេញព័ត៌មាន ពុំទាន់មានភាពត្រឹមត្រូវ។

ករណីនេះ នាំឱ្យការកត់ត្រា ពុំសមស្របតាមការអនុវត្តន៍ជាក់ស្តែង និងបែបបទរដ្ឋបាល។

មន្ត្រីទទួលបន្ទុកការងារ ត្រូវធ្វើការពិនិត្យទៅលើព័ត៌មានដែលបានទទួល។ **កម្រិតហានិភ័យ ទាប។**

*ជាការឆ្លើយតប : យើងខ្ញុំនឹងធ្វើការកែលម្អ នៃកំហុសខាងលើឱ្យបានត្រឹមត្រូវតាមបែបបទរដ្ឋបាល។*

*យើងខ្ញុំនឹងធ្វើការកែសម្រួលឡើងវិញ បន្ទាប់ពីទទួលនូវរបាយការណ៍សវនកម្ម។*

## ៤- ការលើកគម្រោង អនុវត្តពុំទាន់បានសមស្រប ដោយមានលេខកូដគម្រោងស្ទួនគ្នា

នាយកដ្ឋានផែនការ និងគម្រោង មានតួនាទីតាមដានត្រួតពិនិត្យរាល់សកម្មភាពការងារអនុវត្តធៀបនឹងផែនការ។ សវនកម្មផ្ទៃក្នុង បានធ្វើការពិនិត្យគម្រោងដែលបានលើកក្នុងផែនការ និងការអនុវត្តន៍ការងារ ឃើញថាការលើកគម្រោងមានលេខស្ទួនគ្នា ចំនួន ១៦ គម្រោង។

ប្រការនេះ អនុវត្តពុំទាន់បានសមស្របទៅនឹងស្តង់ដានីតិវិធីប្រតិបត្តិការការងារបច្ចេកទេស និងគម្រោង ត្រង់ចំណុច **៤.២.២.៣ ប្រការគួរជៀសវាង** " គម្រោងនីមួយៗ ត្រូវមានលេខកូដគម្រោង និងលេខកូដឯកសារដាច់ខាតមិនត្រូវឱ្យស្ទួន ឬជាន់គ្នាជាមួយគម្រោងដែលបានធ្វើរួចហើយជាដាច់ខាត " ។

ករណីនេះ នាំឱ្យការលើកគម្រោងពុំមានប្រសិទ្ធភាព។

មន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវធ្វើការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងការពិនិត្យ និងតាមដានលេខកូដគម្រោងឱ្យបានត្រឹមត្រូវ មុននឹងធ្វើការលើកគម្រោង។ **កម្រិតហានិភ័យ ទាប។**

*ជាការឆ្លើយតប : ករណីពិនិត្យឃើញនូវគម្រោង ចំនួន ១៦ គម្រោង ជាមួយប្រព័ន្ធឌីណាម៉ិចឃើញថាពុំមានការស្ទួនលេខកូដនោះទេ ដោយកំហុសទាំងនោះជាការកត់ត្រាទិន្នន័យនៅក្នុងកម្មវិធី Microsoft Excel ប៉ុណ្ណោះ ពុំប៉ះពាល់ជាមួយនឹងនីតិវិធីអនុវត្តការងារលើកគម្រោងនោះទេ។*

*យើងខ្ញុំនឹងធ្វើការកែសម្រួលនូវកំហុសនេះ បន្ទាប់ពីបានទទួលនូវរបាយការណ៍សវនកម្ម។*

## ៥- ការកត់ត្រាគម្រោងដែលបានលើក និងការអនុវត្តន៍របស់សាខាសេវាកម្មទឹកស្អាត និងអនាម័យ ពុំទាន់ស្របគ្នា

ក្នុងឆ្នាំ២០២២ នាយកដ្ឋានផែនការ និងគម្រោង បានលើកគម្រោងក្នុងផែនការ (Job Budget) ចំនួន ១.០៩៨ គម្រោង ក្នុងនោះគម្រោងដែលបានប្រគល់ជូន៖ 847

- សាខាសេវាកម្មទឹកស្អាត និងអនាម័យ (ភ្នំពេញ និងក្រុងតាខ្មៅ) ចំនួន ៨៩៨ គម្រោង
- សាខាសេវាកម្មទឹកស្អាត និងអនាម័យ (ត្បូងឃ្មុំ) ចំនួន ៦៣ គម្រោង
- នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក (ភ្នំពេញ និងក្រុងតាខ្មៅ) ចំនួន ១០៦ គម្រោង
- នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក (ត្បូងឃ្មុំ) ចំនួន ៣១ គម្រោង

សវនកម្មផ្ទៃក្នុង ពិនិត្យឃើញថានាយកដ្ឋានផែនការ និងគម្រោង ពុំបានកត់ត្រាបញ្ចូលក្នុងតារាងតាមដាន ចំនួន ១២៥ គម្រោង នៃ ១.០៩៨ គម្រោង។

ប្រការនេះ អនុវត្តពុំទាន់បានសមស្របទៅនឹងស្តង់ដានីតិវិធីប្រតិបត្តិការការងារផែនការ និងហិរញ្ញប្បទាន ត្រង់ចំណុច **៤.១.១.១ កំណត់ទីតាំងពង្រីកបណ្តាញចែកចាយទឹក** " ការិយាល័យសិក្សាគម្រោង ចំណុះឱ្យនាយកដ្ឋានផែនការ និងគម្រោង ត្រូវចុះអង្កេតទីតាំង ត្រូវវិនិយោគបណ្តាញចែកចាយទឹក កសាងបញ្ជីសម្ភារបំពង់ទឹក-សម្ភារតភ្ជាប់ និងប្លង់ទីតាំងត្រូវវិនិយោគពង្រីកបណ្តាញចែកចាយទឹក។ **នាយកដ្ឋានផែនការ និងគម្រោង ត្រូវសហការជាមួយសាខាសេវាកម្មទឹកស្អាត និងអនាម័យ ដើម្បីឱ្យប្រាកដថាផែនការពង្រីកបណ្តាញចែកចាយទឹកនេះអាចអនុវត្តបានតាមផែនការ " ។**

ករណីនេះ ការកត់ត្រាគម្រោងពង្រីកបណ្តាញចែកចាយទឹក ពុំបានច្បាស់លាស់។

មន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវធ្វើការសហការជាមួយសាខាសេវាកម្មទឹកស្អាត និងអនាម័យ ក្នុងការកត់ត្រាការតាមដានការងារអនុវត្តន៍គម្រោងឱ្យបានត្រឹមត្រូវ។ **កម្រិតហានិភ័យ ទាប។**

*ជាការឆ្លើយតប : ចំពោះគម្រោង ចំនួន ១២៥ គម្រោង ជាក់ស្តែងយើងបានបញ្ជូនគម្រោង ទៅសាខាសេវាកម្មទឹកស្អាត និងអនាម័យ រួចហើយ ប៉ុន្តែគ្រាន់តែការផ្តល់ទិន្នន័យជា Soft Copy ជូនទៅសវនកម្មមានការខ្វះចន្លោះ។ យើងខ្ញុំនឹងធ្វើការកែសម្រួលឡើងវិញ បន្ទាប់ពីទទួលនូវរបាយការណ៍សវនកម្ម។*

*សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានផ្ញើរបាយការណ៍កែលម្អ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣។*

### iii. សាខាសេវាកម្មទឹកស្អាត និងអនាម័យ

ក្នុងឆ្នាំ២០២២ សាខាសេវាកម្មទឹកស្អាត និងអនាម័យ បានអនុវត្ត៖

- ការងារក្នុងអង្គភាព
  - ការងារដាក់បំពង់ ចំនួន ១.៣៥៨ គម្រោង
  - ការងារដាក់លូ ចំនួន ០១ គម្រោង
- ការផ្តល់សេវាតាមបណ្តាខេត្ត
  - ខេត្តសៀមរាប
  - ខេត្តត្បូងឃ្មុំ
  - ខេត្តកំពង់ធំ
  - ខេត្តពោធិ៍សាត់

សាខាសេវាកម្មទឹកស្អាត និងអនាម័យ អនុវត្តការងារបានល្អ និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

**ការអនុវត្តន៍គម្រោងរបស់សាខាសេវាកម្មទឹកស្អាត និងអនាម័យ អនុវត្តមុនលើក/ទទួល បានគម្រោង**

ក្នុងឆ្នាំ២០២២ សាខាសេវាកម្មទឹកស្អាត និងអនាម័យ បានអនុវត្តគម្រោងនៅក្នុងរាជធានីភ្នំពេញ ចំនួន ១.៣៥៨ គម្រោង។ ក្នុងនោះសវនកម្មផ្ទៃក្នុង បានពិនិត្យឃើញថា សាខាសេវាកម្មទឹកស្អាត និងអនាម័យ បានអនុវត្តមុនលើក/ទទួលបានគម្រោង ចំនួន ៧២ គម្រោង ស្មើនឹង ៥.៣% មាន៖

- គម្រោង ក្នុងផែនការ (Job Budget) មាន ៦៧ គម្រោង
- គម្រោង បង់វិនិយោគ (Quotation) មាន ០៥ គម្រោង 847

ប្រការនេះ អនុវត្តពុំទាន់បានសមស្របទៅនឹងស្តង់ដានីតិវិធីប្រតិបត្តិការការងារបច្ចេកទេស និងគម្រោង SOP ត្រង់ចំណុចៈ

- **៤.២.១.២ គូរប្លង់លំអិត** ការិយាល័យបច្ចេកទេស និងគម្រោងបានគូរប្លង់តាមការកំណត់ទំហំរបស់ការិយាល័យគ្រប់គ្រងប្លង់ និងព័ត៌មានភូមិសាស្ត្រ ដោយមានការឯកភាពពីថ្នាក់ដឹកនាំ។
- **៤.២.២.២ ទំហំការងារនៃការលើកគម្រោង ត្រូវរៀបចំធ្វើជា** បញ្ជីរួមជាមួយ (Recap) និងធ្វើរបាយការណ៍នូវចំនួនគម្រោងដែលបានអនុវត្ត ដោយបរិយាយនូវមតិជំនាញក្នុងកំណត់បង្ហាញអំពីគោលបំណងនៃការបង្កើតគម្រោងទាំងនេះ រួចបញ្ជូនទៅថ្នាក់ដឹកនាំដើម្បីពិនិត្យ-សម្រេច **បន្ទាប់មកបញ្ជូនទៅការិយាល័យអនុវត្តសំណង់ទូទៅ។**

ករណីនេះ នាំឱ្យការបើកសម្ភារយកទៅប្រើប្រាស់ ពុំស្របតាមលក្ខណៈបច្ចេកទេស។

រាល់គម្រោងដែលបានអនុវត្តមុន លើកឬទទួលបានគម្រោង សាខាសេវាកម្មទឹកស្អាត និងអនាម័យ ត្រូវសហការជាមួយនាយកដ្ឋានផែនការ និងគម្រោង/នាយកដ្ឋានពាក់ព័ន្ធ ដោយមានចំណារឯកភាពលើប្លង់ និងលេខកូដគម្រោងជាមុន ទើបអនុវត្តបាន។ **កម្រិតហានិភ័យ ទាប។**

*ជាការឆ្លើយតប : ដោយមានតម្រូវការប្រើប្រាស់ទឹកស្អាតបន្ទាន់សម្រាប់ការងារសង្គមជាច្រើនកន្លែង ដូចជាមន្ទីរពេទ្យ សាលារៀន ក៏ដូចជាសហគមន៍ (ប្រធានសក្តិ និងអាទិភាព)។ សាខានឹងសហការជាមួយបណ្តានាយកដ្ឋានពាក់ព័ន្ធ ក្នុងការអនុវត្តគម្រោង។*

***សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានធ្វើរបាយការណ៍កែលម្អ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤។***

## iv. ក- នាយករដ្ឋបាល និងធនធានមនុស្ស

ក្នុងឆ្នាំ២០២២ នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស អនុវត្តបាន៖

❖ ការិយាល័យរដ្ឋបាល

- ទទួលលិខិតចូលក្នុងអង្គភាព ចំនួន ៤៨៨ សំណើ
- ធ្វើលិខិតស្នើក្នុងនាយកដ្ឋាន ចំនួន២២៤ សំណើ
- ធ្វើលិខិតបេសកកម្ម ចំនួន ៨៧ សំណើ
- បានធ្វើការថែទាំ-ជួសជុលអគាររដ្ឋបាលក្នុងផែនការ ចំនួន ៥៥ មុខ

❖ ការិយាល័យធនធានមនុស្ស

- បានធ្វើការបណ្តុះបណ្តាលក្នុងអង្គភាព ចំនួន ១៥ មុខជំនាញ
- បណ្តុះបណ្តាល ទស្សនកិច្ច និងវេទិកាផ្សេងៗ នៅក្រៅប្រទេស ចំនួន ៥៨ នាក់ (ស្រី ១០ នាក់)

នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សអនុវត្តការងារបានល្អ និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយ ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

### ការលើកផែនការថែទាំ-ជួសជុលអគាររដ្ឋបាល អនុវត្តពុំស្របតាមផែនការប្រចាំឆ្នាំ

ការលើកផែនការប្រចាំឆ្នាំរបស់នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស លើការថែទាំ-ជួសជុលអាគាររដ្ឋបាលសម្រាប់ឆ្នាំ២០២៣ មានចំនួន ៥៧ មុខ។ ក្នុងនោះអនុវត្តបានចំនួន ៥៥ មុខ នៅសល់ចំនួន ០២ មុខ ដែលមិនទាន់បានអនុវត្ត ក្នុងនោះ៖

- ការងារជួសជុលកាវីឡាក្នុងបរិវេណអង្គភាព
- ការងារជួសជុលខឿនចិញ្ចើម

ប្រការនេះអនុវត្តពុំទាន់បានសមស្របតាមផែនការប្រចាំឆ្នាំ។

ករណីនេះនាំឱ្យ ប៉ះពាល់ដល់សោភ័ណភាពរបស់អង្គភាព។

មន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តន៍ការងារឱ្យស្របតាមផែនការដែលបានកំណត់។ **កម្រិតហានិភ័យ ទាប។** ៥

*ជាការឆ្លើយតប ៖*

- *យោងតាមការណែនាំរបស់ **ឯកឧត្តមប្រតិភូ** ឱ្យផ្លាស់ប្តូរឯកសារបឋម លើកន្លែងដែលស្រុតខ្លាំង។*
- *ត្រៀមសាងសង់អគារថ្មី។*

## ខ- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ បានអនុវត្តការងារលើការគ្រប់គ្រងបញ្ជីការគណនេយ្យ គ្រប់គ្រងហិរញ្ញវត្ថុ និងគ្រប់គ្រងសន្និធិស្តុកបានល្អប្រសើរ និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយ ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

**ការងារទូទាត់ចំណាយលើការងារដាក់បំពង់ចែកចាយទឹកថ្មី ក្នុងកំណត់ហេតុរបស់គណៈកម្មការស្តីពីការចុះពិនិត្យលើការងារជីកដាក់បំពង់ ពុំបានបញ្ជាក់ពីគម្រោងបានអនុវត្តរួច និងគម្រោងកំពុងអនុវត្តបន្ត**

ការងារទូទាត់ចំណាយ៖

- ឆ្នាំ២០២២ ចំនួន ៣៨៧ សំណើ (ខែកុម្ភៈ, ខែវិច្ឆិកា និងខែធ្នូ)
- ឆ្នាំ២០២៣ ចំនួន ៣២៧ សំណើ (ខែឧសភា និងខែមិថុនា)

សវនកម្មផ្ទៃក្នុងពិនិត្យឃើញថា ក្នុងឆ្នាំ ២០២២ ការងារទូទាត់ចំណាយលើការងារដាក់បំពង់ចែកចាយទឹកថ្មី និងការងារដាក់បំពង់មេនាំទឹក ក្នុងកំណត់ហេតុរបស់គណៈកម្មការស្តីពីការចុះពិនិត្យការងារជីកដាក់បំពង់ពុំមានភ្ជាប់គម្រោងបានអនុវត្តរួច មានចំនួន ១៩ គម្រោង ស្មើនឹង ១០០% ដោយមានភ្ជាប់តែតារាងដាក់បំពង់ទឹកប្រចាំសប្តាហ៍របស់សាខាសេវាកម្មទឹកស្អាត និងអនាម័យ។ មន្ត្រីទទួលបន្ទុក រៀបចំពុំទាន់សមស្របតាមបែបបទរដ្ឋបាល។

ករណីនេះ ការកត់ត្រាគម្រោងដែលបានអនុវត្ត ពុំមានភាពច្បាស់លាស់ ឬអាចមានស្ទួនគ្នា។

មន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវធ្វើការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ក្នុងការកត់ត្រាលើគម្រោងបានអនុវត្តបញ្ចប់ និងគម្រោងកំពុងអនុវត្តបន្ត ដោយធ្វើជាតារាងរួមភ្ជាប់ជាឧបសម្ព័ន្ធ។ **កម្រិតហានិភ័យ ទាប**។

*ជាការឆ្លើយតប ៖ ដោយមន្ត្រីទទួលបន្ទុកបានតាមដានតារាងការអនុវត្តន៍គម្រោងរួម ទើបមិនញែកឱ្យតាមផ្នែកនូវការអនុវត្តន៍រួច និងកំពុងអនុវត្ត ដោយគ្រាន់តែដាក់កំណត់សម្គាល់ប៉ុណ្ណោះ ដូច្នេះនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនឹងណែនាំមន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវធ្វើការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងការកត់ត្រាលើគម្រោងដែលបានអនុវត្តបញ្ចប់ និងគម្រោងដែលកំពុងបន្តអនុវត្ត ដោយធ្វើជាតារាងរួមភ្ជាប់ដើម្បីជាឧបសម្ព័ន្ធកំណត់ហេតុ នៅដើមឆ្នាំ២០២៤។*

## គ- សន្និដ្ឋាន

ការធ្វើសវនកម្មដែលបានធ្វើឡើងខាងលើ នេះបង្ហាញថាដំណើរការនៃប្រតិបត្តិការខាងលើអនុវត្តបានល្អ អនុលោមតាមសេចក្តីកំណត់ស្តង់ដាការងារ ព្រមទាំងបទដ្ឋានគតិយុត្តិនានា។ មន្ត្រី-និយោជិត នៅតាមបណ្តានាយកដ្ឋាន/អង្គភាព បានខិតខំប្រឹងប្រែងសហការអនុវត្តការងារតាមតួនាទី-ភារកិច្ច និងសម្រេចបានលទ្ធផលល្អ។ សវនដ្ឋានមានការឯកភាព និងកែលម្អតាមអនុសាសន៍ណែនាំនូវរាល់ចំណុចខ្វះចន្លោះខាងលើ ព្រមទាំងធ្វើរបាយការណ៍បំភ្លឺតបចំណុចដែលបានកែលម្អ និងពុំទាន់បានធ្វើការកែលម្អ ក្នុងរយៈពេល **០៣ខែ** បន្ទាប់ពីចេញរបាយការណ៍។

សវនកម្មផ្ទៃក្នុង នឹងធ្វើការតាមដានរាល់អនុសាសន៍ដែលបានពិនិត្យឃើញ នូវបណ្តាចំណុចខ្វះចន្លោះរបស់សវនដ្ឋានក្នុងកំឡុងពេលចុះត្រួតពិនិត្យតាមការកំណត់ក្នុងផែនការប្រចាំឆ្នាំ។

## II. សវនកម្មពុំប្រាប់ទុក (Surprise Audit)

### ការពិនិត្យសន្និធិស្តុក នៃការិយាល័យបណ្តាញចូលផ្ទះ

គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ របាយការណ៍ស្តុកសម្ភារ មានចំនួន ៣២ មុខ ក្រោយពីបានចុះពិនិត្យជាក់ស្តែងឃើញថា មានភាពលម្អៀងចំនួន ១៣ មុខ ដូចខាងក្រោម៖

**ក- សម្ភារខ្វះពីបញ្ជីសន្និធិស្តុក (០៧ មុខ)**

| ល.រ | លេខកូដ | បរិយាយ | ចំនួនសម្ភារ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | សម្ភារចុងគ្រា | ជាក់ស្តែង | ក្នុងឯកសារ | លម្អៀងខ្វះ | |
| | | | 1 | 2 | 3 | 4=2+3-1 | |
| 1 | I-01312 | Water meter Kent 20 mm | 11 | 6 | 3 | -2 | |
| 2 | I-00910 | Tapping tee 110 x 63 | 14 | 11 | 2 | -1 | |
| 3 | I-00912 | Tapping tee 160 x 32 | 150 | 45 | 103 | -2 | |
| 4 | I-00682 | Clamp saddle 110 x 1 | 681 | 413 | 266 | -2 | |
| 5 | I-00702 | Ferrule 25 | 650 | 447 | - | -203 | |
| 6 | I-00953 | White Tape | 1,066 | 800 | - | -266 | |
| 7 | I-00804 | Reducing 32 x 25 | 519 | 450 | 50 | -19 | |

**ខ- សម្ភារលើសពីបញ្ជីសន្និធិស្តុក (០៦ មុខ)**

| ល.រ | លេខកូដ | បរិយាយ | ចំនួនសម្ភារ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | សម្ភារចុងគ្រា | ជាក់ស្តែង | ក្នុងឯកសារ | លម្អៀងលើស | |
| | | | 1 | 2 | 3 | 4=2+3-1 | |
| 1 | I-00776 | Pipe 25mm | 1,996 | 1,396 | 732.8 | 132.8 | |
| 2 | I-00777 | Pipe 32 mm | 3,367 | 2,500 | 898.5 | 31.5 | |
| 3 | I-01450 | Coupler 63 | 16 | 18 | - | 2 | |
| 4 | I-00914 | Tapping tee 160 x 63 | 14 | 14 | 2 | 2 | |
| 5 | I-00755 | Male Adaptor 32 x 1 | 551 | 563 | - | 12 | |
| 6 | I-03433 | Tee Equal 32 mm | 945 | 543 | 405 | 3 | |

ករណីនេះ ធ្វើឱ្យមាន៖

1. ការបាត់បង់សម្ភារដោយឥតហេតុ។
2. ការគ្រប់គ្រងស្តុក ពុំទាន់មានប្រសិទ្ធភាព។

ការិយាល័យ ត្រូវ៖

1. សរសេរលិខិតប្រគល់-ទទួលសម្ភារឱ្យបានត្រឹមត្រូវ មុននឹងយកទៅប្រើប្រាស់។
2. ខិតខំបង្កើនការផ្ទៀងផ្ទាត់រវាងសម្ភារជាក់ស្តែង ជាមួយនឹងបញ្ជីសន្និធិស្តុកជារៀងរាល់ចុងខែនីមួយៗ ករណី សម្ភារដែលលើសពីបញ្ជីសន្និធិស្តុក ត្រូវធ្វើការបង្វែរចូលទៅក្នុងសន្និធិស្តុក ។

*ជាការឆ្លើយតប :*

*ក- សម្ភារខ្វះពីបញ្ជីសន្និធិស្តុក (០៧ មុខ)*

*1. (1, 2, 3 និង 4) ដោយសារជាការងារបន្ទាន់ ការិយាល័យបានយកទៅប្រើប្រាស់មុននៅការដ្ឋាន និងធ្វើសំណើតាមក្រោយ*

2. (5) ដោយសារក្រវ៉ាត់ 110 x 1 យកទៅប្រើប្រាស់មានចំនួន ២៦៦ ក្នុងនោះប្រើក្រវ៉ាត់ (3 in 1) មានចំនួន ៦៣ គ្រាប់ និងក្រវ៉ាត់បង្គំ ចំនួន ២០៣ គ្រាប់ ដោយការិយាល័យកត់ត្រាជាសម្ភារកំប្លេ (ក្រវ៉ាត់, Ferrule និងបង់រុំ) មិនបានកត់ត្រាតាមលម្អិតមុខសម្ភារ

3. (6) ជាបង់រុំសម្រាប់ប្រើប្រាស់ជាមួយសម្ភារតភ្ជាប់ប្រភេទក្រវ៉ាត់មេកានិច (កំប្លេ) 110 x 1 យកទៅប្រើប្រាស់នៅការដ្ឋាន

4. (7) ដោយសារការិយាល័យមានតម្រូវការចាំបាច់ បានយកទៅភ្ជាប់សងបណ្ដាញជូនអតិថិជននៅសង្កាត់ទាំង០៤ នៃខណ្ឌច្បារអំពៅ ដោយធ្វើប័ណ្ណខ្ចីសម្រាប់ប្រើប្រាស់ផ្ទៃក្នុងបណ្ដោះអាសន្ន និងធ្វើសំណើតាមក្រោយ។

ខ- សម្ភារលើសពីបញ្ជីសន្និធិស្តុក (០៦ មុខ)

1. (1 និង 2) ដោយសារការប្រើប្រាស់ទៅតាមស្ថានភាពជាក់ស្ដែង ហើយសម្ភារដែលនៅសល់ការិយាល័យនឹងរក្សាទុកសម្រាប់ប្រើប្រាស់បន្ត

2. (3 និង 4) ការិយាល័យខ្ចីពីឃ្លាំង រ.ទ.ស.ភ មកប្រើប្រាស់មុន និងធ្វើសំណើតាមក្រោយ

3. (5) ការបើកសម្ភារយកទៅប្រើប្រាស់នៅសង្កាត់ទាំង០៤ និងកោះពេជ្រជាសម្ភារកំប្លេ ប៉ុន្តែបណ្ដាញទាំង០២ ទីតាំង មានលក្ខណៈខុសពីស្តង់ដារបស់ រ.ទ.ស.ភ ទើបធ្វើឱ្យនៅសល់ Male Adaptor 32 x 1 ចំនួន ១២ គ្រាប់ សម្ភារដែលនៅសល់ការិយាល័យនឹងរក្សាទុកសម្រាប់ប្រើប្រាស់បន្ត

4. (6) សម្ភារសម្រាប់ប្រើប្រាស់នៅសល់ពីបណ្ដាញបណ្ដោះអាសន្ន ក្នុងមន្ទីរពេទ្យសម្រាកព្យាបាលជំងឺកូវីដ-១៩ ដូច្នេះការិយាល័យនឹងរក្សាទុក ដើម្បីប្រើប្រាស់ក្នុងករណីចាំបាច់ណាមួយ។

ការិយាល័យនឹងធ្វើការកែលម្អលើចំណុចខ្វះខាតខាងលើ ឱ្យបានប្រសើរតាមការណែនាំរបស់សវនករ។ ការិយាល័យនឹងចាប់ផ្ដើមអនុវត្តចាប់ពីខែមិថុនា ឆ្នាំ២០២៣ តទៅ។

**ការពិនិត្យបេឡាទទួលប្រាក់ថ្លៃតបណ្ដាញចូលផ្ទះ នៃការិយាល័យហិរញ្ញវត្ថុ**

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ១៦ : ០០ នាទី និងបញ្ចប់នៅវេលាម៉ោង ១៦ : ៣០ នាទី ទទួលបានលទ្ធផលដូចខាងក្រោម៖

**ក- តារាងទទួលប្រាក់ថ្លៃតបណ្ដាញ**

| ល.រ | បរិយាយ | ចំនួនទឹកប្រាក់បង់ចូលបេឡា | | ទឹកប្រាក់សរុប |
|---|---|---|---|---|
| | | សាច់ប្រាក់ | អាករលើតម្លៃបន្ថែម | |
| 1 | ថ្លៃតបណ្ដាញថ្មី | 54,010,400 ៛ | | 54,010,400 ៛ |
| 2 | ប្រាក់បើកបណ្ដាញឡើងវិញ | 4,932,000 ៛ | 493,200 ៛ | 5,425,200 ៛ |
| 3 | ប្រាក់កក់ថ្លៃប្រើប្រាស់ទឹក | 20,135,700 ៛ | | 20,135,700 ៛ |
| 4 | ប្រាក់បង់រំលោះបណ្ដាញ | 293,900 ៛ | | 293,900 ៛ |
| 5 | ប្រាក់បង់ផ្ដាច់បណ្ដាញ | 147,700 ៛ | | 147,700 ៛ |
| 6 | ប្រាក់ថ្លៃលក់នាឡិកាទឹក | 536,000 ៛ | 53,600 ៛ | 589,600 ៛ |
| **ទឹកប្រាក់សរុប** | | **80,055,700 ៛** | **546,800 ៛** | **80,602,500 ៛** |

## ខ- តារាងសាច់ប្រាក់ជាក់ស្តែង

| ល.រ | ក្រដាសប្រាក់ | ចំនួន (សន្លឹក) | ចំនួនទឹកប្រាក់សរុប |
|---|---|---|---|
| 1 | 100,000 | 41 | 4,100,000 ៛ |
| 2 | 50,000 | 1,424 | 71,200,000 ៛ |
| 3 | 20,000 | 97 | 1,940,000 ៛ |
| 4 | 15,000 | 1 | 15,000 ៛ |
| 5 | 10,000 | 312 | 3,120,000 ៛ |
| 6 | 5,000 | 40 | 200,000 ៛ |
| 7 | 1,000 | 8 | 8,000 ៛ |
| 8 | 500 | 38 | 19,000 ៛ |
| 9 | 100 | 5 | 500 ៛ |
| **ទឹកប្រាក់សរុប** | | | **80,602,500 ៛** |

## សន្និដ្ឋាន

ក្នុងអំឡុងពេលធ្វើសវនកម្មពុំព្រាងទុក (Surprise Audit) សវនករពិនិត្យឃើញថា សវនដ្ឋានបានរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងប្រតិបត្តិការបានល្អ។ ក្នុងនោះ៖

- ការិយាល័យបណ្ណាញចូលផ្ទះ៖ មានចំណុចខ្វះចន្លោះមួយចំនួន ដែលត្រូវធ្វើការកែលម្អដូចដែលបានរៀបរាប់ខាងលើ ដូចនេះ ការិយាល័យគួរបានរៀបចំ និងកែសម្រួលឡើងវិញ ដើម្បីឱ្យការគ្រប់គ្រងសន្និធិស្តុកទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផល។ លទ្ធផល កម្រិត **B ( Priority)**។
- ការិយាល័យហិរញ្ញវត្ថុ បន្ទាប់ពីធ្វើការពិនិត្យជាក់ស្តែងលើសាច់ប្រាក់ដែលទទួលបានរបស់បេឡាទទួលប្រាក់ថ្លៃតបណ្តាញ ឃើញថាបានត្រឹមត្រូវ និងគ្រប់ចំនួន។ លទ្ធផល កម្រិត **A** ។

សវនកម្មផ្ទៃក្នុង នឹងពិនិត្យវឌ្ឍនភាពនៃការកែលម្អតាមអនុសាសន៍ជាបន្តទៀត។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២៤
**សវនកម្មផ្ទៃក្នុង**

**សេង តារា**

**បានអាន និងឯកភាព**
ថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤
**ជ. គណៈកម្មាធិការសវនកម្ម**
**ប្រធាន**

**ស្រេង សំឌិក**

# ឧបសម្ព័ន្ធ ៣

## របាយការណ៍ក្រុមប្រឹក្សាភិបាល

## និង

## របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

**សម្រាប់ការិយបរិច្ឆេទបញ្ចប់ដែលបានថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

# របាយការណ៍ក្រុមប្រឹក្សាភិបាល និង
# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

**មាតិកា** **ទំព័រ**


| | |
|---|---|
| របាយការណ៍ក្រុមប្រឹក្សាភិបាល | ១ - ៥ |
| របាយការណ៍ហិរញ្ញវត្ថុ | |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៦ - ៧ |
| របាយការណ៍លទ្ធផលលម្អិត | ៨ |
| របាយការណ៍បម្រែបម្រួលមូលធន | ៩ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១០ - ១១ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ១២ - ៥៥ |
| របាយការណ៍សវនករឯករាជ្យ | ៥៦ - ៦២ |

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍របស់ខ្លួន ដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

### សកម្មភាពអាជីវកម្មចម្បង

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ និងតំបន់ក្បែរដែលរួមមានតាខ្មៅ ខេត្តត្បូងឃ្មុំ និងម្លេច ខេត្តកំពត ព្រមទាំងផ្តល់សេវាផ្សេងៗ។ គោលដៅរបស់ រ.ទ.ស.ភ គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែទាំមធ្យោបាយសម្រាប់ផលិត និងចែកចាយទឹកស្អាត
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្មទឹក និងបង្កើនសេវាកម្ម និងគុណភាពទឹកស្អាតដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេសដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលការណ៍របស់រដ្ឋាភិបាល និង
- ធានាឱ្យបាននូវចិរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ សម្រាប់ផលប្រយោជន៍សាធារណៈ។

នៅក្នុងអំឡុងការិយបរិច្ឆេទនេះ ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពអាជីវកម្មចម្បងទាំងនេះទេ។

### លទ្ធផលប្រតិបត្តិការ

| | **គិតជាពាន់រៀល** |
|---|---|
| ប្រាក់ចំណេញក្នុងឆ្នាំ | ១២៦.៦០៩.៥៨២ |

### ភាគលាភ

ចំនួនភាគលាភដែលបានប្រកាស និងទូទាត់ដោយ រ.ទ.ស.ភ តាំងពីចុងការិយបរិច្ឆេទមុន មានដូចខាងក្រោម និងព័ត៌មានលម្អិតត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ២៣ នៃរបាយការណ៍ហិរញ្ញវត្ថុ៖

| | **គិតជាពាន់រៀល** |
|---|---|
| ភាគលាភតម្លៃ៣៣០រៀល ក្នុងមួយភាគហ៊ុនធម្មតាត្រូវបានប្រកាសនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ និងទូទាត់ក្នុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៤.៣០៥.១៥៨ |

### ទុនបម្រុង និងសំវិធានធន

ពុំមានការផ្ទេរជាសារវន្តទៅលើទុនបម្រុង និងពុំមានសំវិធានធនក្នុងអំឡុងការិយបរិច្ឆេទនេះទេ លុះត្រាតែមានការបង្ហាញក្រៅពីនេះ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## បំណុលពិបាកទារ និងបំណុលជាប់សង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលបំណុលពិបាកទារ និងការធ្វើសំវិធានធនលើបំណុលជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា ពុំមានបំណុលពិបាកទារទេ និងមិនតម្រូវឱ្យធ្វើសំវិធានធនលើបំណុលដែលជាប់សង្ស័យនោះទេ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលនាំឱ្យមានភាពចាំបាច់ដើម្បីលុបបំបាត់ចោលបំណុលពិបាកទារ និងធ្វើសំវិធានធនចំពោះបំណុលជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឡើយ។

## ទ្រព្យសកម្មរយៈពេលខ្លី

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីធានាថា ទ្រព្យសកម្មរយៈពេលខ្លីដែលមិនមានតម្លៃស្មើនឹងតម្លៃទីផ្សារនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ រ.ទ.ស.ភ ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលបានរំពឹងថានឹងអាចលក់បានលើទីផ្សារ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ថាមានភាពមិនត្រឹមត្រូវឡើយ។

## វិធីសាស្រ្តក្នុងការវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល មិនបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្ត ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម ឬបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) ការទាមទារទ្រព្យសកម្មណាមួយរបស់ រ.ទ.ស.ភ ដែលបានកើតឡើងចាប់តាំងពីចុងបញ្ចប់នៃការិយបរិច្ឆេទ ដើម្បីធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង

(២) បំណុលយថាហេតុណាមួយ ដែលកើតមានឡើងចំពោះ រ.ទ.ស.ភ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទឡើយ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ រ.ទ.ស.ភ ដែលត្រូវទាមទារឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងការិយបរិច្ឆេទ ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទដែលនឹង ឬអាចធ្វើឱ្យមានផលប៉ះពាល់ដល់លទ្ធភាពរបស់ រ.ទ.ស.ភ ក្នុងការសងបំណុលនៅថ្ងៃកំណត់សងនោះទេ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានបញ្ចូលនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដែលបណ្តាលឱ្យតួលេខនៃចំនួនណាមួយដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ មានភាពមិនត្រឹមត្រូវនោះទេ។

## កត្តាជាសារវន្ត និងមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល៖

(១) លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ រ.ទ.ស.ភ ក្នុងការិយបរិច្ឆេទនេះ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរដោយកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ និង

(២) ពុំមានកត្តា ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេក្នុងចន្លោះពេលរវាងចុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ ដែលអាចនាំឱ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលប្រតិបត្តិការរបស់ រ.ទ.ស.ភ ក្នុងការិយបរិច្ឆេទដែលបានរៀបចំរបាយការណ៍នេះទេ។

## ការបោះផ្សាយភាគហ៊ុន និងប័ណ្ណបំណុល

នៅក្នុងអំឡុងការិយបរិច្ឆេទនេះ រ.ទ.ស.ភ ពុំបានបោះផ្សាយភាគហ៊ុន ឬប័ណ្ណបំណុលថ្មីនោះទេ។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបម្រើការងារនៅចុងអាណត្តិចាស់ និងក្នុងអំឡុងអាណត្តិថ្មីគិតមកដល់កាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ រួមមាន៖

| | |
|---|---|
| ឯកឧត្តម អ៊ុំ សុថា | (បញ្ចប់អាណត្តិនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣) |
| ឯកឧត្តម ស៊ឹម ស៊ីថា | (ត្រូវបានតែងតាំងនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣) |
| ឯកឧត្តម ម៉ី វ៉ាន់ | |
| ឯកឧត្តម ឡុង ណារ៉ូ | |
| ឯកឧត្តម នួន ផារ័ត្ន | |
| លោក ម៉ា ណូវ៉ារីន | (ត្រូវបានតែងតាំងនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣) |
| លោក ណាំ ចន្រ្ទី | |
| លោក ស្រេង សំឌិក | |

## ព្រឹត្តិការណ៍សំខាន់បន្ទាប់ពីចុងបញ្ចប់នៃការិយបរិច្ឆេទ

ព័ត៌មានលម្អិតអំពីព្រឹត្តិការណ៍សំខាន់បន្ទាប់ពីចុងបញ្ចប់នៃការិយបរិច្ឆេទនេះ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៣១ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ទទួលខុសត្រូវលើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ត្រូវ៖

១) អនុវត្តគោលការណ៍គណនេយ្យ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "ស.រ.ទ.ហ.អ.ក") ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តតាមគោលការណ៍នោះប្រកបដោយសង្គតិភាព

២) អនុលោមទៅតាមតម្រូវការ ក្នុងការលាតត្រដាងព័ត៌មាន ស.រ.ទ.ហ.អ.ក ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបាន ត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ

៣) រក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យ រ.ទ.ស.ភ អាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមទៅតាម ស.រ.ទ.ហ.អ.ក និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព

៤) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកតាមមូលដ្ឋានក្នុងការបន្តនិរន្តរភាពអាជីវកម្ម លុះត្រាតែមានភាពមិនត្រឹមត្រូវក្នុងការសន្មតថា រ.ទ.ស.ភ នឹងបន្តកិច្ចប្រតិបត្តិការរបស់ខ្លួននាពេលអនាគត និង

៥) គ្រប់គ្រង និងដឹកនាំ រ.ទ.ស.ភ ឱ្យមានប្រសិទ្ធិភាពតាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផល ហើយត្រូវប្រាកដថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា រ.ទ.ស.ភ បានអនុលោមតាមគ្រប់តម្រូវការខាងលើនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## របាយការណ៍ក្រុមប្រឹក្សាភិបាល

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ **ឯកឧត្តម ស៊ឹម ស៊ីថា ឯកឧត្តម ឡុង ណារ៉ូ** និងលោក **ដេង ប៉ូលីដែន** ជាអភិបាល និងមន្ត្រី នៅក្នុង រ.ទ.ស.ភ សូមបញ្ជាក់ថាតាមយោបល់របស់ក្រុមប្រឹក្សាភិបាល ដែលបានភ្ជាប់មកជាមួយរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងរបាយការណ៍លទ្ធផលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "ស.រ.ទ.ហ.អ.ក")។

ចុះហត្ថលេខាជំនួសឱ្យក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង

**ឡុង ណារ៉ូ**
អគ្គនាយក

**ដេង ប៉ូលីដែន**
អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច

**ស៊ឹម ស៊ីថា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃ.ពុធ ៤កើត.....ខែ.ផល្គុន....... ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៣...........ខែមីនា ឆ្នាំ២០២៤

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**
**គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| | កំណត់សម្គាល់ | ២០២៣ គិតជាពាន់រៀល | ២០២២ គិតជាពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ២.៤៩៤.៩៧៩.២៩០ | ២.២០៣.០៤១.៩១៤ |
| ទ្រព្យសកម្មអរូបី | | ១០.៤៦៣.០៧៤ | ១២.០៨៩.៥៨៧ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | ២.៥០៥.៤៤២.៣៦៤ | ២.២១៥.១៣១.៥០១ |
| | | | |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ៦ | ៣១៨.៧៤៦.៥៩២ | ១៥២.៧៣៧.០៧៨ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនី ត្រូវទទួលផ្សេងៗ | ៧ | ២៧.៩៨០.២៣៦ | ៣២.៧០៧.៤១៦ |
| កិច្ចសន្យាទ្រព្យសកម្ម | ៨ | ១៥៥.៥០១.២៥៥ | ៩២.៧៦៨.៣៧៤ |
| ឥណទានផ្តល់ឱ្យនិយោជិក | ៩ | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |
| ការវិនិយោគរយៈពេលខ្លី | ១០ | ១២៧.៣១៦.០០៣ | ១២៦.១១៨.៤១៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១១ | ១៦.១១៧.២២២ | ៥៦.៧១៦.៤៣៩ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | ៦៥៣.៦១៧.៩៥៩ | ៤៦៩.០០៤.៣៧៤ |
| **ទ្រព្យសកម្មសរុប** | | **៣.១៥៩.០៦០.៣២៣** | **២.៦៨៤.១៣៥.៨៧៥** |
| | | | |
| **មូលធន និងបំណុល** | | | |
| **មូលធនរបស់ភាគហ៊ុនិករបស់ រ.ទ.ស.ភ** | | | |
| ដើមទុន និងបុព្វលាភភាគហ៊ុន | ១២ | ៦២០.៧៥៩.១០៧ | ៦២០.៧៥៩.១០៧ |
| ទុនបម្រុង | ១៣ | ៦៤៧.១៤៨.៧៨២ | ៥៤៣.២៦៨.០៧៥ |
| ចំណេញរក្សាទុក | | ១២៦.៦០៩.៥៨២ | ១០៨.១៨៥.៨៦៥ |
| **មូលធនសរុប** | | **១.៣៩៤.៥១៧.៤៧១** | **១.២៧២.២១៣.០៤៧** |
| | | | |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ១៤ | ១.២៩៦.៩២៤.៦៨៤ | ៩៨៦.៤៩៥.៧១៧ |
| ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ១៥ | ៧៤.១៦២.៧៤៦ | ៦៩.២៣៨.៤៧៧ |
| បំណុលពន្ធពន្យា - សុទ្ធ | ២០ | ៨១.៩៤៦.៨៥៨ | ៧៧.០១៦.៧១៦ |
| គណនីត្រូវទូទាត់ផ្សេងៗ | ១៦ | ៨២.៩០៣.៧៣២ | ៧៦.៨០១.៧០៥ |
| **បំណុលរយៈពេលវែងសរុប** | | ១.៥៣៥.៩៣៨.០២០ | ១.២០៩.៥៥២.៦១៥ |

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ២០២៣ គិតជាពាន់រៀល | ២០២២ គិតជាពាន់រៀល |
|---|---|---|---|
| **បំណុលរយៈពេលខ្លី** | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនី | | | |
| ត្រូវទូទាត់ផ្សេងៗ | ១៦ | ១៧៩.៩៤៤.៦២១ | ១៥៤.៦៦១.១៥២ |
| ប្រាក់កម្ចី | ១៤ | ២៣.៦៧៧.៤០១ | ២៣.៤៩៩.១៥៨ |
| កិច្ចសន្យាបំណុល | ៨ | ៤.២៥៤.១៣៨ | ៤.៤៥៦.៧៥៦ |
| បំណុលពន្ធលើប្រាក់ចំណូល | | ២០.៧២៨.៦៧២ | ១៩.៧៥៣.១៤៧ |
| **បំណុលរយៈពេលខ្លីសរុប** | | ២២៨.៦០៤.៨៣២ | ២០២.៣៧០.២១៣ |
| **បំណុលសរុប** | | **១.៧៦៤.៥៤២.៨៥២** | **១.៤១១.៩២២.៨២៨** |
| **មូលធន និងបំណុលសរុប** | | **៣.១៥៩.០៦០.៣២៣** | **២.៦៨៤.១៣៥.៨៧៥** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**របាយការណ៍លទ្ធផលលម្អិត**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| | កំណត់សម្គាល់ | ២០២៣ គិតជាពាន់រៀល | ២០២២ គិតជាពាន់រៀល |
|---|---|---|---|
| **ចំណូល៖** | | | |
| ចំណូលពីការផ្គត់ផ្គង់ទឹក | ១៧ | ៣៤៩.៦៤០.០៧៣ | ២៩៩.៧២៣.៥០៧ |
| កម្រៃពីការសាងសង់ | | ១៦.៦៦៥.៦១៧ | ២៤.៩៧៦.៣១៦ |
| ចំណេញពីការប្តូររូបិយប័ណ្ណ - សុទ្ធ | | ៤.១១១.០៣៩ | ១.១០៥.៧០០ |
| ចំណូលផ្សេងៗ | | ២១.៦៣៧.៦៣៦ | ២១.៤៧៨.៣៣៣ |
| | | ៣៩២.០៥៤.៣៦៥ | ៣៤៧.២៨៣.៨៥៦ |
| **ចំណាយ៖** | | | |
| ចំណាយអត្ថប្រយោជន៍របស់នយោជិក | ១៨ | (៨០.២៩២.៤៣៨) | (៧០.១៧៥.៤២២) |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | | (៦១.៩៧៨.១៣៥) | (៥៩.៤៥៥.០៧៤) |
| ចំណាយថ្លៃភ្លើង | | (៥២.២៩១.៤៤៦) | (៣៥.២១៨.៧៤៣) |
| ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត | | (១៥.៨៧៥.៣១៣) | (១២.១៤០.៧៤០) |
| ចំណាយជួសជុល និងថែទាំ | | (១១.៦៥១.០៥៨) | (៨.០០៩.៣៥៨) |
| ចំណាយសេវាសាងសង់ | | (៩.៧៣១.៥១៨) | (១៦.៦១៨.០២៤) |
| ចំណាយវត្ថុធាតុដើមសម្រាប់តភ្ជាប់បណ្តាញទឹកតាមគេហដ្ឋាន | | (៤.៨១៦.៥១៤) | (៤.៩៥៣.៣៧១) |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (១៥.១៥៥.៤៣៦) | (១១.២៤៣.៤១៦) |
| | | (២៤១.៧៩១.៨៥៨) | (២១៧.៨១៤.១៤៨) |
| **ចំណេញប្រតិបត្តិការ** | | **១៥០.២៦២.៥០៧** | **១២៩.៤៦៩.៧០៨** |
| ចំណូលហិរញ្ញប្បទាន | | ៦.៧៣៧.៧៦៦ | ៤.៦៥៦.៦១៨ |
| ចំណាយហិរញ្ញប្បទាន | ១៩ | (៣.៥២៧.៧៣០) | (៣.៦១០.៤៣៤) |
| **ចំណេញមុនបង់ពន្ធ** | | **១៥៣.៤៧២.៥៤៣** | **១៣០.៥១៥.៨៩២** |
| ពន្ធលើប្រាក់ចំណូល | ២០ | (២៦.៨៦២.៩៦១) | (២២.៣៣០.០២៧) |
| **ចំណេញក្នុងឆ្នាំ តំណាងឱ្យលទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | **១២៦.៦០៩.៥៨២** | **១០៨.១៨៥.៨៦៥** |
| | | | |
| ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិក៖ | | | |
| ចំណេញគោលក្នុងមួយភាគហ៊ុន (គិតជាប្រាក់រៀល) | ២២ | ១.៤៥៥,៧៣ | ១.២៤៣,៩០ |
| ចំណេញថយចុះក្នុងមួយភាគហ៊ុន (គិតជាប្រាក់រៀល) | ២២ | ១.៤៥៥,៧៣ | ១.២៤៣,៩០ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**របាយការណ៍បម្រែបម្រួលមូលធន**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| | កំណត់សម្គាល់ | ដើមទុន និង បុព្វលាភភាគហ៊ុន គិតជាពាន់រៀល | ទុនបម្រុង គិតជាពាន់រៀល | ចំណេញរក្សាទុក គិតជាពាន់រៀល | មូលធនសរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | | **៦១៩.៣១៥.៨៨៦** | **៤១៨.០៣៨.៤១០** | **១២៩.២៧៣.៩១៧** | **១.១៦៦.៦២៨.២១៣** |
| ចំណេញក្នុងឆ្នាំ តំណាងឱ្យ លទ្ធផលលម្អិតសរុបក្នុងឆ្នាំ | | - | - | ១០៨.១៨៥.៨៦៥ | ១០៨.១៨៥.៨៦៥ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | |
| ការបន្ថែមដើមទុន | ១២ | ១.៤៤៣.២២១ | - | - | ១.៤៤៣.២២១ |
| ការផ្ទេរទៅគណនីទុនបម្រុង | ១៣ | - | ១២៥.២២៩.៦៦៥ | (១២៥.២២៩.៦៦៥) | - |
| ភាគលាភ | ២៣ | - | - | (៤.០៤៤.២៥២) | (៤.០៤៤.២៥២) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក សរុប** | | ១.៤៤៣.២២១ | ១២៥.២២៩.៦៦៥ | (១២៩.២៧៣.៩១៧) | (២.៦០១.០៣១) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | | ៦២០.៧៥៩.១០៧ | ៥៤៣.២៦៨.០៧៥ | ១០៨.១៨៥.៨៦៥ | ១.២៧២.២១៣.០៤៧ |
| ចំណេញក្នុងឆ្នាំ តំណាងឱ្យ លទ្ធផលលម្អិតសរុបក្នុងឆ្នាំ | | - | - | ១២៦.៦០៩.៥៨២ | ១២៦.៦០៩.៥៨២ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | |
| ការផ្ទេរទៅគណនីទុនបម្រុង | ១៣ | - | ១០៣.៨៨០.៧០៧ | (១០៣.៨៨០.៧០៧) | - |
| ភាគលាភ | ២៣ | - | - | (៤.៣០៥.១៥៨) | (៤.៣០៥.១៥៨) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក សរុប** | | - | ១០៣.៨៨០.៧០៧ | (១០៨.១៨៥.៨៦៥) | (៤.៣០៥.១៥៨) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | **៦២០.៧៥៩.១០៧** | **៦៤៧.១៤៨.៧៨២** | **១២៦.៦០៩.៥៨២** | **១.៣៩៤.៥១៧.៤៧១** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**របាយការណ៍លំហូរសាច់ប្រាក់**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| | កំណត់សម្គាល់ | ២០២៣ គិតជាពាន់រៀល | ២០២២ គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| **ចំណេញមុនបង់ពន្ធ** | | **១៥៣.៤៧២.៥៤៣** | **១៣០.៥១៥.៨៩២** |
| និយ័តកម្មលើ៖ | | | |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ៦០.១១៥.៣៦៩ | ៥៧.៤៦០.៩២៧ |
| ចំណាយហិរញ្ញប្បទាន | ១៩ | ៣.៥២៧.៧៣០ | ៣.៦១០.៤៣៤ |
| ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណមិនមែនជាសាច់ប្រាក់លើ គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | | ២.១៤២.៩៤៤ | ៦.១៤០.៦០៦ |
| រំលស់ទ្រព្យសកម្មអរូបី | | ១.៨៥៦.៤៥០ | ១.៩៩៤.១៤៧ |
| ការជម្រះបញ្ជីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ១.៦២៨.៤៥៥ | ១៣៦.៨៣៩ |
| ការជម្រះបញ្ជីទ្រព្យសកម្មអរូបី | | ៦.៣១៥ | - |
| ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណមិនមែនជាសាច់ប្រាក់លើ ប្រាក់កម្ចី | | (៩.៩៦៧.៩៥៨) | (៤.៥៨៦.៨៦៦) |
| ចំណូលហិរញ្ញប្បទាន | | (៦.៧៣៧.៧៦៦) | (៤.៦៥៦.៦១៨) |
| រំលស់ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ១៥ | (២.០០៩.៩០៨) | (២.០០៩.៩០៨) |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **២០៤.០៣៤.១៧៤** | **១៨៨.៦០៥.៤៥៣** |
| **បម្រែបម្រួលទុនបង្វិល៖** | | | |
| សន្និធិ | | (២៣៨.១៥២.៩៣៨) | (៨៩.៨១៩.២០១) |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | ៦.១១២.៧០៣ | (៦.១១០.៥២៥) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ | | ២៣.១៤០.៥២៥ | ៨.៥០៩.៦៩៤ |
| កិច្ចសន្យាទ្រព្យសកម្ម | | (៦២.៧៣២.៨៨១) | (២៦.៧៤៣.៧៩៤) |
| កិច្ចសន្យាបំណុល | | (២០២.៦១៨) | ២.៦៦៧.៨៦២ |
| ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ | | ៦.១០២.០២៧ | ៧.៣៥៥.៦៣២ |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ បានពីប្រតិបត្តិការ** | | **(៦១.៦៩៩.០០៨)** | **៨៤.៤៦៥.១២១** |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (២០.៩៥៧.២៩៤) | (២២.២៣៣.១៥៧) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ បានពីសកម្មភាព ប្រតិបត្តិការ** | | **(៨២.៦៥៦.៣០២)** | **៦២.២៣១.៩៦៤** |

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**របាយការណ៍លំហូរសាច់ប្រាក់**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| | កំណត់សម្គាល់ | ២០២៣ គិតជាពាន់រៀល | ២០២២ គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការប្រាក់បានទទួល | | ៥.៣៥២.២៤៣ | ២.៩៣៤.៨៩៤ |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | (២៦៩.៨៨៦.៩៤៦) | (២៨១.៦១៩.៧១៦) |
| កំណើនក្នុងការវិនិយោគរយៈពេលខ្លី | | (១.១៩៧.៥៨៧) | (៥៧.៩៥៤.៥៨៣) |
| ការទិញទ្រព្យសកម្មអរូបី | | (២៣៦.២៥២) | (៣៩០.០៧៥) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(២៦៥.៩៦៨.៥៤២)** | **(៣៣៧.០២៩.៤៨០)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | ៣៤១.៩៨៧.៥៣៧ | ២១៨.២៨០.៤៣៩ |
| ជំនួយទទួលបានពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ១៥ | ៦.៩៣៤.១៧៧ | ៥៤.៤៣៦.១៩៩ |
| ការបន្ថែមដើមទុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | - | ១.៤៤៣.២២១ |
| ការទូទាត់សងប្រាក់កម្ចី | | (២១.៤៧៩.៤៥៤) | (២០.៧៦៩.៣៨៦) |
| ការប្រាក់បានទូទាត់ | | (១៥.១១១.៤៧៥) | (៧.៤៩១.៨០៤) |
| ភាគលាភបានទូទាត់ | ២៣ | (៤.៣០៥.១៥៨) | (៤.០៤៤.២៥២) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន** | | **៣០៨.០២៥.៦២៧** | **២៤១.៨៥៤.៤១៧** |
| **តំហយចុះនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **(៤០.៥៩៩.២១៧)** | **(៣២.៩៤៣.០៩៩)** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមឆ្នាំ** | | **៥៦.៧១៦.៤៣៩** | **៨៩.៦៥៩.៥៣៨** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងឆ្នាំបញ្ចប់** | ១១ | **១៦.១១៧.២២២** | **៥៦.៧១៦.៤៣៩** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុ**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ១. ព័ត៌មានអំពី រ.ទ.ស.ភ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ហៅកាត់ថា "រ.ទ.ស.ភ") ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ហៅកាត់ថា "ក.ស.ហ.វ") ហើយមានការិយាល័យកណ្ដាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្មថាជា សហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម Co. ០៨៣៩ Et/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២។

ការិយាល័យចុះបញ្ជីរបស់ រ.ទ.ស.ភ មានទីតាំងស្ថិតនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ និងតំបន់ក្បែរដែលរួមមានក្រុងតាខ្មៅ ខេត្តត្បូងឃ្មុំ និងម្លេចក្នុងខេត្តកំពត ព្រមទាំងផ្តល់ សេវាផ្សេងៗ។ គោលដៅរបស់ រ.ទ.ស.ភ គឺៈ

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែទាំមធ្យោបាយសម្រាប់ផលិត និងចែកចាយទឹកស្អាត
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្មទឹក និងបង្កើនសេវាកម្ម និងគុណភាពទឹកស្អាតដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលការណ៍របស់រដ្ឋាភិបាល និង
- ធានាឱ្យបាននូវចិរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ សម្រាប់ផលប្រយោជន៍សាធារណៈ។

## ២. មូលដ្ឋាននៃការរៀបចំ

### ២.១ របាយការណ៍អនុលោមភាព

ព័ត៌មានហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "ស.រ.ទ.ហ.អ.ក")។

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### ២.២ ការអនុវត្ត ស.រ.ទ.ហ.អ.ក ថ្មី និងការធ្វើវិសោធនកម្ម ឬការកែសម្រួលលើ ស.រ.ទ.ហ.អ.ក

(ក) ការធ្វើវិសោធនកម្ម ឬការកែសម្រួលស្តង់ដារដែលបានអនុវត្តក្នុងឆ្នាំ

- ការបង្ហាញគោលការណ៍គណនេយ្យ – វិសោធនកម្មលើ ស.គ.អ.ក ១ និង ស.រ.ទ.ហ.អ.ក សេចក្ដីថ្លែងការណ៍ស្ដីពីការអនុវត្ត ២

  វិសោធនកម្មនេះ តម្រូវឱ្យអង្គភាពបង្ហាញនូវព័ត៌មានគោលការណ៍គណនេយ្យជាសារវន្តរបស់ខ្លួនជាជាងគោលការណ៍គណនេយ្យសំខាន់ៗ។ វិសោធនកម្មនេះ ក្នុងចំណោមវិសោធនកម្មផ្សេងទៀតរួមទាំងឧទាហរណ៍នៃកាលៈទេសៈណាមួយ ដែលអង្គភាពពិចារណាចាត់ជាព័ត៌មានគោលការណ៍គណនេយ្យមានភាពជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។ ដើម្បីជាជំនួយដល់ការធ្វើវិសោធនកម្មនេះ ស.រ.ទ.ហ.អ.ក សេចក្ដីថ្លែងការណ៍ស្ដីពីការអនុវត្ត ២ ក៏ត្រូវបានកែសម្រួលផងដែរ ដើម្បីផ្ដល់ការណែនាំអំពីរបៀបអនុវត្តទស្សនៈនៃភាពជាសារវន្តចំពោះការបង្ហាញព័ត៌មានគោលការណ៍គណនេយ្យ។ ការណែនាំ និងឧទាហរណ៍ដែលបានផ្ដល់នៅ ស.រ.ទ.ហ.អ.ក សេចក្ដីថ្លែងការណ៍ស្ដីពីការអនុវត្ត ២ បានសង្កត់ធ្ងន់ពីតម្រូវការក្នុងការផ្ដោតលើព័ត៌មានជាក់លាក់របស់អង្គភាព និងបង្ហាញពីរបៀបដែលដំណើរការនៃភាពជាសារវន្ត៤ជំហានអាចកំណត់បាននូវព័ត៌មានស្តង់ដារ (ឬBoilerplate) និងការចម្លងតាមតម្រូវការរបស់ស.រ.ទ.ហ.អ.ក នៅក្នុងការបង្ហាញព័ត៌មានគោលការណ៍គណនេយ្យ។

  ទោះបីជាវិសោធនកម្មទាំងនេះ មិនបានប៉ះពាល់ដល់ការផ្លាស់ប្ដូរគោលការណ៍គណនេយ្យក៏ដោយ ប៉ុន្តែវាមានផលប៉ះពាល់ដល់ព័ត៌មានគោលការណ៍គណនេយ្យដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

  ការធ្វើវិសោធនកម្ម ឬការកែសម្រួលស្តង់ដារខាងក្រោមនេះ ត្រូវបានអនុវត្តដោយ រ.ទ.ស.ភ ប៉ុន្តែមិនមានផលប៉ះពាល់ជាសារវន្តទៅលើការិយបរិច្ឆេទបច្ចុប្បន្ន ឬលើការិយបរិច្ឆេទមុនៗឡើយ ហើយក៏មិនមានផលប៉ះពាល់ដល់ការិយបរិច្ឆេទនាពេលអនាគតឡើយ។

- និយមន័យនៃការប៉ាន់ស្មានគណនេយ្យ – វិសោធនកម្ម ស.គ.អ.ក៨
- ពន្ធពន្យាទាក់ទងនឹងទ្រព្យសកម្ម និងបំណុលដែលកើតឡើងពីប្រតិបត្តិការតែមួយ – វិសោធនកម្មលើ ស.គ.អ.ក ១២

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### ២.២ ការអនុវត្ត ស.រ.ទ.ហ.អ.ក ថ្មី និងការធ្វើវិសោធនកម្ម ឬការកែសម្រួលលើ ស.រ.ទ.ហ.អ.ក (ត)

(ខ) ស្តង់ដារ និងការធ្វើវិសោធនកម្ម/ការកែសម្រួលដែលបានចេញផ្សាយតែមិនទាន់ចូលជាធរមាន

| | | ថ្ងៃចូលជាធរមានអំឡុងការិយបរិច្ឆេទចាប់ផ្តើម ឬការិយបរិច្ឆេទបន្ទាប់ពី |
|---|---|---|
| ស.គ.អ.ក ១ | ចំណាត់ថ្នាក់នៃបំណុលជាបំណុលរយៈពេលខ្លី ឬរយៈពេលវែង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.គ.អ.ក ១ | បំណុលរយៈពេលវែងដែលមានកិច្ចព្រមព្រៀង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.រ.ទ.ហ.អ.ក ១៦ | បំណុលភតិសន្យាក្នុងការលក់ ហើយជួលត្រឡប់វិញ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.គ.អ.ក ៧ និង ស.រ.ទ.ហ.អ.ក ៧ | កិច្ចព្រមព្រៀងអ្នកផ្គត់ផ្គង់ហិរញ្ញវត្ថុ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.គ.អ.ក ១៧ | ការអនុវត្តដំបូងនៃ ស.រ.ទ.ហ.អ.ក ១៧ និង ស.រ.ទ.ហ.អ.ក ៩ – ព័ត៌មានប្រៀបធៀប | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ |
| ស.រ.ទ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ | ការលក់ ឬបន្ថែមទ្រព្យសកម្មរវាងវិនិយោគិន និងញាតិសម្ព័ន្ធ ឬការបណ្តាក់ទុនរួម | ពន្យា |

ស្តង់ដារ និងវិសោធនកម្មពិពណ៌នាខាងលើនេះ ត្រូវបានចេញផ្សាយ ប៉ុន្តែមិនទាន់ចូលជាធរមានអំឡុងការិយបរិច្ឆេទចាប់ផ្តើម ឬការិយបរិច្ឆេទបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ និងមិនទាន់ត្រូវបានអនុវត្តដោយ រ.ទ.ស.ភ ជាមុននៅឡើយទេ។ ស្តង់ដារ វិសោធនកម្ម ឬបំណកស្រាយទាំងនេះមិនត្រូវបានរំពឹងថាមានផលប៉ះពាល់ជាសារវន្តដល់អង្គភាពក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ឬអនាគត និងប្រតិបត្តិដែលរំពឹងទុកថានឹងអាចកើតមាននាពេលខាងមុខឡើយ។

### ២.៣ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

របាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានបង្ហាញជាប្រាក់រៀល ដែលជារូបិយប័ណ្ណមុខងាររបស់ រ.ទ.ស.ភ ហើយត្រូវបានបង្គត់ទៅខ្ទង់ពាន់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ២.៤ មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ បានរៀបចំតាមវិធីសាស្ត្រថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែមានបង្ហាញផ្សេងពីនេះនៅក្នុងកំណត់សម្គាល់ ៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### ២.៥ ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ផ្នែកដែលទាក់ទងទៅនឹងការវិនិច្ឆ័យ ឬមានភាពភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៤ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត

លើកលែងតែមានការចែងផ្សេងពីនេះ គោលការណ៍គណនេយ្យខាងក្រោមត្រូវបានអនុវត្តដោយសង្គតិភាពគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ។

### ៣.១ ការប្តូររូបិយប័ណ្ណបរទេស

ការប្តូររូបិយប័ណ្ណបរទេសនៅក្នុងឆ្នាំ ត្រូវបានប្តូរតាមអត្រាប្តូរប្រាក់បរទេសនាកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុ ត្រូវបានកំណត់ជារូបិយប័ណ្ណបរទេស ដោយប្តូរតាមអត្រាប្តូរប្រាក់បរទេសនាចុងការិយបរិច្ឆេទរាយការណ៍។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណត្រូវបានកត់ត្រាក្នុងចំណេញ ឬខាត។

ទ្រព្យសកម្ម និងបំណុលមិនមែនរូបិយវត្ថុ ត្រូវបានវាស់វែងតាមថ្លៃវិធីសាស្រ្តថ្លៃដើមប្រវត្តិសាស្រ្តជារូបិយប័ណ្ណបរទេសដែលត្រូវបានប្តូរតាមអត្រាប្តូរប្រាក់បរទេសនាកាលបរិច្ឆេទនៃប្រតិបត្តិការ។

### ៣.២ ឧបករណ៍ហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេល និងខណៈពេលដែល រ.ទ.ស.ភ ក្លាយជាភាគីនៃបទបញ្ញត្តិកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុប៉ុណ្ណោះ។

លើកលែងតែគណនីអតិថិជនពាណិជ្ជកម្ម ដែលមិនមានសមាសធាតុជាហិរញ្ញប្បទានគួរឱ្យកត់សម្គាល់ ឬដែល រ.ទ.ស.ភ បានអនុវត្តតាមតម្រូវការជាក់ស្តែង ឧបករណ៍ហិរញ្ញវត្ថុ គឺត្រូវបានទទួលស្គាល់ដំបូងនៅតម្លៃសមស្រប បូក ឬដក ថ្លៃដើមប្រតិបត្តិការដែលត្រូវបានកើតឡើងដោយផ្ទាល់ពីការទិញ ឬបោះផ្សាយនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ គណនីអតិថិជនពាណិជ្ជកម្មដែលមិនមានសមាសធាតុហិរញ្ញប្បទានសំខាន់ ឬដែល រ.ទ.ស.ភ បានអនុវត្តតាមតម្រូវការជាក់ស្តែង ត្រូវបានវាស់វែងនៅតម្លៃប្រតិបត្តិការដែលបានកំណត់ដោយ ស.រ.ទ.ហ.អ.ក ១៥ ។

## ៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

### (១) ទ្រព្យសកម្មហិរញ្ញវត្ថុ

រ.ទ.ស.ភ ចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

ការវាស់វែងជាបន្តបន្ទាប់នៃឧបករណ៍បំណុលអាស្រ័យលើ គំរូអាជីវកម្មរបស់ រ.ទ.ស.ភ សម្រាប់ការគ្រប់គ្រងទ្រព្យសកម្ម និងលក្ខណៈលំហូរសាច់ប្រាក់នៃទ្រព្យសកម្មនោះ។ រ.ទ.ស.ភ បានចាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួនជាទ្រព្យសកម្មហិរញ្ញវត្ថុដោយវិធីសាស្ត្ររំលស់ថ្លៃដើម។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានរក្សាទុកសម្រាប់ប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា ហើយលំហូរសាច់ប្រាក់ទាំងនោះតំណាងឱ្យការទូទាត់នៃប្រាក់ដើម និងការប្រាក់ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម។ ទ្រព្យសកម្មហិរញ្ញវត្ថុតាមរំលស់ថ្លៃដើមត្រូវបានវាស់វែងបន្ទាប់ ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព ហើយជាកម្មវត្ថុនៃឱនភាពតម្លៃ។ ចំណេញ ឬខាតត្រូវបានកត់ត្រាក្នុងចំណេញ ឬខាត នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់ កែតម្រូវ ឬធ្វើឱនភាពតម្លៃ។

### (២) បំណុលហិរញ្ញវត្ថុ

រ.ទ.ស.ភ បានចាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួន ជាបំណុលហិរញ្ញវត្ថុក្នុងវិធីសាស្ត្ររំលស់ថ្លៃដើម។

បន្ទាប់ពីការទទួលស្គាល់ជាដំបូង បំណុលហិរញ្ញវត្ថុផ្សេងៗត្រូវបានវាស់វែងតាមវិធីសាស្ត្ររំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ ចំណេញ និងខាត ត្រូវបានកត់ត្រាក្នុងចំណេញ ឬខាត នៅពេលដែលបំណុលហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់ និងតាមរយៈដំណើរការរំលស់។

## ៣.៣ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

ធាតុទាំងអស់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាដំបូងនៅថ្លៃដើម ហើយបន្ទាប់មកទទួលស្គាល់នៅថ្លៃដើមដករំលស់បង្គរ និងឱនភាពក្នុងតម្លៃណាមួយ។ ថ្លៃដើមដំបូងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់រួមទាំងតម្លៃនៃទ្រព្យសកម្ម និងចំណាយពាក់ព័ន្ធផ្សេងៗ ដែលបានកើតឡើងដោយផ្ទាល់ក្នុងការនាំយកទ្រព្យសកម្មនោះទៅកាន់ទីតាំង និងស្ថិតក្នុងលក្ខខណ្ឌចាំបាច់សម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការដែលបានគ្រោងទុកដោយគណៈគ្រប់គ្រង។

គ្មានការកំណត់អាយុកាលលើការប្រើប្រាស់ដីធ្លីនោះទេ ដូច្នេះហើយវាមិនត្រូវបានយកមកធ្វើការរំលស់។ ទ្រព្យសកម្មកំពុងសាងសង់ ដែលបានកត់ត្រាក្នុងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ក៏មិនត្រូវបានយកមកធ្វើការរំលស់ដែរ ដោយសារតែទ្រព្យសកម្មទាំងនោះនៅមិនទាន់អាចប្រើប្រាស់បាននៅឡើយ។

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារទាំងអស់ ក្រៅពីដីធ្លី និងទ្រព្យសកម្មកំពុងសាងសង់ត្រូវបានធ្វើការរំលស់ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរដោយបែងចែកតម្លៃរំលស់ទៅតាមអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មទាំងនោះ។

## ៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ៣.៣ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | អាយុកាលប្រើប្រាស់ (ឆ្នាំ) |
|---|---|
| អគារ | ៣០ - ៥០ |
| គ្រឿងចក្រ | ៣ - ២០ |
| បំពង់បង្ហូរទឹក | ៦ - ៥០ |
| បរិក្ខារមន្ទីរពិសោធន៍ | ៦ - ៧ |
| គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ | ២ - ៧ |
| បរិក្ខារអគ្គិសនី | ២ - ២០ |
| យានយន្ត | ២ - ៧ |
| វ៉ាន និងឧបករណ៍ | ៣ - ១៥ |
| នាឡិកាទឹក | ៥ - ២០ |
| បណ្តាញតចូលផ្ទះ | ១២ |

### ៣.៤ សន្និធិ

សន្និធិត្រូវបានវាស់វែងតាមតម្លៃទាបជាងរវាងថ្លៃដើម និងតម្លៃដែលអាចទទួលបានមកវិញ។

ថ្លៃដើមត្រូវបានកំណត់ដោយមូលដ្ឋានថ្លៃដើមគិតជាមធ្យម។ ថ្លៃដើមរួមមាន ថ្លៃទិញបូកបញ្ចូលចំណាយផ្សេងៗ ដែលកើតឡើងក្នុងការនាំសន្និធិនោះមកកាន់ទីតាំង និងតាមលក្ខខណ្ឌព្រមព្រៀង។ សន្និធិរួមមានវត្ថុធាតុដើម វត្ថុប្រើប្រាស់ គ្រឿងបន្លាស់ និងសន្និធិដ៏ទៃទៀតដែលទាក់ទងនឹងការផ្គត់ផ្គង់ទឹក ហើយត្រូវកំណត់តម្លៃទៅតាមថ្លៃដើមពិតប្រាកដ ក្នុងការនាំយកសន្និធិដកនឹងចំណាយសំវិធានធនលើសន្និធិបាក់បែក សម្រាប់ការខូចខាត ខូចខាត និងសន្និធិដែលមានចលនាប្រើប្រាស់ក្នុងប្រតិបត្តិការយឺតដោយប្រើប្រាស់មូលដ្ឋានថ្លៃដើមគិតជាមធ្យម។ គ្រឿងបន្លាស់ និងសន្និធិដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកដែលមានអាយុកាលលើសពីមួយឆ្នាំ ត្រូវទទួលស្គាល់ជាទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ នៅពេលដាក់ចូលទៅក្នុងការប្រើប្រាស់។

### ៣.៥ កិច្ចសន្យាទ្រព្យសកម្ម/(បំណុល)

កិច្ចសន្យាទ្រព្យសកម្ម គឺជាសិទ្ធិក្នុងការទទួលបានផលប្រយោជន៍ជាថ្នូរនឹងការផ្ទេរទំនិញឬសេវាកម្មទៅឱ្យអតិថិជននៅពេលដែលសិទ្ធិនោះត្រូវបានបំពេញតាមស្ថិតក្នុងមានលក្ខខណ្ឌជាជាងពេលវេលា ដែលបានកន្លងផុតទៅ (ឧទាហរណ៍៖ ការបំពេញកាតព្វកិច្ចនាពេលអនាគតរបស់ រ.ទ.ស.ភ)។ កិច្ចសន្យាទ្រព្យសកម្ម ត្រូវបានផ្ទេរទៅជាគណនីត្រូវទទួលនៅពេលដែលសិទ្ធិមិនស្ថិតក្រោមលក្ខខណ្ឌ។ ការផ្ទេរនេះជាធម្មតាកើតឡើងនៅពេលដែល រ.ទ.ស.ភ បានចេញវិក័យបត្រទៅឱ្យអតិថិជន។

កិច្ចសន្យាបំណុល គឺជាកាតព្វកិច្ចផ្ទេរទំនិញ ឬសេវាកម្មជូនអតិថិជនដែល រ.ទ.ស.ភ បានទទួលផលតបស្នង ឬការទូទាត់ពីអតិថិជន។

## ៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ៣.៦ ចំណូល និងចំណូលផ្សេងៗ

រ.ទ.ស.ភ ទទួលស្គាល់ចំណូលនៅពេលដែលទំនិញ ឬសេវាត្រូវបានផ្ទេរទៅអតិថិជនក្នុងទឹកប្រាក់ដែលឆ្លុះបញ្ចាំងការតបស្នង ដែល រ.ទ.ស.ភ រំពឹងថានឹងទទួលបានក្នុងការដោះដូរទំនិញ ឬសេវានោះ។

ការទទួលស្គាល់ចំណូលរបស់ រ.ទ.ស.ភ ត្រូវបានអនុវត្តសម្រាប់កិច្ចសន្យានីមួយៗ ជាមួយនឹងអតិថិជន ឬការបញ្ចូលគ្នានៃកិច្ចសន្យាជាមួយនឹងអតិថិជនដូចគ្នា (ឬភាគីពាក់ព័ន្ធរបស់អតិថិជន)។ ជាការអនុវត្តជាក់ស្តែង រ.ទ.ស.ភ បានអនុវត្តការទទួលស្គាល់ចំណូលចំពោះផលប័ត្រនៃកិច្ចសន្យា (ឬកាតព្វកិច្ចដែលត្រូវបំពេញ) ជាមួយនឹងលក្ខណៈស្រដៀងគ្នា ប្រសិន រ.ទ.ស.ភ រំពឹងថា ផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុ មិនខុសគ្នាខ្លាំងពីការទទួលស្គាល់ចំណូលលើកិច្ចសន្យានីមួយៗ (ឬកាតព្វកិច្ចដែលត្រូវបំពេញ) ជាមួយនឹងផលប័ត្រនោះ។

រ.ទ.ស.ភ វាស់វែងចំណូលពីការលក់ទំនិញ ឬផ្តល់សេវាកម្មនៅថ្លៃប្រតិបត្តិការ គឺជាការតបស្នង ដែល រ.ទ.ស.ភ រំពឹងទុកថានឹងទទួលបាននៅពេលដោះដូរទំនិញ ឬផ្តល់សេវាតាមការព្រមព្រៀងទៅឱ្យអតិថិជិន ដែលមិនរាប់បញ្ចូលទឹកប្រាក់ដែលប្រមូលបានជំនួសភាគីទីបី ដូចជាពន្ធលើសេវាកម្ម និយ័តកម្មលើផលប៉ះពាល់ការតបស្នងអថេរ ការប៉ាន់ស្មានការតបស្នងអថេរ ធាតុហិរញ្ញប្បទានសំខាន់ៗ ការតបស្នងលើធាតុមិនមែនសាច់ប្រាក់ និងការតបស្នងត្រូវទូទាត់ឱ្យអតិថិជន។ ប្រសិនបើថ្លៃប្រតិបត្តិការ រួមទាំងការតបស្នងអថេរ រ.ទ.ស.ភ ប្រើប្រាស់វិធីសាស្រ្តតម្លៃរំពឹងទុក ដោយការប៉ាន់ស្មានសមតុល្យសរុប ប្រូបាប៊ីលីតេគិតជាមធ្យមចំនួនក្នុងចន្លោះ ឬចំនួនទឹកប្រាក់តបស្នង ឬតាមវិធីសាស្រ្តលទ្ធផល ដោយផ្អែកលើវិធីសាស្រ្តណាដែល រ.ទ.ស.ភ រំពឹងទុកថាការព្យាករណ៍ដែលល្អប្រសើរជាងគេសម្រាប់ទឹកប្រាក់តបស្នងអាចទទួលបានដែលត្រូវបានទទួល។

សម្រាប់កិច្ចសន្យាដែលមានកាតព្វកិច្ចត្រូវបំពេញដាច់ដោយឡែក ថ្លៃប្រតិបត្តិការត្រូវបានធ្វើការបែងចែកដោយឡែកទៅតាមការបែងចែកកាតព្វកិច្ចត្រូវបំពេញនោះដោយផ្អែកលើមូលដ្ឋានថ្លៃលក់ទោល។ ប្រសិនបើថ្លៃលក់ទោលនោះមិនអាចអង្កេតដោយផ្ទាល់បាន រ.ទ.ស.ភ ត្រូវធ្វើការប៉ាន់ស្មានដោយប្រើប្រាស់ថ្លៃដើមរំពឹងទុកបូកនឹងគម្លាតចំណេញ។

ចំណូលពីកិច្ចសន្យាជាមួយអតិថិជន ត្រូវបានទទួលស្គាល់ដោយយោងតាមកាតព្វកិច្ចត្រូវបំពេញផ្សេងគ្នាក្នុងកិច្ចសន្យាជាមួយអតិថិជន ពោលគឺ នៅពេលកាតព្វកិច្ចត្រូវបំពេញក្នុងកិច្ចសន្យាជាមួយអតិថិជនត្រូវបានបំពេញ។ កាព្វកិច្ចត្រូវបំពេញ ត្រូវបានបំពេញនៅពេលដែលអតិថិជនទទួលបានការគ្រប់គ្រងទំនិញ ឬសេវានោះ ក្រោមកាតព្វកិច្ចត្រូវអនុវត្តជាក់លាក់ ដែលកាតព្វកិច្ចត្រូវអនុវត្តជាក់លាក់នោះអាចត្រូវបានបំពេញនៅពេលជាក់លាក់ណាមួយ ឬតាមពេល។

## ៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ៣.៦ ចំណូល និងចំណូលផ្សេងៗ (ត)

ការកែប្រែកិច្ចសន្យា ជាការផ្លាស់ប្តូរនៅវិសាលភាព ឬថ្លៃ (ឬទាំងពីរ) នៃកិច្ចសន្យាដែលត្រូវបានអនុម័តដោយភាគីនៅក្នុងកិច្ចសន្យា។ ការកែប្រែកើតមាននៅពេលដែលមានការផ្លាស់ប្តូរថ្មី ឬការផ្លាស់ប្តូរសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីក្នុងកិច្ចសន្យា។ រ.ទ.ស.ភ បានវាយតម្លៃប្រភេទនៃការកែប្រែ និងចាត់ទុកជាការរៀបចំកិច្ចសន្យាថ្មីដាច់ដោយឡែក បញ្ចប់កិច្ចសន្យាដែលមានស្រាប់ និងបង្កើតកិច្ចសន្យាថ្មី ឬរៀបចំផ្នែកណាមួយនៃកិច្ចសន្យាដែលមានស្រាប់។

**ចំណូលបានមកពីការផ្គត់ផ្គង់ទឹក**

ចំណូលពីការផ្គត់ផ្គង់ទឹក ត្រូវបានទទួលស្គាល់ក្នុងពេលជាក់លាក់មួយនៅពេលដែល រ.ទ.ស.ភ បានបំពេញកាតព្វកិច្ចរបស់ខ្លួនដោយផ្អែកលើការប្រើប្រាស់ទឹករបស់អតិថិជន និងនៅពេលដែលទឹកត្រូវបានផ្គត់ផ្គង់ដោយ រ.ទ.ស.ភ។

### ៣.៧ ជំនួយពីរដ្ឋាភិបាល

ជំនួយពីរដ្ឋាភិបាល និងភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀតត្រូវបានទទួលស្គាល់នៅពេលដែលមានអំណះអំណាងដែលសមហេតុផលថាជំនួយនឹងត្រូវទទួលបាន ហើយ រ.ទ.ស.ភ នឹងអនុលោមទៅតាមលក្ខខណ្ឌទាំងអស់ដែលមានភ្ជាប់នឹងជំនួយនោះ។ ជំនួយនឹងត្រូវបានពន្យា និងទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទចាំបាច់ ដើម្បីធ្វើឱ្យមានសមាមាត្រទៅនឹងថ្លៃដើមដែលត្រូវបានទូទាត់។

ជំនួយពន្យា ត្រូវបានចាត់ថ្នាក់ជាបំណុលរយៈវែង និងត្រូវកត់ត្រាជាចំណូល នៅក្នុងរបាយការណ៍លទ្ធផលលម្អិតតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីផ្គូរផ្គង់នឹងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មនោះ។

### ៣.៨ បន្ទុកលើប្រាក់កម្ចី

បន្ទុកលើប្រាក់កម្ចីដែលចូលរួមដោយផ្ទាល់ក្នុងការទិញ ការសាងសង់ ឬការផលិតនៃទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

បន្ទុកលើប្រាក់កម្ចីដែលមិនចូលរួមដោយផ្ទាល់ក្នុងការទិញ ការសាងសង់ ឬការផលិតនៃទ្រព្យសកម្មដែលមានលក្ខណៈគ្រប់គ្រាន់ គឺទ្រព្យសកម្មដែលត្រូវការពេលវេលាច្រើន ដើម្បីរួចរាល់សម្រាប់ប្រើប្រាស់ ឬលក់ ត្រូវធ្វើមូលធនីយកម្ម ដែលជាផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្មទាំងនោះ រហូតដល់ពេលដែលទ្រព្យសកម្មនោះរួចរាល់សម្រាប់គោលបំណងប្រើប្រាស់។

រ.ទ.ស.ភ ចាប់ផ្តើមធ្វើមូលធនីយកម្មលើប្រាក់កម្ចី នៅពេលដែល រ.ទ.ស.ភ កើតមានចំណាយសម្រាប់ទ្រព្យសកម្ម បន្ទុកលើប្រាក់កម្ចីពាក់ព័ន្ធ និងអនុវត្តសកម្មទាំងឡាយដែលចាំបាច់ ដើម្បីរៀបចំទ្រព្យសកម្ម សម្រាប់គោលបំណងប្រើប្រាស់។

## ៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ៣.៩ ចំណេញក្នុងមួយភាគហ៊ុន

រ.ទ.ស.ភ បង្ហាញព័ត៌មានចំណេញគោលក្នុងមួយភាគហ៊ុនសម្រាប់ភាគហ៊ុនធម្មតារបស់ខ្លួន។ ចំណេញគោលក្នុងមួយ ភាគហ៊ុនត្រូវបានគណនាដោយបែងចែកប្រាក់ចំណេញ ឬខាតទៅឱ្យភាគហ៊ុនិកធម្មតារបស់ រ.ទ.ស.ភ តាមវិធីសាស្ត្រគិតជាមធ្យមនៃចំនួនភាគហ៊ុនធម្មតាដែលមានក្នុងគ្រា។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ឆ្នាំ២០២២ ពុំមានសក្តានុពលចំណេញថយចុះក្នុងមួយភាគហ៊ុនទេ។ ដូច្នេះហើយទើបចំណេញថយចុះក្នុងមួយភាគហ៊ុនស្មើនឹងចំណេញគោលក្នុងមួយភាគហ៊ុន។

### ៣.១០ ចំណែកនៃប្រតិបត្តិការ

ចំណែកនៃប្រតិបត្តិការត្រូវបានរាយការណ៍ក្នុងលក្ខណៈមួយ ដោយសមស្របជាមួយនឹងការរាយការណ៍ផ្ទៃក្នុងដែលបានផ្តល់ដោយប្រធានផ្នែកប្រតិបត្តិការដែលមានសិទ្ធិក្នុងការសម្រេចចិត្ត។ អគ្គនាយក រ.ទ.ស.ភ ដែលជាអ្នកទទួលខុសត្រូវក្នុងការបែងចែកធនធាន និងវាយតម្លៃការអនុវត្តចំណែកនៃប្រតិបត្តិការ ត្រូវបានគេកំណត់ថាជាអ្នកធ្វើការសម្រេចចិត្តលើប្រតិបត្តិការយុទ្ធសាស្ត្រនានា។

## ៤. ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត គណនេយ្យសំខាន់ៗ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាម ស.រ.ទ.ហ.អ.ក ដែលតម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មតគណនេយ្យជាក់លាក់មួយចំនួន ដែលជះឥទ្ធិពលដល់ចំនួនទឹកប្រាក់ដែលត្រូវបានរាយការណ៍នៃទ្រព្យសកម្ម និងបំណុល និងការបង្ហាញពីទ្រព្យសកម្ម និងបំណុលយថាហេតុនាកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងទឹកប្រាក់ដែលត្រូវបានរាយការណ៍នៃចំណូល និងចំណាយរាយការណ៍ក្នុងគ្រា។ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការពិនិត្យពិច័យលើការវិនិច្ឆ័យក្នុងដំណើរការអនុវត្តគោលការណ៍គណនេយ្យនេះផងដែរ។ ទោះបីជាការប៉ាន់ស្មាន និងការវិនិច្ឆ័យដោយផ្អែកលើចំណេះដឹង និងព្រឹត្តិការណ៍នាពេលបច្ចុប្បន្នរបស់ក្រុមប្រឹក្សាភិបាលក៏ដោយ ក៏លទ្ធផលជាក់ស្តែងអាចនឹងមានភាពខុសគ្នា។

ផ្នែកសំខាន់ៗនៃការប៉ាន់ស្មាន ភាពមិនប្រកដប្រជា និងការវិនិច្ឆ័យសំខាន់ក្នុងការអនុវត្តតាមគោលការណ៍គណនេយ្យដែលមានផលប៉ះពាល់ជាសារវន្តក្នុងការកំណត់ចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

### ៤.១ ការកំណត់រូបិយប័ណ្ណមុខងារ

រ.ទ.ស.ភ ដំណើរការប្រតិបត្តិការក្នុងប្រទេសកម្ពុជា និងធ្វើប្រតិបត្តិការទិញ និងប្រតិបត្តិការផ្សេងៗជារូបិយប័ណ្ណជាច្រើន។ ការវិនិច្ឆ័យត្រូវបានអនុវត្តក្នុងការកំណត់រូបិយប័ណ្ណមុខងារ នៅពេលដែលមានសូចនាកររួម។ រ.ទ.ស.ភ ប្រើឋានុក្រម សូចនាករនៃការលក់ ជាមូលដ្ឋានចម្បង បន្ទាប់មកដោយការទិញ និងសូចនាករនៃចំណាយប្រតិបត្តិការ និងករណីដែលសូចនាករទាំងនោះ ពុំមានការសន្និដ្ឋានទេ រូបិយប័ណ្ណកម្ចី និងមូលនិធិផ្សេងទៀតត្រូវបានលើកឡើងសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការ។

## ៤. ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត គណនេយ្យសំខាន់ៗ (ត)

### ៤.២ រំលស់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

រ.ទ.ស.ភ បានពិនិត្យតម្លៃកាកសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្រ្តរំលសរាល់ចុងគ្រារាយការណ៍នីមួយៗ។ ការប៉ាន់ស្មានត្រូវបានប្រើប្រាស់ក្នុងការជ្រើសរើសវិធីសាស្រ្តរំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់។ ការប្រើប្រាស់ជាក់ស្តែងនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ អាចខុសគ្នាពីការប៉ាន់ស្មានដែលបានប្រើប្រាស់ ដូចនេះរំលស់នាពេលអនាគតអាចត្រូវបានកែតម្រូវឡើងវិញ។

តម្លៃយោងរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខាររបស់ រ.ទ.ស.ភ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ៥ នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ៤.៣ ឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងកិច្ចសន្យាទ្រព្យសកម្ម

សំវិធានធនឱនភាពតម្លៃសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងកិច្ចសន្យាទ្រព្យសកម្ម គឺផ្អែកលើការសន្មតពីហានិភ័យនៃការខកខានមិនបានសង និងអត្រាការខាតបង់ឥណទានរំពឹងទុក។ រ.ទ.ស.ភ ប្រើប្រាស់ការវិនិច្ឆ័យក្នុងការធ្វើការសន្មត និងជ្រើសរើសធាតុចូលក្នុងការគណនាឱនភាពតម្លៃដោយផ្អែកលើប្រវត្តិរបស់ រ.ទ.ស.ភ ស្ថានភាព ទីផ្សារបច្ចុប្បន្ន ក៏ដូចជាការប៉ាន់ស្មាននាពេលខាងមុខនៅចុងបញ្ចប់នៃគ្រារបាយការណ៍នីមួយៗ។

ព័ត៌មានអំពីការខាតបង់នៃឱនភាពតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ និងកិច្ចសន្យាទ្រព្យសកម្មរបស់ រ.ទ.ស.ភ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ២៥(ក) នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ៤.៤ ការទទួលស្គាល់ចំណូលទាក់ទងនឹងចំណូលពីថ្លៃទឹកបង្គរ

ចំណូលថ្លៃទឹកបង្គរ ត្រូវបានទទួលស្គាល់ដោយផ្អែកលើបរិមាណទឹកផលិត បរិមាណទឹកដែលបានចេញវិកយបត្រ បរិមាណទឹកបាត់បង់ជាមធ្យម និងតារាងតម្លៃជាមធ្យមតាមប្រភេទអតិថិជន។ ក្រុមប្រឹក្សាភិបាលប្រើប្រាស់ស្ថិតិនៃអត្រាបរិមាណទឹកបាត់បង់ និងតារាងតម្លៃជាមធ្យមដោយផ្អែកលើបទពិសោធន៍កន្លងមកដែលមិនអាចឆ្លុះបញ្ចាំងពីអត្រាពិតប្រាកដ និងស្ថានភាពនាពេលបច្ចុប្បន្នឱ្យបានត្រឹមត្រូវនោះឡើយ។

### ៤.៥ ការវាស់វែងពន្ធលើប្រាក់ចំណូល

ការវិនិច្ឆ័យសំខាន់ គឺចាំបាច់ក្នុងការកំណត់ការប៉ាន់ស្មានសម្រាប់ពន្ធក្នុងគ្រា និងពន្ធពន្យា ដោយ រ.ទ.ស.ភ ព្រោះបំណុលពន្ធចុងក្រោយសម្រាប់ រ.ទ.ស.ភ មិនមានភាពប្រាកដប្រជា។ នៅពេលដែលលទ្ធផលចុងក្រោយនៃពន្ធដែលត្រូវបានកំណត់ដោយអាជ្ញាធរពន្ធដារ ទឹកប្រាក់ទូទាត់ពន្ធនេះអាចខុសគ្នាពីការប៉ាន់ស្មានដំបូងនៃប្រាក់ពន្ធដែលត្រូវទូទាត់។ ចំនួនដែលខុសគ្នានោះអាចមានផលប៉ះពាល់លើពន្ធក្នុងគ្រា ពន្ធពន្យា និងពន្ធប្រយោលនានាក្នុងគ្រាដែលបានកំណត់។ រ.ទ.ស.ភ នឹងធ្វើនិយ័តកម្មពន្ធក្នុងគ្រា ឬពន្ធពន្យាដែលពាក់ព័ន្ធនឹងឆ្នាំមុនក្នុងគ្រាបច្ចុប្បន្នលើភាពខុសគ្នាទាំងនោះ។

ចំណាយពន្ធលើប្រាក់ចំណូលរបស់ រ.ទ.ស.ភ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ២០ នៃរបាយការណ៍ហិរញ្ញវត្ថុ។

# កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | ដីធ្លី<br>គិតជាពាន់រៀល | អគារ<br>គិតជាពាន់រៀល | គ្រឿងចក្រ<br>គិតជាពាន់រៀល | បំពង់បង្ហូរទឹក<br>គិតជាពាន់រៀល | បរិក្ខារមន្ទីរពិសោធន៍<br>គិតជាពាន់រៀល | គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ<br>គិតជាពាន់រៀល |
|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ១៧៦.៥៧៦.១៥៥ | ៤១៥.៩៨៦.៨៧០ | ១៣៧.៤៩៨.៨២៩ | ៧២៤.១១៦.៨៣២ | ៣.១២៣.៧០០ | ២៨.២៤៩.៥៦១ |
| ការទិញបន្ថែម | - | ៨៨.៥២៥ | ៣៦៨.៦៩០ | - | - | ១.៧៨៩.១៧៥ |
| ការផ្ទេរពីសន្និធិ | - | - | ៣.២៨១.៥៣៣ | ៤.៣៨៥ | ១៤៤.៦៣៣ | ៥៦.៨៤៩ |
| ការផ្ទេរ | ២៣.៥៣៥.១៥៣ | ១.៥៩៣.៩៧៥ | ៧៨.៥៦៧ | ៦៧.៩២៧.០៣០ | - | - |
| ការជំរះចេញពីបញ្ជី | - | (៤៤៨.០៩២) | (១.២៧៦.៩៩៧) | - | (៥៧.៦៦២) | (៨០២.៨១៩) |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២៣ | ២០០.១១១.៣០៨ | ៤១៧.២២១.២៧៨ | ១៣៩.៩៥០.៦២២ | ៧៩២.០៤៨.២៤៧ | ៣.២១០.៦៧១ | ២៩.២៩២.៧៦៦ |
| **រំលស់បង្គរ** | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | - | (៩៣.៧៩៥.៧៧១) | (៧២.៦៦២.៦៥៧) | (២២៨.៦៣៦.២៤៥) | (១.១៩៤.៤៩៩) | (១៩.២២១.៥៥៥) |
| រំលស់ក្នុងឆ្នាំ | - | (៨.៩០៧.៣០៥) | (៧.២៨៨.៨០៤) | (២០.៤៧៩.២៨០) | (៣៦៤.៧១១) | (២.៥៧១.០១៩) |
| ការជំរះចេញពីបញ្ជី | - | ១១០.២៣១ | ១.២២៣.៨០៤ | - | ៥៦.១៣៧ | ៧៨០.៣៦២ |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២៣ | - | (១០២.៥៩២.៨៤៥) | (៧៨.៧២៧.៦៥៧) | (២៤៩.១១៥.៥២៥) | (១.៥០៣.០៧៣) | (២១.០១២.២១២) |
| **តម្លៃយោង** | | | | | | |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២៣ | ២០០.១១១.៣០៨ | ៣១៤.៦២៨.៤៣៣ | ៦១.២២២.៩៦៥ | ៥៤២.៩៣២.៧២១ | ១.៧០៧.៥៩៨ | ៨.២៨០.៥៥៤ |

| | បរិក្ខារអគ្គិសនី<br>គិតជាពាន់រៀល | យានយន្ត<br>គិតជាពាន់រៀល | វ៉ាននិងឧបករណ៍<br>គិតជាពាន់រៀល | នាឡិកាទឹក<br>គិតជាពាន់រៀល | បណ្ដាញតចូលផ្ទះ<br>គិតជាពាន់រៀល | ការងារកំពុងដំណើរការ<br>គិតជាពាន់រៀល | សរុប<br>គិតជាពាន់រៀល |
|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ១៦៤.៦៧១.៥៩០ | ៤៩.៩៣៥.៦៨០ | ៤៥.៤៣៩.២៨៨ | ១៣.៥៨០.២៨៦ | ៣០.៣៩៤.០៣៣ | ១.០១៥.៨៨៨.៤០៥ | ២.៨០៥.៤៦១.២៣០ |
| ការទិញបន្ថែម | ១.៣៣៤.៨២២ | ៧.៧៧៥.៣៥៧ | ៤៣០.២១៤ | - | - | ២៦៩.៧៥០.៩៩៣ | ២៨១.៥៣៧.៧៧៦ |
| ការផ្ទេរពីសន្និធិ | ១.២៦១.៤៣០ | ១១.០៨៨ | ២.៤៨៧.០៥៨ | ៥៤.៩៧៤ | - | ៦៤.៨៤១.៤៧៥ | ៧២.១៤៣.៤២៥ |
| ការផ្ទេរ | ៨៦៤.៧៥៧ | ៣.៥០៥.៣១១ | ៤៥២.៩៣៣ | ៨៤៨.៥២១ | ៦.៥៣៧.៦១៦ | (១០៥.៣៤៣.៨៦៣) | - |
| ការជំរះចេញពីបញ្ជី | (៧២៧.៤៥៤) | (៦០៧.៤៧០) | (១.១៣១.៣១៤) | (៣.៧៤១) | - | (១.១៨៣.៧៨៥) | (៦.២៣៩.៣៣៤) |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២៣ | ១៦៧.៤០៥.១៤៥ | ៦០.៦១៩.៩៦៦ | ៤៧.៦៧៨.១៧៩ | ១៤.៤៨០.០៤០ | ៣៦.៩៣១.៦៤៩ | ១.២៤៣.៩៥៣.២២៦ | ៣.១៥២.៩០៣.០៩៧ |
| **រំលស់បង្គរ** | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | (១០៧.៣៨៥.៥៩៥) | (៤១.៦៩៩.៨០៨) | (២២.១៩០.៩៣៥) | (៩.៥១៧.២៩៣) | (៦.១១៤.៩៥៩) | - | (៦០២.៤១៩.៣១៧) |
| រំលស់ក្នុងឆ្នាំ | (៨.២៤០.៨០៥) | (៣.៧២៤.៤៥៣) | (៤.២៦៨.៧៦៦) | (១.៤៨៧.៨២៨) | (២.៧៨២.៣៩៨) | - | (៦០.១១៥.៣៦៩) |
| ការជំរះចេញពីបញ្ជី | ៧២៧.៤៥៤ | ៦០៧.៤៧០ | ១.១០១.៦៨០ | ៣.៧៤១ | - | - | ៤.៦១០.៨៧៩ |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២៣ | (១១៤.៨៩៨.៩៤៦) | (៤៤.៨១៦.៧៩១) | (២៥.៣៥៨.០២១) | (១១.០០១.៣៨០) | (៨.៨៩៧.៣៥៧) | - | (៦៥៧.៩២៣.៨០៧) |
| **តម្លៃយោង** | | | | | | | |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២៣ | ៥២.៥០៦.១៩៩ | ១៥.៨០៣.១៧៥ | ២២.៣២០.១៥៩ | ៣.៤៧៨.៦៥៩ | ២៨.០៣៤.២៩២ | ១.២៤៣.៩៥៣.២២៦ | ២.៤៩៤.៩៧៩.២៩០ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

# កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | ដីធ្លី គិតជាពាន់រៀល | អគារ គិតជាពាន់រៀល | គ្រឿងចក្រ គិតជាពាន់រៀល | បំពង់បង្ហូរទឹក គិតជាពាន់រៀល | បរិក្ខារមន្ទីរពិសោធន៍ គិតជាពាន់រៀល | គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ គិតជាពាន់រៀល | បរិក្ខារអគ្គិសនី គិតជាពាន់រៀល | យានយន្ត គិតជាពាន់រៀល | វ៉ាននិងឧបករណ៍ គិតជាពាន់រៀល | នាឡិកាទឹក គិតជាពាន់រៀល | បណ្តាញតចូលផ្ទះ គិតជាពាន់រៀល | ការងារកំពុងដំណើរការ គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ១៧៦.៥៧៦.១៥៥ | ៤១៤.៧៥២.២៣០ | ១៣៤.៧៨៧.២២១ | ៧០១.០៩៦.៧៨៥ | ២.៩៣៨.៥០៤ | ២៥.២៩២.២១៨ | ១៦៣.៥៩៣.៦៨០ | ៤៩.៧៥០.៣៩០ | ៣៩.៧៧៣.២៦៨ | ១២.៨០៤.០០២ | ២៤.១១៥.០៣១ | ៦៩៣.៣៤៣.៥២៤ | ២.៤៣៨.៨២៣.០០៨ |
| ការទិញបន្ថែម | - | ៤៣.០៤៨ | ៨៩.៣៧៥ | - | - | ២.៩៥៧.៣៤៣ | ៨២.៤៨៣ | ១៥២.១៦៩ | ២៥០.៥១៥ | ៣.៤៥១ | - | ២៨៣.៥៤៦.៤២៨ | ២៨៧.១២៤.៨១២ |
| ការផ្ទេរ | - | ១.១៩១.៥៩២ | ១.៣៨៦.១៦០ | ២៣.០២០.០៤៧ | - | - | ២៧៩.៧៨៤ | - | ៧៦២.៨៥៥ | ៧៣២.៣៤០ | ៦.២៧៩.០០២ | (៣៣.៦៥១.៧៨០) | - |
| ការផ្ទេរទៅទ្រព្យសកម្មអរូបី | - | - | - | - | - | - | - | - | - | - | - | (១.១២៥.០០០) | (១.១២៥.០០០) |
| ការផ្ទេរពីសន្និធិ | - | - | ១.២៣៦.០៧៣ | - | ១៨៥.១៩៦ | - | ៧១៥.៦៤៣ | ៣៣.១២១ | ៤.៦៥២.៦៥០ | ៤០.៤៩៣ | - | ៧៣.៩១២.០៧២ | ៨០.៧៧៥.២៤៩ |
| ការជំរះចេញពីបញ្ជី | - | - | - | - | - | - | - | - | - | - | - | (១៣៦.៨៣៩) | (១៣៦.៨៣៩) |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២២ | ១៧៦.៥៧៦.១៥៥ | ៤១៥.៩៨៦.៨៧០ | ១៣៧.៤៩៨.៨២៩ | ៧២៤.១១៦.៨៣២ | ៣.១២៣.៧០០ | ២៨.២៤៩.៥៦១ | ១៦៤.៦៧១.៥៩០ | ៤៩.៩៣៥.៦៨០ | ៤៥.៤៣៩.២៨៨ | ១៣.៥៨០.២៨៦ | ៣០.៣៩៤.០៣៣ | ១.០១៥.៨៨៨.៤០៥ | ២.៨០៥.៤៦១.២៣០ |
| **រំលស់បង្គរ** | | | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | ៨៤.៩១៥.២៤២ | ៦៥.២២២.០៤៤ | ២០៩.៣៩៦.០៣៨ | ៨៤៣.៣៩៨ | ១៦.៨៣៧.៧២៣ | ៩៩.៤០៣.៥៥៩ | ៣៨.២៨៥.៥៩០ | ១៨.៤៥៨.១០១ | ៧.៧៣៤.០៥៣ | ៣.៨៦២.៦៤១ | - | ៥៤៤.៩៥៨.៣៨៩ |
| រំលស់ក្នុងឆ្នាំ | - | ៨.៨៨០.៥២៩ | ៧.៤៤០.៦១៣ | ១៩.២៤០.២០៧ | ៣៥១.១០១ | ២.៣៨៣.៨៣២ | ៧.៩៨២.០៣៦ | ៣.៤១៤.២១៨ | ៣.៧៣២.៨៣៤ | ១.៧៨៣.២៤០ | ២.២៥២.៣១៨ | - | ៥៧.៤៦០.៩២៧ |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២២ | - | ៩៣.៧៩៥.៧៧១ | ៧២.៦៦២.៦៥៧ | ២២៨.៦៣៦.២៤៥ | ១.១៩៤.៤៩៩ | ១៩.២២១.៥៥៥ | ១០៧.៣៨៥.៥៩៥ | ៤១.៦៩៩.៨០៨ | ២២.១៩០.៩៣៥ | ៩.៥១៧.២៩៣ | ៦.១១៤.៩៥៩ | - | ៦០២.៤១៩.៣១៦ |
| **តម្លៃយោង** | | | | | | | | | | | | | |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២២ | ១៧៦.៥៧៦.១៥៥ | ៣២២.១៩១.០៩៨ | ៦៤.៨៣៦.១៧២ | ៤៩៥.៤៨០.៥៨៨ | ១.៩២៩.២០១ | ៩.០២៨.០០៦ | ៥៧.២៨៥.៩៩៥ | ៨.២៣៥.៨៧២ | ២៣.២៤៨.៣៥៣ | ៤.០៦២.៩៩៤ | ២៤.២៧៩.០៧៤ | ១.០១៥.៨៨៨.៤០៥ | ២.២០៣.០៤១.៩១៤ |

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

ក្នុងឆ្នាំ រ.ទ.ស.ភ បានធ្វើការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដោយទូទាត់ជាសាច់ប្រាក់ដូចខាងក្រោម៖

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| ការទិញបន្ថែម | ២៨១.៥៣៧.៧៧៦ | ២៨៧.១២៤.៨១២ |
| មូលធនីយកម្មលើការប្រាក់លើទ្រព្យសកម្មដែលមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ | (១១.៦៥០.៨៣០) | (៥.៥០៥.០៩៦) |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ទូទាត់ ជាសាច់ប្រាក់ | ២៦៩.៨៨៦.៩៤៦ | ២៨១.៦១៩.៧១៦ |

## ៦. សន្និធិ

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| **នៅថ្លៃដើម៖** | | |
| បំពង់ និងបរិក្ខារចែកចាយទឹកស្អាត | ២៣៦.៣៦៩.៧៨០ | ១១៧.៩០៥.៥០២ |
| សន្និធិកំពុងដឹកជញ្ជូន | ៤៨.៩៣៣.៨៥៣ | ៥.៨០៥.០៥២ |
| គ្រឿងបន្លាស់ និងឧបករណ៍ផ្សេងៗ | ៨.៨០៤.២៨២ | ៧.៤៧៤.៣៤០ |
| នាឡិកាទឹក | ៧.៤២១.១៥៩ | ៩.២១៨.៨៩៤ |
| សារធាតុគីមី | ២.៥៤២.០៦០ | ២.០៥៧.០០៤ |
| វត្ថុធាតុដើមផ្សេងៗ | ១៤.៦៧៥.៤៥៨ | ១០.២៧៦.២៨៦ |
| | ៣១៨.៧៤៦.៥៩២ | ១៥២.៧៣៧.០៧៨ |

ថ្លៃដើមនៃសន្និធិ ត្រូវបានទទួលស្គាល់ជាចំណាយក្នុងឆ្នាំចំនួន ២០.៦៩២លានរៀល (ឆ្នាំ២០២២៖ ១៧.០៩៤ លានរៀល)។

សន្និធិកំពុងដឹកជញ្ជូនភាគច្រើនជាប្រភេទបំពង់ ដែលបានមកដល់ត្រឹមកំពង់ផែដើមរបស់អ្នកផ្គត់ផ្គង់ និងកំពុងត្រូវបានដឹកជញ្ជូនឆ្ពោះមកកាន់កំពង់ផែនៃប្រទេសកម្ពុជា។

## ៧. គណនីអតិថិជនពាណិជ្ជកម្ម និង គណនីត្រូវទទួលផ្សេងៗ

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| **គណនីពាណិជ្ជកម្ម** | | |
| គណនីត្រូវទទួលលក្ខណៈរដ្ឋបាលសាធារណៈ | ៦.៦៦២.៨១៩ | ១១.៦៧៣.២៨១ |
| គណនីត្រូវទទួលលក្ខណៈគ្រួសារ | ២.៤២៩.៣៨១ | ១.១១៩.៩២៧ |
| គណនីត្រូវទទួលលក្ខណៈអាជីវកម្ម | ១.៦៧៣.៦៩៦ | ១.៣០០.៩៥៩ |
| តំណាងចែកចាយទឹក | ២២១.៥០៨ | ១០៣.៦៤៧ |
| ដក៖ ការខាតបង់លើឱនភាព(គណនីត្រូវទទួលលក្ខណៈគ្រួសារ) | (៥.៥៥៣) | (៥.៥៥៣) |
| | ១០.៩៨១.៨៥១ | ១៤.១៩២.២៦១ |
| **មិនមែនគណនីពាណិជ្ជកម្ម** | | |
| រតនាគារជាតិ | ៥.២៤២.២៨៦ | ៤.៤៤២.៤៧៦ |
| ប្រាក់ធានាសម្រាប់ប្រតិបត្តិការ | ២.៨៨៧.៧៦៩ | ២.៨៨៧.៧៦៩ |
| ការប្រាក់ត្រូវទទួល | ២.៧៣៦.១៤៦ | ២.៣០៨.៨៧០ |
| បុរេប្រទានទៅអ្នកផ្គត់ផ្គង់ | ៦៤០.២៧៧ | ៦៣៦.១៧៣ |
| អាករលើតម្លៃបន្ថែមត្រូវទទួល - សុទ្ធ | - | ១៤៦.៧៤៦ |
| គណនីត្រូវទទួលផ្សេងៗ | ៥.៤៩១.៩០៧ | ៨.០៩៣.១២១ |
| | ១៦.៩៩៨.៣៨៥ | ១៨.៥១៥.១៥៥ |
| | ២៧.៩៨០.២៣៦ | ៣២.៧០៧.៤១៦ |

គណនីអតិថិជនពាណិជ្ជកម្មគឺមិនមានការប្រាក់ ហើយលក្ខខណ្ឌឥណទានធម្មតាដែលផ្តល់ដោយ រ.ទ.ស.ភ មានរយៈពេល ១ខែ។ ទោះបីជាយ៉ាងណាក៏ដោយ គណនីត្រូវទទួលពីរដ្ឋបាលសាធារណៈ តំណាងឱ្យគណនីត្រូវទទួលពីស្ថាប័នពាក់ព័ន្ធនឹងរាជរដ្ឋាភិបាលមានរយៈពេល ១ឆ្នាំ គិតពីកាលបរិច្ឆេទចេញវិក្កយបត្រ។ លក្ខខណ្ឌឥណទានផ្សេងទៀតត្រូវបានវាយតម្លៃ និងអនុម័តតាមករណីជាក់ស្តែង។

## ៨. កិច្ចសន្យាទ្រព្យសកម្ម ឬបំណុល

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| **កិច្ចសន្យាទ្រព្យសកម្ម** | | |
| កិច្ចសន្យាទ្រព្យសកម្មទាក់ទងនឹងកិច្ចសន្យាសេវាសាងសង់ | ៦.៥៥១.២០១ | ៣.៥៣៣.៨៩៨ |
| កិច្ចសន្យាទ្រព្យសកម្មទាក់ទងនឹងការលក់ទឹកស្អាត | ១៤៨.៩៥០.០៥៤ | ៨៩.២៣៤.៤៧៦ |
| | ១៥៥.៥០១.២៥៥ | ៩២.៧៦៨.៣៧៤ |
| **កិច្ចសន្យាបំណុល** | | |
| កិច្ចសន្យាបំណុលទាក់ទងនឹងកិច្ចសន្យាសេវាសាងសង់ | ៤.២៥៤.១៣៨ | ៤.៤៥៦.៧៥៦ |

កិច្ចសន្យាទ្រព្យសកម្មទាក់ទងនឹងកិច្ចសន្យាសេវាសាងសង់ តំណាងឱ្យភាពខុសគ្នានៃពេលវេលាក្នុងការទទួលស្គាល់ចំណូល និងការចេញវិក្កយបត្រ។ ការចេញវិក្កយបត្រ គឺត្រូវបានកំណត់ និង/ឬ ត្រូវបានចរចាជាមួយអតិថិជនដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីការបញ្ចប់នៃកិច្ចសន្យា។

កិច្ចសន្យាទ្រព្យសកម្មទាក់ទងនឹងចំណូលថ្លៃទឹក តំណាងឱ្យបរិមាណទឹកដែលបានផ្គត់ផ្គង់ទៅឱ្យអតិថិជន ប៉ុន្តែមិនទាន់បានចេញវិក្កយបត្រនៅចុងឆ្នាំបញ្ចប់។ កិច្ចសន្យាទ្រព្យសកម្មទាំងនេះ ត្រូវបានផ្ទេរទៅគណនីត្រូវទទួលនៅពេលមានសិទ្ធក្នុងការទទួលបានផលប្រយោជន៍សេដ្ឋកិច្ចដោយឥតលក្ខខណ្ឌ ដែលកើតឡើងនៅពេលដែល រ.ទ.ស.ភ ចេញវិក្កយបត្រ។

កិច្ចសន្យាបំណុលទាក់ទងនឹងកិច្ចសន្យាសេវាការសាងសង់ តំណាងឱ្យសាច់ប្រាក់ដែលទទួលបានមុនសម្រាប់សេវាការសាងសង់ ដែលបានផ្តល់ឱ្យក្នុងការពង្រីកប្រព័ន្ធចែកចាយទឹកទៅឱ្យអ្នកផ្គត់ផ្គង់ទឹកតាមបណ្តាខេត្ត។ សាច់ប្រាក់ដែលទទួលបានមុន ត្រូវបានទទួលស្គាល់ជាចំណូលនៅពេលដែលកាតព្វកិច្ចត្រូវបានបំពេញ។

## ៨. ទ្រព្យសកម្ម ឬកិច្ចសន្យាបំណុល (ត)

*បម្រែបម្រួលជាសារវន្តនៃសមតុល្យកិច្ចសន្យា*

| | កិច្ចសន្យាទ្រព្យសកម្ម ទាក់ទងនឹងកិច្ចសន្យា សេវាសាងសង់ គិតជាពាន់រៀល | កិច្ចសន្យាទ្រព្យសកម្ម ទាក់ទងនឹងការលក់ទឹក ស្អាត គិតជាពាន់រៀល | កិច្ចសន្យាបំណុល ទាក់ទងនឹងកិច្ចសន្យា សេវាសាងសង់ គិតជាពាន់រៀល |
|---|---|---|---|
| **២០២២** | | | |
| នាថ្ងៃទី១ ខែមករា | ៥៣៦.០៥១ | ៦៥.៤៨៨.៥២៩ | ១.៧៨៨.៨៩៤ |
| កើនឡើងដោយសារចំណូលទទួលស្គាល់កម្រៃពីការផ្តល់សេវាសាងសង់មិនទាន់បានចេញវិក្កយបត្រទៅឱ្យអតិថិជន | ១២.៨០៧.៧១៨ | ៣២០.៥១០.៧២៩ | ២.៦៦៧.៨៦២ |
| ថយចុះដោយសារបានចេញវិក្កយបត្រទៅឱ្យអតិថិជន | (៩.៨០៩.៨៧១) | (២៩៦.៧៦៤.៧៨២) | - |
| នាថ្ងៃទី៣១ ខែធ្នូ | ៣.៥៣៣.៨៩៨ | ៨៩.២៣៤.៤៧៦ | ៤.៤៥៦.៧៥៦ |
| **២០២៣** | | | |
| នាថ្ងៃទី១ ខែមករា | ៣.៥៣៣.៨៩៨ | ៨៩.២៣៤.៤៧៦ | ៤.៤៥៦.៧៥៦ |
| កើនឡើងដោយសារចំណូលទទួលស្គាល់កម្រៃពីការផ្តល់សេវាសាងសង់មិនទាន់បានចេញវិក្កយបត្រទៅឱ្យអតិថិជន | ៥.៦៧៤.៥៥៨ | ៣៦៧.៣២៣.៥១១ | - |
| ថយចុះដោយសារបានចេញវិក្កយបត្រទៅឱ្យអតិថិជន | (២.៦៥៧.២៥៥) | (៣០៧.៦០៧.៩៣៣) | (២០២.៦១៨) |
| នាថ្ងៃទី៣១ ខែធ្នូ | ៦.៥៥១.២០១ | ១៤៨.៩៥០.០៥៤ | ៤.២៥៤.១៣៨ |

## ៩. ឥណទានផ្តល់ឱ្យនិយោជិក

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមប្រឹក្សាភិបាលបានអនុម័តសំណើផ្តល់ភាគហ៊ុនអណ្តែត ១០% ទុកបម្រុងសម្រាប់និយោជិករបស់ រ.ទ.ស.ភ។ ចំនួនភាគហ៊ុនដែលត្រូវបែងចែកទៅនិយោជិកម្នាក់ៗ ត្រូវបានកំណត់នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២ ដែលជាកាលបរិច្ឆេទក្នុងការអនុម័តលើគម្រោងភាគហ៊ុនពេលអនាគតដែលបានផ្តល់ឱ្យនិយោជិកដែលមានតម្លៃសរុបចំនួន ៨.២១៨លានរៀល។ រ.ទ.ស.ភ បានផ្តល់ប្រាក់កម្ចីឥតការប្រាក់ដែលមានរយៈពេល ៣ឆ្នាំសម្រាប់និយោជិក និងមន្ត្រីជាន់ខ្ពស់ក្នុងការទិញភាគហ៊ុនទាំងនេះ។ តាមរយៈកំណត់ហេតុនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ និយោជិកត្រូវបានអនុញ្ញាតឱ្យជួញដូរភាគហ៊ុនរបស់ខ្លួនប្រសិនបើប្រាក់កម្ចីត្រូវបានទូទាត់។ គិតត្រឹមថ្ងៃនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ប្រាក់កម្ចីទាំងនេះនៅតែមិនទាន់ត្រូវបានទូទាត់សង ជាមួយនឹងឱនភាពតម្លៃសរុបជាទឹកប្រាក់ចំនួន ២៦១លានរៀល។

ក្រុមប្រឹក្សាភិបាល ស្ថិតក្នុងដំណាក់កាលរង់ចាំមតិយោបល់ពីនិយ័តករមូលបត្រកម្ពុជាលើគម្រោងភាគហ៊ុនពេលអនាគតដែលបានផ្តល់ឱ្យនិយោជិកគិតត្រឹមការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ១០. ការវិនិយោគរយៈពេលខ្លី

ទាំងនេះតំណាងឱ្យប្រាក់បញ្ញើមានកាលកំណត់តម្កល់នៅគ្រឹះស្ថានហិរញ្ញវត្ថុ សម្រាប់រយៈពេលមួយឆ្នាំ ឬតិចជាងនេះ ហើយទទួលបានការប្រាក់ចន្លោះពី ៣,៥០% ទៅ ៦,៧៥% (ឆ្នាំ២០២២៖ ៣,៥០% ទៅ ៤,៧៥%) ក្នុងមួយឆ្នាំ។

## ១១. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| សមតុល្យធនាគារ | ១៥.៧៨២.១៥១ | ៣៩.៩៦៥.៨១៧ |
| ប្រាក់តម្កល់រយៈពេលខ្លី (កំឡុងពេល ៣ខែ) | - | ១៦.៤៦៨.០០០ |
| សាច់ប្រាក់ក្នុងដៃ | ៣៣៥.០៧១ | ២៨២.៦២២ |
| | ១៦.១១៧.២២២ | ៥៦.៧១៦.៤៣៩ |

សមតុល្យធនាគារទទួលបានអត្រាការប្រាក់ចន្លោះពី ០,២៥% ទៅ ១,៥% (ឆ្នាំ២០២២៖ ០,៥% ទៅ ២%) ក្នុងមួយឆ្នាំ ហើយចំណែកឯ ប្រាក់តម្កល់រយៈពេលខ្លីវិញទទួលបានអត្រាការប្រាក់ចន្លោះពី ២,២៥% ទៅ ២,៧៥% (ឆ្នាំ២០២២៖ ២,២៥% ទៅ ២,៧៥%) ក្នុងមួយឆ្នាំ។

## ១២. ដើមទុន និងបុព្វលាភភាគហ៊ុន

| | | ២០២៣ | ២០២២ |
|---|---|---|---|
| | ចំនួនភាគហ៊ុន | គិតជាពាន់រៀល | គិតជាពាន់រៀល |
| ភាគហ៊ុនប្រភេទ A | ៣៩១.១០០.៩៤២ | ៣៩១.១០០.៩៤២ | ៣៩១.១០០.៩៤២ |
| ភាគហ៊ុនធម្មតា | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ |
| បុព្វលាភភាគហ៊ុន | - | ៦៣.១៥៣.១៧៨ | ៦៣.១៥៣.១៧៨ |
| ទុនបម្រុង | - | ៧៩.៥៣១.៨២៥ | ៧៩.៥៣១.៨២៥ |
| | ៤៧៨.០៧៤.១០៤ | ៦២០.៧៥៩.១០៧ | ៦២០.៧៥៩.១០៧ |

(ក) នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមប្រឹក្សាភិបាលបានអនុម័តលើការបំបែកដើមទុនដែលមានចំនួន ៤៦៥.០២៨.000រៀល ទៅជាភាគហ៊ុនធម្មតាចំនួន ៧៣.៩២៧.១៨៧ និងភាគហ៊ុនប្រភេទA ចំនួន ៣៩១.១០០.៩៤២ ដែលមានតម្លៃចារិក ១.000រៀលក្នុងមួយហ៊ុន។ ភាគហ៊ុនប្រភេទA ត្រូវបានកាន់កាប់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនមានសិទ្ធទទួលបានការប្រាក់ ឬភាគលាភទេ និងទទួលបានសិទ្ធ និងមានលក្ខខណ្ឌដូចដែលបានបរិយាយលម្អិតក្នុងកថាខណ្ឌ ១២.២ នៃលក្ខន្តិកៈរបស់ រ.ទ.ស.ភ ដែលបានចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២។

(ខ) នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ រ.ទ.ស.ភ បានក្លាយជាក្រុមហ៊ុនដំបូងដែលបានចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជាដោយជោគជ័យ ដែលមានចំនួនភាគហ៊ុនធម្មតាសរុបចំនួន ៨៦.៩៧៣.១៦២ភាគហ៊ុន ដែលមានតម្លៃចារិក ១.000រៀលក្នុងមួយហ៊ុន។ ថ្លៃដើមក្នុងការបោះផ្សាយ ១៣.០៤៥.៩៧៥ភាគហ៊ុនដំបូង មានចំនួន ៦.000 លានរៀល ដែលបានកាត់កងជាមួយបុព្វលាភភាគហ៊ុន។ ភាគហ៊ុនធម្មតាដែលបានបោះផ្សាយទាំងអស់ត្រូវបានទូទាត់រួច។ ភាគហ៊ុនិកធម្មតាមានដូចខាងក្រោម៖

| | ចំនួនភាគហ៊ុន | % |
|---|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៧៣.៩២៧.១៨៧ | ៨៥% |
| ភាគហ៊ុនិកផ្សេងៗ | ១១.៧៤១.៦០៦ | ១៤% |
| ភាគហ៊ុននាពេលអនាគតដែលបានផ្តល់ឱ្យនិយោជិក | ១.៣០៤.៣៦៩ | ១% |
| | ៨៦.៩៧៣.១៦២ | ១០០% |

យោងតាមកំណត់ហេតុនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ និយោជិកទាំងអស់ត្រូវបានអនុញ្ញាតឱ្យជួញដូរភាគហ៊ុនរបស់ខ្លួន ប្រសិនបើប្រាក់កម្ចីត្រូវបានទូទាត់។

ភាគហ៊ុនធម្មតាទាំងអស់ត្រូវបានធ្វើចំណាត់ថ្នាក់ស្មើៗគ្នាដោយផ្អែកលើទ្រព្យសកម្មនៅសល់របស់ រ.ទ.ស.ភ។

## ១២. ដើមទុន និងបុព្វលាភភាគហ៊ុន (ត)

(គ) មូលនិធិបម្រុងភាគច្រើនរួមមាន ការបណ្តាក់ទុនជាទ្រព្យសកម្ម និងបំណុលដែលបានសន្មតនៅកាលបរិច្ឆេទដាក់បន្ថែមដើមទុន។

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| នាថ្ងៃទី១ ខែមករា | ៧៩.៥៣១.៨២៥ | ៧៨.០៨៨.៦០៤ |
| ការបន្ថែមដើមទុន | - | ១.៤៤៣.២២១ |
| នាថ្ងៃទី៣១ ខែធ្នូ | ៧៩.៥៣១.៨២៥ | ៧៩.៥៣១.៨២៥ |

នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើនដើមទុនរបស់ខ្លួននៅ រ.ទ.ស.ភ ដោយបណ្តាក់ទុនបន្ថែមនូវទ្រព្យសកម្ម បំណុល និងមូលធន សម្រាប់ប្រតិបត្តិការរោងចក្រផលិតទឹកស្អាតខេត្តត្បូងឃ្មុំ (ហៅកាត់ថា "គម្រោងខេត្តត្បូងឃ្មុំ") ទៅឱ្យ រ.ទ.ស.ភ ដែលមានចំនួនសរុប ៧៨.០៨៨.៦០៤.០០០រៀល ដោយគ្មានការបោះផ្សាយភាគហ៊ុនបន្ថែមរបស់ រ.ទ.ស.ភ នោះទេ។

## ១៣. ទុនបម្រុង

| | ទុនបម្រុង មូលធន គិតជាពាន់រៀល | ទុនបម្រុង តាមច្បាប់ គិតជាពាន់រៀល | ទុនបម្រុង ទូទៅ គិតជាពាន់រៀល | ទុនបម្រុង សម្រាប់ការអភិវឌ្ឍន៍ គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ១.៦៤៨.៤៣៥ | ៣២.១១៧.៩៧៧ | ៣២.១១៧.៩៧៧ | ៣៥២.១៥៤.០២១ | ៤១៨.០៣៨.៤១០ |
| ការផ្ទេរពីចំណេញរក្សាទុក | - | ៦.៤៦៣.៦៩៤ | ៦.៤៦៣.៦៩៤ | ១១២.៣០២.២៧៧ | ១២៥.២២៩.៦៦៥ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២/ នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ១.៦៤៨.៤៣៥ | ៣៨.៥៨១.៦៧១ | ៣៨.៥៨១.៦៧១ | ៤៦៤.៤៥៦.២៩៨ | ៥៤៣.២៦៨.០៧៥ |
| ការផ្ទេរពីចំណេញរក្សាទុក | - | ៥.៤០៩.២៩៤ | ៥.៤០៩.២៩៤ | ៩៣.០៦២.១១៩ | ១០៣.៨៨០.៧០៧ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ១.៦៤៨.៤៣៥ | ៤៣.៩៩០.៩៦៥ | ៤៣.៩៩០.៩៦៥ | ៥៥៧.៥១៨.៤១៧ | ៦៤៧.១៤៨.៧៨២ |

(ក) យោងតាមលក្ខន្តិកៈរបស់ រ.ទ.ស.ភ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌទី៤៤ បញ្ជាក់ពីការបែងចែកភាគលាភ និងទុនបម្រុងមានដូចខាងក្រោម៖

ចំណេញរក្សាទុកត្រូវបានបែងចែកដូចខាងក្រោម៖

(១) ផ្តល់ជាប្រាក់រង្វាន់ចំពោះគណៈគ្រប់គ្រង និងនិយោជិក
- ប្រាក់ខែ ១ខែសម្រាប់និយោជិកទាំងអស់ ប្រសិនបើចំណេញសុទ្ធនៅចន្លោះពី ៥% ទៅ ១០% នៃចំណាយប្រតិបត្តិការ
- ប្រាក់ខែ ២ខែសម្រាប់និយោជិកទាំងអស់ ប្រសិនបើចំណេញសុទ្ធនៅចន្លោះពី ១០% ទៅ ២០% នៃចំណាយប្រតិបត្តិការ
- ប្រាក់ខែ ៣ខែសម្រាប់និយោជិកទាំងអស់ ប្រសិនបើចំណេញសុទ្ធលើសពី ២០% នៃចំណាយប្រតិបត្តិការ

(២) ២% សម្រាប់អត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ និងពិការភាព

(៣) ៥% សម្រាប់ទុនបម្រុងតាមច្បាប់

(៤) ៥% សម្រាប់ទុនបម្រុងទូទៅ

(៥) ៥% សម្រាប់មូលនិធិសង្គម ដែលនឹងត្រូវកត់ត្រាជាចំណាយក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។

## ១៣. ទុនបម្រុង (ត)

ចំនួនទឹកប្រាក់នៅសល់បន្ទាប់ពីការបែងចែកខាងលើនឹងត្រូវបន្តបែងចែកដូចខាងក្រោម៖

(១) ទុនបម្រុងសម្រាប់ការវិនិយោគពេលអនាគតដែលត្រូវមានការអនុម័តដោយក្រុមប្រឹក្សាភិបាល

(២) ទឹកប្រាក់នៅសល់បន្ទាប់ពីបែងចែកទុនបម្រុង សម្រាប់ការការវិនិយោគទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៨៥% និងវិនិយោគិនសាធារណៈ ១៥%។

(ខ) ការប្រើប្រាស់ទុនបម្រុងក្នុងការទូទាត់ទៅសកម្មភាពសង្គម គឺអនុលោមតាមលិខិតលេខ២៨៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០។ សកម្មភាពសង្គមទាក់ទងនឹងការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ ទឹកស្អាតសម្រាប់ក្រុមយោធានៅតាមបណ្តាខេត្តមួយចំនួន។ សកម្មភាពការងារត្រូវបន្តដល់ឆ្នាំ២០១១ ដោយយោងតាមលិខិតរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់ លេខ២២១០ សហវ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១។

## ១៤. ប្រាក់កម្ចី

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| **បំណុលរយៈពេលវែង** | | |
| ប្រាក់កម្ចីមិនមានការធានា | ១.២៩៦.៩២៤.៦៨៤ | ៩៨៦.៤៩៥.៧១៧ |
| **បំណុលរយៈពេលខ្លី** | | |
| ប្រាក់កម្ចីមិនមានការធានា | ២៣.៦៧៧.៤០១ | ២៣.៤៩៩.១៥៨ |
| **ប្រាក់កម្ចីសរុប** | **១.៣២០.៦០២.០៨៥** | **១.០០៩.៩៩៤.៨៧៥** |

## ១៤. ប្រាក់កម្ចី (ត)

លក្ខខណ្ឌនៃប្រាក់កម្ចីនៅសល់មានដូចខាងក្រោម៖

| | រូបិយប័ណ្ណ | អត្រាការប្រាក់ ធម្មតា + អត្រា កវ.ហ.ស. | ឆ្នាំនៃ កាលវសាន្ត | ២០២៣ គិតជាពាន់រៀល | ២០២២ គិតជាពាន់រៀល |
|---|---|---|---|---|---|
| ធនាគារវិនិយោគអឺរ៉ុប | ដុល្លារអាមេរិក | ០,៦១០% - ០,៩៦៥% | ២០៤៨ | ៣៩៦.៨៤២.៤៩២ | ៣៩២.១០០.២៥៤ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១២៤៤ ០១ M | ដុល្លារអាមេរិក | ០,៩០០% | ២០៣៩ | ៣៤៨.៩៦៨.២៦៥ | ១១៨.៤៧៨.៩៥៦ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១៧៦ ០១ S | ដុល្លារអាមេរិក | ០,៩០០% | ២០៣៨ | ៣៣៤.៤០០.៥៩៤ | ២៨៥.៤៣៤.៤៨៥ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១៧៤ ០១ P | ដុល្លារអាមេរិក | ១,៨០០% | ២០៣៧ | ១៤៨.១៤០.២៣៤ | ១៤៩.២៩៩.៨៣៨ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន | យេន | ០,៦៦០% | ២០៤៩ | ៣៤.៣១១.៤៥៨ | ៣៧.៨៦៩.៨៣៩ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ធនាគារអភិវឌ្ឍន៍អាស៊ី | អេស ដេ អា | ១,៦៥០% | ២០៣៧ | ៣០.៥៥៨.៤៣៥ | ៣២.៨១០.០៩៥ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ ០១ F | អឺរ៉ូ | ០,២៥០% | ២០២៥ | ២៧.៣៨០.៦០៧ | ៤៤.០០១.៤០៨ |
| **បំណុលមានការប្រាក់សរុប** | | | | ១.៣២០.៦០២.០៨៥ | ១.០០៩.៩៩៤.៨៧៥ |

## ១៤. ប្រាក់កម្ចី (ត)

### ការបំពានលើកិច្ចព្រមព្រៀងប្រាក់កម្ចី

ប្រាក់កម្ចីរបស់ រ.ទ.ស.ភ មានការប្រាក់ចាប់ពី 0,២៥០% ទៅ ១,៨00% និងត្រូវសងចន្លោះពេលពី ១ ទៅ ២៥ ឆ្នាំ។ ប្រាក់កម្ចីពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង មានកិច្ចព្រមព្រៀងប្រាក់កម្ចី ដែល រ.ទ.ស.ភ ត្រូវអនុលោមតាម បើមិនដូច្នេះទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង/ឬ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងនឹងព្យួរ ឬលុបសិទ្ធិរបស់ រ.ទ.ស.ភ ក្នុងការស្នើសុំការទូទាត់បន្ថែមនៃចំនួនប្រាក់កម្ចីដែលមិនទាន់បានដក និងតម្រូវឱ្យសងវិញតាមតម្រូវការនៃសមតុល្យដែលនៅសល់ ប្រសិនបើការបំពានលើកិច្ចព្រមព្រៀងប្រាក់កម្ចីនោះមានលក្ខណៈជាសារវន្ត។

រ.ទ.ស.ភ បានហួសពីកម្រិតអានុភាពអតិបរមាគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ រ.ទ.ស.ភ ទទួលបានការលើកលែងពីភាគីពាក់ព័ន្ធដែលពន្យាដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ ដោយហេតុនេះ ប្រាក់កម្ចីពុំត្រូវបានចាត់ទុកជាប្រាក់កម្ចី ត្រូវសងតាមតម្រូវការនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ នោះទេ។

## ១៥. ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗ

| | ជំនួយរបស់ សហភាពអឺរ៉ុប គិតជាពាន់រៀល | ជំនួយរបស់ ទីភ្នាក់ងារ សហប្រតិបត្តិការ អន្តរជាតិជប៉ុន គិតជាពាន់រៀល | ជំនួយរដ្ឋាភិបាល គិតជាពាន់រៀល | ជំនួយផ្សេងៗ គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | ១២.០៤៤.៥៣៣ | ៤.១០៦.៥៧១ | ៦៦១.០៨២ | ១៦.៨១២.១៨៦ |
| ជំនួយបន្ថែមក្នុងឆ្នាំ | ៥៤.៤៣៦.១៩៩ | - | - | - | ៥៤.៤៣៦.១៩៩ |
| រំលស់ក្នុងឆ្នាំ | - | (១.៨៥៣.00៦) | (១៣៤.០៦៩) | (២២.៨៣៣) | (២.00៩.៩0៨) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ៥៤.៤៣៦.១៩៩ | ១០.១៩១.៥២៧ | ៣.៩៧២.៥០២ | ៦៣៨.២៤៩ | ៦៩.២៣៨.៤៧៧ |
| ជំនួយបន្ថែមក្នុងឆ្នាំ | - | ៦.១៥៧.៨00 | - | ៧៧៦.៣៧៧ | ៦.៩៣៤.១៧៧ |
| រំលស់ក្នុងឆ្នាំ | - | (១.៨៥៣.00៦) | (១៣៤.០៦៩) | (២២.៨៣៣) | (២.00៩.៩0៨) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៥៤.៤៣៦.១៩៩ | ១៤.៤៩៦.៣២១ | ៣.៨៣៨.៤៣៣ | ១.៣៩១.៧៩៣ | ៧៤.១៦២.៧៤៦ |

<u>ជំនួយសហភាពអឺរ៉ុប</u>

ជំនួយបន្ថែមតំណាងឱ្យការផ្តល់ជំនួយ សម្រាប់ការទិញសម្ភារសម្រាប់គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង C ក្នុងចំនួនទឹកប្រាក់ ១២.៧00.000អឺរ៉ូ ក្នុងទម្រង់ជាជំនួយវិនិយោគដែលធ្វើឡើងតាមរយៈថវិកាទូទៅរបស់សហភាពអឺរ៉ុប។

## ១៥. ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗ (ត)

<u>ជំនួយរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន</u>

ជំនួយរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ជាជំនួយលើគម្រោងអនុវត្តថាមពលស្អាត ដោយប្រព័ន្ធប្រតិបត្តិការអគ្គិសនីទៅតាមប្រព័ន្ធសូឡា។

ជំនួយបន្ថែម គឺជាទឹកប្រាក់ទទួលបានពីកញ្ចប់ថវិកាទូទៅរបស់រាជរដ្ឋាភិបាលជប៉ុនដែលមានចំនួន១.៥៩៥.៦២៤ ដុល្លារអាមេរិក ឬស្មើនឹង ៦.១៥៧.៨០០.០០០រៀល។ គោលបំណងនៃជំនួយ គឺដើម្បីជួយលើគម្រោងសាងសង់រោងចក្រផលិតកម្មទឹកស្អាតបឹងធំ ដើម្បីបង្កើនសេវាផ្គត់ផ្គង់ទឹកដល់ភាគនិរតីនៃទីក្រុងភ្នំពេញ។

<u>ជំនួយរដ្ឋាភិបាល</u>

ជំនួយរដ្ឋាភិបាលជាផលចំណេញកើតចេញពីភាពលម្អៀងនៃអត្រាថេរ ដែលបានប្រើដើម្បីប្តូរប្រាក់ (រៀល/អេស ដេ អា) ក្រោមកិច្ចព្រមព្រៀងឥណទានបន្តរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រ.ទ.ស.ភ ដែលបានចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៧ ដែលមានទឹកប្រាក់សរុបចំនួន ៩.៦៩៥.០០០អេស ដេ អា ពីធនាគារអភិវឌ្ឍន៍អាស៊ី។ រ.ទ.ស.ភ បានសម្រេចរក្សាទុកចំណេញពីការប្តូរប្រាក់នេះថាជាជំនួយក្នុងបញ្ជីរបស់ខ្លួន (ដោយសារមិនមានតម្រូវការឱ្យបង្វិលប្រាក់ចំណេញនេះទៅវិញទេ) ហើយប្រាក់ចំណេញនេះនឹងត្រូវរំលស់ដោយផ្អែកលើគោលការណ៍ដូចគ្នានឹងជំនួយពន្យាផ្សេងៗទៀត។

<u>ជំនួយផ្សេងៗ</u>

ជំនួយផ្សេងៗ ជាការឧបត្ថម្ភទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារពីទីស្នាក់ការសហប្រត្តិការអន្តរជាតិរបស់ Association International des Maires Francophones និងគូបូតា ខនស្ត្រាក់សិន។

ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗត្រូវបានរំលស់ដោយមូលដ្ឋានរំលស់ថេរ និងត្រូវបានកត់ត្រាចូលជាចំណូលផ្សេងៗនៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

## ១៦. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ

| | **២០២៣**<br>**គិតជាពាន់រៀល** | **២០២២**<br>**គិតជាពាន់រៀល** |
|---|---|---|
| **រយៈពេលវែង៖** | | |
| **គណនីត្រូវទូទាត់ផ្សេងៗ** | | |
| ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ | ៨២.៩០៣.៧៣២ | ៧៦.៨០១.៧០៥ |
| **រយៈពេលខ្លី៖** | | |
| **គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម** | | |
| ភាគីទីបី | ៦៦.១៥៩.០២២ | ៤៨.០៧៨.៧១០ |
| ទឹកប្រាក់គ្រោងសម្រាប់ការងារកំពុងសាងសង់ | ១៨.៦៣២.២៥៤ | ២៣.២០៨.០៧៥ |
| | ៨៤.៧៩១.២៧៦ | ៧១.២៨៦.៧៨៥ |

## ១៦. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ (ត)

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| **គណនីត្រូវទូទាត់ផ្សេងៗ** | | |
| ទឹកប្រាក់ជំពាក់សាលារាជធានីភ្នំពេញ | ៦៥.៩៩២.៣៣០ | ៥៧.៨៣០.៥៩៤ |
| ប្រាក់លើកទឹកចិត្តនិយោជិកបង្គរ | ១១.៥០៥.១៩១ | ៩.៩៩៣.២២៦ |
| អតីតភាពការងារ | ៤.៥១០.២៨៦ | ៦.០៧១.៤៣៧ |
| ប្រាក់ធានាប្រតិបត្តិការ | ៦៧.៣៥៦ | ៦៧.៣៩០ |
| ពន្ធត្រូវទូទាត់ផ្សេងៗ | ៩៧២.៨៤៨ | ៣៨៥.៩០៣ |
| គណនីត្រូវទូទាត់ផ្សេងៗ | ១២.៦០៥.៣៣៤ | ៩.០២៥.៨១៧ |
| | ៩៥.១៥៣.៣៤៥ | ៨៣.៣៧៤.៣៦៧ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ (រយៈពេលខ្លី) | ១៧៩.៩៤៤.៦២១ | ១៥៤.៦៦១.១៥២ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ | ២៦២.៨៤៨.៣៥៣ | ២៣១.៤៦២.៨៥៧ |

ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ ត្រូវបានប្រមូលពីអតិថិជនដោយផ្អែកតាមទំហំនាឡិកាទឹកមុនពេលភ្ជាប់បណ្តាញ និងត្រូវបានកត់ត្រាជាប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញក្នុងបំណុលរយៈពេលវែង។

គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជមិនមានការប្រាក់ ហើយលក្ខខណ្ឌឥណទានធម្មតាដែលផ្តល់ជូន រ.ទ.ស.ភ ចន្លោះពី ១ខែ ទៅ ៣ខែ។

## ១៧. ចំណូលពីការផ្គត់ផ្គង់ទឹក

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| ការលក់ទឹកស្អាត៖ | | |
| - អ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម | ១៦៩.៧៤៣.៩៣៩ | ១៥១.៨៧០.១៥៣ |
| - អ្នកប្រើប្រាស់តាមផ្ទះ | ១២៩.០៣៨.២០៤ | ១១០.៨៧៣.៥១៩ |
| - ស្ថាប័នរដ្ឋបាលសាធារណៈ | ២៣.៧៨៥.៩៥៧ | ១៩.៦៧១.០៣៦ |
| - អ្នកចែកចាយទឹកលក់បន្ត | ១១.៩៤០.០៦០ | ១០.៣១៧.៣៨៩ |
| បង្គត់ភាពខុសគ្នាលើប្រាក់ចំណូលពីការលក់ទឹកស្អាត | ៨២.១១៩ | ៧០.៤៤២ |
| ដក៖ ការលុបចោលវិក្កយបត្រ | (៨៣៣.៣៩៩) | (៦.៥១៣.៣២១) |
| | ៣៣៣.៧៥៦.៨៨០ | ២៨៦.២៨៩.២១៨ |

## ១៧. ចំណូលពីការផ្គត់ផ្គង់ទឹក (ត)

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| ចំណូលបានពីការភ្ជាប់បណ្តាញទឹកស្អាតតាមផ្ទះ | ១១.៣១៤.៥២៦ | ៨.៨១៩.៤៨៣ |
| ចំណូលការផ្លាស់ប្តូរនាឡិកាទឹក | ៤.៣៤៣.២៧៥ | ៤.២២២.៧៥៤ |
| ការលក់គ្រឿងបន្លាស់ និងនាឡិកាទឹក | ២២៥.៣៩២ | ៣៩២.០៥២ |
| | ១៥.៨៨៣.១៩៣ | ១៣.៤៣៤.២៨៩ |
| | ៣៤៩.៦៤០.០៧៣ | ២៩៩.៧២៣.៥០៧ |

## ១៨. ចំណាយលើអត្ថប្រយោជន៍និយោជិក

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| ប្រាក់បៀវត្សនិយោជិក | ៤០.៨៣៥.៣៥៧ | ៣៥.១៣០.៨៦៣ |
| ប្រាក់លើកទឹកចិត្ត | ១១.៩៤១.៧៥៥ | ១១.៤៥២.៥២៩ |
| ប្រាក់លាភការ | ១០.៧១៦.០១៧ | ៩.៥១០.៥៥២ |
| ប្រាក់ទាយជ្ជទាន | ៦.៩១៧.៨៤៩ | ៦.៤៦៦.០៥៧ |
| អតីតភាពការងារ | ១.១១៧.៨៨៩ | ១.១៥៣.៨៦២ |
| ប្រាក់ឈ្នួលអ្នកម៉ៅការ | ១.៤៦៥.៦២១ | ៨៨៦.៥៦៣ |
| ចំណាយផ្សេងៗទាក់ទងនឹងនិយោជិក | ៧.២៩៧.៩៥០ | ៥.៥៧៤.៩៨៦ |
| | ៨០.២៩២.៤៣៨ | ៧០.១៧៥.៤២២ |

## ១៩. ចំណាយហិរញ្ញប្បទាន

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| ចំណាយហិរញ្ញប្បទានលើប្រាក់កម្ចី | ១៥.១៧៨.៥៦០ | ៩.១១៥.៥៣០ |
| ការប្រាក់ដែលបានធ្វើមូលធនីយកម្មលើ | | |
| ទ្រព្យសកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | (១១.៦៥០.៨៣០) | (៥.៥០៥.០៩៦) |
| | ៣.៥២៧.៧៣០ | ៣.៦១០.៤៣៤ |

## ២០. ពន្ធលើប្រាក់ចំណូល

### (ក) ចំណាយពន្ធលើប្រាក់ចំណូល

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| ពន្ធក្នុងឆ្នាំ | ២១.៩៣២.៨១៩ | ១៧.៦២០.៦១០ |
| ពន្ធពន្យា | ៤.៩៣០.១៤២ | ៤.៧០៩.៤១៧ |
| | ២៦.៨៦២.៩៦១ | ២២.៣៣០.០២៧ |

ការផ្ទៀងផ្ទាត់ការគណនាពន្ធលើប្រាក់ចំណូលតាមអត្រាពន្ធ ជាមួយនឹងចំណាយពន្ធលើប្រាក់ចំណូលមានដូចខាងក្រោម៖

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| ចំណេញមុនបង់ពន្ធ | ១៥៣.៤៧២.៥៤៣ | ១៣០.៥១៥.៨៩២ |
| គណនាតាមអត្រាពន្ធ ២០% | ៣០.៦៩៤.៥០៩ | ២៦.១០៣.១៧៨ |
| និយ័តកម្មពន្ធ៖ | | |
| - ធាតុមិនអាចកាត់កងបាន | ១.០៩៨.៥៩៤ | ៩៣៦.២៦៦ |
| - ភាពខុសគ្នាបណ្តោះអាសន្ន | (៤.៩៣០.១៤២) | (៤.៧០៩.៤១៧) |
| | ២៦.៨៦២.៩៦១ | ២២.៣៣០.០២៧ |

### (ខ) បំណុលពន្ធពន្យា - សុទ្ធ

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| ទ្រព្យសកម្មពន្ធពន្យា | ៥.០២៣.៦៦៩ | ៣.៤៤៩.៨០២ |
| បំណុលពន្ធពន្យា | (៨៦.៩៧០.៥២៧) | (៨០.៤៦៦.៥១៨) |
| | (៨១.៩៤៦.៨៥៨) | (៧៧.០១៦.៧១៦) |

## ២០. ពន្ធលើប្រាក់ចំណូល (ត)

បម្រែបម្រួលនៃបំណុលពន្ធពន្យាសុទ្ធក្នុងឆ្នាំមានដូចខាងក្រោម៖

| | ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ និងទ្រព្យសកម្មអរូបី គិតជាពាន់រៀល | ការប្តូររូបិយប័ណ្ណ មិនមែនជាសាច់ប្រាក់ គិតជាពាន់រៀល | អត្ថប្រយោជន៍ និយោជិក គិតជាពាន់រៀល | ផ្សេងៗ គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | (៧៤.២១៥.៤៥២) | (១.៦១៨.៤៨៩) | ២.៩៥៣.១៣៩ | ៥៧៣.៥០៣ | (៧២.៣០៧.២៩៩) |
| កត់ត្រាជា (បន្ទុក)/ ឥណទានក្នុងចំណេញ ឬខាត | (៦.២៥១.០៦៦) | ១.៩២៥.៤១៥ | ១២៦.៣៧១ | (៥១០.១៣៧) | (៤.៧០៩.៤១៧) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | (៨០.៤៦៦.៥១៨) | ៣០៦.៩២៦ | ៣.០៧៩.៥១០ | ៦៣.៣៦៦ | (៧៧.០១៦.៧១៦) |
| កត់ត្រាជា (បន្ទុក)/ ឥណទានក្នុងចំណេញ ឬខាត | (៦.៥០៤.០០៩) | ១.៥៨២.០៤៥ | (៨.១៧៨) | - | (៤.៩៣០.១៤២) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | (៨៦.៩៧០.៥២៧) | ១.៨៨៨.៩៧១ | ៣.០៧១.៣៣២ | ៦៣.៣៦៦ | (៨១.៩៤៦.៨៥៨) |

## ២១. ព័ត៌មានអំពីលំហូរសាច់ប្រាក់

ការផ្ទៀងផ្ទាត់បំណុលដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទាន៖

| | ប្រាក់កម្ចី<br>គិតជាពាន់រៀល | ភាគលាភ<br>ដែលត្រូវទូទាត់<br>គិតជាពាន់រៀល | ជំនួយរដ្ឋាភិបាល និង<br>ជំនួយផ្សេងៗ<br>គិតជាពាន់រៀល | ដើមទុន និង<br>បុព្វលាភភាគហ៊ុន<br>គិតជាពាន់រៀល | សរុប<br>គិតជាពាន់រៀល |
|---|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ៨១៣.៤៨៨.២៦៨ | - | ១៦.៨១២.១៨៦ | ៦១៩.៣១៥.៨៨៦ | ១.៤៤៩.៦១៦.៣៤០ |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការបន្ថែមដើមទុនពីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - | - | - | ១.៤៤៣.២២១ | ១.៤៤៣.២២១ |
| ភាគលាភបានទូទាត់ | - | (៤.០៤៤.២៥២) | - | - | (៤.០៤៤.២៥២) |
| សាច់ប្រាក់ទទួលបានពីជំនួយ រដ្ឋាភិបាល និងជំនួយផ្សេងៗ | - | - | ៥៤.៤៣៦.១៩៩ | - | ៥៤.៤៣៦.១៩៩ |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ២១៨.២៨០.៤៣៩ | - | - | - | ២១៨.២៨០.៤៣៩ |
| ការប្រាក់បានទូទាត់ | (៧.៤៩១.៨០៤) | - | - | - | (៧.៤៩១.៨០៤) |
| ការទូទាត់សងប្រាក់កម្ចី | (២០.៧៦៩.៣៨៦) | - | - | - | (២០.៧៦៩.៣៨៦) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាព ហិរញ្ញប្បទាន** | ១៩០.០១៩.២៤៩ | (៤.០៤៤.២៥២) | ៥៤.៤៣៦.១៩៩ | ១.៤៤៣.២២១ | ២៤១.៨៥៤.៤១៧ |

## ២១. ព័ត៌មានអំពីលំហូរសាច់ប្រាក់ (ត)

| | ប្រាក់កម្ចី<br>គិតជាពាន់រៀល | ភាគលាភ<br>ដែលត្រូវទូទាត់<br>គិតជាពាន់រៀល | ជំនួយរដ្ឋាភិបាល និង<br>ជំនួយផ្សេងៗ<br>គិតជាពាន់រៀល | ដើមទុន និង<br>បុព្វលាភភាគហ៊ុន<br>គិតជាពាន់រៀល | សរុប<br>គិតជាពាន់រៀល |
|---|---|---|---|---|---|
| **បំណុលដែលពាក់ព័ន្ធនឹងបម្រែបម្រួលផ្សេងៗ** | | | | | |
| ភាគលាភ | - | ៤.០៤៤.២៥២ | - | - | ៤.០៤៤.២៥២ |
| រំលស់លើជំនួយរដ្ឋាភិបាល និងជំនួយផ្សេងៗ | - | - | (២.០០៩.៩០៨) | - | (២.០០៩.៩០៨) |
| ការប្រាក់បង្គរលើប្រាក់កម្ចី | ៩.១១៥.៥៣០ | - | - | - | ៩.១១៥.៥៣០ |
| ចំណេញពីការប្តូររូបិយប័ណ្ណលើប្រាក់កម្ចីសុទ្ធ | (២.៦២៨.១៧២) | - | - | - | (២.៦២៨.១៧២) |
| **បំណុលដែលពាក់ព័ន្ធនឹងបម្រែបម្រួលផ្សេងៗសរុប** | ៦.៤៨៧.៣៥៨ | ៤.០៤៤.២៥២ | (២.០០៩.៩០៨) | - | ៨.៥២១.៧០២ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២/ នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ១.០០៩.៩៩៤.៨៧៥ | - | ៦៩.២៣៨.៤៧៧ | ៦២០.៧៥៩.១០៧ | ១.៦៩៩.៩៩២.៤៥៩ |

## ២១. ព័ត៌មានអំពីលំហូរសាច់ប្រាក់ (ត)

| | ប្រាក់កម្ចី<br>គិតជាពាន់រៀល | ភាគលាភ<br>ដែលត្រូវទូទាត់<br>គិតជាពាន់រៀល | ជំនួយរដ្ឋាភិបាល និង<br>ជំនួយផ្សេងៗ<br>គិតជាពាន់រៀល | ដើមទុន និង<br>បុព្វលាភភាគហ៊ុន<br>គិតជាពាន់រៀល | សរុប<br>គិតជាពាន់រៀល |
|---|---|---|---|---|---|
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ភាគលាភបានទូទាត់ | - | (៤.៣០៥.១៥៨) | - | - | (៤.៣០៥.១៥៨) |
| សាច់ប្រាក់ទទួលបានជំនួយ រដ្ឋាភិបាល និងជំនួយផ្សេងៗ | - | - | ៦.៩៣៤.១៧៧ | - | ៦.៩៣៤.១៧៧ |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ៣៤១.៩៨៧.៥៣៧ | - | - | - | ៣៤១.៩៨៧.៥៣៧ |
| ការប្រាក់បានទូទាត់ | (១៥.១១១.៤៧៥) | - | - | - | (១៥.១១១.៤៧៥) |
| ការទូទាត់សងប្រាក់កម្ចី | (២១.៤៧៩.៤៥៤) | - | - | - | (២១.៤៧៩.៤៥៤) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាព ហិរញ្ញប្បទាន** | ៣០៥.៣៩៦.៦០៨ | (៤.៣០៥.១៥៨) | ៦.៩៣៤.១៧៧ | - | ៣០៨.០២៥.៦២៧ |

## ២១. ព័ត៌មានអំពីលំហូរសាច់ប្រាក់ (ត)

| | ប្រាក់កម្ចី<br>គិតជាពាន់រៀល | ភាគលាភ<br>ដែលត្រូវទូទាត់<br>គិតជាពាន់រៀល | ជំនួយរដ្ឋាភិបាល និង<br>ជំនួយផ្សេងៗ<br>គិតជាពាន់រៀល | ដើមទុន និង<br>បុព្វលាភភាគហ៊ុន<br>គិតជាពាន់រៀល | សរុប<br>គិតជាពាន់រៀល |
|---|---|---|---|---|---|
| **បំណុលដែលពាក់ព័ន្ធនឹងការប្រែប្រួលផ្សេងៗ** | | | | | |
| ភាគលាភ | - | ៤.៣០៥.១៥៨ | - | - | ៤.៣០៥.១៥៨ |
| រំលស់លើជំនួយរដ្ឋាភិបាល និងជំនួយផ្សេងៗ | - | - | (២.០០៩.៩០៨) | - | (២.០០៩.៩០៨) |
| ការប្រាក់បង្គរលើប្រាក់កម្ចី | ១៥.១៧៨.៥៦០ | - | - | - | ១៥.១៧៨.៥៦០ |
| ចំណេញពីការប្តូររូបិយប័ណ្ណលើប្រាក់កម្ចីសុទ្ធ | (៩.៩៦៧.៩៥៨) | - | - | - | (៩.៩៦៧.៩៥៨) |
| **បំណុលដែលពាក់ព័ន្ធនឹងបម្រែបម្រួលផ្សេងៗសរុប** | ៥.២១០.៦០២ | ៤.៣០៥.១៥៨ | (២.០០៩.៩០៨) | - | ៧.៥០៥.៨៥២ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **១.៣២០.៦០២.០៨៥** | **-** | **៧៤.១៦២.៧៤៦** | **៦២០.៧៥៩.១០៧** | **២.០១៥.៥២៣.៩៣៨** |

## ២២. ចំណេញក្នុងមួយភាគហ៊ុន

### ចំណេញគោលក្នុងមួយភាគហ៊ុនធម្មតា

ការគណនាលម្អិតនៃចំណេញគោលក្នុងមួយភាគហ៊ុនធម្មតា ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ៣.៩ នៃរបាយការណ៍ហិរញ្ញវត្ថុ។ ចំណេញក្នុងមួយភាគហ៊ុនធម្មតាសម្រាប់ការិយបរិច្ឆេទត្រូវបានគណនាដូចខាងក្រោម៖

| | ២០២៣ | ២០២២ |
|---|---|---|
| ចំណេញបែងចែកទៅភាគហ៊ុនិក រ.ទ.ស.ភ (គិតជាពាន់រៀល) | ១២៦.៦០៩.៥៨២ | ១០៨.១៨៥.៨៦៥ |
| ចំនួនភាគហ៊ុនគិតជាមធ្យម | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ |
| ចំណេញក្នុងមួយហ៊ុនគោល (គិតជារៀល) (តម្លៃពេញ) | ១,៤៥៥.៧៣ | ១,២៤៣.៩០ |
| ចំណេញក្នុងមួយហ៊ុនថយចុះ (គិតជារៀល) (តម្លៃពេញ) | ១,៤៥៥.៧៣ | ១,២៤៣.៩០ |

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងឆ្នាំ២០២២ ពុំមានចំណេញថយចុះក្នុងមួយភាគហ៊ុនទេ។ ដូច្នេះហើយ ចំណេញថយចុះក្នុងមួយភាគហ៊ុនស្មើនឹងចំណេញគោលក្នុងមួយភាគហ៊ុន។

## ២៣. ភាគលាភ

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| **ទទួលស្គាល់ក្នុងឆ្នាំ** | | |
| ភាគលាភតម្លៃ៣៣០រៀល ក្នុងមួយភាគហ៊ុនធម្មតាត្រូវបានប្រកាស និងទូទាត់ក្នុងឆ្នាំ | ៤.៣០៥.១៥៨ | - |
| ភាគលាភតម្លៃ៣១០រៀល ក្នុងមួយភាគហ៊ុនធម្មតាត្រូវបានប្រកាស និងទូទាត់ក្នុងឆ្នាំ | - | ៤.០៤៤.២៥២ |

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាលបានប្រកាស និងអនុម័តលើភាគលាភក្នុងតម្លៃ ៣៣០រៀល ក្នុងមួយភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ។ ភាគលាភត្រូវបានទូទាត់នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣។

យោងតាមលិខិតអនុម័តពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ រ.ទ.ស.ភ ត្រូវបានលើកលែងលើការទូទាត់ភាគលាភជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រហូតដល់ចុងឆ្នាំ ២០២៤។ ក.ស.ហ.វ នឹងត្រូវបន្តទទួលបានភាគលាភវិញគិតចាប់ពីការិយបរិច្ឆេទចាប់ផ្តើមថ្ងៃទី១ ខែមករា ឆ្នាំ២០២៥។

ហេតុដូច្នេះ ភាគលាភបានទទួលស្គាល់ក្នុងឆ្នាំ គឺសម្រាប់តែភាគហ៊ុនិកដទៃទៀតរបស់ រ.ទ.ស.ភ។

## ២៤. ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

រ.ទ.ស.ភ មានប្រតិបត្តិការសំខាន់ៗជាមួយភាគីពាក់ព័ន្ធដូចខាងក្រោមៈ

(ក) ស្ថាប័នពាក់ព័ន្ធរាជរដ្ឋាភិបាល

សាជីវកម្មដែលភ្ជាប់ទៅនឹងរាជរដ្ឋាភិបាល ត្រូវបានពាក់ព័ន្ធជាមួយ រ.ទ.ស.ភ ដែលតកាន់កាប់ភាគហ៊ុនដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្ថាប័នដែលគ្រប់គ្រងដោយផ្ទាល់ដោយរាជរដ្ឋាភិបាល ត្រូវបានសំដៅទាំងស្រុងជាស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធជាមួយ រ.ទ.ស.ភ។

រាជរដ្ឋាភិបាល និងស្ថាប័នដែលគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺជាភាគីពាក់ព័ន្ធជាមួយនឹង រ.ទ.ស.ភ។ រ.ទ.ស.ភ បានធ្វើប្រតិបត្តិការជាមួយស្ថាប័នជាច្រើន ដែលមានត្រឹមការទិញទំនិញ រួមទាំងមានការប្រើប្រាស់ទឹកជាសាធារណៈ និងការដាក់ប្រាក់បញ្ញើ។

រាល់ប្រតិបត្តិការទាំងអស់ដែលបានកត់ត្រាដោយ រ.ទ.ស.ភ ជាមួយស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ គឺត្រូវបានធ្វើឡើងក្នុងសកម្មភាពអាជីវកម្មធម្មតារបស់ រ.ទ.ស.ភ ស្តីពីលក្ខខណ្ឌចរចា ឬលក្ខខណ្ឌប្រហាក់ប្រហែលនឹងស្ថាប័នផ្សេងទៀត ដែលមិនមែនជាស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ លើកលែងតែមានការបង្ហាញនៅកន្លែងផ្សេងទៀតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

រ.ទ.ស.ភ បានពាក់ព័ន្ធយ៉ាងសំខាន់នៅក្នុងដំណើរការ និងការចែកចាយទឹកដែលជាផ្នែកមួយនៃប្រតិបត្តិការធម្មតារបស់ខ្លួន។ សេវាកម្មទាំងនេះត្រូវបានអនុវត្តជាប្រចាំ លើលក្ខខណ្ឌពាណិជ្ជកម្មដែលត្រូវបានអនុវត្តជាមួយអតិថិជនទាំងអស់។ ប្រតិបត្តិការទាំងនេះត្រូវបានបង្កើតឡើងដោយផ្អែកលើលក្ខខណ្ឌដែលមិនខុសគ្នាជាសារវន្តពីប្រតិបត្តិការជាមួយភាគីដែលមិនពាក់ព័ន្ធគ្នា។

ក្រៅពីប្រតិបត្តិការ និងសមតុល្យឯកបុគ្គលសំខាន់ៗ ដូចបានបង្ហាញនៅកន្លែងផ្សេងទៀតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ រ.ទ.ស.ភ មានប្រតិបត្តិការសំខាន់ៗជាសមូហភាព ប៉ុន្តែមិនមានប្រតិបត្តិការ ឯកបុគ្គលឡើយ។

(ខ) លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗ

លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗសរុបត្រូវបានបង្ហាញដូចខាងក្រោមៈ

| | **២០២៣**<br>**គិតជាពាន់រៀល** | **២០២២**<br>**គិតជាពាន់រៀល** |
|---|---|---|
| ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗ | ២.៣៩៨.២៩៩ | ២.៣៨០.៥៧២ |

## ២៥. ឧបករណ៍ហិរញ្ញវត្ថុ

**ការចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុ**

តារាងខាងក្រោមជាការវិភាគឧបករណ៍ហិរញ្ញវត្ថុ ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតាមថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុដែលបានបែងចែកៈ

| | រំលស់ថ្លៃដើម<br>គិតជាពាន់រៀល | តម្លៃយោង<br>គិតជាពាន់រៀល |
|---|---|---|
| **២០២៣** | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | |
| ការវិនិយោគរយៈពេលខ្លី | ១២៧.៣១៦.០០៣ | ១២៧.៣១៦.០០៣ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ មិនរួមបញ្ចូលបុរេប្រទានទៅអ្នកផ្គត់ផ្គង់ | ២៧.៣៣៩.៩៥៩ | ២៧.៣៣៩.៩៥៩ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៦.១១៧.២២២ | ១៦.១១៧.២២២ |
| ប្រាក់កម្ចីនិយោជិក | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |
| | ១៧៨.៧២៩.៨៣៥ | ១៧៨.៧២៩.៨៣៥ |
| **បំណុលហិរញ្ញវត្ថុ** | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ២៦១.៨៧៥.៥០៥ | ២៦១.៨៧៥.៥០៥ |
| ប្រាក់កម្ចី | ១.៣២០.៦០២.០៨៥ | ១.៣២០.៦០២.០៨៥ |
| | ១.៥៨២.៤៧៧.៥៩០ | ១.៥៨២.៤៧៧.៥៩០ |
| **២០២២** | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | |
| ការវិនិយោគរយៈពេលខ្លី | ១២៦.១១៨.៤១៦ | ១២៦.១១៨.៤១៦ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ មិនរួមបញ្ចូលបុរេប្រទានទៅអ្នកផ្គត់ផ្គង់ និងអាករលើតម្លៃបន្ថែមត្រូវទទួល | ៣១.៩២៤.៤៩៧ | ៣១.៩២៤.៤៩៧ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៥៦.៧១៦.៤៣៩ | ៥៦.៧១៦.៤៣៩ |
| ប្រាក់កម្ចីនិយោជិក | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |
| | ២២២.៧១៦.០០៣ | ២២២.៧១៦.០០៣ |
| **បំណុលហិរញ្ញវត្ថុ** | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ មិនរួមបញ្ចូលប្រាក់ពន្ធត្រូវទូទាត់ផ្សេងៗ | ២៣១.០៧៦.៩៥៤ | ២៣១.០៧៦.៩៥៤ |
| ប្រាក់កម្ចី | ១.០០៩.៩៩៤.៨៧៥ | ១.០០៩.៩៩៤.៨៧៥ |
| | ១.២៤១.០៧១.៨២៩ | ១.២៤១.០៧១.៨២៩ |

## ២៥. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

សកម្មភាពអាជីវកម្មរបស់ រ.ទ.ស.ភ ប្រឈមនឹងហានិភ័យហិរញ្ញវត្ថុជាច្រើនដែលកើតឡើងពីប្រតិបត្តិការ និងការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ។ ហានិភ័យហិរញ្ញវត្ថុសំខាន់ៗរួមមាន ហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យអត្រាការប្រាក់។ ក្រុមប្រឹក្សាភិបាលធ្វើការត្រួតពិនិត្យឡើងវិញ និងយល់ព្រមលើគោលការណ៍សម្រាប់ការគ្រប់គ្រងហានិភ័យទាំងនោះ ដូចដែលបានសង្ខេបខាងក្រោម៖

### (ក) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ហិរញ្ញវត្ថុដល់ រ.ទ.ស.ភ ដែលអាចកើតឡើងលើឧបករណ៍ហិរញ្ញវត្ថុ ប្រសិនបើគូភាគីអាចនឹងមិនអាចបំពេញកាតព្វកិច្ចទូទាត់សង។ រ.ទ.ស.ភ ប្រឈមមុខនឹងហានិភ័យឥណទានកើតឡើងពីសកម្មភាពប្រតិបត្តិការ (គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ ដែលរួមមានរតនាគារជាតិ ប្រាក់រក្សាទុកពីអតិថិជនសាង់សង់ ប្រាក់ធានាសម្រាប់ប្រតិបត្តិការ ការប្រាក់ត្រូវទទួល និងបុរេប្រទានទៅអ្នកផ្គត់ផ្គង់) និងកើតឡើងពីសកម្មភាពហិរញ្ញប្បទាន រួមមានសាច់ប្រាក់ និងសាច់ប្រាក់ សមមូល និងការវិនិយោគរយៈពេលខ្លី។ រ.ទ.ស.ភ មានគោលការណ៍ឥណទាន ហើយការប្រឈមនឹងហានិភ័យឥណទានត្រូវបានគ្រប់គ្រងតាមរយៈការអនុម័តលើឥណទាន កម្រិតឥណទាន និងនីតិវិធីតាមដាន។

### គណនីអតិថិជនពាណិជ្ជកម្ម និងកិច្ចសន្យាទ្រព្យសកម្ម

ហានិភ័យឥណទានដែល រ.ទ.ស.ភ ងាយរងផលប៉ះពាល់គឺ តាមរយៈគណនីអតិថិជនពាណិជ្ជកម្ម និងកិច្ចសន្យាទ្រព្យសកម្មដែលត្រូវទទួលពីអតិថិជន។ អាយុកាលឥណទានសម្រាប់អ្នកប្រើប្រាស់តាមផ្ទះ និងអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម គឺ ១ខែ និង ១ឆ្នាំ សម្រាប់គ្រឹះស្ថានសាធារណៈ។ រ.ទ.ស.ភ បានធ្វើការគ្រប់គ្រងយ៉ាងដិតដល់លើគណនីពាណិជ្ជកម្ម ដើម្បីកាត់បន្ថយហានិភ័យ។ សមតុល្យដែលហួសកំណត់ ត្រូវបានពិនិត្យឡើងវិញយ៉ាងទៀតទាត់ដោយក្រុមប្រឹក្សាភិបាល។

<u>បណ្តុំនៃព័ត៌មានហានិភ័យឥណទាន</u>

រ.ទ.ស.ភ កំណត់បណ្តុំនៃព័ត៌មានហានិភ័យឥណទាននៃគណនីអតិថិជនពាណិជ្ជកម្ម ដោយផ្អែកតាមមូលដ្ឋានដែលកំពុងដំណើរការ។ បណ្តុំនៃព័ត៌មានហានិភ័យឥណទាននៃគណនីអតិថិជនពាណិជ្ជរបស់ រ.ទ.ស.ភ នៅចុងការិយបរិច្ឆេទ រាយការណ៍មានដូចខាងក្រោម៖

## ២៥. ឧបករណ៍ហិរញ្ញវត្ថុ (ត)

(ក) ហានិភ័យឥណទាន (ត)

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | គិតជាពាន់រៀល | % | គិតជាពាន់រៀល | % |
| គណនីត្រូវទទួលតាមគេហដ្ឋាន | ៦.៦៦២.៨១៩ | ៦១% | ១១.៦៧៣.២៨១ | ៨២% |
| គណនីត្រូវទទួលអាជីវកម្ម | ២.៤២៣.៨២៨ | ២២% | ១.១១៤.៣៧៤ | ៨% |
| គណនីត្រូវទទួលរដ្ឋបាលសាធារណៈ | ១.៦៧៣.៦៩៦ | ១៥% | ១.៣០០.៩៥៩ | ៩% |
| គណនីត្រូវទទួលតំណាងចែកចាយទឹក | ២២១.៥០៨ | ២% | ១០៣.៦៤៧ | ១% |
| | ១០.៩៨១.៨៥១ | | ១៤.១៩២.២៦១ | |

រ.ទ.ស.ភ មិនរំពឹងថាតម្លៃយោងដែលបានកត់ត្រានៅចុងគ្រារាយការណ៍នីមួយៗ មានភាពខុសគ្នាជាសារវន្តពីតម្លៃដែលនឹងត្រូវបានទទួលបាននោះទេ។

ដើម្បីគ្រប់គ្រងហានិភ័យលើគណនីអតិថិជនពាណិជ្ជកម្ម រ.ទ.ស.ភ តម្រូវឱ្យកក់ប្រាក់មុនពេលមានការតភ្ជាប់នាឡិកាទឹក។ ចំពោះអង្គភាពរដ្ឋមិនចាំបាច់មានប្រាក់កក់ទេ ដោយសារ រ.ទ.ស.ភ ជឿជាក់ថានឹងអាចប្រមូលបានពីស្ថាប័នទាំងនោះតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ប្រភពនៃហិរញ្ញវត្ថុសម្រាប់ស្ថាប័នទាំងនោះ) ហើយក៏ជាភាគហ៊ុនិក និងអ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ផងដែរ។

គោលការណ៍កាត់បន្ថយប្រាក់កក់ ត្រូវបានអនុវត្តលើអតិថិជន ដែលមិនទាន់បានសងបំណុលទៅតាមពេលកំណត់ និងលក្ខខណ្ឌឥណទាន។

### សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងការវិនិយោគរយៈពេលខ្លី

ដើម្បីកាត់បន្ថយហានិភ័យឥណទានលើសាច់ប្រាក់ និងសាច់ប្រាក់សមមូល និងការវិនិយោគរយៈពេលខ្លី (ប្រាក់បញ្ញើមានកាលកំណត់នៅគ្រឹះស្ថានហិរញ្ញវត្ថុ) រ.ទ.ស.ភ បានដាក់បញ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗដោយប្រើប្រាស់គ្រឹះស្ថានហិរញ្ញវត្ថុធំៗមួយចំនួនដែលគេទទួលស្គាល់ទូទៅក្នុងប្រទេសកម្ពុជា។

គិតត្រឹមចុងបញ្ចប់នៃការិយបរិច្ឆេទរាយការណ៍នេះ រ.ទ.ស.ភ មិនបានទទួលស្គាល់សំវិធានធនលើឱនភាពតម្លៃណាមួយឡើយសម្រាប់គណនីអតិថិជនពាណិជ្ជកម្ម ទ្រព្យសកម្មជាប់កិច្ចសន្យា សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងការវិនិយោគរយៈពេលខ្លី។

(ខ) ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យដែល រ.ទ.ស.ភ នឹងជួបផលលំបាកក្នុងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដល់កាលកំណត់។ រ.ទ.ស.ភ ប្រឈមមុខនឹងហានិភ័យសាច់ប្រាក់ងាយស្រួលចម្បងពីភាពមិនត្រូវគ្នានៃកាលវសានរវាងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ ការប្រឈមមុខនឹងហានិភ័យសាច់ប្រាក់ងាយស្រួលជាចម្បងកើតឡើងពីគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ (មិនរួមបញ្ចូលប្រាក់ពន្ធដែលត្រូវទូទាត់ផ្សេងៗ) និងប្រាក់កម្ចី។

## ២៥. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ខ) ហានិភ័យសាច់ប្រាក់ងាយស្រួល (ត)

កម្មវត្ថុរបស់ រ.ទ.ស.ភ គឺគ្រប់គ្រងតុល្យភាពរវាងការបន្តការផ្តល់ហិរញ្ញប្បទាន និងភាពបត់បែនតាមរយៈការសម្របសម្រួលប្រចាំការ។ រ.ទ.ស.ភ បានគ្រប់គ្រងសាច់ប្រាក់ងាយស្រួលគ្រប់គ្រាន់ និងមានស្រាប់នៃកញ្ចប់ថវិកាសម្រាប់បំពេញតម្រូវការប្រើប្រាស់ប្រចាំថ្ងៃ ស្របពេលដែលគ្រប់គ្រងការត្រួតពិនិត្យ និងសុវត្ថិភាពលើបម្រែបម្រួលសាច់ប្រាក់។ រ.ទ.ស.ភ ប្រើប្រាស់លំដាប់លំដោយនៃប្រតិបត្តិការដើម្បីទទួលបាននូវផលប្រយោជន៍ជាធំពីលំហូរថវិកា ដើម្បីឱ្យពួកគេគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ក្នុងការបង្កើនប្រាក់ចំណូលពីការវិនិយោគ និងកាត់បន្ថយថ្លៃដើមនៃការខ្ចីប្រាក់។ នាយកដ្ឋានរតនាគាររបស់ រ.ទ.ស.ភ ក៏ត្រូវធានាឱ្យបានថាមានមូលធនសម្របសម្រួលមិនទាន់ប្រើប្រាស់គ្រប់គ្រាន់ និងទ្រព្យដែលអាចប្តូរយកប្រាក់សម្រាប់តម្រូវការថវិការយៈពេលខ្លី និងរយៈពេលវែង។

## ២៥. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ខ) ហានិភ័យសាច់ប្រាក់ងាយស្រួល (ត)

ការវិភាគកាលវសាន្ត

ការវិភាគកាលវសាន្តនៃបំណុលហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ តាមកាលវសាន្តដែលពាក់ព័ន្ធនាកាលបរិច្ឆេទរាយការណ៍ គឺផ្អែកលើកាតព្វកិច្ចទូទាត់សងតាមកិច្ចសន្យាដែលបានធ្វើអប្បហារតម្លៃដូចខាងក្រោម៖

| | | លំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានធ្វើអប្បហារតម្លៃ | | | |
|---|---|---|---|---|---|
| | តម្លៃយោង<br>គិតជាពាន់រៀល | តាមតម្រូវការ ឬក្នុងពេល ១ឆ្នាំ<br>គិតជាពាន់រៀល | ចន្លោះពី ១ឆ្នាំ ទៅ ៥ឆ្នាំ<br>គិតជាពាន់រៀល | លើសពី ៥ឆ្នាំ<br>គិតជាពាន់រៀល | សរុប<br>គិតជាពាន់រៀល |
| **២០២៣** | | | | | |
| **បំណុលហិរញ្ញវត្ថុ** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ | ២៦១.៨៧៥.៥០៥ | ១៧៨.៩៧១.៧៧៣ | - | ៨២.៩០៣.៧៣២ | ២៦១.៨៧៥.៥០៥ |
| ប្រាក់កម្ចី | ១.៣២០.៦០២.០៨៥ | ២៣.៦៧៧.៤០១ | ៣៤៦.១៦៨.៥៦៧ | ៩៥០.៧៥៦.១១៧ | ១.៣២០.៦០២.០៨៥ |
| | ១.៥៨២.៤៧៧.៥៩០ | ២០២.៦៤៩.១៧៤ | ៣៤៦.១៦៨.៥៦៧ | ១.០៣៣.៦៥៩.៨៤៩ | ១.៥៨២.៤៧៧.៥៩០ |
| **២០២២** | | | | | |
| **បំណុលហិរញ្ញវត្ថុ** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ | ២៣១.០៧៦.៩៥៤ | ១៥៤.២៧៥.២៤៩ | - | ៧៦.៨០១.៧០៥ | ២៣១.០៧៦.៩៥៤ |
| ប្រាក់កម្ចី | ១.០០៩.៩៩៤.៨៧៥ | ២៣.៤៩៩.១៥៨ | ២០០.៧៦៥.១៧៤ | ៧៨៥.៧៣០.៥៤៣ | ១.០០៩.៩៩៤.៨៧៥ |
| | ១.២៤១.០៧១.៨២៩ | ១៧៧.៧៧៤.៤០៧ | ២០០.៧៦៥.១៧៤ | ៨៦២.៥៣២.២៤៨ | ១.២៤១.០៧១.៨២៩ |

## ២៥. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (គ) ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យរូបិយប័ណ្ណបរទេស គឺជាហានិភ័យនៃបម្រែបម្រួលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នាពេលអនាគត នៃឧបករណ៍ហិរញ្ញវត្ថុ ដែលជាលទ្ធផលនៃបម្រែបម្រួលអត្រាប្តូរប្រាក់បរទេស។ ការប្រឈមរបស់ រ.ទ.ស.ភ នឹងហានិភ័យនៃបម្រែបម្រួលអត្រាប្តូរប្រាក់បរទេសទាក់ទងជាចម្បងទៅនឹងសកម្មភាពប្រតិបត្តិការរបស់ រ.ទ.ស.ភ (នៅពេលដែលសាច់ប្រាក់ និងសាច់ប្រាក់សមមូល ការវិនិយោគរយៈពេលខ្លី ការទិញ និងប្រាក់កម្ចីដែលជារូបិយប័ណ្ណបរទេស)។

ការមិនទប់ស្កាត់ហានិភ័យនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលមិនមែនជារូបិយប័ណ្ណគោលមានដូចខាងក្រោម៖

| | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|
| **<u>សាច់ប្រាក់ និងសាច់ប្រាក់សមមូល</u>** | | |
| ដុល្លារអាមេរិក | ៤.១៦៨.៥៨០ | ៣៤.៨៩៤.៣៨៥ |
| **<u>ការវិនិយោគរយៈពេលខ្លី</u>** | | |
| ដុល្លារអាមេរិក | ៩០.៧៥៩.៣៦៩ | ៩១.១១៨.៤១៦ |
| **<u>គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ</u>** | | |
| ដុល្លារអាមេរិក | ៦១.៨២៨.២៣៥ | ៨១.៩៩៣.២៥០ |
| អឺរ៉ូ | ៣៩.៨០០.៨៤៨ | ២៣.៩៩១.៨៥៤ |
| | ១០១.៦២៩.០៨៣ | ១០៥.៩៨៥.១០៤ |
| **<u>ប្រាក់កម្ចី</u>** | | |
| ដុល្លារអាមេរិក | ១.២២៨.៣៥១.៥៨៥ | ៨៩៥.៣១៣.៥៣៣ |
| យេន | ៣៤.៣១១.៤៥៨ | ៣៧.៨៦៩.៨៣៩ |
| សិទ្ធិដកប្រាក់ពិសេស | ៣០.៥៥៨.៤៣៥ | ៣២.៨១០.០៩៥ |
| អឺរ៉ូ | ២៧.៣៨០.៦០៧ | ៤៤.០០១.៤០៨ |
| | ១.៣២០.៦០២.០៨៥ | ១.០០៩.៩៩៤.៨៧៥ |

## ២៥. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (គ) ហានិភ័យរូបិយប័ណ្ណបរទេស (ត)

ការវិភាគវេទយិតភាពលើហានិភ័យរូបិយប័ណ្ណបរទេស

តារាងខាងក្រោមបង្ហាញពីការវិភាគវេទយិតភាពដែលអាចកើតមានឡើងលើ រូបិយប័ណ្ណដុល្លារអាមេរិក រូបិយប័ណ្ណអឺរ៉ូ សិទ្ធិដកប្រាក់ពិសេស និងរូបិយប័ណ្ណយេន ស្របពេលដែលធាតុផ្សេងៗទៀតនៃមូលធន និងចំណេញក្នុងឆ្នាំសរុបរបស់ រ.ទ.ស.ភ នៅដដែល៖

| | បម្រែបម្រួលនៃអត្រា % | ២០២៣ គិតជាពាន់រៀល | ២០២២ គិតជាពាន់រៀល |
|---|---|---|---|
| ដុល្លារអាមេរិក/រៀល | + ៣% | (៣៥.៨៥៧.៥៥៦) | (២៥.៣៨៨.៥៧៩) |
| | - ៣% | ៣៥.៨៥៧.៥៥៦ | ២៥.៣៨៨.៥៧៩ |
| អឺរ៉ូ/រៀល | + ៣% | (២.០១៥.៤៤៤) | (២.០៣៩.៧២៧) |
| | - ៣% | ២.០១៥.៤៤៤ | ២.០៣៩.៧២៧ |
| អេស ដេ អា/រៀល | + ៣% | (៩១៦.៧៥៣) | (៩៨៤.៣០៣) |
| | - ៣% | ៩១៦.៧៥៣ | ៩៨៤.៣០៣ |
| យេន/រៀល | + ៣% | (១.០២៩.៣៤៤) | (១.១៣៦.១៦៦) |
| | - ៣% | ១.០២៩.៣៤៤ | ១.១៣៦.១៦៦ |

### (ឃ) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ អាចនឹងប្រែប្រួលដោយសារតែបម្រែបម្រួលរបស់អត្រាការប្រាក់ទីផ្សារ។

ស្របពេលដែលលទ្ធផលប្រតិបត្តិការអាចរងផលប៉ះពាល់ដោយសារបម្រែបម្រួលនៃអត្រាការប្រាក់ រ.ទ.ស.ភ ធ្វើការត្រួតពិនិត្យយ៉ាងជាប់លាប់ទៅលើផលប៉ះពាល់សុទ្ធនៃប្រតិបត្តិការ ដែលមានគោលបំណងតែមួយក្នុងការកាត់បន្ថយការប្រឈមនឹងហានិភ័យអត្រាការប្រាក់។ អភិបាលយល់ឃើញថាមិនមានផលប៉ះពាល់ជាសារវន្តណាមួយពីហានិភ័យអត្រាការប្រាក់នោះទេ។ ដូច្នេះហើយ គ្មានការវិភាគវេទយិតភាពត្រូវបានបានបង្ហាញទេ។

### (ង) តម្លៃសមស្រប

តម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ មិនមានភាពខុសគ្នាជាសារវន្តពីតម្លៃយោងទេ ដោយសារវាមានរយៈពេលខ្លី ឬក៏អត្រាការប្រាក់មានភាពប្រហាក់ប្រហែលនឹងអត្រាទីផ្សារបច្ចុប្បន្ន។

## ២៦. ចំណាយជាប់កិច្ចសន្យា

នៅចុងឆ្នាំបញ្ចប់នេះ រ.ទ.ស.ភ បានជាប់កិច្ចសន្យាក្នុងការចំណាយមូលធនទៅលើទ្រព្យសកម្មដូចខាងក្រោម៖

| | ២០២៣ | ២០២២ |
|---|---|---|
| | គិតជាពាន់រៀល | គិតជាពាន់រៀល |
| ការសាងសង់រោងចក្រផលិតទឹកស្អាត | ៣៦.៣៤៣.៨០០ | ១០១.៧៤០.០៦៨ |
| ការទិញបំពង់ដែកស្ទិត បរិក្ខារភ្ជាប់ និងបរិក្ខារផ្សេងៗ | ២៦.៩៥០.៥៤៧ | ២៣.១២០.៣៩៩ |
| សេវាផ្តល់ការប្រឹក្សាយោបល់ | ៩.៧៦២.៨៧៧ | ៩.៨៩១.៧២២ |
| | ៧៣.០៥៧.២២៤ | ១៣៤.៧៥២.១៨៩ |

## ២៧. ព័ត៌មានតាមផ្នែក

ព័ត៌មានតាមផ្នែកពុំត្រូវបានបង្ហាញទេ ដោយសារ រ.ទ.ស.ភ មានការពាក់ព័ន្ធជាចម្បងនៅក្នុងដំណើរការ និងការចែកចាយទឹក សម្រាប់ប្រើប្រាស់ជាទូទៅដល់សាធារណជននៅក្នុងរាជធានីភ្នំពេញ និងការផ្តល់សេវាកម្មពាក់ព័ន្ធផ្សេងៗដែលស្ថិតនៅក្នុងរង្វង់អាជីវកម្មតែមួយ និងមានសង្គតិភាពស្របនឹងការអនុវត្តបច្ចុប្បន្ននៃរបាយការណ៍ផ្ទៃក្នុងរបស់ខ្លួន។ រ.ទ.ស.ភ ធ្វើប្រតិបត្តិការតែក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## ២៨. ពន្ធយថាហេតុ

ប្រព័ន្ធពន្ធនៅក្នុងប្រទេសកម្ពុជា គឺត្រូវបានកំណត់លក្ខណៈដោយប្រភេទពន្ធជាច្រើន និងការផ្លាស់ប្តូរជានិច្ចកាលនៃបទបញ្ញត្តិ ដែលជាធម្មតាមានលក្ខណៈមិនសូវជាក់លាក់មានភាពផ្ទុយគ្នា និងប្រែប្រួលទៅតាមការបកស្រាយ។ ជានិច្ចកាល ការបកស្រាយផ្សេងៗគ្នាកើតមានក្នុងចំណោមអាជ្ញាធរពន្ធ និងយុត្តាធិការជាច្រើនខុសៗគ្នា។ ពន្ធត្រូវតែត្រួតពិនិត្យឡើងវិញ និងស៊ើបអង្កេតដោយអាជ្ញាធរជាច្រើនដែលអនុញ្ញាតដោយច្បាប់ក្នុងការប្រតិបត្តិការផាកពិន័យធ្ងន់ធ្ងរ ការពិន័យព្រហ្មទណ្ឌ និងការពិន័យលើការប្រាក់។

គណៈគ្រប់គ្រងជឿជាក់ថា បំណុលពន្ធរបស់ រ.ទ.ស.ភ ត្រូវបានប្រកាសយ៉ាងត្រឹមត្រូវ ដោយផ្អែកលើការបកស្រាយនៃបទបញ្ញាតិពន្ធ។ ទោះបីជាយ៉ាងណាក៏ដោយ អាជ្ញាធរដែលពាក់ព័ន្ធអាចនឹងមានការបកស្រាយផ្សេងពីនេះ ហើយផលប៉ះពាល់របស់វាអាចមានភាពជាសារវន្ត។

## ២៩. ការគ្រប់គ្រងដើមទុន

គោលការណ៍របស់ រ.ទ.ស.ភ គឺដើម្បីប្រាកដថាមានដើមទុនគ្រប់គ្រាន់នៅក្នុងការបន្តមុខងារតាមច្បាប់របស់ខ្លួន។ ដើម្បីសម្រេចបានតាមគោលនយោបាយនេះ រ.ទ.ស.ភ ត្រួតពិនិត្យភាពគ្រប់គ្រាន់នៃដើមទុនរបស់ខ្លួនយ៉ាងត្រឹមត្រូវ ដោយរួមបញ្ចូលទាំងតម្រូវការចំណាយមូលធន គោលការណ៍រដ្ឋាភិបាល តម្រូវការច្បាប់ និងលទ្ធភាពរបស់ខ្លួនក្នុងការជ្រៀតចូលទីផ្សារមូលធន។ រ.ទ.ស.ភ កំណត់និយមន័យដើមទុន ជាមូលធនសរុប។

ពុំមានបម្រែបម្រួលនៃវិធីសាស្ត្រក្នុងការគ្រប់គ្រងដើមទុនរបស់ រ.ទ.ស.ភ ក្នុងអំឡុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងឆ្នាំ២០២២ នោះទេ។

## ៣០. តួលេខប្រៀបធៀប

ចំនួនប្រៀបធៀបជាក់លាក់មួយចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងការបង្ហាញកំណត់សម្គាល់ត្រូវបានចាត់ថ្នាក់ឡើងវិញដើម្បីឱ្យស្របតាមការបង្ហាញក្នុងឆ្នាំបច្ចុប្បន្ន។ គណៈគ្រប់គ្រងជឿជាក់ថា ការចាត់ថ្នាក់ឡើងវិញទាំងនេះនឹងឆ្លុះបញ្ចាំងនូវលក្ខណៈត្រឹមត្រូវនៃប្រតិបត្តិការនេះកាន់តែប្រសើរជាងមុន។

សេចក្តីសង្ខេបនៃការផ្លាស់ប្តូរដែលកើតឡើងពីការចាត់ថ្នាក់ឡើងវិញនេះត្រូវបានបង្ហាញដូចខាងក្រោម៖

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**

| | គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ការបង្ហាញពីមុន) គិតជាពាន់រៀល | ផលប៉ះពាល់នៃការចាត់ថ្នាក់ឡើងវិញ គិតជាពាន់រៀល | គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (ការចាត់ថ្នាក់ឡើងវិញ) គិតជាពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ២៨.២៦៤.៩៤០ | ៤.៤៤២.៤៧៦ | ៣២.៧០៧.៤១៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៦១.១៥៨.៩១៥ | (៤.៤៤២.៤៧៦) | ៥៦.៧១៦.៤៣៩ |
| | ៨៩.៤២៣.៨៥៥ | - | ៨៩.៤២៣.៨៥៥ |

**របាយការណ៍លទ្ធផលលម្អិត**

| | គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ការបង្ហាញពីមុន) គិតជាពាន់រៀល | ផលប៉ះពាល់នៃការចាត់ថ្នាក់ឡើងវិញ គិតជាពាន់រៀល | គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (ការចាត់ថ្នាក់ឡើងវិញ) គិតជាពាន់រៀល |
|---|---|---|---|
| ចំណូលហិរញ្ញប្បទាន | ១៧.៧៣៧.៧៤៦ | (១៣.០៨១.១២៨) | ៤.៦៥៦.៦១៨ |
| ចំណាយហិរញ្ញប្បទាន | (១២.១០៤.៦៩៦) | ៨.៤៩៤.២៦២ | (៣.៦១០.៤៣៤) |
| ចំណេញលើការប្តូររូបិយប័ណ្ណបរទេស - សុទ្ធ | - | ១.១០៥.៧០០ | ១.១០៥.៧០០ |
| ខាតលើការប្តូររូបិយប័ណ្ណបរទេស - សុទ្ធ | (៣.៤៨១.១៦៦) | ៣.៤៨១.១៦៦ | - |
| | ២.១៥១.៨៨៤ | - | ២.១៥១.៨៨៤ |

## ៣១. ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីចុងបញ្ចប់នៃការិយបរិច្ឆេទ

នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ រ.ទ.ស.ភ បានទទួលលិខិតនៃកំណត់ពន្ធឡើងវិញពីអគ្គនាយកដ្ឋានពន្ធដារ (ហៅកាត់ថា "អ.ព.ដ") លើសវនកម្មពន្ធមានកម្រិតសម្រាប់ចន្លោះពេលគិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។ លិខិតនោះបានដាក់ពិន័យលើការទូទាត់ប្រាក់ពន្ធលើអាករតម្លៃបន្ថែមខ្វះសរុបចំនួន ៨.៧៤៣.៦២៩.១៤៨រៀល។ រ.ទ.ស.ភ បានដាក់លិខិតតវ៉ានៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤។ គិតមកដល់ការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ រ.ទ.ស.ភ ពុំទាន់ទទួលបានការឆ្លើយតបពី អ.ព.ដ នៅឡើយទេ។

គណៈគ្រប់គ្រងរបស់ រ.ទ.ស.ភ ជឿជាក់ថា ពួកគេអាចអាចមានប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាពនូវជំហររបស់ពួកគេទៅកាន់ អ.ព.ដ ដែលមានការគាំទ្រដោយភស្តុតាងដ៏រឹងមាំដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ។ ហេតុដូច្នេះ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ គ្មានសំវិធានធនត្រូវបានកត់ត្រាពាក់ព័ន្ធនឹងចំណាយបង្គរលើការពិន័យពន្ធនោះទេ ។

## ៣២. ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ សម្រាប់ឆ្នាំបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ត្រូវបានអនុញ្ញាតឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤។

bakertilly

Baker Tilly (Cambodia) Co., Ltd.
Certified Public Accountants
No. 87, Street 294,
Sangkat Boeung Keng Kang 1,
120102, Khan Boeung Keng Kang,
Phnom Penh, Cambodia.

T: +855 23 987 100/
+855 23 987 388

info@bakertilly.com.kh
www.bakertilly.com.kh

លេខយោង៖ GA/0012/0324/P014-0004/KMT

# របាយការណ៍របស់សវនករឯករាជ្យ
# ជូនចំពោះភាគហ៊ុនិកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## របាយការណ៍ស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

### មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា "រ.ទ.ស.ភ" ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងរបាយការណ៍លទ្ធផលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់របស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត ដូចដែលបានបង្ហាញពីទំព័រទី៦ ដល់ ៥៥។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា"ស.រ.ទ.ហ.អ.ក")។

### មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "ស.ស.អ.ក")។ ទំនួលខុសត្រូវរបស់យើងខ្ញុំស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមនៅក្នុងកថាខណ្ឌស្តីពី *ទំនួលខុសខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពី រ.ទ.ស.ភ ដោយអនុលោមទៅតាម *ក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ* ដែលចេញផ្សាយដោយក្រុមប្រឹក្សាក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញទំនួលខុសត្រូវក្នុងផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដោយអនុលោមទៅតាមតម្រូវការទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល គឺមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

AUDIT · TAX · ADVISORY

Baker Tilly (Cambodia) Co., Ltd. trading as Baker Tilly is a member of the global network of Baker Tilly International Ltd., the members of which are separate and independent legal entities.

### បញ្ហាសវនកម្មសំខាន់ៗ

បញ្ហាសវនកម្មសំខាន់ៗ គឺជាបញ្ហាទាំងឡាយណា ដែលនៅក្នុងការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំមានសារៈសំខាន់បំផុតក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។ បញ្ហាទាំងនេះត្រូវបានដោះស្រាយនៅក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ទាំងមូល និងជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំនាពេលបន្ទាប់ ហើយយើងខ្ញុំមិនមានការបញ្ចេញមតិយោបល់ដាច់ដោយឡែកចំពោះបញ្ហាទាំងនេះឡើយ។

**ក. តម្លៃយោងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងការវាយតម្លៃអាយុកាលប្រើប្រាស់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ**

***យោងតាមកំណត់សម្គាល់ ៣.៣ កំណត់សម្គាល់ ៤.២ និងកំណត់សម្គាល់ ៥ នៃរបាយការណ៍ហិរញ្ញវត្ថុ***

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ តម្លៃយោងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខាររបស់ រ.ទ.ស.ភ មានចំនួន ២,៤៩៥ ពាន់លានរៀល។

យើងខ្ញុំផ្ដោតលើតម្លៃយោងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ដោយសារតែគណនីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារភាគច្រើន តំណាងឱ្យទ្រព្យសកម្មសរុបរបស់ រ.ទ.ស.ភ ហើយការវិនិច្ឆ័យជាក់លាក់របស់គណៈគ្រប់គ្រងត្រូវបានពាក់ព័ន្ធក្នុងការកំណត់អាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ។ ដោយហេតុថាទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារមានលក្ខណៈជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ កំហុសខុសឆ្គងក្នុងការប៉ាន់ស្មានអាយុកាលប្រើប្រាស់របស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ អាចបណ្ដាលឱ្យមានការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ។

ហេតុដូចនេះ យើងខ្ញុំបានកំណត់ថា នេះជាបញ្ហាសវនកម្មសំខាន់។

ការឆ្លើយតបរបស់យើងខ្ញុំ៖

- យើងខ្ញុំបានត្រួតពិនិត្យភាពស្រមស្របលើការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង នៃអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដូចខាងក្រោម៖
  - ១ ពិភាក្សាជាមួយគណៈគ្រប់គ្រង លើផែនការប្រតិបត្តិការរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ
  - ២ វាយតម្លៃការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង នៃអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារថ្មី ដែលបានទិញចូលដោយពិនិត្យលើឯកសារពាក់ព័ន្ធ ដូចជាឯកសារគម្រោង ការវាយតម្លៃបច្ចេកទេស និងការបញ្ជាក់ពីអ្នកផ្គត់ផ្គង់
  - ៣ ត្រួតពិនិត្យការវិភាគរបស់គណៈគ្រប់គ្រង លើការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ដែលរួមបញ្ចូលការកំណត់អត្តសញ្ញាណលក្ខខណ្ឌដែលអាចបង្ហាញពីការផ្លាស់ប្ដូរមានលក្ខណៈជាសារវន្តទៅលើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មាន ដូចជាការប្រើប្រាស់ទ្រព្យសកម្មរំពឹងទុក ការសឹករិចរិលប៉ាន់ស្មាន បច្ចេកទេស ឬ ភាពហួសសម័យ និងកំហិតផ្លូវច្បាប់ ឬកំហិតស្រដៀងគ្នាលើការប្រើប្រាស់ទ្រព្យសកម្ម
  - ៤ ប្រៀបធៀបអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ជាមួយនឹងអង្គភាពក្នុងវិស័យទឹកភ្លើងដោយផ្អែកលើព័ត៌មានជាសាធារណៈនៃអង្គភាពទាំងនេះ និង
  - ៥ វាយតម្លៃភាពពេញលេញនៃការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**ក. តម្លៃយោងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងការវាយតម្លៃអាយុកាលប្រើប្រាស់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)**

- យើងខ្ញុំបានសង្កេតមើលទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ តាមរយៈការកំណត់វិធីសាស្ត្រការជ្រើសគំរូរបស់យើងខ្ញុំ។

ដោយផ្អែកលើនីតិវិធីដែលបានអនុវត្តខាងលើ យើងខ្ញុំពុំរកឃើញភាពខុសឆ្គងជាសារវន្តទេ លើកលែងតែភាពមិនស៊ីចង្វាក់គ្នានៃអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ជាមួយនឹងអង្គភាពក្នុងវិស័យទឹកភ្លើង។

**ខ. ការចាត់ថ្នាក់ និងតម្លៃសមស្របនៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសង**

***យោងតាមកំណត់សម្គាល់ ១៦ នៃរបាយការណ៍ហិរញ្ញវត្ថុ***

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ តម្លៃយោងនៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញរបស់ រ.ទ.ស.ភ មានចំនួន៨២,៩៣៣ាន់លានរៀល។

យើងខ្ញុំផ្តោតលើចំណុចនេះ ដោយសារតែការវិនិច្ឆ័យត្រូវបានអនុវត្តដោយគណៈគ្រប់គ្រងក្នុងការកំណត់ចំណាត់ថ្នាក់ និងតម្លៃសមស្របនៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ ជាប់ជាបំណុលរយៈពេលវែងរបស់ រ.ទ.ស.ភ។

ហេតុដូចនេះ យើងខ្ញុំបានកំណត់ថា នេះជាបញ្ហាសវនកម្មសំខាន់។

ការឆ្លើយតបរបស់យើងខ្ញុំ៖

- យើងខ្ញុំបានពិភាក្សាជាមួយគណៈគ្រប់គ្រងលើការវិនិច្ឆ័យ និងការសន្មតក្នុងការកំណត់ការចាត់ថ្នាក់នៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ។
- យើងខ្ញុំបានពិភាក្សាជាមួយគណៈគ្រប់គ្រងលើតម្លៃសមស្រប ដែលអាចនឹងប៉ះពាល់ដល់ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ។
- យើងខ្ញុំត្រួតពិនិត្យភាពត្រឹមត្រូវ លើតម្លៃយោងនៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ ដោយអនុវត្តនីតិវិធីពិនិត្យ លើបម្រែបម្រួលក្នុងអំឡុងការិយបរិច្ឆេទ នៅក្នុងគណនីគ្រប់គ្រងប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ។

ដោយផ្អែកលើនីតិវិធីដែលបានអនុវត្តខាងលើ យើងខ្ញុំពុំរកឃើញភាពខុសឆ្គងជាសារវន្តទេ លើកលែងតែចំណុចខ្វះខាតនៃការគ្រប់គ្រងលើការកំណត់អត្តសញ្ញាណនៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ ដែលយោងពីការិយបរិច្ឆេទមុន។

**គ. ការទទួលស្គាល់នៃចំណូលបង្គរពីការលក់ទឹក**

***យោងតាមកំណត់សម្គាល់ ៣.៦ កំណត់សម្គាល់ ៤.៣ និងកំណត់សម្គាល់ ៨ នៃរបាយការណ៍ហិរញ្ញវត្ថុ***

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ តម្លៃយោងនៃចំណូលបង្គរពីការលក់ទឹក បានបញ្ចូលនៅក្នុងកិច្ចសន្យាទ្រព្យសកម្ម និងចំណូលរបស់ រ.ទ.ស.ភ មានចំនួន ១៤៩ ពាន់លានរៀល។

ឥ. **ការទទួលស្គាល់នៃចំណូលបង្គរពីការលក់ទឹក (ត)**

យើងខ្ញុំផ្ដោតលើចំណុចនេះ ដោយសារតែចំនួននៃចំណូលបង្គរពីការលក់ទឹក បានទទួលស្គាល់ក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានប៉ះពាល់ដោយការប៉ាន់ស្មានខុសៗគ្នា ដែលរួមបញ្ចូលការវិនិច្ឆ័យជាក់លាក់ដែលបានអនុវត្តដោយគណៈគ្រប់គ្រង និងជាពិសេសទាក់ទងនឹងការកំណត់បរិមាណទឹកដែលបានផលិត ចំណូលពីការលក់ទឹកដែលបានបោះវិក្កយបត្រ អត្រាទឹកបាត់បង់ និងអត្រាពន្ធដែលពាក់ព័ន្ធ។

ហេតុដូចនេះ យើងខ្ញុំបានកំណត់ថា នេះជាបញ្ហាសវនកម្មសំខាន់។

ការឆ្លើយតបរបស់យើងខ្ញុំ៖

- យើងខ្ញុំបានត្រួតពិនិត្យភាពស្រមស្របនៃការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង នៃការកំណត់ចំណូលបង្គរពីការលក់ទឹករបស់ រ.ទ.ស.ភ ដូចខាងក្រោម៖

១ ពិភាក្សាជាមួយគណៈគ្រប់គ្រងលើការកំណត់វិធីសាស្ត្រ សម្រាប់ប្រើប្រាស់ក្នុងការទាញយកចំណូលបង្គរពីការលក់ទឹក

២ ធ្វើការតវ៉ានឹងការសន្មតសំខាន់ៗដែលប្រើប្រាស់ដោយគណៈគ្រប់គ្រង ជាពិសេសបរិមាណទឹកដែលបានផលិតអត្រាទឹកបាត់បង់ និងអត្រាពន្ធដែលពាក់ព័ន្ធ និង

៣ ធ្វើការគណនាឡើងវិញលើការគណនាចំណូលបង្គរពីការលក់ទឹក ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវជាក់លាក់។

- យើងខ្ញុំបានត្រួតពិនិត្យការគ្រប់គ្រង ដែលមានការចូលរួមជាមួយអ្នកឯកទេសព័ត៌មានវិទ្យារបស់យើងខ្ញុំ ដោយក្នុងចំណោមនោះធ្វើការប្រៀបធៀបព័ត៌មានលម្អិតនៃចំនួនចំណូល នៅក្នុងប្រព័ន្ធគណនេយ្យជាមួយនឹងប្រភពឯកសារ ការកត់ត្រាចំណូលទទួលបាន ក្នុងប្រព័ន្ធគណនីពាណិជ្ជ ការផ្ទៀតផ្ទាត់បញ្ជីសាច់ប្រាក់សរុប ជាមួយសាច់ប្រាក់ទទួលបាន និងការកត់ត្រាចំណូលទទួលបានទៅបញ្ជីធំទូទៅ។
- យើងខ្ញុំបានពិនិត្យការបោះវិក្កយបត្រជាបន្តបន្ទាប់នៃចំណូលបង្គរពីការលក់ទឹក។

ដោយផ្អែកលើនីតិវិធីដែលបានអនុវត្តខាងលើ យើងខ្ញុំពុំរកឃើញភាពខុសឆ្គងជាសារវន្តទេ។

**ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ**

គណៈគ្រប់គ្រងរបស់ រ.ទ.ស.ភ មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ក្រុមប្រឹក្សាភិបាល (ប៉ុន្តែមិនរាប់បញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ និងរបាយការណ៍របស់សវនករនោះទេ) ដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករឯករាជ្យនេះ និងផ្នែកផ្សេងទៀតដែលរួមបញ្ចូលរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងថានឹងត្រូវបានដាក់ឱ្យប្រើប្រាស់សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនេះ។

មតិសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ មិនគ្របដណ្ដប់លើព័ត៌មានផ្សេងៗ ហើយយើងខ្ញុំក៏មិនបញ្ចេញមតិសន្និដ្ឋានជានាណាមួយឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ និងទន្ទឹមនឹងនេះពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឬការយល់ដឹងរបស់យើងខ្ញុំទទួលបានពីការធ្វើសវនកម្ម ឬបើមិនដូច្នោះទេមានកំហុសឆ្គងជាសារវន្ត។

ប្រសិនបើផ្អែកលើកិច្ចការដែលយើងខ្ញុំ បានអនុវត្តលើព័ត៌មានផ្សេងៗ ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តទៅលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដែលបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ គណៈគ្រប់គ្រងក៏ទទួលខុសត្រូវផងដែរ ចំពោះការត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថា មានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឲ្យជៀសផុតពីការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬភ័ន្តច្រឡំ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធភាពរបស់ រ.ទ.ស.ភ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងមានបំណងបិទអាជីវកម្មរបស់ រ.ទ.ស.ភ ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យណាផ្សេងក្រៅពីធ្វើបែបនេះ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការរាយកាណ៍របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬភ័ន្តច្រឡំ និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផល គឺជាអំណះអំណាងក្នុងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថា សវនកម្មដែលធ្វើឡើងដោយអនុលោមទៅតាម ស.ស.អ.ក តែងរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើង ដោយសារការក្លែងបន្លំ ឬភ័ន្តច្រឡំ ត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើការរាយការណ៍ខុសតែមួយ ឬរួមបញ្ចូលគ្នា ត្រូវបានរំពឹងថានឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយពឹងផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាម ស.ស.អ.ក យើងខ្ញុំតម្រូវឱ្យអនុវត្តនូវការវិនិច្ឆ័យដែលប្រកបដោយវិជ្ជាជីវៈ និងរក្សានូវការសង្ស័យស្របតាមវិជ្ជាជីវៈក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់ និងវាយតម្លៃហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង រៀបចំ និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលភស្តុតាងសវនកម្មដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការរាយការណ៍ខុសដែលកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា បំណកស្រាយមិនពិត ឬការបំពានលើនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ស្វែងយល់អំពីនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណងរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃនីតិវិធីគ្រប់គ្រងផ្ទៃក្នុងរបស់ រ.ទ.ស.ភ ឡើយ។
- វាយតម្លៃលើភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយគណៈគ្រប់គ្រង។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រង និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានថាតើភាពមិនច្បាស់លាស់ជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានភាពមិនប្រាកដប្រជាជាសារវន្តទៅលើលទ្ធភាពរបស់ រ.ទ.ស.ភ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍នៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំទៅលើការលាតត្រដាងព័ត៌មានពាក់ព័ន្ធ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឬប្រសិនបើការបង្ហាញព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវធ្វើការកែប្រែមតិសវនកម្មរបស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើងខ្ញុំ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យ រ.ទ.ស.ភ បញ្ឈប់និរន្តរភាពអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញជាទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍នានាតាមលក្ខណៈដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចក្នុងចំណោមបញ្ហាផ្សេងៗ ស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលរួមមានចំណុចខ្វះខាតនៃនីតិវិធីគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់សេចក្តីបញ្ជាក់ជូនអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចនូវសេចក្តីអះអាងថា យើងខ្ញុំអនុវត្តតាមតម្រូវការផ្នែកក្រមសីលធម៌វិជ្ជាជីវៈដែលពាក់ព័ន្ធនឹងឯករាជ្យភាព ព្រមទាំងបានជូនដំណឹងពួកគាត់នូវរាល់ទំនាក់ទំនងទាំងអស់ និងបញ្ហាផ្សេងៗ ដែលយើងខ្ញុំយល់ថាមានផលប៉ះពាល់ចំពោះឯករាជ្យភាពរបស់យើងខ្ញុំ ហើយរួមជាមួយនឹងការអនុវត្តវិធានការនានា ដើម្បីលុបបំបាត់នូវការគំរាមកំហែង ឬអនុវត្តនូវវិធីសាស្ត្រការពារ។

bakertilly

បញ្ហានានាដែលយើងខ្ញុំបានផ្តល់ព័ត៌មានជូនអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច យើងខ្ញុំកំណត់ថាបញ្ហាទាំងនោះជាបញ្ហាដែលមានផលប៉ះពាល់ជាសារវន្ត នៅក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ក្នុងបច្ចុប្បន្ន និងជាបញ្ហាសវនកម្មសំខាន់ៗ។ យើងខ្ញុំពណ៌នាបញ្ហាទាំងនេះនៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ លើកលែងតែច្បាប់ ឬបទប្បញ្ញត្តិរារាំងនូវការលាតត្រដាងជាសាធារណៈអំពីបញ្ហានេះក្នុងការធ្វើសវនកម្ម ឬក៏ក្នុងកាលៈទេសៈដ៏កម្របំផុត ដែលយើងខ្ញុំកំណត់ថាបញ្ហានោះ មិនគួរត្រូវបានបង្ហាញក្នុងរបាយការណ៍របស់យើងខ្ញុំទេ ដោយសារការបង្ហាញពីបញ្ហានេះនឹងបណ្តាលឱ្យមានផលអវិជ្ជមានដែលត្រូវបានរំពឹងថានឹងបណ្តាលឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

**បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក**
ក្រុមហ៊ុនគណនេយ្យករជំនាញ

**ឧកញ៉ា Tan Khee Meng**
គណនេយ្យករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 13 MAR 2024

# ឧបសម្ព័ន្ធ ៤

## លទ្ធផលពិនិត្យគុណភាពទឹក
## ពីបណ្ដាញចែកចាយ
## ក្នុងតំបន់ស្ទឹងមានជ័យ ក្នុងរាជធានីភ្នំពេញ

TEST REPORT 7191321955-CHM23-NHT

# TEST REPORT: 7191321955-CHM23-NHT

Date: 20 DEC 2023 Tel: +65 6973 6164

Client's Ref: Email: na.pi@tuvsud.com

**Note:** This report is issued subject to the Testing and Certification Regulations of the TÜV SÜD Group and the General Terms and Conditions of Business of TÜV SÜD PSB Pte Ltd. In addition, this report is governed by the terms set out within this report.

PSB Singapore

Add value.
Inspire trust.

## SUBJECT

Analysis of Drinking Water Sample

## CLIENT

Phnom Penh Water Supply Authority (PPWSA)
#45, Street 106, Phnom Penh 12202
Cambodia

Attention: Keo Heng

## DATE OF SAMPLE SUBMISSION / TESTING

20 Nov 2023 / 20 Nov to 14 Dec 2023

## DESCRIPTION OF SAMPLE

One water sample was received and labelled as "Drinking Water"

## METHOD OF TEST

1. APHA-AWWA-WEF 23rd Edition 2017 - Standard Methods for the Examination of Water and Wastewater.
2. USEPA Method 508 Determination of Chlorinated Pesticides in Water by Gas Chromatography Electron Capture Detector (GC/ECD).
3. USEPA Method 515 Determination of Chlorinated Acids in Drinking Water by Liquid-Liquid Extraction, Derivitization, and GC/ECD.
4. EPA 8260D: Volatile Organic Compounds by Gas Chromatography Mass Spectrometry (GC/MS).
5. EPA 8270E: Semi-Volatile Organic Compounds by GC/MS.
6. USEPA Method 551.1 Determination of Chlorination Disinfection Byproducts, Chlorinated Solvents, and Halogenated Pesticides/Herbicides in Drinking Water by Liquid-Liquid Extraction and GC/ECD.
7. USEPA Method 552.2 Determination of Haloacetic Acids and Dalapon in Drinking Water by Liquid-Liquid Extraction, Derivatization and GC/ECD.
8. Determination of EDTA and NTA by Solid Phase Extraction, Derivatization and GC/MS.
9. Determination of Bromate by Derivatization and GC/MS.
10. Determination of Inorganic Anions in Drinking Water by Ion Chromatography (IC).

**The below tests were sub-contracted to the partner laboratory:**

11. NF EN ISO 10704 : 2019 Water quality - Gross Alpha and Gross Beta Activity.
12. Determination of Malathion by Liquid-Liquid Extraction and GC/MS.
13. High Performance Liquid Chromatography with Tandem Mass Spectrometry (LC/MS/MS) for:
    - Acrylamide
    - Aldicarb Sulfoxide and Aldicarb Sulfone
    - Carbofuran
    - Chlorotoluron
    - Microcystin-LR
    - Isoproturon
    - N-Nitrosodimethylamine (NDMA)
    - Dichlorvos
    - Atrazine and its chloro-s-triazine metabolites
    - Bentazone
    - Diquat
    - Glyphosate and Aminomethylphosphonic acid (AMPA)
    - Sodium dichloroisocyanurate

PSB Singapore

## RESULTS

| Test Parameter | | Drinking Water | Detection Limit | *WHO Guideline Value |
|---|---|---|---|---|
| **Microbiological Parameter** | | | | |
| Escherichia coli | cfu/100mL | < 1 | 1 | < 1 |
| | | | | |
| **Physical Parameters** | | | | |
| Color | Hazen | Not detected | 2.5 | - |
| Conductivity at 25ºC | µS/cm | 111 | - | - |
| Odour | | Unobjectionable | - | - |
| pH @ 25°C | | 7.1 | - | - |
| Total Dissolved Solids | mg/L | 67.3 | 1 | - |
| Turbidity | NTU | 0.30 | 0.1 | 5 |
| | | | | |
| **Radiological Parameters** | | | | |
| Gross Alpha | Bq/L | Not detected | 0.02 | 0.5 |
| Gross Beta | Bq/L | 0.22 | 0.16 | 1 |
| | | | | |
| **Chemical Parameters** | | | | |
| Acrylamide | mg/L | Not detected | 0.0005 | 0.0005 |
| Alachlor | mg/L | Not detected | 0.001 | 0.02 |
| Aldicarb Sulfoxide and Aldicarb Sulfone | mg/L | Not detected | 0.01 | 0.01 |
| Aldrin & Dieldrin | mg/L | Not detected | 0.00003 | 0.00003 |
| Antimony | mg/L | Not detected | 0.001 | 0.02 |
| Arsenic | mg/L | Not detected | 0.001 | 0.01 |
| Atrazine and its chloro-s-triazine metabolites | mg/L | Not detected | 0.005 | 0.1 |
| Aluminium | mg/L | 0.05 | 0.001 | - |
| Barium | mg/L | 0.02 | 0.001 | 1.3 |
| Bentazone | mg/L | Not detected | 0.001 | - |
| Benzene | mg/L | Not detected | 0.001 | 0.01 |
| Benzo (a) pyrene | mg/L | Not detected | 0.0001 | 0.0007 |
| Boron | mg/L | < 0.02 | 0.001 | 2.4 |
| Bromate | mg/L | Not detected | 0.01 | 0.01 |
| Bromodichloromethane | mg/L | Not detected | 0.001 | 0.06 |
| Bromoform | mg/L | Not detected | 0.001 | 0.1 |
| Cadmium | mg/L | Not detected | 0.001 | 0.003 |
| Calcium | mg/L | 9.10 | 0.001 | - |
| Carbofuran | mg/L | Not detected | 0.005 | 0.007 |
| Carbon Tetrachloride | mg/L | Not detected | 0.001 | 0.004 |
| Chlorate | mg/L | Not detected | 0.2 | 0.7 |
| Chlordane (total isomers) | mg/L | Not detected | 0.0001 | 0.0002 |
| Chlorine (Free) | mg/L | Not detected | 0.01 | 5 |
| Chlorite | mg/L | Not detected | 0.2 | 0.7 |
| Chloroform | mg/L | Not detected | 0.001 | 0.3 |
| Chlorotoluron | mg/L | Not detected | 0.01 | 0.03 |
| Chlorpyrifos | mg/L | Not detected | 0.001 | 0.03 |
| Chromium (in all forms as a total) | mg/L | Not detected | 0.01 | 0.05 |
| Copper | mg/L | < 0.01 | 0.01 | 2 |

PSB Singapore

**RESULTS** (Continued)

| Test Parameter | | Drinking Water | Detection Limit | *WHO Guideline Value |
|---|---|---|---|---|
| Cyanazine | mg/L | Not detected | 0.0001 | 0.0006 |
| Cyanide | mg/L | Not detected | 0.01 | - |
| Cyanogen chloride (as cyanide) | mg/L | Not detected | 0.01 | - |
| Chloride | mg/L | 13.0 | 0.1 | - |
| 2,4-D (2,4-dichlorophenoxyacetic acid) in free acid form | mg/L | Not detected | 0.01 | 0.03 |
| 2,4-DB [2,4-Dichlorophenoxy) butyric acid] | mg/L | Not detected | 0.01 | 0.09 |
| DDT & Metabolites | mg/L | Not detected | 0.0001 | 0.001 |
| Di(2-Ethylhexyl) phthalate | mg/L | Not detected | 0.001 | 0.008 |
| 1,2-Dibromo-3-chloropropane (DBCP) | mg/L | Not detected | 0.001 | 0.001 |
| Dibromoacetonitrile | mg/L | Not detected | 0.001 | 0.07 |
| Dibromochloromethane | mg/L | Not detected | 0.001 | 0.1 |
| 1,2-Dibromoethane (Ethylene Dibromide) 1,2- | mg/L | Not detected | 0.0001 | 0.0004 |
| Dichloroacetate | mg/L | Not detected | 0.01 | 0.05 |
| Dichloroacetonitrile | mg/L | Not detected | 0.01 | 0.02 |
| Dichlorobenzene, 1,2- | mg/L | Not detected | 0.001 | 1 |
| Dichlorobenzene, 1,4- | mg/L | Not detected | 0.001 | 0.3 |
| Dichloroethane, 1,2- | mg/L | Not detected | 0.001 | 0.03 |
| Dichloroethene (cis & trans), 1,2- | mg/L | Not detected | 0.001 | 0.05 |
| Dichloromethane | mg/L | Not detected | 0.001 | 0.02 |
| Dichloropropane, 1,2- | mg/L | Not detected | 0.001 | 0.04 |
| Dichloropropene, 1,3- | mg/L | Not detected | 0.001 | 0.02 |
| Dichlorvos | mg/L | Not detected | 0.1 | - |
| Dicofol | mg/L | Not detected | 0.1 | - |
| Dichlorprop | mg/L | Not detected | 0.01 | 0.1 |
| Dimethoate | mg/L | Not detected | 0.001 | 0.006 |
| Dioxane, 1,4- | mg/L | Not detected | 0.01 | 0.05 |
| Diquat | mg/L | Not detected | 0.001 | - |
| Endrin | mg/L | Not detected | 0.0001 | 0.0006 |
| Epichlorohydrin | mg/L | Not detected | 0.0001 | 0.0004 |
| Ethylbenzene | mg/L | Not detected | 0.001 | 0.3 |
| Edetic acid (EDTA-Ethylene Diamine Tetraacetic Acid) in free acid form | mg/L | Not detected | 0.1 | 0.6 |
| Fenoprop (2,4,5-TP; 2,4,5-trichlorophenoxy propionic acid) | mg/L | Not detected | 0.003 | 0.009 |
| Fluoride | mg/L | < 0.1 | 0.1 | 1.5 |
| Glyphosate and Aminomethylphosphonic acid (AMPA) | mg/L | Not detected | 0.001 | - |
| Hexachlorobutadiene (HCBD) | mg/L | Not detected | 0.0001 | 0.0006 |
| Hydroxyatrazine | mg/L | Not detected | 0.01 | 0.2 |
| Isoproturon | mg/L | Not detected | 0.005 | 0.009 |
| Iron | mg/L | < 0.01 | 0.01 | - |
| Lead | mg/L | Not detected | 0.001 | 0.01 |
| Lindane | mg/L | Not detected | 0.0001 | 0.002 |
| Malathion | mg/L | Not detected | 0.001 | - |
| MCPA (4-Chloro-2-methylphenoxyacetic acid) | mg/L | Not detected | 0.003 | - |
| Mecoprop (MCPP; [2(2-methyl-chlorophenoxy) propionicacid] | mg/L | Not detected | 0.003 | 0.01 |
| Mercury, in inorganic form | mg/L | Not detected | 0.001 | 0.006 |
| Methoxychlor | mg/L | Not detected | 0.001 | 0.02 |
| Metolachlor | mg/L | Not detected | 0.01 | 0.01 |
| Microcystin-LR | mg/L | Not detected | 0.001 | 0.001 |

PSB Singapore

**RESULTS** (Continued)

| Test Parameter | | Drinking Water | Detection Limit | *WHO Guideline Value |
|---|---|---|---|---|
| Molinate | mg/L | Not detected | 0.001 | 0.006 |
| Monochloramine | mg/L | 0.05 | 0.1 | 3 |
| Monochloroacetic acid (chloroacetic acid) | mg/L | Not detected | 0.01 | 0.02 |
| Manganese | mg/L | Not detected | 0.01 | - |
| Magnesium | mg/L | 2.90 | 0.001 | - |
| Molybdenum | mg/L | Not detected | 0.01 | - |
| Nickel | mg/L | Not detected | 0.02 | 0.07 |
| Nitrate (as N) | mg/L | 0.09 | 0.02 | 11 |
| Nitrilotriacetic acid (NTA) | mg/L | Not detected | 0.1 | 0.2 |
| Nitrite (as N) | mg/L | < 0.03 | 0.03 | 0.9 |
| Nitrate plus nitrite combined | units | < 0.009 | 0.009 | 1 |
| Nitrisodimethylamine (NDMA) | mg/L | Not detected | 0.0001 | 0.0001 |
| Pendimethalin | mg/L | Not detected | 0.001 | 0.02 |
| Pentachlorophenol (PCP) | mg/L | Not detected | 0.001 | 0.009 |
| Perchlorate | mg/L | Not detected | 0.04 | 0.07 |
| Permethrin, where used as a larvicide for public health purposes | mg/L | Not detected | 0.04 | - |
| Pyriproxyfen | mg/L | Not detected | 0.04 | - |
| Selenium | mg/L | Not detected | 0.001 | 0.04 |
| Simazine | mg/L | Not detected | 0.001 | 0.002 |
| Sodium dichloroisocyanurate | mg/L | Not detected | 0.1 (as cyanuric acid) | 50 (40 as cyanuric acid) |
| Styrene | mg/L | Not detected | 0.001 | 0.02 |
| Sulfate as $SO_4^{2-}$ | mg/L | 3.1 | 0.1 | - |
| Silica (as $SiO_2$) | mg/L | 8.10 | 0.002 | - |
| Sodium | mg/L | 4.75 | 0.001 | - |
| Terbuthylazine (TBA) | mg/L | Not detected | 0.001 | 0.007 |
| Tetrachloroethene | mg/L | Not detected | 0.001 | 0.04 |
| Toluene | mg/L | Not detected | 0.001 | 0.7 |
| Trichloroethene | mg/L | Not detected | 0.001 | 0.02 |
| Trichlorophenol, 2,4,6- | mg/L | Not detected | 0.001 | 0.2 |
| 2,4,5-T (2,4,5-Trichlorophenoxyacetic acid) | mg/L | Not detected | 0.003 | 0.009 |
| Trichloroacetate | mg/L | Not detected | 0.01 | 0.2 |
| Trifluralin | mg/L | Not detected | 0.001 | 0.02 |
| Total Trihalomethanes Ratio# | unit | Not detected | 0.04 | < 1 |
| Total Organic Carbon (TOC) | mg/L | 2 | 1.0 | - |
| Total Alkalinity (as $CaCO_3$) | mg/L | 28.0 | 1.0 | - |
| Total Hardness as ($CaCO_3$) | mg/L | 34.7 | 0.007 | - |
| Total Phosphorus (as P) | mg/L | Not detected | 0.1 | - |
| Uranium | mg/L | Not detected | 0.001 | 0.03 |
| Vinyl Chloride | mg/L | Not detected | 0.0001 | 0.0003 |
| Xylenes | mg/L | Not detected | 0.001 | 0.5 |

Note:

1. *Specification is based on Environmental Public Health (Water Suitable for Drinking) (No. 2) Regulations 2019 / WHO Guideline for Drinking Water Quality, 1st Addendum to 4th Edition, 2017.
2. #The sum of the ratio of the concentration of each to its respective guideline value should not exceed 1.

PSB Singapore

**REMARKS**

The parameters tested for the water sample complied with WHO Guidelines for Drinking-Water Quality, 1st Addendum to 4th Edition, 2017.

**HO THI THANH NHA**
CHEMIST

**DR. PI NA**
ASSISTANT PRODUCT MANAGER
ENVIRONMENTAL MONITORING
CHEMICAL & MATERIALS

PSB Singapore

Please note that this Report is issued under the following terms :

1. This report applies to the sample of the specific product/equipment given at the time of its testing/calibration. The results are not used to indicate or imply that they are applicable to other similar items. In addition, such results must not be used to indicate or imply that TÜV SÜD PSB approves, recommends or endorses the manufacturer, supplier or user of such product/equipment, or that TÜV SÜD PSB in any way "guarantees" the later performance of the product/equipment. Unless otherwise stated in this report, no tests were conducted to determine long term effects of using the specific product/equipment.

2. The sample/s mentioned in this report is/are submitted/supplied/manufactured by the Client. TÜV SÜD PSB therefore assumes no responsibility for the accuracy of information on the brand name, model number, origin of manufacture, consignment or any information supplied.

3. Nothing in this report shall be interpreted to mean that TÜV SÜD PSB has verified or ascertained any endorsement or marks from any other testing authority or bodies that may be found on that sample.

4. This report shall not be reproduced wholly or in parts and no reference shall be made by the Client to TÜV SÜD PSB or to the report or results furnished by TÜV SÜD PSB in any advertisements or sales promotion.

5. Unless otherwise stated, the tests were carried out in TÜV SÜD PSB Pte Ltd, 15 International Business Park Singapore 609937.

6. The tests carried out by TÜV SÜD PSB and this report are subject to TÜV SÜD PSB's General Terms and Conditions of Business and the Testing and Certification Regulations of the TÜV SÜD Group.

Effective 01 January 2021

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)**

---

: + ៨៥៥(២៣) ៦៣៥ ០៨ ០៨

: ir@ppwsa.com.kh

: WWW.PPWSA.COM.KH

---

អគារលេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# ឧបសម្ព័ន្ធ ៤

## ទិសដៅអាជីវកម្មប្រចាំឆ្នាំ ២០២៤

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ



# ទិសដៅអាជីវកម្ម ឆ្នាំ២០២៤



រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ខែឧសភា ឆ្នាំ២០២៤

# មាតិកា

# ផែនការឆ្នាំ២០២៣

## ផ្នែក ក: ផែនការដំណើរការសហគ្រាស


១ ផែនការផលិតទឹកស្អាត 2

២ ផែនការសេវាអតិថិជន 4

៣ ផែនការហិរញ្ញវត្ថុ 8

៤ ផែនការធនធានមនុស្ស 9


## ផ្នែក ខ: ផែនការវិនិយោគ


៥ ការពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត 10

៦ កែលម្អប្រព័ន្ធផលិតកម្ម 12

៧ ឧបករណ៍ទ្រទ្រង់គម្រោង 14

៨ ផែនការសំណង់ស៊ីវិល 17

៩ តារាងសង្ខេបបំណែងចែកប្រភពថវិកាវិនិយោគ ឆ្នាំ២០២៤ 17

# សេចក្តីផ្តើម

ផែនការឆ្នាំ 2024 របស់ **រ.ឧ.ស.ភ** គឺកសាងឡើងក្នុងគោលបំណងកំណត់ទិសដៅចម្បងៗ ដែលត្រូវអនុវត្ត សម្រាប់សកម្មភាពដែលមានក្នុងកម្មវត្ថុអាជីវកម្មដូចខាងក្រោម៖

ក. វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ប្រព្រឹត្តកម្ម និង ប្រព័ន្ធចែកចាយទឹកស្អាតព្រមទាំងគុណភាពទឹកស្អាត ។

ខ. ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើនប្រព្រឹត្តកម្មទឹក-សេវាកម្ម និងធានាគុណភាពទឹកស្អាត ឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅ អាជីវកម្ម-សេវាកម្ម និងឧស្សាហកម្ម ។

គ. ធ្វើអាជីវកម្ម-សេវាកម្ម និងការងារផ្សេងៗទៀត ដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុង ឬក្រៅប្រទេស តាមការសម្រេចរបស់ **ក្រុមប្រឹក្សាភិបាល** ឬ **ឯកឧត្តមប្រតិភូ** និងដោយអនុលោមតាមច្បាប់ ។

ឃ. សហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ដើម្បីអភិវឌ្ឍន៍ **រ.ឧ.ស.ភ** ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ង. ធានាឱ្យបាននូវចីរភាពដំណើរការប្រព្រឹត្តកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម ។

# ផ្នែក ក ផែនការដំណើរការសហគ្រាស

គោលបំណងចម្បងរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញគឺ ជានាការផ្គត់ផ្គង់ទឹកស្អាត 24ម៉ោង ក្នុងមួយថ្ងៃ 7ថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងករណីដាច់ចរន្តអគ្គិសនី) មានសំពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់នឹងរាជធានីភ្នំពេញ ព្រមទាំងទីតាំងរោងចក្រប្រព្រឹត្តកម្មទឹកស្អាតម្លេច និងត្បូងឃ្មុំ ដោយមិនមើលរំលងប្រជាពលរដ្ឋដែលមានចំណូលទាប។ ដើម្បីសម្រេចបាននូវគោលបំណងនេះ រ.ទ.ស.ភ បានកសាងផែនការដំណើរការសហគ្រាសសម្រាប់ឆ្នាំ 2024 ដោយផ្អែកលើរបាយការណ៍លទ្ធផលជាក់ស្តែង 8ខែ បូកប៉ាន់ស្មាន 4ខែ ឆ្នាំ2023 មានដូចខាងក្រោម៖

## ១ ផែនការផលិតកម្មទឹកស្អាត

នៅក្នុងឆ្នាំ2024 រ.ទ.ស.ភ មានរោងចក្រផលិតទឹកចំនួនប្រាំបី ហើយមានសមត្ថភាពផលិតសរុប 1,050,000 ម៉ែត្រគូបក្នុងមួយថ្ងៃ ដែលមានដូចខាងក្រោមនេះ៖

- រោងចក្រភូមិព្រែក 170,000 $m^3$/ថ្ងៃ
- រោងចក្រជ្រោយចង្វារ 160,000 $m^3$/ថ្ងៃ
- រោងចក្រចំការមន 52,000 $m^3$/ថ្ងៃ
- រោងចក្រនិរោធ 260,000 $m^3$/ថ្ងៃ
- រោងចក្របាក់ខែងដំហានទី1 195,000 $m^3$/ថ្ងៃ
- រោងចក្របាក់ខែងដំហានទី2 195,000 $m^3$/ថ្ងៃ
- រោងចក្របឹងធំ 6,000 $m^3$/ថ្ងៃ
- រោងចក្រម្លេច 2,000 $m^3$/ថ្ងៃ
- រោងចក្រត្បូងឃ្មុំ 10,000 $m^3$/ថ្ងៃ

នាឆ្នាំ2024 ខាងមុខ ដើម្បីជានាការផ្គត់ផ្គង់ទឹកស្អាតឱ្យស្របតាមតម្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋ នៅតំបន់សេវាមានស្រាប់ និងតំបន់សេវាថ្មី រ.ទ.ស.ភ បានគ្រោងផលិត និងផ្គត់ផ្គង់ទឹកស្អាតប្រចាំឆ្នាំចំនួន 311,224,300$m^3$ ដែលជាមធ្យមគឺផលិតទឹកស្អាតប្រមាណ 850,340$m^3$/ថ្ងៃ ។ បរិមាណទឹកផលិតនៅឆ្នាំ2024 នេះ មានកំណើនប្រមាណ 11% ធៀបនឹងបរិមាណទឹកផលិតប្រចាំឆ្នាំ2023 ។ ការមានកំណើនលើដំណើរការផលិតទឹកនេះ ដោយសារ រ.ទ.ស.ភ គ្រោងដាក់ដំណើរការរោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ ខែងដំហានទី២ សមត្ថភាពផលិត 195,000$m^3$/ថ្ងៃ នាខែមីនា ឆ្នាំ2024 និងរោងចក្រប្រព្រឹត្តកម្មទឹកស្អាតបឹងធំ សមត្ថភាពផលិត 6,000$m^3$/ថ្ងៃ នាខែមិថុនា ឆ្នាំ2024។

ផែនការផលិតទឹកស្អាតក្នុងឆ្នាំ2024 មានអត្រា 81% ធៀបនឹងសមត្ថភាពផលិតទឹកសរុប។ អត្រានេះ យើងឃើញថា សមត្ថភាពផលិតរបស់រោងចក្រទាំងប្រាំបី អាចមានលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋនៅឆ្នាំបន្ទាប់ទៀតបាន។ ដូច្នេះ រ.ទ.ស.ភ មានសមត្ថភាពជានាការផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋបាននៅក្នុងឆ្នាំ2024។

ការចាត់ចែងដំណើរការរោងចក្រផលិតទឹកស្អាតដូចខាងក្រោម៖

| រោងចក្រ ផលិតទឹកស្អាត | ផែនការផលិតកម្មទឹកស្អាតឆ្នាំ2024 (ម៉ែត្រគូប) | | | | | |
|---|---|---|---|---|---|---|
| | ទឹកផលិត ឆ្នាំ2023 | ផែនការឆ្នាំ 2024 | កំណើន ធៀប2023 | ផែនការ ផលិតកម្ម មធ្យមប្រចាំថ្ងៃ | សមត្ថភាព ផលិតមធ្យម ប្រចាំថ្ងៃ | ប្រសិទ្ធភាព ដំណើរការ រោងចក្រ |
| | (1) | (2) | 2/1 | (3) | (4) | (3/4) |
| ភូមិព្រែក | **60,987,910** | 59,441,000 | 97% | 162,852 | 170,000 | 96% |
| ជ្រោយចង្វារ | **54,744,240** | 41,420,000 | 76% | 113,479 | 160,000 | 71% |
| ចំការមន | **20,148,852** | 19,639,000 | 97% | 53,805 | 52,000 | 103% |

| រោងចក្រផលិតទឹកស្អាត | ផែនការផលិតកម្មទឹកស្អាតឆ្នាំ2024 (ម៉ែត្រគូប) | | | | | |
|---|---|---|---|---|---|---|
| | ទឹកផលិតឆ្នាំ2023 | ផែនការឆ្នាំ2024 | កំណើនធៀប2023 | ផែនការផលិតកម្មមធ្យមប្រចាំថ្ងៃ | សមត្ថភាពផលិតមធ្យមប្រចាំថ្ងៃ | ប្រសិទ្ធភាពដំណើរការរោងចក្រ |
| | (1) | (2) | 2/1 | (3) | (4) | (3/4) |
| និរោធ | **95,317,380** | 96,921,000 | 102% | 265,537 | 260,000 | 102% |
| ប៉ាក់ខែងជំហានទី1+2 | **47,527,478** | 91,902,000 | 193% | 375,110 | 390,000 | 96% |
| បឹងធំ | - | 797,000 | - | 3,724 | 6,000 | 62% |
| ម្លេច | **430,393** | 558,000 | 130% | 1,529 | 2,000 | 76% |
| ត្បូងឃ្មុំ | **321,317** | 546,300 | 170% | 1,497 | 10,000 | 15% |
| **សរុប** | 279,477,570 | 311,224,300 | 111% | 850,340 | 1,050,000 | 81% |

អត្រាដំណើរការប្រព្រឹត្តកម្មទឹកស្អាតរបស់រោងចក្រទាំងប្រាំបី




ចំពោះការគ្រោងវត្ថុធាតុដើមសម្រាប់ផលិតកម្មទឹកស្អាត គឺផ្អែកលើកត្តាប្រើប្រាស់ជាក់ស្តែងក្នុងឆ្នាំ2021 ឆ្នាំ2022 និងឆ្នាំ2023 ដោយគោរពយ៉ាងខ្ជាប់ខ្ជួនទៅនឹងបទដ្ឋានដំណើរការផលិតកម្មទឹក និងគុណភាពទឹក ដើម្បីធានាបានគុណភាពទឹកស្អាត គ្មានមេរោគ ស្របតាមស្តង់ដារទឹកផឹកថ្នាក់ជាតិ និងស្តង់ដារគុណភាពទឹករបស់អង្គការសុខភាពពិភពលោក។

**ការគ្រោងវត្ថុធាតុដើម និងថាមពលអគ្គិសនី សម្រាប់ផលិតកម្មទឹកស្អាតឆ្នាំ2024 មានដូចខាងក្រោម៖**

| បរិយាយ | ឯកតា | ផែនការប្រើប្រាស់វត្ថុធាតុដើមសម្រាប់ឆ្នាំ2024 | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ភូមិព្រែក | ជ្រោយចង្វារ | ចំការមន | និរោធ | ប៉ាក់ខែងជំហានទី1+2 | បឹងធំ | ម្លេច | ត្បូងឃ្មុំ | សរុប |
| | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | (1+2+3+4+5+6+7+8) |
| PAC | គ.ក្រ | 769,688 | 290,767 | 210,804 | 922,812 | 1,444,962 | 37,758 | 7,361 | 13,878 | 3,698,030 |
| | ក្រ.ម$^3$ | 12.95 | 7.02 | 10.73 | 9.52 | 15.72 | 47.38 | 13.19 | 25.40 | 11.88 |
| អំបិល-ក្លរីន | គ.ក្រ | 112,747 | 65,478 | 78,605 | - | 350,671 | - | - | - | 607,500 |
| | ក្រ.ម$^3$ | 1.90 | 1.58 | 4.00 | | 3.82 | | | | 2.82 |
| កំបោរ | គ.ក្រ | 265,008 | - | - | - | - | - | - | - | 265,008 |
| | ក្រ.ម$^3$ | 6.00 | | | | | | | | 6.00 |

| បរិយាយ | ផែនការប្រើប្រាស់វត្ថុធាតុដើមសម្រាប់ឆ្នាំ2024 | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ភូមិព្រៃក | ជ្រោយចង្វារ | ចំការមន | និរោធ | បាក់ខែង ដំហាន ទី1+2 | បឹងធំ | ម្លេច | ត្បូងឃ្មុំ | សរុប |
| | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | (1+2+3+4+5+6+7+8) |
| ក្លរឧស្ម័ន | គ.ក្រ<br>ក្រ.ម$^3$ | 91,126<br>1.53 | 54,754<br>1.32 | - | 311,598<br>3.21 | - | - | - | - | 457,478<br>2.15 |
| ក្លរម្សៅ | គ.ក្រ<br>ក្រ.ម$^3$ | - | - | - | - | - | 7,902<br>9.91 | 4,715<br>8.45 | 4,874<br>8.92 | 17,491<br>8.89 |
| អគ្គិសនី | គ.វ៉.ម៉<br>វ៉.ម៉./ម$^3$ | 17,119,008<br>288 | 12,473,028<br>301 | 4,968,667<br>253 | 27,083,900<br>279 | 23,710,845<br>258 | 239,100<br>300 | 129,821<br>233 | 199,920<br>366 | 85,924,289<br>276 |
| អគ្គិសនីរដ្ឋបាល | គ.វ៉.ម៉ | 763,940 | - | - | - | - | - | - | 25,550 | 789,490 |

## ឯកតាប្រើប្រាស់វត្ថុធាតុដើម គ្រោងពីឆ្នាំ 2023 ដល់ 2024៖

| បរិយាយ | ឯកតាប្រើប្រាស់វត្ថុធាតុដើម | | |
|---|---|---|---|
| | អនុវត្តក្នុង ឆ្នាំ2023 | ផែនការ ឆ្នាំ2024 | បម្រែបម្រួល |
| | (1) | (2) | (2)-(1) |
| PAC(គ.ក) | 11.45 | 11.88 | 0.43 |
| ក្លររាវ ( ក្រ.ម$^3$) | 2.35 | 2.82 | 0.47 |
| ក្លរឧស្ម័ន (ក្រ.ម$^3$) | 2.07 | 2.15 | 0.08 |
| ក្លរម្សៅ (ក្រ.ម$^3$) | 8.18 | 8.89 | 0.71 |
| កំបោរ (ក្រ.ម$^3$) | 5.89 | 6.00 | 0.11 |
| អគ្គិសនី (វ៉.ម៉/ម$^3$) | 284 | 276 | (8) |

- ការប្រើប្រាស់ PAC គ្រោងកើនឡើង 0.43ក្រាម/ម$^3$ បើធៀបទៅនឹងការប្រើប្រាស់ឆ្នាំ2023 ដោយសារនៅឆ្នាំ 2024 កំពស់ទឹក មានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំដែលជាហេតុធ្វើឱ្យគុណភាពទឹកមានការប្រែប្រួល។
- ការប្រើប្រាស់ក្លររាវគ្រោងកើនឡើង 0.47ក្រាម/ម$^3$ បើធៀបនឹងការប្រើប្រាស់ឆ្នាំ2023 ដោយសារ ការដាក់ដំណើរការរោងចក្រផលិតទឹកស្អាតបាក់ខែងដំហានទី1 និងទី2 ពេញសមត្ថភាពផលិតដែលរោងចក្រនេះមានតួនាទីយ៉ាងសំខាន់ក្នុងការផលិតក្លររាវ ដើម្បីជួយដល់ការបញ្ចូលក្លររាវទៅដល់ចុងបណ្តាញចែកចាយ។
- ការប្រើប្រាស់ក្លរឧស្ម័ន មានការកើនឡើង 0.08 ក្រាម/ម$^3$ ការកើនឡើងនេះដោយសារការជួយបំពេញបន្ថែម នៃការប្រើប្រាស់ក្លររាវ។
- ការប្រើប្រាស់កំបោរ គ្រោងកើនប្រមាណជា 0.11 ក្រ.ម$^3$ បើធៀបនឹងការប្រើប្រាស់ឆ្នាំ2023 ដោយសារកត្តាដើម្បីដកស្លែបែតងនៅក្នុងដំណើរការប្រព័ន្ធប្រព្រឹត្តកម្មរោងចក្រផលិតទឹកស្អាតភូមិព្រៃក។
- ការប្រើប្រាស់ថាមពលអគ្គីសនីមានការថយចុះ 8w/ម$^3$ ធៀបនឹងឆ្នាំ 2023 ដោយសារនៅក្នុងឆ្នាំ2024 រ.ទ.ស.ភ បានដាក់ដំណើរការរោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំហានទី1 និងទី2 ដែលជារោងចក្រមួយដើរតួនាទីក្នុងការរុញសម្ពាធពីរោងចក្រកាន់តែខ្លាំង ដើម្បីឱ្យប្រជាពលរដ្ឋនៅតំបន់ជាយក្រុងទទួលបានសម្ពាធទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ និងបន្ថែមពីលើនេះទៀតរោងចក្របាក់ខែងបានប្រើប្រាស់នូវឧបករណ៍បច្ចេកវិទ្យាទំនើបដែលប្រើប្រាស់ថាមពលអគ្គិសនី តិចក្នុងដំណើរការប្រព្រឹត្តកម្ម។

## ២ ផែនការសេវាអតិថិជន

នៅក្នុងឆ្នាំ2024 រោងចក្រផលិតទឹកស្អាតទាំងប្រាំបីបានដាក់ដំណើរការពេញសមត្ថភាព (ភូមិព្រែក ជ្រោយចង្វារ ចំការមន និរោធ បាក់ខែងជំហានទី1និងទី2 បឹងធំ ម្លេច និងត្បូងឃ្មុំ) ដែលផ្តល់លទ្ធភាពដល់ រ.ទ.ស.ភ ធ្វើការពង្រីកសេវាផ្គត់ផ្គង់ទឹកបន្ថែមនៅតំបន់ជាយក្រុង និងពង្រីកតំបន់តាមច្រកក្នុងផ្ទៃសេវា។ ការពង្រីកផ្ទៃសេវានេះត្រូវបានផ្តល់អាទិភាពទៅតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច ដោយមិនមើលរំលងតំបន់ប្រជាពលរដ្ឋចំណូលទាប។

## ២.១ ផែនការតបណ្តាញចូលផ្ទះ

យោងតាមលទ្ធផលនៃការធ្វើអង្កេតតម្រូវការប្រើប្រាស់ទឹកស្អាតលើទីតាំងដែលគ្រោងពង្រីកតំបន់សេវា សម្រាប់ឆ្នាំ2024 រ.ទ.ស.ភ បានគ្រោងតបណ្តាញទឹកស្អាតជូនប្រជាពលរដ្ឋចំនួន 36,000គ្រួសារ (រាជធានីភ្នំពេញ និងតាខ្មៅចំនួន 35,000គ្រួសារ និងខេត្តត្បូងឃ្មុំចំនួន 1,000គ្រួសារ) ដែលក្នុងនោះប្រភេទអតិថិជនជីវភាពចំនួន 32,464គ្រួសារ អាជីវកម្មចំនួន 1,725គ្រួសារ និងអតិថិជនចំណូលទាបចំនួន 1,811គ្រួសារ។ លទ្ធផលនៃការធ្វើអង្កេតមានលម្អិតជូនក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះទីតាំង | ចំនួនអតិថិជន | អតិថិជន | | | អតិថិជនចំណូលទាប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ជីវភាព | អាជីវកម្ម | ភាគរយ | តួរលេខ ស/ក | ភាគរយ | |
| I. គម្រោងដាក់បំពង់ថ្មីជាយក្រុង ឆ្នាំ2024 | | 7,330 | 6,201 | 186 | | 943 | | |
| ក ខណ្ឌជ្រោយចង្វារ | | | | | | | | |
| 1 | សង្កាត់ព្រែកតាសេក (ភូមិព្រែកតាគង់ ព្រែករាំង និងព្រែកតាវ័ន្ត) | 450 | 230 | 28 | 57% | 192 | 43% | 1 ឃ្លាំង |
| ខ ខណ្ឌច្បារអំពៅ | | | | | | | | |
| 1 | សង្កាត់ព្រែកថ្មី (ភូមិកោះក្របី) | 210 | 205 | 5 | 100% | 0 | 0% | |
| គ ខណ្ឌដង្កោ | | | | | | | | |
| 1 | សង្កាត់ពងទឹក (ភូមិត្រពាំងស្រាយ ត្រពាំងទាត្រពាំងគ,ត្រពាំងទឹក) | 600 | 535 | 10 | 91% | 55 | 9% | 11ឃ្លាំង |
| 2 | សង្កាត់ព្រែកកំពិស (ភូមិក្រាំងស្វាយ ព្រែកកំពិស) | 700 | 608 | 18 | 89% | 74 | 11% | 12ឃ្លាំង |
| 3 | សង្កាត់ព្រៃវែង (ភូមិត្រពាំងចេក) | 60 | 57 | 3 | 100% | 0 | 0% | |
| 4 | សង្កាត់ស្ពានថ្ម (ភូមិព្រែកជ្រៃ ដូងហា ស្វាយមានលក្ខណ៍) | 480 | 450 | 16 | 97% | 14 | 3% | 10ឃ្លាំង |
| 5 | សង្កាត់សាក់សំពៅ (ភូមិពោធិ៍រលំ ខ្វិត ក្រាំង តាផូ កំរៀង) | 600 | 408 | 12 | 70% | 180 | 30% | |
| ឃ ខណ្ឌព្រែកព្នៅ | | | | | | | | |
| 1 | សង្កាត់គោករកា (ភូមិបែកបក) | 90 | 73 | 5 | 87% | 12 | 13% | 05ឃ្លាំង |
| ង ខណ្ឌកំបូល | | | | | | | | |
| 1 | សង្កាត់បឹងធំ (ភូមិដូនកុក ខ្ទៅ ក្រោក) | 540 | 523 | 17 | 100% | 0 | 0% | 17ឃ្លាំង |
| 2 | សង្កាត់ភ្លើងឆេះរទេះ (ភូមិទួលគី កប់ត្អក ព្រៃរងៀល) | 640 | 340 | 11 | 55% | 289 | 45% | 11ឃ្លាំង |
| 3 | សង្កាត់កន្ទោក (ភូមិស្រែក្នុង អង្គត្រគៀត) | 520 | 501 | 19 | 100% | 0 | 0% | |

| ល.រ | ឈ្មោះទីតាំង | ចំនួនអតិថិជន | អតិថិជន | | | អតិថិជនចំណូលទាប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ជីវភាព | អាជីវកម្ម | ភាគរយ | គូរលេខ ស/ក | ភាគរយ | |
| 4 | សង្កាត់កន្ទោក (ភូមិស្រែក្នុង អង្គត្រគៀត ថ្មដា) | 150 | 143 | 7 | 100% | 0 | 0% | 7ឃ្លាំង |
| 5 | សង្កាត់កំបូល (ភូមិព្រៃកាយ កប់អំពិល អង្គបឹងចេក ភូមិលិចវត្ត ព្រៃកុជិ ស្នួលខ្ពស់) | 360 | 254 | 17 | 75% | 89 | 25% | |
| 6 | សង្កាត់ស្នោ (ភូមិរំដួលត្បូង ព្រៃកាយ ប្រសាទ តាអិន ភូមិផ្លាំង ពង្រ គល់ក្រសា តាពួង ស្នោលិច ប្រសាទ ស្នោកើត) | 380 | 368 | 12 | 100% | 0 | 0% | 4ឃ្លាំង |
| ច ក្រុងតាខ្មៅ | | | | | | | | |
| 1 | សង្កាត់តាខ្មៅ (ភូមិអាចម៍កុក ព្រៃករាំង1) | 550 | 506 | 6 | 93% | 38 | 7% | |
| ឆ ខេត្តត្បូងឃ្មុំ (ឃុំកណ្ដោលជ្រុំ) | | | | | | | | |
| 1 | ភូមិស្តុកសម្បត្តិ,ភូមិអំពុក,ភូមិដៃនិគម,ភូមិជីកពរ | 1,000 | 1,000 | 0 | 100% | 0 | 0% | |
| II គម្រោងបំពេញផ្ទៃសេវា ឆ្នាំ2024 | | 28,670 | 26,263 | 1,539 | | 868 | | |
| 1 | 04ខណ្ឌក្នុងក្រុង (D1,D2,D3,D4) | 240 | 212 | 12 | 93% | 16 | 7% | |
| 2 | ខណ្ឌ ពោធិសែនជ័យ | 3,760 | 3,541 | 186 | 99% | 33 | 1% | សំណង់ 3000 |
| 3 | ខណ្ឌ សែន សុខ | 440 | 369 | 24 | 89% | 47 | 11% | |
| 4 | ខណ្ឌ ដង្កោ | 10,260 | 9,796 | 417 | 100% | 47 | 0% | សំណង់10,050 |
| 5 | ខណ្ឌ មាន ជ័យ | 680 | 464 | 34 | 73% | 182 | 27% | |
| 6 | ខណ្ឌ ច្បារអំពៅ | 3,530 | 3,211 | 210 | 97% | 109 | 3% | សំណង់ 3,150 |
| 7 | ខណ្ឌ ឫស្សីកែវ | 1,660 | 1,416 | 107 | 92% | 137 | 8% | សំណង់ 1000 |
| 8 | ខណ្ឌ ជ្រោយចង្វារ | 5,600 | 5,273 | 300 | 100% | 27 | 0% | សំណង់ 5,250 |
| 9 | ក្រុងតាខ្មៅ | 560 | 451 | 73 | 94% | 36 | 6% | សំណង់ 300 |
| 10 | ខណ្ឌ ព្រែកព្នៅ | 1,940 | 1,530 | 176 | 88% | 234 | 12% | សំណង់ 1500 |
| សរុប (គ្រួសារ) | | 36,000 | 32,464 | 1,725 | 95% | 1,811 | 5% | |

## ២.២ ផែនការអាជីវកម្ម

- **ការងារអាជីវកម្មស្នាក់ការកណ្តាល (រាជធានីភ្នំពេញ និងតាខ្មៅ)**

ក្រោយពីដាក់ដំណើររោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំហានទី1 និងទី2 ដែលមានសមត្ថភាពផលិត 390ពាន់ ម៉ែត្រគូបក្នុងមួយថ្ងៃ និងការងារដាក់បំពង់មេនាំទឹក ដើម្បីឱ្យប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ជាពិសេសតំបន់ជាយក្រុង ដើម្បីទទួលបានសម្ពាធទឹកគ្រប់គ្រាន់ក្នុងការប្រើប្រាស់។

នៅក្នុងឆ្នាំ 2024 រ.ទ.ស.ភ គ្រោងនឹងបង្កើនអតិថិជនថ្មីចំនួន 35,000 បណ្តាញ នៅទូទាំងផ្ទៃសេវា និងតំបន់ដែលគ្រោងនឹងពង្រីកបណ្តាញចែកចាយទឹកក្នុង ឆ្នាំ2024 តាមកម្មវិធីដាក់បំពង់។

តាមការធ្វើអង្កេតអតិថិជន ពិសេសនៅក្នុងតំបន់ដែលគ្រោងពង្រីកបណ្តាញចែកចាយ ឃើញថាមានបណ្តាញអតិថិជនប្រភេទអាជីវកម្ម ដែលប្រើប្រាស់ទឹកបរិមាណច្រើនមានចំនួន 1,725 ទីតាំង និងភាគច្រើនជាប្រភេទជីវភាពធម្មតា និងសំណង់ផ្ទះល្វែង ។ តាមរយៈលទ្ធផលអង្កេតនេះ និងសន្ទស្សន៍តាមបណ្តាឆ្នាំកន្លងមក រ.ទ.ស.ភ សន្និដ្ឋានថានៅក្នុង ឆ្នាំ2024 ខាងមុខអតិថិជនសរុបនឹងកើនដល់ 515,600 បណ្តាញ (អតិថិជនមិនបានប្រើប្រាស់ទឹកចំនួន 20,000 បណ្តាញ) ដែលមានបរិមាណប្រើប្រាស់ទឹកជាមធ្យមក្នុងមួយ បណ្តាញ 48.00 ម$^3$/បណ្តាញ/ខែ និងថ្លៃលក់ទឹកមធ្យម 1,400រៀល/ម$^3$ ។

ដូចនេះបរិមាណទឹកលក់សរុបមានចំនួន 280,657,760 ម$^3$ ធ្វើឱ្យចំណូលថ្លៃលក់ទឹកសរុបមានចំនួន 392,920,864,000 រៀល។ អត្រាទឹកគ្មានចំណូលសម្រាប់ ឆ្នាំ2024 កំណត់ 9.50% តម្រូវឱ្យដំណើរការផលិតកម្មទឹកស្អាតចំនួន 310,120,000ម$^3$។

**សន្ទស្សន៍អាជីវកម្មសំខាន់ៗ៖**

| បរិយាយ | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 |
|---|---|---|---|---|---|---|---|---|
| បរិមាណទឹក/បណ្តាញ/ខែ(ម៣) | 44.08 | 44.88 | 44.96 | 42.58 | 41.16 | 41.35 | 45.67 | 48.00 |
